# លំអានទំនៀមខ្មែរបុរាណ

ពិធីបុណ្យផ្សេងៗ របស់ ពុទ្ធសាសនិក
ពិធីកម្មមួយចំនួន តាម ទម្លាប់ខ្មែរពីបុរាណ

រៀបរៀងដោយ
លោក ញាណ ឈឿន
លោក ម៉ម រៃ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៤៦ គ.ស ២០០២
[illegible]

ទទួលបានពីលោកខ្មៅ ឈានសីហ៍ដែលគារពារខ្មែរ
ដើម្បីទុកដាក់ក្នុង elibrary of cambodia
១ សីហា ២០15

# លំអានទំនៀមខ្មែរបុរាណ

## ពិធីបុណ្យផ្សេងៗ របស់ ពុទ្ធសាសនិក
## ពិធីកម្មមួយចំនួន តាម ទម្លាប់ខ្មែរពីបុរាណ

៖ រៀបរៀងដោយ
លោក ញាណ តឿន
លោក ម៉ម ឆែ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៤៦ គ.ស ២០០២
រក្សាសិទ្ធគ្រប់យ៉ាង

www.elibraryofcambodia.org

# ចំណាប់អារម្មណ៍

សៀវភៅស្តីពីបុណ្យផ្សេងៗ របស់ពុទ្ធសាសនិក និង ពិធីកម្មមួយចំនួន តាម **លំអានខ្មែរបុរាណ** នេះ ខ្ញុំយល់ឃើញថា មានលក្ខណៈគ្រប់គ្រាន់ សម្រាប់ផ្សព្វផ្សាយដល់គ្រប់ជនអ្នកត្រូវការស្រឡាញ់រក្សាប្រពៃណីទំនៀមទម្លាប់ជាតិ ។

ទោះបីមានការខ្វះខាតដោយចំនុចខ្លះ តែមានសៀវភៅពិគ្រោះជាច្រើន ជាឯកសារដើមរបស់អ្នកប្រាជ្ញ កោវិទខ្មែរ ។

សៀវភៅជាការជួយជំរុញ ឱ្យគ្រប់គ្នារួមអនុវត្តរក្សានូវ អត្តសញ្ញាណជាតិខ្លួន ។

ខ្ញុំយល់ឃើញថា មានអ្នកចង់ចេះចង់ដឹងមួយចំនួនធំ តែលទ្ធភាពមានកម្រិត គួរបំផុសសប្បុរសជន ជួយរួមវិភាគទានបោះពុម្ព រួចផ្សព្វផ្សាយគ្រប់ទីកន្លែង ។

សូមថ្លែងសរសើរចំពោះសិស្ស **ញាណ តៀន** និងលោក **ម៉មឆែ** ដែលមានការព្យាយាមុតមាំ ជួយជំរុញការយល់ដឹងពីអត្តសញ្ញាណជាតិ ។

វត្តជម្ពូព្រឹក្សា ថ្ងៃទី ១ ខែ ៨ ឆ្នាំ ២០០១

ជេត_ឌិន

www.elibraryofcambodia.org

# មតិយោបល់អ្នកពិនិត្យ

ខ្ញុំបានអាន និង ពិនិត្យ ដោយយកចិត្តទុកដាក់នូវខ្លឹមសារនៃអត្ថបទទាំងឡាយនៅក្នុងសៀវភៅនេះ ដោយតាមសំណូមពររបស់អ្នករៀបរៀង គឺលោក **ញាណ តៀន** ដែលជាមិត្តភក្តិកំសត់កម្រ ធ្លាប់បំរើការងារចលនាមហាជនតាំងពីឆ្នាំ ១៩៧៩ មក ។

អ្នករៀបរៀង មានសៀវភៅជាច្រើន ជាឯកសារពិគ្រោះផ្នែកព្រះពុទ្ធសាសនា ដែលខ្ញុំធ្លាប់បានរៀនសូត្រ និង បានចេះចាំ និង ច្បាប់ចំលងត។របស់ព្រឹទ្ធាចារ្យមួយចំនួន ដែលខ្ញុំពុំធ្លាប់បានរៀន ពុំធ្លាប់បានចូលរួមអនុវត្តផ្ទាល់ធ្វើជាមូលដ្ឋាន នៃការចងក្រងសៀវភៅនេះ ។

ខ្ញុំយល់ថា ខ្លឹមសារទាំងពីរផ្នែក នៅក្នុងសៀវភៅនេះពិតជាបានជំនួយស្មារតីដ៏សំខាន់ដល់ពុទ្ធបរិសទ័ទាំងឡាយ ក្នុងការចាត់តាំងប្រារព្ធពិធីបុណ្យទានជាប្រពៃណីតាមបែបពុទ្ធសាសនានឹងតាមទំនៀមទម្លាប់ពីបូរាណរបស់ជាតិយើង ។

សៀវភៅនេះនឹងបានជាមិត្តដ៏ល្អកម្ររករបស់អស់លោកអ្នកអានក្នុងការជួយទ្រទ្រង់នូវវប្បធម៌ សាសនា ប្រពៃណី ទំនៀមទម្លាប់ និង អត្តសញ្ញាណជាតិដ៏មានតំលៃរបស់យើង ។

សូមកោតសរសើរដោយស្មោះចំពោះលោក **ញាណ តៀន** នឹង **ម៉មនៃ** ដែលបានខិតខំស្រាវជ្រាវ ឯកសារពិគ្រោះ និង សរសេរចងក្រង បោះពុម្ពជាសៀវភៅដ៏មានគុណប្រយោជន៍នេះ ដែលមួយផ្នែកជាបុណ្យកុសលផ្ទាល់ និង មួយផ្នែក

www.elibraryofcambodia.org

ទៀតគឺ ជាការថែរក្សានូវខ្លឹមសារដ៏ពិត នៃពុទ្ធសាសនាជាទីគោរពសក្ការៈ និងប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់ជាតិយើង ។

សូមជូនពរ បវរប្រសើរប្រកបដោយសុភមង្គលវិបុលសុខគ្រប់ប្រការ ។

ភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០១

**ខាង សាន**

ទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា

អគ្គលេខាធិការរងគណៈកម្មការជាតិ អន្តរជាតិ

www.elibraryofcambodia.org

# ចំណាប់អារម្មណ៍

សៀវភៅស្តីពីបុណ្យផ្សេងៗ របស់ពុទ្ធសាសនិក និង ពិធីកម្មមួយចំនួន តាម **លំអានខ្មែរបុរាណ** នេះ ខ្ញុំយល់ឃើញថា មានលក្ខណៈគ្រប់គ្រាន់ សម្រាប់ផ្សព្វផ្សាយដល់គ្រប់ជនអ្នកត្រូវការស្រឡាញ់រក្សាប្រពៃណីទំនៀមទម្លាប់ ជាតិ ។

ទោះបីមានការខ្វះខាតដោយចំនុចខ្លះ តែមានសៀវភៅពិគ្រោះជាច្រើន ជាឯកសារដើមរបស់អ្នកប្រាជ្ញ កោវិទខ្មែរ ។

សៀវភៅជាការជួយជំរុញ ឱ្យគ្រប់ផ្ការួមអនុវត្តរក្សានូវ អត្តសញ្ញាណ ជាតិខ្លួន ។

ខ្ញុំយល់ឃើញថា មានអ្នកចង់ចេះចង់ដឹងមួយចំនួនធំ តែលទ្ធភាពមាន កម្រិត គួរបំផុសសប្បុរសជន ជួយរួមវិភាគទានបោះពុម្ព រួចផ្សព្វផ្សាយគ្រប់ទី កន្លែង ។

សូមថ្លែងសរសើរចំពោះសិស្ស **ញាណ តៀន** និងលោក **ម៉មនៃ** ដែលមានការព្យាយាមុតមាំ ជួយជំរុញការយល់ដឹងពីអត្តសញ្ញាណជាតិ ។

វត្តជម្ពូព្រឹក្សា ថ្ងៃទី ១ ខែ ៨ ឆ្នាំ ២០០១

**ជេត_ឌិន**

- ដើម្បីជាមនោសញ្ចេតនា លើកទឹកចិត្ត និង លើកស្ទួយ ទ្រទ្រង់ពូនជ្រោយនូវស្នាដៃដ៏ល្អប្រសើរនេះ ឱ្យកាន់តែរីកសុះសាយបន្ថែមទៀត ខ្ញុំនិងភរិយាសូមចូលរួមវិភាគទាន ជាបច្ច័យសម្រាប់បោះពុម្ពសៀវភៅនេះចំនួន ១០០ ក្បាល (មួយរយក្បាល) ជាចំនងដៃទុកចែកជូន បងប្អូនរួមជាតិសិក្សាស្រាវជ្រាវ តាម ការគួរ ។

- សូមលោក **ញាណ តឿន** និងសហការី មេត្តាទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះពីខ្ញុំ ។

ភ្នំពេញ ថ្ងៃ ច័ន្ទ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០១

**ឧ/ទោ នំយ ជុល**

www.elibraryofcambodia.org

## មាតិកា ទំព័រ


១. អារម្ភកថា ........................................ ១

២. សេចក្ដីបញ្ជាក់ ........................................ ៤

៣. ពិធីក្រុងពលី ........................................ ៦

៤. ទំនៀមសង់ផ្ទះនិងឡើងផ្ទះ ........................................ ១០

៥. មើលដីសង់ផ្ទះ ........................................ ១៨

៦. មើលទិសដាក់ជណ្ដើរ ........................................ ២០

៧. តម្រាវាស់សសរ ........................................ ២២

៨. ពិស្ដុកាគ្រូដើម ........................................ ២៣

៩. ពិធីអាពាហ៍ពិពាហ៍ ........................................ ២៦

១០. របៀបរកថ្ងៃពិលា ........................................ ៦០

១១. មើលទិសដាក់ចង្ក្រាន ........................................ ៦៣

១២. មើលទិសធ្វើរោងផ្កាស្លា ........................................ ៦៥

១៣. មើលពេលាសំពះពិលា ........................................ ៦៦

១៤. បំរាមបូរាណ ........................................ ៦៨

១៥. ធាតុ + ពង្ស ........................................ ៦៩

១៦. ពិធីរៀបចំសព ........................................ ៧០

១៧. មើលត្បូងនាគ កន្ទុយនាគ បញ្ចុះធាតុ ........................................ ៨១

១៨. អំពីវិធីរៀបចំខ្មោចតែហោង ........................................ ៨៥

១៩. ទង់ព្រលឹង ........................................ ៨៧


www.elibraryofcambodia.org

២០ . ចង់ក្រពើ ........................................ ៨៨

២១ . មតិពិចារណាអំពីការប្រែរូប ........................................ ៩២

២២ . បុណ្យឆ្លងផ្សេងៗ ........................................ ៩៤

២៣ . ពិធីចំរើនព្រះជន្ម ........................................ ៩៦

២៤ . វិសាខបូជា ........................................ ៩៨

២៥ . មាឃបូជា ........................................ ១០២

២៦ . ប្រវត្តិទាក់ទងមនុស្សស្លាប់ថ្មីៗ ........................................ ១០៥

២៧ . ទំនៀមដាក់ក្បាលខ្មោចទៅលិច ........................................ ១០៧

២៨ . ទំនៀមដាក់ប្រាក់ក្នុងមាត់ខ្មោច ........................................ ១០៨

២៩ . ទំនៀមដាក់ផ្កា-ធូបក្នុងដៃខ្មោច ........................................ ១០៩

៣០ . ប្រវត្តិលោកអភិធម្ម ........................................ ១១០

៣១ . ប្រវត្តិអុជទៀនកាឡ ........................................ ១១១

៣២ . បុណ្យចូលឆ្នាំខ្មែរ ........................................ ១១៥

៣៣ . ស្រង់ព្រះ ........................................ ១១៩

៣៤ . ពូនភ្នំខ្សាច់ ........................................ ១២១

៣៥ . បុណ្យចូលវស្សា ........................................ ១២៤

៣៦ . បុណ្យភ្ជុំ ........................................ ១២៩

៣៧ . ដាក់បិណ្ឌ ........................................ ១៣៤

៣៨ . ចេញវស្សា-បវារណា ........................................ ១៣៨

៣៩ . បណ្តែតប្រទីប ........................................ ១៤៥

www.elibraryofcambodia.org

៤០ . បុណ្យកឋិន ........................................ ១៥២
៤១ . អ្នកធ្វើកឋិនសម័យពុទ្ធកាល ........................................ ១៥៥
៤២ . ពិគ្រោះការវេរកឋិន ........................................ ១៥៩
៤៣ . សុន្ទរកថាកឋិន ........................................ ១៦២
៤៤ . សង្ឃកម្ម ........................................ ១៦៥
៤៥ . ឧបោសថកម្ម ........................................ ១៦៩
៤៦ . បុណ្យបច្ច័យបួន ........................................ ១៧៤
៤៧ . បុណ្យសង្ឃទាន ........................................ ១៧៩
៤៨ . បុណ្យបញ្ចុះសីមា ........................................ ១៨៧
៤៩ . វេរឧបោសថាគារ កុដិថ្មី ........................................ ១៩៣
៥០ . វេរជុំថ្ម ........................................ ២០៣
៥១ . ពុទ្ធាភិសេក ........................................ ២០៤
៥២ . បុណ្យកតញ្ញូ ........................................ ២០៦
៥៣ . ឆាកទស្សបន្ទុង ........................................ ២១០
៥៤ . លើករាសី ........................................ ២១៤
៥៥ . រំដោះគ្រោះ ........................................ ២១៦
៥៦ . រម្លាប់ ឬ ស្តុតជី ........................................ ២២០
៥៧ . បូជាព្រះភូមិ ........................................ ២២១

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅនេះ ប្រសូតឡើងក្នុងសម័យដែលពុំនឹកស្មានដល់ថា នឹងអាចបដិសន្ធិបានយ៉ាងហ្នឹងឡើយ ។ តើនេះជានិស្ស័យឬមកពីសេចក្ដីព្យាយាម ? តាមពិតទៅវាមិនសូវជាប្លែកណាស់ណាទេព្រោះដូចជាគាថា សំស្ក្រឹតមួយកន្លែងចែងថា :

វាសនាគ្មានការប្រឹងមកជួយផ្ដល់ មិនអាចឱ្យផលសម្រេចបាន
រទេះកង់ម្ខាងនឹងគិតអាន រុញច្រានឱ្យលឿនពុំកើតពិត ។
រីឯវាសនានិងព្យាយាម តាមពាក្យទំនៀមប្រាជ្ញកោវិទ
ថាត្រូវតែមានទាំងពីរពិត នោះទើបប្រសិទ្ធឱ្យផលបាន ។

ក្នុងយុគសម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ( ១៩៧៥ - ១៩៧៩ ) កម្ពុជាទាំងមូលត្រូវរងទារុណកម្ម មនុស្សនិងចលនាចលនវត្ថុ ត្រូវព្រាត់ប្រាស់បែកបាក់ហិនហោច ។ អ្នកប្រាជ្ញរាជបណ្ឌិតត្រូវសម្លាប់ ។ ក្បួនច្បាប់ត្រូវបំផ្លាញ ។ ទំនៀមទម្លាប់ប្រពៃណីត្រូវបិទសិទ្ធិ ។ វិស័យព្រះពុទ្ធសាសនាត្រូវសូន្យគឺព្រះសង្ឃទូទៅត្រូវចាប់ផ្សឹក ពិសេសព្រះសង្ឃ ជាបណ្ឌិតកោវិទត្រូវសម្លាប់ ។ វត្តអារាមមួយភាគធំត្រូវកំទេចនិងសល់ប៉ុន្មានត្រូវក្លាយជាជង្រុកជី ទ្រុងជ្រូក ជាគុកនិងជាពិឃាតដ្ឋាន ។ ឆ្នាំ ១៩៧៩ មក អ្វីៗត្រូវបានបង្កើតឡើងវិញ រហូតបច្ចុប្បន្នសន្តិភាពកើតមាន សាមគ្គីភាពវឌ្ឍនភាពនៃសង្គមត្រូវបង្កើត ក្ដីសង្ឃឹមនៃសុភមង្គលមហាគ្រួសារខ្មែរមានពេញលេញ ។ ព្រះពុទ្ធសាសនាត្រូវបានលើកតម្កើងជាសាសនារបស់រដ្ឋ ។ អាយុកាលកើតជាថ្មីនៃព្រះពុទ្ធសាសនា



www.elibraryofcambodia.org

អស់រយៈពេល ២១ ឆ្នាំ ( ១៩៧៩ - ២០០០ ) ប៉ុណ្ណោះ ។ តែការលូតលាស់ទាំងផ្នែកព្រះបរិយត្តិធម៌ ទាំងផ្នែកបដិបត្តិធម៌នៅទីក្រុងនិងខេត្តពុំទាន់ឱ្យរីកចម្រើនទាន់ភាពយ៉ាងក្រៃលែង ។ ទោះជាយ៉ាងនេះក្តីក៏បណ្ណាជនបទ ស្រេចការភាគច្រើនពុំទាន់សម្បូរគម្រាក្បួនច្បាប់នៅឡើយ ហើយបើមានខ្លះៗក៏ពុំទាន់ចែងប្រាប់អំពីរបៀបធ្វើបុណ្យទានឬពិធីកម្មនានាតាមបែបប្រពៃណីខ្មែរពីបុរាណ ឱ្យច្បាស់លាស់ផងទេ ។ ម្យ៉ាងទៀត កន្លែងមួយចំនួនមានធ្វើតៗគ្នាតាមតែការចាំឬការយល់ឃើញរបស់លោកអ្នកខ្លះប៉ុណ្ណោះ ។ ម្ល៉ោះហើយការធ្វើនោះនៅមានការជជែកមិនច្បាស់លាស់ ។ ព្រោះហេតុខាងលើនេះផង និងអនុលោមតាមបំណងប្រាថ្នានៃពុទ្ធសាសនិកជាន់ក្រោយ ដែលសំណូមពរឱ្យមានក្បួនស្តីអំពីពិធីផ្សេងៗ សម្រាប់ដឹកនាំធ្វើបុណ្យទាននានា និងពិធីការខ្លះៗតាមបែបខ្មែរបុរាណផង ពិសេសដើម្បីបានជាទិដ្ឋានុគតិ ជាពន្លឺដល់អ្នកមិនធ្លាប់ចេះមិនធ្លាប់យល់ផង ទើបយើងខ្ញុំប្រមូលឯកសារពិគ្រោះមួយចំនួនមានសាស្ត្រាស្លឹករឹតជាដើមនិងរៀបរៀងតាមដែលធ្លាប់ចេះចាំតៗមកខ្លះផង ចងក្រងជាសៀវភៅនេះឱ្យឈ្មោះថា « **សំអាងទំនៀមខ្មែរបុរាណ** » ។

យើងខ្ញុំពុំបានអះអាងថា សៀវភៅនេះត្រឹមត្រូវមួយរយភាគរយនោះទេ ព្រោះហេតុថាទង្វើជាទម្លាប់ទៅតាមមូលដ្ឋានមានច្រើនប្លែកៗគ្នា ប៉ុន្តែចំពោះខ្លឹមសារនិងគោលបំណង ខ្ញុំយល់ថាដូចៗគ្នា ។ ដូច្នេះសំណេររៀបរៀងសៀវភៅ « **សំអាងទំនៀមខ្មែរបុរាណនេះ** » ពិតជាពុំទាន់គ្រប់គ្រាន់ទេ ។ យើងខ្ញុំសំណូមពរ ចំពោះលោកអ្នកប្រាជ្ញកោវិទបណ្ឌិតជនព្រឹទ្ធាចារ្យនិងប្រិយជនទាំងឡាយ មេត្តាជួយកែលំអប្រកបដោយសុទិដ្ឋិនិយមក្នុងឆន្ទៈតែមួយគឺ



www.elibraryofcambodia.org

ដើរកៅរក្សាភាពវ៉ែកផ្គុះប្រពៃណីនៃមរតកខ្មែរ ។ ព្រោះថា អំឡេអមធម្មាប់ខ្មែរពិតជា « បូរាណមិនយឺត សម័យមិនបរទេស » ។ សង្ឃឹមមិនរង់ចាំការជួយផ្ដល់មតិយោបល់ជានិច្ច ដើម្បីសាបនាសេចក្ដីផ្ទៃផ្ទរពិត។ ។ ឆ្លៀតឱកាសនេះដែរ

យើងខ្ញុំសូមសំដែងនូវមនោសញ្ចេតនា ត្រេកអរដ៏បរិសុទ្ធ ចំពោះវិរិយភាពភិក្ខុ **តួច តិរម្យ** ភិក្ខុ **ទី សុវណ្ណជារា** សមណសិស្សពុទ្ធិកវិទ្យាល័យព្រៃវែង លោក **ឡាច ហាស់** មន្ត្រីធម្មការស្រុកកំពង់លាវជួយចំឡងបណ្ដាអត្ថបទមួយចំនួន ដែលយើងខ្ញុំទើបនឹងប្រមូលបានជាដំបូង ។ សូមថ្លែងអំណរគុណចំពោះ លោកតា គ្រូអាចារ្យមួយចំនួនជាអាទិ៍ ដូចជា លោកតា **តេងយ៉ាត** លោកតា **យូនយីន** លោកតាអាចារ្យ **ម៉ែត** នៅស្រុកស៊ីធកណ្ដាល និង លោកតា **នៅ ទ្រោង** លោកតា **សៅ ឈុន** នៅស្រុកពាមជរ ខេត្តព្រៃវែង និងលោកតា **ញាណ តួច** ភូមិដូនណួយ ឃុំច្រេស ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដែលបានជួយផ្ដល់ឯកសារនិងមតិដកពិសោធ៍មួយចំនួនយ៉ាងល្អប្រសើរ ។

ដោយអានិសង្សនៃការប្រឹងប្រែងរបស់លោកម្ចាស់ទាំងពីរអង្គនិងអស់លោកដូចមាននាមខាងលើនិងសេចក្ដីព្យាយាមរបស់យើងខ្ញុំទាំងពីរនាក់នេះផង

- សូមព្រះពុទ្ធសាសនាស្ថិតស្ថេរគ្រប់ ប្រាំពាន់ព្រះវស្សា
- សូមជាតិខេមរា សុខក្សេមក្សាន្តជានិច្ចនិរន្តរ៍

ព្រៃវែងថ្ងៃ ៤ ១៥ ១០ ឆ្នាំរោង ទោសក័ ព-ស ២៥៤៤

ត្រូវនិងថ្ងៃទី ១៣កញ្ញា គ-ស ២០០០

វាចាអ្នករៀបរៀង



www.elibraryofcambodia.org

## សេចក្ដីបញ្ជាក់បន្ថែម

ការប្រសិទ្ធិនាមសៀវភៅនេះថា **លំអានចំនៀមខ្មែរបុរាណ** ពីព្រោះខ្លឹមសារភាគច្រើន រៀបរាប់អំពីរបៀបធ្វើតាមទំនៀមទម្លាប់របស់ពុទ្ធសាសនិកខ្មែរពីបូរាណនិងតាមព្រះរាជបន្ទូលផ្ទាល់របស់ព្រះមហាសុមេធាធិបតី សម្ដេចព្រះសង្ឃរាជ គណមហានិកាយ **ទេព វង្ស** ឧបេក្ខាសម្មោជ្ឈង្គិកោ ។

ឯពិធីកម្មគ្រប់យ៉ាងក្នុងសៀវភៅនេះចែកចេញជាពីរផ្នែកគឺ :

១. នៅជុំវិញពិធីកម្មទាំងអស់ រៀបរាប់អំពីការធ្វើតាមទម្លាប់ខ្មែរពីដើមដែលអាចារ្យធ្លាប់រៀបចំធ្វើតៗមកហើយជាពិធីធ្វើតាមចេតនាកម្ម ( តាមបំណងប្រាថ្នារបស់អ្នកធ្វើ ) ។ សព្វថ្ងៃពិធីខ្លះ ត្រូវកាត់បន្ថយខ្លីទៅតាមតំបន់ដែលពុំសូវបានដឹងពីរបៀបរៀបចំធ្វើ ។

២. ក្នុងពិធីទាំងនេះ រៀបរាប់អំពីការធ្វើតាមលក្ខណៈបទដ្ឋានព្រះវិន័យ គឺជាព្រះពុទ្ធដីកាសុទ្ធសាធដែលជាពុទ្ធានុញ្ញាតនិងពុទ្ធប្បញ្ញត្តិនិងជាអដ្ឋកថា ដីកា យោជនា ហើយជាពិធីត្រូវធ្វើឱ្យបានត្រឹមត្រូវមិនអាចបន្ថែមឬបន្ថយបានព្រោះជាបញ្ញត្តិកម្ម ។

អ្នករៀបរៀងបានស្រាវជ្រាវប្រមូលផ្ដុំឯកសារពិគ្រោះនិងមតិយោបល់ ជាអាទិ៍

១. សៀវភៅពុទ្ធសាសនា ២៥០០ របស់ពុទ្ធសាសនបណ្ឌិត្យ

២. ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរវីរិយបណ្ឌិតោ **ប៉ាំងខាត់**

៣. សីមាវិនិច្ឆ័យព្រះវិសុទ្ធិវង្ស **ហួត តាត**

៤. ភិក្ខុប្បាតិមោក្ខបាលីព្រះធម្មារាមោ **ប៊ុណ្ណ សម្ភាជន៍**

៥. ព្រះវិន័យបិដកត្រង់កឋិនក្ខន្ធកៈ និងកឋិនកថាសង្ខេបរបស់សម្ដេច



www.elibraryofcambodia.org

ព្រះពោធិវង្ស **ហួត តាត**

៦. សៀវភៅសង្ឃកម្មកថា របស់ព្រះឃោសធម្មមហា **ម៉ុង សែស** ( **ចន្ទចក្ខោ** ) និងព្រះវិន័យបិដកត្រង់កម្មក្ខន្ធកៈ ។ល។

៧. សៀវភៅឧបោសថាទិកថារបស់ភិក្ខុ **ឡុង គីម**

៨. សុត្តន្តបិដកត្រង់បេតវត្ថុនិងវិមានវត្ថុ

៩. សៀវភៅសំណុំឯកសារបុណ្យផ្សេងៗរបស់បណ្ឌិត **ឈឹមស៊ុមន៍**

១០. កម្ពុជសុរិយា ១៩២៦ - ៣៤ - ៣៨ - ពុទ្ធសាសនបណ្ឌិត្យ

១១. មាតាធិបតេយ្យរបស់ឯកឧត្តម **ខួន ញ៉ិល**

១២. ច្បាប់ចម្លងរបស់អាចារ្យ **ម៉ែត** ឃុំរលេច ស៊ុធរកណ្ដាល **ខ.វ**

១៣. ច្បាប់ចម្លងពីលោកតា **ញាណ តួច** ឃុំប្រេស ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

១៤. ច្បាប់ចម្លងពីព្រះគ្រូ **សោរមុនី** វត្តកំសាន្តច្បារអំពៅ ភ្នំពេញ

១៥. ច្បាប់ចម្លងពីលោកតា **នៅ ឡេង** និង **សៅ ឈួន** ឃុំកោះសំពៅ ស្រុកពាមជរ ខេត្តព្រៃវែង

១៦. ទម្លាប់ខ្លះៗតាមលំអានអាចារ្យ **គុណា** អាចារ្យបរមរាជវាំង

១៧. សាស្ត្រាស្លឹករិត **វត្តបារាយខាងកើត** ឃុំបារាយ ស្រុកកំពង់លាវ

១៨. ក្បួនពិភេកហោរាច្បាប់ដើមរបស់ **ពុទ្ធសាសនបណ្ឌិត្យ**

ព្រៃវែងថ្ងៃទី ៦ ។ ៤ ឆ្នាំរោង ទោសក័ ព.ស ២៥៤៤
១៤

ត្រូវថ្ងៃទី ២៣ ខែមិនា ២០០១

អ្នករៀបរៀង



www.elibraryofcambodia.org

# ពិធីក្រុងពលី

ពិធីនេះជាទម្លាប់មក មានពីរបែបគឺ

ក- តាមពិធីកម្មត។របស់ខ្មែរបុរាណ គឺបូជាទេព្តាតាមលទ្ធិដទៃក្រៅព្រះពុទ្ធសាសនា ។

ខ- តាមរបៀបព្រះពុទ្ធសាសនា ពលីនេះមាន៥គឺ :

១- **បុព្វបេតពលី** : រៀបអណ្តាប់អណ្តា មានបាយស្កក បង្អែម ចំអាប ទៀន ធូប ឧទ្ទិសជូនបុព្វការីជនដែលស្លាប់ ។

២- **អតិថិពលី** : បដិសណ្ឋារៈភ្ញៀវ ដែលបានអញ្ជើញចូលរួមក្នុងពិធីដើម្បីជាសក្ខីភាព ។

៣- **ញាតិពលី** : បដិសណ្ឋារៈញាតិសាច់សារលោហិត ដែលបានជួបជុំទទួលស្គាល់ដឹងឮ ។

៤- **រាជពលី** : ធ្វើពិធីគោរព តាមច្បាប់ទម្លាប់របស់ប្រទេសជាតិ គឺស្នើសុំដល់រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ដឹងឮនិងអនុញ្ញាត ដែលហៅថា « ក្រុងពលី » នោះឯង ។

៥- **ទេវតាពលី** : បូជាដល់ទេវតា មានពិធីបួងសួងទេវតាជាដើម ។

## របៀបប្រកាសក្រុងពលីតាមបែបខ្មែរបុរាណ

ពិធីនេះឃើញភាគច្រើនក្នុងពិធីមង្គលការ : **ឱកាស** ខ្ញុំព្រះករុណា សូមគោរព អារាធនាព្រះរតនត្រៃ ត្រៃត្រឹង្ស និន្ទទេវាទេវតា ទាំងឆកាមា ទាំងអ្នកតាចាស់ស្រុក ទាំងម្រេញគង្វាល នាងហ៊ីង ព្រះធរណី និង ទេព



www.elibraryofcambodia.org

រីតោ កុមារភូមិភាពេសភាល័យរំព្រះព្រះវេទក្មុង **ឥរិឥន្ទមុនី អង្គអនុរុទ្ធឥន្ទ កោសីយ៍** ទើបយាងសម្តេចព្រះស្រី តិច្ចាព្រហ្មាលោកា មហាសុរិង ឥសីសុទ្ធ ព្រះចិត្តកូដ ព្រះចន្ទកុមារ ព្រះយក្សកុមារព្រះ **វិរុឡ្ហកៈ** សេនាព្រះរាម ទើបព្រះអង្គបញ្ជាព្រះបារមីសួរ ព្រះចតុលោកបាលព្រះបាទស្តេចភុជង្គនាគ ព្រះពិស្ណុកា ព្រះបាទក្រុងពាលីព្រះវេស្សវណ្ណព្រះបាទឆព្រ័ពាន់ ព្រះបាទកងជុំព្រះព្រហ្មមុខបួន ព្រះរាមមុខដប់ មូលមកសព្វគ្រប់ទាំងព្រះធម៌៨៤០០០ ធម្មក្ខន្ធ ទើបលោកហោះឈានចាកឋានវិមានមកគង់ក្នុងទីនេះ ព្រោះយើងខ្ញុំជាអ្នកដើមការទាំងបួន សាមីខ្លួនទាំងពីរ មាននាម ......... បានរៀបចំប្រដាប់ប្រដា សំពត់ផ្ទត់ ប្រេងម្សៅ ក្រាស់ កញ្ចក់ ពោត សណ្តែក ល្ង ព្រមទាំងភស្តុភារបណ្ណាការក្រយាបូជាសូមអញ្ជើញស្តេចក្រុងពាលី យាងមកទទួលយកនូវក្រយាបូជានេះហោង ។ តមកអាចារ្យសូត្របាលីជូនពែ : **អមនុស្សោ វា អមនុស្សី វា ភូតោ វា ភូតី វា បិសាចោ វា បិសាចី វា អសុរោ វា អសុរី វា ភុញ្ជន្តុ ស្វាហាយៈ ៦** រួចចង្អុលទិសឱ្យនាំពែចេញតាមដង្ហើមថ្ងៃ អាទិត្យទិសឧត្តរ ចន្ទ នីរតី អង្គារ និងពុធ ពាយ័ព្យ ព្រហស្បតិ៍ បូពិ សុក្រ អគ្នេយ៍ សៅរ៍ទក្សិណ ។ ឯមុននឹងនាំពែចេញអាចារ្យធ្វើសញ្ញា បើខ្មែតលើកដៃឡើង អ្នកភ្លេងដឹងថាផ្ងារពែ បើរនោចលើកដៃឡើងដែរតែខ្វែងដៃ អ្នកភ្លេងដឹងថាផ្កាប់ពែ ។ អ្នកភ្លេងលេងបទសែងពែ ដោយមានអ្នករបាំពីរនាក់ រាំចាប់ពែសែងចេញតាមទិសដែលអាចារ្យចង្អុល ។

ចំពោះពិធីក្រុងពលីតាមបែបព្រះពុទ្ធសាសនា យើងឃើញមានភាគ



www.elibraryofcambodia.org

ច្រើនក្នុងពិធីបុណ្យបញ្ចុះសីមា លើកផ្ទះ ឡើងផ្ទះ ឆ្លងរោងរាន ឆ្លងថ្នល់ ឆ្លងស្ពាន ឆ្លងសាលាឆទាន ឆ្លងស្រះ ឆ្លងដើមពោធិ៍ ឆ្លងព្រះត្រៃបិដកនិង សមិទ្ធិផ្សេងៗទៀតឬពិធីបញ្ចុះបឋមសិលាជាដើម ។ល។

ក្នុងពិធីនេះរបៀបប្រកាសទេវតា ដូចក្នុងពិធីក្រុងពលីក្នុងពិធីបញ្ចុះ សីមា គ្រាន់តែខុសគ្នាអំពីឈ្មោះនៃពិធីប៉ុណ្ណោះ ( សូមពិនិត្យមើលក្នុងពិធី បញ្ចុះសីមា ) ឯវត្ថុដែលគេរៀបក្នុងពិធីក្រុងពលីគេច្រើនជូនទៅអាចារ្យ ។

បញ្ជាក់ : ពិធីក្រុងពលីមានច្រើនបែប នៃពិធីកម្ម ដែលជាទម្លាប់ យើងខ្ញុំបានលើកឡើងដូចជា ក្នុងពិធីបូជាសព ( មើលអំពីវិធីរៀបចំសព ) និងពិធីលើកផ្ទះ ( សូមមើលត្រង់កន្លែងពិធីលើកផ្ទះ ) ។

ឯវិធីដែលអាចារ្យត្រូវធ្វើគឺ : ក្រោយពីរៀបចំស្រេចបាច់ហើយ អាចារ្យចាប់ធ្វើពិធីបួងសួងប្រកាសទេវតា តាមដែលខ្ញុំបានជំរាបជូន ខាងលើស្រាប់បន្ទាប់មកអាចារ្យចាប់ផ្តើមនមស្សការជាមួយពុទ្ធបរិស័ទ ។ ខាងចុងសូត្រ **យោគបេ្យកោធី** រួចបន្ទាប់មកអាចារ្យប្រកាសបន្តទៀតថា :

បពិត្រទេវតា គ្រប់ទាំងគន្ធព្វគ្រុឌនាគា ព្រះឥន្ទព្រះព្រហ្ម ព្រះ ចិត្តលោកបាលនៃ ទោះទាំងទេពធរណី ទាំងគិរីទីព្រឹក្សព្រៃ ទ្វីបកោះ ជ្រោះជលស័យ សមុទ្រនៃស្ទឹងនទី ទេព្តាស្ថិតសព្វស្ថាន សួគ៌ាភិមានអាកាស ខ្ទី មែនមានឫទ្ធិបុណ្យបារមីបុព្វេពិតព្យាបាល គេជះយើងរឮកទឹកគិតប្រ កាសថាសូមជួយជោគជយា បំបាត់ទាក្តីអន្តរាយ យើងខ្ញុំសូមសុខសេរីជ័យ វុឌ្ឍិទីសប្បាយ ក្នុងអង្គវង់រូបកាយ ចំរើនយូរអាយុផង ដោយគុណបុណ្យ



www.elibraryofcambodia.org

ពេលនេះ យើងប្រកាសអញ្ជើញទេវតា ពេលនេះពិធីការជាអ្នកធ្វើបុណ្យកុសល ព្បិតយើងខ្ញុំមានមេត្រី ចិត្តបេតីប្រតិពល ឃើញអានិសង្សផល បរិយត្តិធមិដល់បុណ្យទាន សូមជួយឱ្យសុខសួស្តីជ័យក្សេមក្សាន្ត សូមលោកអ្នកម្ចាស់ទាន ....... បាននូវបុញ្ញសម្បទា មានសម្បត្តិជាបុណ្យ សូមស្តេចចតុ-លោកបាលមានព្រះបាទ **ធតរដ្ឋ:** កាន់ទិសបូព៌ ព្រះបាទ **វិរូបក្ខ:** កាន់ទិសបស្ចិម ព្រះបាទ **វិរុឡ្ហក:** កាន់ទិសទក្សិណ ព្រះបាទ **កុវេរ:** កាន់ទិសឧត្តរ មហារាជទាំងបួនស្ថិតក្រោមអំណាចព្រះឥន្ទ សូមមេត្តាអញ្ជើញមកជាអធិបតីនៃយើង និងសូមជូនពរជ័យសិរីមហាប្រសើរ ចូលមករក្សាធម្មការពួកយើងថ្កើងសាធុការទៅហោង ។ បន្ទាប់មកទៀតក៏ផ្តើមកម្មវិធីតាមសំណូមពរម្ចាស់ទានប្រធានដើមបុណ្យឬតាមកម្មវិធីដែលមានគ្រោងទុក ។



www.elibraryofcambodia.org

# ធំនៀមសង់ផ្ទះ និង ឡើងផ្ទះថ្មី

បូរាណលោកសង់ផ្ទះត្រូវពិនិត្យសសរជាមុន ។ ឯការពិនិត្យនោះមានលក្ខណៈផ្សេង១ដូចតទៅ :

១, *មើលសសរមិនល្អ*

– ឈើសសរដែលគេកាប់រលំដួលទៅដកទាំងបណ្តូលផង ហៅថា : ( ដកអណ្តាត ) ។

– សសរមានថ្នាំង ឬ ភ្នែកនៅគល់ កាលសង់ផ្ទះ ឃើញមានភ្នែក ឬ ថ្នាំងនៅក្បែរដី ហៅថា : ( មាន់កកាយ ) ។

– សសរដែលមានថ្នាំង ឬ ភ្នែកឡើងពីដី កំពស់មួយហត្ថ ហៅថា : ( ជ្រូកត្រដុស ) ។

– សសរដែលឈូសដំរង់ទៅធ្លាយចេញ ឃើញបណ្តូលត្រង់ណាមួយ ហៅថា : ( ធ្លាយបណ្តូល ) ។

– សសរដែលឈូសទៅឃើញសំបកនៅក្នុងសាច់ ហៅថា : ( ពាំសំបក ) ។ ឯគ្រឿងដទៃទៀតមិនមានរើសទេ ធ្វើម្តេចឱ្យតែល្មមសង់ផ្ទះបាន ចាស់១ពិនិត្យសំខាន់តែសសរទេ ។

២, *មើលថ្ងៃ ខែសង់ផ្ទះ*

– ខែចេត្រសង់គ្រឹះស្ថានពុំបានត្រូវទុក្ខសោកកើតចង្រៃក្តៅក្រហាយ អាចស្លាប់ព្រាត់ប្រាស់គ្នា ។

– ខែពិសាខ សង់គ្រឹះស្ថានបានប្រពៃ មានមាសមានប្រាក់ទ្រព្យធន គង់វង់ចូលច្រើន ។



www.elibraryofcambodia.org

- ខែជេស្ឋ សង់គ្រឹះស្ថានកើតវិនាសវិនាសខ្ចាត់ខ្ចាយ ខ្លួនក្សិនក្សយ ។

- ខែអាសាឍ សង់គ្រឹះស្ថានរលាយទ្រព្យធន ហិនហោច ។

- ខែស្រាពណ៍សង់គ្រឹះស្ថានមានលាភ មានជ័យ មានទ្រព្យធន សំបូរឥតគណនា ។

- ខែភទ្របទ សង់គ្រឹះស្ថានពុំបាន មានជំងឺ ដំកាត់ច្រើនកន្លង ។

- ខែអស្សុជ សង់គ្រឹះស្ថានឥតជ័យ កើតជម្លោះទាស់ទែង ។

- ខែកត្តិក សង់គ្រឹះស្ថានមានសេរីសួស្តី ទ្រព្យធនហូរចូល ។

- ខែមិគសិរ សង់គ្រឹះស្ថានមានសេរីសួស្តី មានយសសក្តិ សម្បត្តិទ្រព្យ ។

- ខែបុស្ស ចូលមាសប្រាក់កែវកងគ្រប់ប្រការ ។

- ខែមាឃ សង់គ្រឹះស្ថានមានកើតចង្រៃមហិមាមានភ្លើងឆេះអស់ ។

- ខែផល្គុណ សង់គ្រឹះស្ថាន បានជោគជ័យមានលាភដូចក្តីប្រាថ្នា ។

៣. *មើលទិសនាគ*

- ផល្គុណ ចេត្រ ពិសាខ នាគបែរក្បាលទៅទិសបស្ចិម កន្ទុយទៅទិសបូព៌ា . ពោះទៅទិសឧត្តរ . ខ្នងទៅទិសទក្សិណ . ពិសទៅទិសពាយ័ព្យ ។ កាលសង់ផ្ទះ ឱ្យអង្គុយជីករណ្តៅបែរមុខទៅទិសបូព៌ .បារដីទៅទិសឧត្តរ ជ្រែងសសរទៅទិសពាយ័ព្យ ហើយលើកសសរទៅទិសពាយ័ព្យ ជាដំបូង ជាកំណត់ ។

- ជេស្ឋ អាសាឍ ស្រាពណ៍ នាគបែរក្បាលទៅទិសឧត្តរ កន្ទុយទៅទិសទក្សិណ . ផ្ទៃពោះទៅទិសបូព៌ ខ្នងទៅទិសបស្ចិម ពិសទៅទិសឦសាន ។



www.elibraryofcambodia.org

កាលនឹងជីករណ្ដៅ ឱ្យបារជីដាក់ទិស បូពិ អង្គុយបែរមុខទៅទិសទក្សិណ ជ្រែងចុងសសរទៅទិសឦសាន លើកពីទិសឦសានដំបូង ជាកំហោត់ ។

- ភទ្របទ អស្សុជ កត្តិក នាគបែរក្បាលទៅទិសបូពិ កន្ទុយទៅបស្ចឹម បាជីដាក់ទិសទក្សិណ ជ្រែងចុងសសរទៅទិស អាគ្នេយ៍ លើកសសរជ្រុងអាគ្នេយ៍ ជាដំបូង ។

- មិគសិរ បុស្ស មាឃ នាគបែរក្បាលទៅទិសទក្សិណ កន្ទុយទៅឧត្តរ ផ្ងៃទៅទិសបស្ចឹម ខ្នងទៅទិសបូពិ ពិសទៅទិសនីរតី កាលជីករណ្ដៅឱ្យបែរមុខទៅទិសឧត្តរ បារជីដាក់ទិសបស្ចឹម ជ្រែងចុងសសរទៅទិសនិរតី លើកសសរជ្រុងនិរតីជាដំបូង ។

៩.<u>របៀបប្រុងផ្ទះ និង សែនក្រុងពាលី</u>

ចំពោះថ្ងៃខែ យើងបានជំរាបជូនខាងដើមពីពិធីរក **សុខោ លាភី សិទ្ធី** របស់ម្ចាស់ផ្ទះ ដូចដែលបានធ្វើពិធី មង្គលការ ។

ដំបូងយើងប្រាប់ជាង ឱ្យយកសសរកន្លោងទាំងប៉ុន្មាននោះ ដាក់ផ្តេកនៅចំកណ្ដាលសសរទាំងនោះ ខ្ពស់បន្តិចឡើង ។

<u>បន្ទាប់មករៀបសែនក្រុងពាលី ។ រណ្ដាប់សែនមាន</u> :

សាជម ៤ . បង្អែមមួយចាស . ចំអាបមួយចាស . ទឹកអប់មួយគូ . មូស្លាបារីមួយគូ (ពីរជើងពាន) សំពត់អាវព្រៃថ្មី១មួយប្រដាប់ គ្រឿងសំអាងមានក្រាស់ កញ្ចក់ ប្រេង ម្សៅ មួយប្រដាប់ ទឹក១ផ្តិល . ពែរូតមួយទំហំ ១ហត្ថ មួយទះ (មួយហត្ថ៥ធ្នាប់) រាង៤ជ្រុងស្មើ ។ រូបធ្វើពែមូលតូចមួយដាក់ត្រង់កណ្ដាលពែធំនោះ ធ្វើពែច្រមុះជ្រូក គឺពែបីជ្រុង ចំនួន ៤ ដាក់ត្រង់



www.elibraryofcambodia.org

ជ្រុងទាំង៤ នៃពែធំ ។

*បញ្ជាក់* : ពែតូចមួយកណ្ដាល សំរាប់ក្រុងពាលី ។ ឯពែបីជ្រុងចំនួន៤ សំរាប់ព្រះភូមិ និងនាង ហ៊ីងព្រះធរណី ។

– រៀបបាយស បាយក្រហម ញាំភ្លាដាក់ក្នុងពែ អំបាលនោះដាក់ត្រង់ទីណាមួយសមគួរដោយមានតុមួយ មានកំរាលដាក់ផ្កាមួយថូ ឆត្របាំងពីលើ ឬ ក្លស់ និងមានភ្លេងមួយវង់ លេងថ្វាយក្រុងពាលី ។

*របៀបអាចារ្យក្រុងពាលី* :

ដំបូងអាចារ្យថ្វាយបង្គំពាដង រួចមកផ្ដើមសូត្រអញ្ជើញទេវតាដើម្បីមកស្ថិតនៅនឹងខ្លួនជួយធ្វើការឱ្យជាមង្គល កុំឱ្យមានមោះមែភ័យ សត្រូវ ឬការ ថ្លោះធ្លោយអ្វី ។

*ខ្លឹមសារសូត្រ* : សិរោ មេ ពុទ្ធទេវញ្ចលលាដេ ព្រហ្មទេវតាបរមេស្សរហទ្ទយំ នារាយណញ្ច ពិស្ណុការ (សូត្របីចប់ប្រួចទឹកម្ដង) ។ ឱម អាពាធិ តេជោ ចិនរកេសសរា សសរេចិតោរសនស្មិ គហណំ លលាតេព្រហ្មទេវតា បរមេស្សរហទយំ នារាយណញ្ច ហត្ថិ ចរបេន ពិស្ណុការ ទេវតរាហិកា ការោ សព្វការ សព្វកិច្ចា សព្វកម្មា ព្រះមង្គលា ឱម នមោពុទ្ធស្ស នមោធម្មស្ស នមោ សង្ឃស្ស អាគច្ឆន្តុ បរិតុញ្ញន្តុ ស្វាហាយ ៗ រួចប្រួចទឹកម្ដងទៀត បន្ទាប់មកសូត្រអញ្ជើញព្រះភូមិទេវតាដែលរក្សាផែនដី : ឱមព្រះភូមិរាជាទេវា ឱមព្រះភូមិលក្ខណា ឱមព្រះភូមិរាជាឯហិៗ អាគច្ឆន្តុ តុញ្ញន្តុ តេសំ បុជានុតាទេន សព្វានុកូ



www.elibraryofcambodia.org

សព្វសោក សព្វរោគ សព្វឧបទ្រពចង្រៃវិនាសាយ សព្វលាភំ គវន្តុតេ ប្រូចទឹកម្ដងទៀត ។

រួចមកសូត្រសែន ថ្វាយក្រយាបូជាថា :

**ឱមបន្ទុមុត្តរោ បុរពាយំ អគ្គនិយេ ចនេទតា ទក្ខិណាយ្យំ កស្សបោ ពុទ្ធោ** ទើបអញ្ជើញក្រុងពាលី ព្រះភូមិនិង នាងគង្ហីងព្រះធរណី ចូរអ្នកអញ្ជើញមកយកក្រយាបូជា សារពើ ទៀន ធូប ផ្កាលាបុប្ផគន្ធវិលេបនះ ស្លា ម្លូរ ស្រូវអង្ករ ចេក អំពៅ ត្រាវដំឡូង ល្ង សណ្ដែកទាំងឡាយយើងខ្ញុំរៀបចំបូជាថ្វាយអ្នកហោង ។ ត្បិតយើងខ្ញុំធ្វើបុណ្យសង់ផ្ទះនេះ ក៏សូមឱ្យបានសេចក្ដី សុខ សេចក្ដីចំរើនជាឆាប់តុត ដូចក្ដីប្រាថ្នាហោង ។

អាចារ្យត្រូវមើលទិសដែលត្រូវយកពែចេញគឺ :

ឱ្យជីកដីត្រង់ទិសខាងត្បូង ចំងាយពីជើងសសរប្រមាណ១ហត្ថ ទំហំរណ្ដៅល្មមចុះពែជម្រៅ១ចំអាម លើកពែដាក់ក្នុងរណ្ដៅ ។ បើខ្មៅតដាក់ផ្កាបើរនោចដាក់ផ្កាប់រួចប្រូចទឹក ហើយសូត្រថា : **ឱមព្រះពិស្ណុការ ព្រះភូមិ ព្រះ-ធរណី បិទាឧប្បត្តិទេស្ដា នាមនាងអស្សមុខា** តែងតែរក្សាព្រះធរណីផ្ទៃក្រោមនេះណា នាងមានប្រដាប់ស័ក្ដិ សិទ្ធិ រិទ្ធិខ្លាំងក្លា មានជ័យចេស្ដា នាមក្រុងពាលីទ្រទ្រង់អំណាចប្រសើរឯង ពិតមែនមានរិទ្ធិ សូមឱ្យទទួលភោជន ផ្កាភ្ញី ទទួលការអភិវាទវន្ទាពីយើងខ្ញុំនេះណា យើងសូមសុខសួស្ដីជ័យគ្រៀមក្សាន្តមគ្គផលថ្កើងថ្កានបានដូចបំណង សូមឈ្នះទុក្ខសោក រោគភ័យផង ដូចក្ដីបំណងតរៀងទៅអើយ ។

រួចអាចារ្យស្រែកសួរ អ្នកអង្គុយជុំជិតថា : សុខមែនទេ ? អ្នកទាំងបួង



www.elibraryofcambodia.org

ត្រែរកថា សុះអែបហើយព្រុំរញា ។

អាចារ្យបន្តទៀតថា : សូមទោសទុក្ខចង្រៃរោគាភ័តភ័យវិនាសម៉ត់ហោះរ សូមក្តីចំរើន កើតកើនដូចរ៉ែង ច្រើនក្តាត់កន្លងដូចក្តីប្រាថ្នា ។

រួចអាចារ្យធ្វើឧបកិច្ចថា : កើតសម្បត្តិហើយ ឬ ? អ្នកទាំងអស់គ្នាឆ្លើយថា កើតសម្បត្តិហើយថែមទាំងមានកុសលផលបុណ្យប្រសើរទៀតផង ។

បានអីបន្ទាល់ ! ហ៊ោ .......! ផុតសំលេងហ៊ោហើយ ភ្លេងចាប់លេងសែនក្រុងពាលី ។

បន្ទាប់មក : ទើបនាំគ្នាលើកសសរផ្ទះនោះតាមទិសត្រូវលើក និង ជាបន្តបន្ទាប់រហូតធ្វើហើយជាស្ថាពរ ។ ពេលធ្វើផ្ទះថ្មី ជាទម្លាប់កន្លងមក គេហាមមនុស្សស្រីមិនឱ្យឡើង( ត្រង់នេះអាស្រ័យនិយមតាមតំបន់របស់ខ្លួនទៅចុះ) ។

## ៦. ពិធីឡើងផ្ទះថ្មី :

ពេលឡើងផ្ទះ ក៏ត្រូវរកពេលាដែរ ។ វិធីរៀបពេលឡើងផ្ទះមាន : បង្អែមមួយថាស . ចំអាបមួយថាស . ស្រូវតង់មួយការ៉ុង . បន្លែ . ផ្លែឈើ ប្រដាប់ធ្វើសំពត់ គឺតម្របធ្មេញឈើ ប្រដាប់ធ្វើស្រែចំការមាន កាំបិត កណ្ដៀវ កញ្ចើ ល្អី ប្រដាប់ប្រដាស្លៀកពាក់ហិបដាក់សំពត់អាវ ឆត្រមួយគ្រឿង មាសប្រាក់ គ្រឿងស្អិតស្អាងខ្លួន ដូចជាក្រាស់ កញ្ចក់ ប្រេងម្សៅ កន្ត្រៃកាំបិត កោរ ។ គ្រឿងដេកមាន កន្ទេល ពូកខ្នើយ មុង និងរូមមាន មួស្លា បារី ប្រអប់ស្លា ចាយព្រលឹង ត្បាល់កិនថ្នាំ ឬប្រដាប់ ដុសថ្នាំបូរាណ ។

ក្អមទឹកសិរិទ្ធ បើគ្មានយកផ្តិលសិរិទ្ធ ផ្តិលលង់ហិនជំនួសទៅ ។ កុយភ្លុក សង្ក័ ផ្លែដូងទុំបិទមាសមួយផ្លែ ត្រឡាចបិទមាសមួយផ្លែ ឆ្នាញីសម្បុរបីមួយ សារពើយុទ្ធ គឺប្រដាប់ចំបាំង មានធ្នូ ស្នា លំពែង ស្ព ។ល។



www.elibraryofcambodia.org

( របស់នេះរៀបមុខទីផ្ទះថ្មី ) អាចារ្យអ្នករៀបពិធី ត្រូវរើសរកស្ត្រីមានលក្ខណៈពិសេសសុទ្ធមិនបែកបាក់មែកធាង ជាតំណាង ។ អាចារ្យប្រសិទ្ធិនាមថា : នាងស្រី នាង រតន៍ នាង សួស្តី នាង កែវ នាងនាគ នាងជ័យ រួចមកឱ្យនាងទាំងនោះ កាន់វត្ថុសំខាន់ៗមួយចំនួនហែឡើងផ្ទះ ។

- នាងស្រីកាន់ក្អម ឬ ផ្តិលទឹក
- នាងរតន៍កាន់ហិបស្លា
- នាងសួស្តីកាន់សំពត់អាវ
- នាងគង់កាន់ពូក កន្ទេល ខ្នើយ
- នាងកែវកាន់មាសប្រាក់កែវកង
- នាងជ័យកាន់គ្រឿងភ្ជុកកុយ
- អ្នកក្រៅពីនេះកាន់គ្រឿងប្រដាប់ផ្សេងៗ

ដើរដង្ហែម្ចាស់ផ្ទះពាជុំ ( ម្ចាស់ផ្ទះត្រូវមានគេបាំងឆត្រ័ ឬ ក្លស់ឱ្យផង ។

- មនុស្សចាស់ទុំពីរនាក់ត្រូវនៅលើផ្ទះជាមុនតំណាងទេវតាប្រចាំផ្ទះ ពេលដង្ហែបានពាជុំហើយអ្នកនៅលើផ្ទះ ស្រែកសួរថា "អ្នកណា ? មកពីណា ? ច្រើនម្ល៉េះ ? "

- អ្នកនៅដីមានអាចារ្យជាដើមឆ្លើយថា : "យើងមកពីឆ្ងាយ នាំគ្រឿងឧបភោគបរិភោគកែវកងជាដើម ច្រើនស្នេកស្នាស់មករកទីលំនៅ ដោយឮថានៅទីនេះ មានផ្ទះមួយទើបសាងថ្មីនៅទំនេរ ព្រោះយើងខ្ញុំជឿជាក់ថាជាលំនៅផ្តល់សេចក្តីសុខក្សេមក្សាន្ត សុខកាយសប្បាយចិត្ត ដំណើរជីវិតប្រព្រឹត្តទៅ ដោយសុភមង្គលពិតៗ ។



www.elibraryofcambodia.org

អ្នកនៅលើផ្ទះឆ្លើយថា ផ្ទះនេះជាផ្ទះរបស់ ............... (រៀបរាប់ឈ្មោះប្រពន្ធប្តី កូនចៅទាំងអស់) នៃម្ចាស់ផ្ទះនេះ ។

អ្នកនៅដីឆ្លើយថា យើងខ្ញុំហែ អមតម ដំណើររបស់ឈ្មោះ ...... ដើម្បីបានលំនៅថ្មី ។

អ្នកនៅលើផ្ទះឆ្លើយថា អញ្ជើញមកចុះ ផ្ទះនេះអ្នកណាបាននៅហើយពិតជាបានសេចក្តីសុខចំរើន ទ្រព្យសម្បត្តិបរិបូណ៌ គ្រប់ប្រការ ។

### ៧. ពិធីសែនចងបៃប្លាស់ផ្ទះ :

ពេលឡើងដល់លើផ្ទះ ហើយអាចារ្យត្រូវរៀបចំពិធីសែន វិញ្ញាណដល់ជីដូនជីតា ដែលចែកឋានទៅហើយ និង ព្រះភូមិដែលជាម្ចាស់ទឹកដី សូមអញ្ជើញមកសេពសោយគ្រឿងក្រយាបូជា និង សុំពរជ័យពីអស់លោកទាំងអស់នោះ ។

បន្ទាប់មកអាចារ្យ យកអំបោះឆៅស ជ្រលក់ក្នុងប្រេងម្សៅក្រអូបចងដៃឱ្យប្រពន្ធប្តីម្ចាស់ផ្ទះជូនពរឱ្យមានសេចក្តីសុខសប្បាយ និងចំរើនធនធានគ្រប់ប្រការ ។ ក្នុងពិធីនេះ ទម្លាប់កន្លែងខ្លះពេបង្វិលពពិលផង ។ រៀបបង្វិលពពិលដូចមង្គលការដែរ ។

*ចំពោះវត្ថុផ្សេងៗដែលយកឡើងលើផ្ទះត្រូវទុកដូចតទៅ :*

- ឆត្រ័ ឬ ក្លស់ទុកទិសអាគ្នេយ៍
- ចង្ក្រានទុកទិសបូពិ
- អង្ករ ឆ្នាំង ទុកទិសទក្សិណ
- សង្ខ័ ទុកទិសនិរតី
- កាំបិត ពូថៅ ថ្ម ទុកទិស បស្ចឹម



www.elibraryofcambodia.org

- ភ្លុក ដែកផ្សេងៗ ទុកទិសពាយព្យ
- ស្រូវគង់ ទុកទិសឧត្តរ
- ឆ្នាំ កែវកង រូបស្ត្រីមានពពោះ (បើមាន) ទុកទិសឦសាន្ត
- ពូក កន្ទេល និង គ្រឿងសារពើភ័ណ្ឌ ផ្សេងៗទុកកណ្តាលផ្ទះ ។

៤. **ពិធីចំរើនព្រះបរិត្ត :**

ពេលព្រលប់ចាស់ៗថា ពេលគោក្របីចូលក្រោល ត្រូវនិមន្តព្រះសង្ឃ ៤ឬ៥អង្គ ចំរើនព្រះបរិត្ត ។ ពិធីនេះដូចពិធីសូត្រមន្តធម្មតា ដែលអាចារ្យ និងពុទ្ធបរិស័ទធ្លាប់ធ្វើ ។ ពិសេសមង្គលសូត្រ **ពាហុំ ជយន្តោ យន្ទុន្និមិត្តំ** និង **តេអត្ថលទ្ធា** ។ល។

## តម្រុយមើលដីតាមទិសចំផ្ទះ

ខាងកើត

ខាងជើង (left) — ខាងត្បូង (right)

| | | | | |
|---|---|---|---|---|
| ៤ មហាសេដ្ឋី | ព្រះបាទ ៣ ស្រីសញ្ជ័យ | ព្រះបាទ ២ សុទ្ធោទនៈ | ចោរ | អារក្ស |
| អស្សមុខី | ប្រពន្ធ ជិតប្តី | ភ្លើងឆេះ | ខ្មោច | អ្នក ប្រមាញ់ |
| ៦ មេស្រុក | ជោគលាភ ៥ សេដ្ឋី | សោះជា សោក | ១ មហោសថ | ផ្សារ |
| ស្តេច | ៧ សេដ្ឋី | ជុំជក | សត្រូវ | ឈ្មួញក្រី |
| អ្នកកំសត់ ៩ | ៨ស្សន្តរ | នាងពៃ ៨ សាខា | ចោរ | កាឡកិណី |

ខាងលិច



www.elibraryofcambodia.org

*បញ្ជាក់* : ក្នុងដីភូមិមួយៗ បែងចែកជា ២៥ ផ្ទះទាំងអស់ ទោះបីភូមិនោះ តូចក្តី ធំក្តី ហើយដែលអាចដាក់ផ្ទះនៅបាន គឺ ចំលេខ ១ ដល់ ៨ ក្រៅពី ៨ ពេញនេះ គឺអាចដាក់ផ្ទះនៅបានដែរតែត្រូវដាក់ជើងរៀង ។

សេដាសោក គឺជាផ្ចិតភូមិទាំងមូល ពុំអាចដាក់ផ្ទះចំពាក់កណ្តាល ដីបានឡើយ ។

ប៉ែកខាងជើង និង ខាងត្បូង សេតាសោក អាចដាក់ផ្ទះបានទាំងអស់ តែត្រង់ផ្សារ បើសិនជាមានគ្រោះថ្នាក់អ្វីមួយ គឺយើងមិនអាចទប់ទល់បានទេ តែបើដីចង្អៀត យើងអាចដាក់សសរជើងរៀងបាន ជៀសវាងសសរកន្លោង ។



www.elibraryofcambodia.org

# ពិធីមើលទិសដាក់ជណ្ដើរផ្ទះ

ពិធីមើរបៀបដាក់ជណ្ដើរផ្ទះនេះ គឺគេមើលតាមអក្សរនៃ ឈ្មោះភូមិដែលយើងរស់នៅ ។ តែអក្សរមើលនៅទីនេះ យើងបានសរសេរតាមកន្លែងមួយមាននាមជាមួយ ។ ចំពោះភូមិគេយកអក្សរចុង ។ ឧទាហរណ៍ ភូមិ "តាពោក" គឺអក្សរ "ក" ខាងចុង ។ ដូច្នេះសូមមើលអក្សរ "ក" នៅក្នុងក្រុមណា - នាមអ្វី ? គឺនាមខ្លា ។ បានន័យថា កាឡកណ្ណីនៅទិសឰសាន្ត ។

តទៅទៀត មើលតាមទិសនោះ១ចុះ ព្រោះបូរាណហាមតែទិសកាឡកណ្ណីតែមួយគត់ ។

## ខាងកើត

ស្រះពេញតួទាំងអស់
អ.អា.ឥ.ឦ......"នាមគ្រុឌ"

| | | |
|---|---|---|
| បរិវារ | អាយុ | តេជះ |
| កាឡកណ្ណី | ១ | សេរី |
| មន្ត្រី | ឱសា | មូល |

ក.ខ.គ.ឃ.ង
នាមខ្លា

| | | |
|---|---|---|
| កាឡកិណ្ណី | បរិវារ | អាយុ |
| មន្ត្រី | ២ | តេជះ |
| ឱសា | មូល | សេរី |



www.elibraryofcambodia.org

ច.ឆ.ជ.ឈ.ញ

នាមរាជសី

| | | |
|---|---|---|
| មន្ត្រី | កាឡកណ្ណី | បរិវារ |
| ឱសា | ៣ | អាយុ |
| មូល | សេរី | តេជះ |

ដ.ឋ.ឌ.ឍ.ណ

នាមឆ្កែ

| | | |
|---|---|---|
| ឱសា | មន្ត្រី | កាឡកណ្ណី |
| មូល | ៤ | បរិវារ |
| សេរី | តេជះ | អាយុ |

ត.ថ.ទ.ធ.ន

នាមនាគ

| | | |
|---|---|---|
| មូល | ឱសា | មន្ត្រី |
| សេរី | ៥ | កាឡកណ្ណី |
| តេជះ | អាយុ | បរិវារ |

ប.ផ.ព.ភ.ម

នាមកណ្តុរ

| | | |
|---|---|---|
| សេរី | មូល | ឱសា |
| តេជះ | ៦ | មន្ត្រី |
| អាយុ | បរិវារ | កាឡកណ្ណី |

**ជើង**

**ខាងត្បូង**

ឡ.យ.រ.ល.វ

នាមដំរី

| | | |
|---|---|---|
| តេជះ | សេរី | មូល |
| អាយុ | ៧ | ឱសា |
| បរិវារ | កាឡកណ្ណី | មន្ត្រី |

ស.ហ.

នាមឥន្ទ្រី

| | | |
|---|---|---|
| អាយុ | តេជះ | សេរី |
| បរិវារ | ៨ | មូល |
| កាឡកណ្ណី | មន្ត្រី | ឱសា |

**ខាងលិច**



www.elibraryofcambodia.org

## គម្រោងវាស់សសរផ្ទះ និង វាស់ទទឹងមាត់ទ្វារផ្ទះ

ការវាស់សសរបូរាណ សំដៅយកសសរកន្លោង ។ ឯមាត់ទ្វារសំដៅទទឹងមាត់ទ្វារចូលផ្ទះ ។

ការវាស់គឺត្រូវរាប់លេខខាងក្រោម កំណត់យកមួយលេខ ជា១តឹក ឯលេខទាំងអស់នេះមាន ៣១ គឺ ៣១ តឹក ត្រង់លេខ ៣១ មានអក្សរថា "មានបុណ្យស័ក្តិ" ។ មានន័យថា ៣១ តឹកនេះបើគិតជា ម៉ែត្រ គឺ ៣ ម៉ែត្រ ១តឹក ។ បើយ៉ាងដូច្នេះការវាស់សសរកន្លោង ត្រូវរាប់ត១រៀងទៅតាមខ្ពស់ទាបនៃសសរកន្លោងដែលយើងចង់បាន ។ ឧទាហរណ៍ ចង់បានដល់ ៧ម៉ែត្រ កន្លះ យើងរាប់រហូត ពី ៣១ ដល់លេខ ១.២.៣.៤ .............. គឺរាប់ថា ៣១ ៣២.៣៣ .៣៤ ............ តើដល់ ៧៥ តឹកប៉ះត្រង់កន្លែងណាមានអក្សរថាដូចម្តេច ? គឺចំលេខ ១៣ អក្សរថា : ច្រើនបានចំ-ណេញ ។ល។

### តទៅនេះជាលេខរៀងមានអក្សរផង

| | |
|---|---|
| ១. ទ្រព្យធនហូរចូល | ១៦. បានសុខសប្បាយ |
| ២. មានមាសពេជ្រ | ១៧. កូនចៅមានបុណ្យ |
| ៣. មានបុណ្យស័ក្តិ | ១៨. ច្រើនមានលាភ |
| ៤. បានជាធំ | ១៩. កូនច្រើនល្អ |
| ៥. រលាយទ្រព្យ | ២០. មានមាសប្រាក់ |
| ៦. ច្រើនមានទ្រព្យ | ២១. ច្រើនកើតក្តីក្តាំ |
| ៧. ស្លាប់ខ្លួន | ២២. ចោរលួចប្លន់ |
| ៨. ចង្រៃទំ | ២៣. ជម្ងឺច្រើន |



www.elibraryofcambodia.org

| | |
|---|---|
| ៩. បាត់ទ្រព្យធន | ២៤. មេម៉ាយកំព្រា |
| ១០. ព្រាត់ប្រាស់គ្នា | ២៥. ល្អសមគួរ |
| ១១. ភ្លើងឆេះផ្ទះ | ២៦. ធ្វើការមិនបាន |
| ១២. បានសម្បត្តិ មានបុណ្យ | ២៧. បានទ្រព្យធន |
| ១៣. ច្រើនបានចំណេញ | ២៨. ទ្រព្យធនហូរចូល |
| ១៤. កើតមាសប្រាក់ | ២៩. សុខប្រាំប្រការ |
| ១៥. មានជ័យជំនះ | ៣០. ទេវតាជួយ |

៣១. មានបុណ្យស័ក្តិ

## ពិធីរៀបពលីការព្រះពិស្ណុការ គ្រូដើម សំរាប់ចិញ្ចាសំណង់

**ពិស្ណុការ** ជានាម ពាក្យហៅមកពីបាលីថា : **វិស្សុកម្ម** សំស្ក្រឹត ថា : **វិស្វកម៌ន** ពីជានាមនៃទេវតា ដែលមានចំណេះខាងការជាង ជាអ្នកសំរេចកិច្ចការថ្វាយព្រះឥន្ទ ដែលយើងធ្លាប់ហៅថា **ព្រះពិស្សុកម្មទេវបុត្រ** ។

ពួកជាងពីបូរាណមានជំនឿរថា : ទេវតានោះជាគ្រូធំលើជាងទាំងឡាយ ។ ព្រោះហេតុនោះហើយបានជាហៅ រណ្តាប់ជា ទ្រនឹបជាង ឬ ទ្រនឹបគ្រូថា : ( **រៀបព្រះពិស្ណុការ** ) ឯពាក្យសាមញ្ញថា " រៀបពលីសការ " ។

តទៅនេះយើងជំរាបពិធីដែលមានត។ ពីបូរាណមក ក្នុងការរៀបព្រះពិស្ណុការ ជា ៣របៀប គឺ :



www.elibraryofcambodia.org

*របៀបទី១*

ពេលធ្វើប្រាសាទព្រះវិហារ ជាការងារធំៗ គឺ :

- រាន ៥ថ្នាក់១ . មានរបស់ពលិការដាក់បូជានៅរាននោះមាន : បាយសី ៥ថ្នាក់ ១គូ .បាយសីប៉ាក់ឆាម ១គូ . ស្លាធរ៍ជម ៤ . ទឹកអប់ ៤ . ទៀន ៥ . ធូប ៥ លាជ ៥ . សំពត់ស ៥ហត្ថ សំរាប់ក្រាលរាន . ប្រាក់ ៤ បាត ឬ ក្រដាសមាស ក្រដាសប្រាក់ . ក្បាលជ្រូកពីរ និង មានភ្លេងពិណពាទ្យមួយវង់ ។

- ដល់វេលានឹងធ្វើពលិការ ត្រូវយកគ្រឿងប្រដាប់ធ្វើទាំងប៉ុន្មាន មានដូចជា រណា ពូថៅ ដឹង ដែកឈូស ពន្លាកជាដើម ។ល។ មករៀបតាំងនៅមុខរានទេវតា ។ ទាំងមេជាង កូនជាង ត្រូវមកអង្គុយនៅមុខរានទេវតាមេជាងសូត្រអញ្ជើញ ព្រះពិស្ណុការ ជាគ្រូជាង និង អញ្ជើញទេវតា ដែលរក្សាទីកន្លែងសាងសង់នោះ សូមឱ្យអញ្ជើញមកទទួលសេពសោយគ្រឿងពលិការ និង សូមឱ្យជួយប្រសិទ្ធិការនេះឱ្យសម្រេចដោយរួសរាន់ កុំឱ្យមានគ្រោះថ្នាក់ មានមុតដៃមុតជើងជាដើមឡើយ ។ បួងសួងចប់អ្នកភ្លេងលេង ៣បទ តាមទំនៀម ។

*របៀបទី២*

កាលនឹងធ្វើការជាកណ្តាល មានធ្វើទូកធំៗ ឬ តទូកជួសជុលទូកធំៗ ជាដើមមាន :

រានទេវតា ៣ថ្នាក់ ១ . ដោយដាក់គ្រឿងពលិការមាន : បាយសីប៉ាក់ឆាម ៤ . ស្លាធរ៍ ៤ . ជម ៤ . ទឹកអប់ ៤ . ទៀន ៥ . ផ្កា ៥ . លាជ ៥ . សំពត់ស ៥ហត្ថ និងប្រាក់ ៦ ស្លឹងឬជាក្រដាសមាសក្រដាសប្រាក់ ។ មានសំពត់ជាតី ២ កំណាត់ទំហំ ១ហត្ថ ៤ជ្រុង គូរជាយន្តក្បាល៤ បញ្ចុះអក្សរ សិច្ចសិ វេលាធ្វើទូកបានជារាង



www.elibraryofcambodia.org

ហើយយកទៅបិតនៅត្រង់ខ្ទង់ ដែលមានមាត់កាត់តព្កា ត្រង់ក្បាលមួយ កន្សែមួយ ។ រួចមកមេជាង ធ្វើពលិការដូចខាងលើត្រង់របៀបទី១ ។

*របៀបទី២*

កាលបើធ្វើផ្ទះ គប្បីរៀបគ្រឿងពលិការ ដូចខាងក្រោម :

- រានទេវតា ៣ថ្នាក់មួយ ដោយរៀបគ្រឿងពលិការ : បាយសីប៉ាក់ឆាម ២គូ , ស្លាធរ័ ១គូ , ជម ១គូ , ទឹកអប់ ១គូ , ទៀន ៥ , ផ្កា៥ , លាជ ៥ , សំពត់ស ៥ហត្ថ និង ក្រដាសមាសក្រដាសប្រាក់ ។

- យកសំពត់ជាតិ មួយហត្ថបួនជ្រុង គូរជាយន្តក្បាល ៤ ទម្លាប់ខ្លះ គូរយន្តគ្រួច ។ គូររួច យន្តនេះយកទៅបិតជាប់និងមេដំបូល រួចហើយធ្វើពលិការដូចពោលខាងលើ ។

ចំណុចកត់សំគាល់ : សំពត់យន្តនេះខ្លះថា ( សំពត់ព្រះភូមិ ) ខ្លះថា ( សំពត់ពិស្ណុការ ) ។

ការរៀបពិស្ណុការគ្រូដើមនេះ ដើម្បីបញ្ចៀសគ្រោះថ្នាក់ផ្សេង១ ដូច្នេះពេលប្រមូលសំភារៈជាងសព្វហើយ ត្រូវរៀបចំពិធី ។ ឯការរៀបក្រុងពលី គឺពេលរៀប និង លើកផ្ទះបានន័យថា : ឈូសចាំងស្រេចហើយ ត្រៀមលើកសសរឡើង ត្រូវរៀបក្រុងពលី ។



www.elibraryofcambodia.org

# ពិធីរៀបអាពាហ៍ពិពាហ៍

## តាមរបៀប តាំងពីបុរាណ

១. ពិធីចែចូវ : អាណាព្យាបាលកូនប្រុស ត្រូវរើសយកស្ត្រីម្នាក់ នៅក្នុងភូមិ ជាអ្នកមានគូស្រករត្រឹមត្រូវ តាមប្រពៃណី មានប្ដីរស់នៅសព្វថ្ងៃ ( ចាស់ថាមិនបែកមែកធាង ) ជាអ្នកមានចរិយាសម្បត្តិល្អ និយាយទៅរកអ្នកណាក៏គេស្ដាប់ គេជឿទុកចិត្ត មានជីវភាពធូរធារ មានកាយសម្បទាគ្រប់គ្រាន់ ឱ្យនាងចូលទៅនិយាយការ ជាមួយម៉ែឪ ឬ អាណាព្យាបាលខាងស្រី ។

នាងដែលយើងពឹង ទៅនិយាយជាមួយម្ដាយឪពុក ឬ អាណាព្យាបាលខាងស្រី ដោយពាក្យពេចន៍ផ្អែផ្អាជាមុនសិនដូចពាក្យថា ទឹកដីជ័យភូមិនេះស្រស់បំព្រង ដំណាំដាំដុះគ្រប់បែបយ៉ាង ដាក់ចុះដុះឡើង អញ្ជឹងបានជាគេចង់មកផ្ញើសាច់ផ្ញើឈាម ចង់រួមរស់នៅលើទឹកដីដ៏មានជីជាតិនេះ ។

ខាងម្ចាស់ផ្ទះកូនស្រី ឮ សំដីនេះ មិនទាន់តបថាម៉េចទេ គ្រាន់តែសួរថា "អើ ! នាង ( ឬអ្នកតាមដែលអាចហៅបាន ) មានការអី ? ទឹកដីជ័យភូមិអី ? មកអង្គុយលេងសិន " ( រួចសួរសុខទុក្ខ ) បន្តថា "មានការអីដែរ ? " ។

នាងដែលយើងពឹងនិយាយត្រង់ថា : សូមទោសបង ( ឬអ្នកតាមស្និទ្ធស្នាល ) មានគេពឹងពររកខ្ញុំឱ្យចូលមកចែចូវ ភ្ជាប់សាច់ភ្ជាប់ឈាមជាមួយ .....។ ម្ដាយ ឬ ឪពុកខាងស្រីសួរឈ្មោះកូនប្រុស ពូជពង្ស គ្រួសារ គេមានកូនប៉ុន្មាននាក់ ប្រុសប៉ុន្មាន ? ស្រីប៉ុន្មាននាក់ ? ជាកូនទីប៉ុន្មាន ? ។ អាណាព្យាបាលខាងស្រីថា មិនអីទេចាំពិគ្រោះជាមួយឪវា ឬ ម៉ាវា និង សួរបងប្អូនសិន ។ តាមពិតគេចង់ពិនិត្យលើពូជពង្ស និង ចរិយាសម្បត្តិរបស់សាមីខ្លួន ។



www.elibraryofcambodia.org

នាងត្រូវតែពឹងពរនោះទៅ ២-៣-៤ដង រហូតបានដំណើងជាវិជ្ជមាន ។ កាលបើបានដំណើងជាវិជ្ជមានហើយ អ្នកចែចូវប្រាប់ខែថ្ងៃឆ្នាំកូនស្រីឱ្យខាងប្រុសយកទៅរកហោរាគន់គូរមើលពិនិត្យពង្សផ្សំធាតុ ។ បើល្អហើយខាងប្រុសរៀបចំចូលស្ដីដណ្ដឹង ។

## ២. ពិធីស្ដីដណ្ដឹង :

បានឯកភាពថាខាងស្រីឱ្យចូលស្ដីដណ្ដឹង ខាងប្រុសត្រូវ :

- រកហោរាមើលពេលាជ័យថ្ងៃ ខែ ឆ្នាំ ល្អដើម្បីសេរីសួស្ដី
- បានពេលាជ័យហើយ ខាងប្រុសប្រាប់អ្នកចែចូវ ឱ្យទៅប្រាប់ខាងស្រីពីពេលាថ្ងៃ ខែ ដែលចូលស្ដីដើម្បីខាងស្រីរកញាតិមិត្តមកជាអធិបតីក្នុងពិធីស្ដីដណ្ដឹងនោះផង ។
- ពឹងពាក់នារីមានលក្ខណៈល្អប្រសើរ ដូចនារីចែចូវជាធ្លាយនិយាយការ ។
- ជំរាបញាតិមិត្តទៅចូលរួមផង
- រកប្រដាប់ប្រដា មួស្លា តែស្ករ ម្ហូបអាហារ នំចំណី ជាទ្រនាប់ដៃ ។

អ្នកទៅស្ដីដណ្ដឹងហៅថា "អ្នកផ្លូវចៅមហា" ។

**<u>ខាងស្រីត្រូវ</u> :**

- ពឹងចាស់ព្រឹទ្ធាចារ្យ ចេះចាំប្រពៃណីស្ទាត់មកជាមេបា ។ ( បង្គោលការ ) សំរាប់សម្រេចកិច្ចការដែលធ្លាយស្នើសួរនិងបង្ហាប់បញ្ហា ឬឱ្យយោបល់ ។
- រៀបចំផ្ទះសំបែង
- រៀបម្ហូបអាហារទទួលភ្ញៀវ



www.elibraryofcambodia.org

- អញ្ជើញញាតិមិត្តសាច់សារលោហិត ។

លុះដល់ថ្ងៃកំណត់ខាងប្រុស នាំផ្ទាយ មហាចូលទៅជួបជុំគ្នា ហើយផ្ទាយចាប់និយាយ :

- អួតសរសើរពីចរិយាសម្បត្តិកូនប្រុសជូនលោកមេបា ។ ខាងមេបាថា "ទុកឱ្យខ្ញុំតាមដានកូនប្រុសឱ្យបានយូរបន្តិចសិន តើដូចពាក្យថា ឬ ទេ ? " ។

*ចណ្ណាក់ :* ពីដើមចូល ៣ លើក :

ទី១ គ្រាន់តែអនុញ្ញាតឱ្យផ្លូវដើរឡើងចុះ ទំនាក់ទំនង ។

ទី២ អនុញ្ញាតឱ្យទំនាក់ទំនងពឹងពាក់ ។

ទី៣ អនុញ្ញាតឱ្យនាំកូនប្រុសទៅជាមួយ ។

- ផ្ទាយថា "បើលោកមេបាមិនយល់ទាស់ទេ ខ្ញុំប្រគល់កូនប្រុសឱ្យនៅបំរើ ទុកពេលឱ្យលោកមេបាសង្កេត តើដូចពាក្យនាងខ្ញុំនិយាយដែរឬទេ ? " ។

- លោកមេបាសួរញាតិមិត្តទាំងអស់អំពីយោបល់ផ្ទាយថា ឱ្យកូនប្រុសនៅបំរើដើម្បីសង្កេតចរិយាសម្បត្តិ ។ បើបានការឯកភាពហើយ មេបាថា "សូមឱ្យកូនប្រុសរបស់អ្នកនៅជាមួយនឹងខ្ញុំចុះ " ។

- ក្រោយពីនៅបំរើមួយរយៈមក បើយល់ថាល្អហើយអាណាព្យាបាលខាងស្រី ហៅកូនប្រុសមកប្រាប់ថា ឱ្យអាណាព្យាលរៀបចំពិធីស៊ីស្លាធំ ឬ តូច ( ភ្ជាប់ពាក្យ ) ។

## ៣. ពិធីស៊ីស្លា :

- ពិធីនេះមានពីរយ៉ាង ស៊ីស្លាធំ ឬ ស្លាតូចទៅតាមធនធាន និង តាមការព្រមព្រៀងគ្នា ។



www.elibraryofcambodia.org

- ស៊ីស្លាធំ ស្មើរប្រហែលអង្គលការ គឺពាក់កណ្តាលនៃពិធីរៀបមង្គលការ ។

- ស៊ីស្លាតូចមួយភាគបី ( 1/3 ) នៃមង្គលការ ។

✳ **ស៊ីស្លានេះខាងប្រុសប្រុងប្រៀប :**

- រកហោរាពន់គួរជោគជតារាសី ថាតើត្រូវធ្វើនៅខែថ្ងៃឆ្នាំណា ? ។ តែត្រូវជំរាប ឱ្យខាងស្រីដឹងមុនយូរថ្ងៃបន្តិច ទុកឱ្យគេរៀបចំផ្ទះសម្បែងប្រុងប្រៀបអាហារទទួល ។

- រកថ្នាយនិងមហាទៅនិយាយជាថ្មី ។

- រកភស្តុភារបណ្ណាការជូនលោកមេបា ។

- អញ្ជើញបងប្អូន មាមីង ទៅចូលរួម ។ ដល់ថ្ងៃកំណត់យើងនាំញាតិ និង ជំនូនទៅខាងស្រីនិយាយការម្តងទៀត ។

ដំបូងថ្នាយនិយាយតាមលំដាប់លំដោយ ។ បើលោកមេបាថាត្រឹមត្រូវថាមិនអីទេ ឱ្យនាងធ្វើផ្ទះមួយខ្នង ឬ ពីរខ្នងទំហំ .........ស្លឹក ឬ ក្បឿង ( ពីដើមគេបង្កាប់ផ្ទះ រៀបការរួចប្រគល់ឱ្យកូននៅផ្ទះនេះតែម្តង ) ។

នាងថ្នាយ ឮ ដូច្នេះ សុំដកបង្អុយថយថា សូមទោសខ្ញុំជាស្រីសំដីតិចយល់មិនបានជ្រៅ ជាប្រពន្ធគេផង មិនអាចទទួលភារៈធ្ងន់ពីលោកមេបាបានទេ សូមប្តឹងដកបង្អុយទៅរកបុរសដែលមានកំលាំងខ្លាំង ស្មារតីរឹង បញ្ញាវាងវៃមកធានារ៉ាប់រងចំពោះលោកមេបា សូមលោកមេបាមេត្តាអនុគ្រោះ ។

*កាលបើនាងថ្នាយអង្វរបែបនេះ មេបាថា :*

"អើ ! បើនាងមិនហ៊ានទទួលភារកិច្ចរបស់ខ្ញុំទេ នាងទៅរកបុរសតាមសំណូម



www.elibraryofcambodia.org

ពារទៅចុះ ដើម្បីនិយាយការតទៅទៀត ។

- បុរសដែលត្រូវមកនិយាយនេះ សុំស្គាល់លោកមេបា និង ជំរាបពីប្រវត្តិសង្ខេបរបស់ខ្លួន ចំណេះវិជ្ជា តួនាទី និង សូមនិយាយការជាមួយលោកមេបា ។

- កាលបានដឹងពីប្រវត្តិ ហើយលោកមេបាអនុញ្ញាតឱ្យនិយាយការនិងបំពាក់តួនាទីថ្មីថាជាមហា ( មហាមាន៣ : មហាទេព មហាមន្ត្រី មហាភក្តិ ) ហៅថា ពាក់អាវសក្តិឱ្យមហាថ្មី ។

- បុរសបានតួនាទីជាមហា និយាយការតាមលំដាប់លំដោយ ។ បើលោកមេបាបង្គាប់តាមប្រពៃណី ហើយមហាបានទទួល មេបាថា ធ្វើសម្រេចថ្ងៃណា ខ្ញុំនឹងអនុញ្ញាតឱ្យលោកមហារៀបអាពាហ៍ពិពាហ៍ ជាមួយកូនស្រីខ្ញុំថ្ងៃនុះឯង ។

- បើសម្រេចហើយមហាត្រូវទៅទូលលោកមេបា នូវកិច្ចដែលបង្គាប់នោះថា សម្រេចហើយ ។

- លោកមេបាផ្ដើមនិយាយ ពីភស្តុភារបណ្ណាការ ( ជំនូន ) ពេលរៀបអាពាហ៍ពិពាហ៍បន្តទៀត ។

- មេបានិងមហាឯកភាពគ្នាហើយ ត្រូវមានសំបុត្រចុះចំនួនមុខរបស់និងចំនួនរបស់ភស្តុភារបណ្ណាការ ជូនលោកមេបា១សន្លឹក និង ខ្លួនឯង១សន្លឹក ។

មហាទទួលបង្គាប់ហើយ ត្រូវប្រាប់អាណាព្យាបាលឱ្យជ្រាប ។

- ខាងប្រុសជ្រាបហើយត្រូវរកហោរា មើលពេលារាសី ចេកមាសខ្មើយទឹម បានថ្ងៃណា ខែណា ឆ្នាំណា ។ រកបានហើយទៅប្រាប់លោកមេបាវិញតាមថ្ងៃខែឆ្នាំដែលហោរាបានប្រាប់ ។



www.elibraryofcambodia.org

- លោកមហានងមេបាប្តូរយោបល់គ្នារួចនាំដំណើងទៅប្រាប់ខាងប្រុស និងខាងស្រីតាមភារកិច្ចមេបា និង មហា ។

*បញ្ជាក់ :* រឿងនេះបើជនួងនិងជនួងពិភាក្សាត្រូវល្អហើយមិនចាំបាច់លោកមេបា និង មហាពិភាក្សាគ្នាក៏បាន ។ ទាល់តែជនួងនិងជនួងមិនឯកភាព ទើបរកកសិណ គឺមានមេបា និង មហាពិភាក្សាគ្នា ។

**បើបានឯកភាពហើយ ខាងប្រុសប្រុងប្រៀប :**

- រកអាចារ្យពេលា
- រកថ្នាយនិងមហា
- រកភ្លេងប្រពៃណី
- ជំរាបមាមីង បងប្អូនញាតិមិត្ត
- រកភស្តុភារ ( ជំនូន )
- រកគ្រឿងម្ហូបអាហារ ទទួលភ្ញៀវ ។

**ខាងស្រីប្រុងប្រៀប :**

- រកលោកមេបា
- រកអាចារ្យខ្មែ និង យាយខ្មែ ( ពីដើមអាចារ្យពីរ គឺខ្មែ+ពេលា )
- ជំរាបមាមីង មងប្អូនញាតិមិត្ត
- រកអង្ករ និង គ្រឿងប្រដាប់ធ្វើធ្មេញ ( ប្រសិនបើធ្វើធ្មេញ )
- រកស្បៀងអាហារទទួលភ្ញៀវ
- រកអ្នកផ្លូង



www.elibraryofcambodia.org

- រៀបចំផ្ទះសម្លៀង

**កំណត់សំគាល់** ៖ មុនស៊ីស្លា ឬក្រោយស៊ីស្លា លោកមេបាប្រើពាក្យថា "បើលោកមហាទទួលបាន សូមអញ្ជើញទៅមកចុះ ។ ប្រសាសន៍ របៀបនេះ លោកមេបានិយាយរហូតដល់ ម៉ោងអាចារ្យចាប់ដៃកូនស្រីប្រុសផ្សំផ្គុំជាស្វាមីភរិយា ទើបផុតពីការលក់ព្លៃ និង ផ្តាច់របស់លោក មេបា ។

*បញ្ជាក់* ៖ ពីដើមក្រោយស៊ីស្លារួចបុរសអាចនិយាយជាមួយ នារីបាន អាចដើរធ្វើការជាមួយគ្នាបាន តែប្រុសមិនអាចយកដៃប៉ះ ពាល់នារីបានទេ បើគេឃើញ គេហៅមកផ្តាច់ ។

**ក. ពេលរៀបអាពាហ៍ពិពាហ៍**

១. ព្រលឹមថ្ងាយ ឬ មហា ( ភាគច្រើនមហា ) ចូលទៅសុំអនុញ្ញាតពីលោកមេបា ។

- សូមទានខ្ញុំបាទ ...... មហាទេព មហាមន្ត្រី មហាភក្តិ ទាំងបីនាក់ ព្រមទាំងអ្នកមុខអ្នកការ ចូលប្រតិបត្តិលោកមេបា សូមផ្លូវលោកដើរ សូមជណ្តើរលោកឡើង សូមផ្ទះលោកអង្គុយនិយាយការ ។
- លោកមេបាអនុញ្ញាត
- មហាបន្ត ...........សុំដីសង់រោងផ្កាស្លា រោងការ និង រោងដាំបាយ
- លោកមេបាអនុញ្ញាត
- មហាបន្ត ............... សុំវាលលែងក្របី សុំព្រៃកាប់ឈើសង់រោង រកអុស សុំត្រពាំងដងទឹក ...... ( ត្រង់ចំណុចនេះមហានិយាយមួយវគ្គម្តង១ ) ។

កាលបើលោកមេបា អនុញ្ញាតសព្វគ្រប់ហើយ មហាសូមដកខ្លួន ចុះ



www.elibraryofcambodia.org

ទៅជំរាបអាចារ្យតាមដំណើរ ។

២. អាចារ្យកាលបើជ្រាបហើយត្រូវមើលដីសង់តាមខែ ត្រង់ហោរោង ផ្កា ស្លា ត្រង់ហោរោងការ ត្រង់ហោរោងដាំបាយ ។

៣. កំណត់ទីកន្លែងបានហើយ អាចារ្យអុជទៀនធូប សុំទីកសុំដី សុំទីសង់រោង ពីភូមិករព្រះធរណី អ្នករក្សាទឹកដី ។

៤. អ្នកធ្វើរោងតាមបញ្ជាអាចារ្យ ។

៥. ព្យាចមហាទាំងបី (ឥឡូវឃើញតែម្នាក់ទេ) ឯកូនមហាពីរនាក់ប្រុសទាំងពីរនាក់ ឬ កូនថ្នាយពីរនាក់ស្រីទាំងពីរ (ឥឡូវឃើញពីរដែរតែប្រុសមួយស្រីមួយ) ។ ព្រមទាំងអ្នកមុខអ្នកការ ចូលទៅសុំគាល់លោក មេបាសូមអនុញ្ញាតរៀបពិធីចូលរោង គោះគងទូងភារិ កូតទ្រ ផ្លុំប៉ី ដេញចាប៉ីដេញសាដៀវ ប្រគុំតន្ត្រីតាមប្រពៃណី សូមលោកមេបាកុំភ្ញាក់ផ្អើល ។

- លោកមេបាអនុញ្ញាតហើយ

- មហាត្រឡប់មករោងវិញ ជំរាបលោកអាចារ្យថា លោកមេបាព្រមហើយ ។

- លោកអាចារ្យបញ្ជាឱ្យ ក្រាលកន្ទេលដាក់ខ្នើយ ក្រាលសំពត់ពីលើខ្នើយបែរមុខទៅតាមកម្លាំងថ្ងៃ ។ អាចារ្យរៀបផ្លែឈើ បាយសម្ល អុជទៀនធូបផ្កាភ្ញី រួចឱ្យភ្លេងលេងបទហោមរោង ។ បន្ទាប់មកអាចារ្យបួងសួងសុំមេមត់ចាស់ស្រុក ភូមិករព្រះធរណី ពពួកទេវតាឱ្យជួយសេចក្ដីសុខ សេចក្ដីចំរើនដល់ពិធីមង្គលការនេះ ។

៦. ពេលយប់មហាទាំងបី ទៅសុំគាល់លោកមេបាសូមអនុញ្ញាតគោល



www.elibraryofcambodia.org

ពិធីរង្គលការនេះ ។

៦. ពេលយប់មហាទាំងបី ទៅសុំគាល់លោកមេបាសូមអនុញ្ញាតពោលការ ( កម្មវិធី ) ធ្វើអ្វីខ្លះទៅខាងមុខ ។

ជាទូទៅលោកមេបាដាក់ពោលការធំៗឱ្យមហា តែទោះជាយ៉ាងណាឱ្យតែដល់ពេលត្រូវមហាឡើង ទៅប្តឹងលោកមេបាជាល់ដាប់លំដោយ ។

**ពោលការធំៗមាន :**

ក. ពិធីសែនក្រុងពាលី

ខ. ពិធីស្តីដណ្តឹង

គ. ពិធីហែកំណត់

ឃ. ពិធីកាត់ផ្កាស្លា

ង. ពិធីកាត់សក់

ច. ពិធីសូត្រមន្ត

ឆ. ពិធីសែនគូចដៃ

ជ. ពិធីធ្វើធ្មេញ មាន :

- ក្រាលអង្គររាប
- ធ្វើធ្មេញ
- ប្រគប់ធ្មេញ
- បរសេះ
- កាត់ខាន់ស្លា
- កប់ជីរ



www.elibraryofcambodia.org

ឈ. ពិធីយកពេលា

ញ. ពិធីផ្ទឹម ( អាចារ្យចាប់ដៃកូនស្រីប្រុស អភិសេកឱ្យជាគូ ស្វាមីភរិយា )

ដ. ពិធីផ្សំដំណេក

*ខ. ការអនុវត្តគោលការណ៍ៗ :*

១. សែនក្រុងពាលី

- មហាសុំលោកមេបា ថាតើឱ្យធ្វើម៉ោងណា ។

- មេបាអនុញ្ញាត

- មហាស្ទើរសុំលោកមេបា ព្រមទាំងត្រកូលរៀមច្បង ចូលរួមពិធីសែនក្រុងពាលី ។

- មហាមកប្រាប់អាចារ្យ អាចារ្យទៅមើលកន្លែងរៀបចំសែនក្រុងពាលី ត្រូវក្រាលកន្ទេលកន្លែងណា ? ។ តាមធម្មតាគេត្រូវក្រាលកន្ទេល នៅលើដីខាងត្បូងផ្ទះកូនស្រី ខាងត្បូងល្វែងចន បែរមុខទៅត្បូង ។ បើផ្ទះកូនស្រីគ្មានកន្លែងខាងត្បូងទេ ត្រូវរៀបខាងកើត បែរមុខទៅត្បូង ។ ចំពោះអាចារ្យត្រូវអង្គុយលើក្បាលនាគជារហូត ។

- បន្ទាប់មករកមេមត់ព្រៃមកបញ្ជាន់ សុំទីកន្លែងក្រុងពាលី បាន ឬមិនបាន ? បើមេមត់ថាព្រមបានហើយទើបធ្វើពិធី ។

- មហាក្រាលកន្ទេល ដាក់ខ្នើយក្រាលសំពត់សពីលើខ្នើយរៀបសក្ការបូជា មានបាយសី ស្លាធរ៍ ផ្កាភ្ញី អុជទៀនធូប ប្រទីបង្ហាលា ម្ហូបអាហារបង្អែម មាន់ស្ងោរមួយគូ ពែពារូត ឬ ពែផ្សូតមួយ.......... ។



www.elibraryofcambodia.org

- ភ្លេងលេងបទស្តេចយាង ពេលហៅកូនប្រុស មកអង្គុយលើកន្ទេល (ពីដើមមានតែកូនប្រុសទេ ដែលមកអង្គុយសែនក្រុងពាលីនេះ ព្រោះទើបមកជាន់ទឹកដីថ្មី តែឥឡូវមានកូនស្រីដែរ) ។

- ភ្លេងលេងបទហោមរោង កងសោយ លោកមេបាអាចារ្យនិងអ្នកច្រៀង បួងសួងអញ្ជើលស្តេចក្រុងពាលីមកសេពសោយ និង ទទួលស្គាល់កូនប្រុសជា សមាជិកថ្មីនៃគ្រួសារនេះ ។

- លោកមេបាចាប់សំណែនមួយភាគដាក់ក្នុងពែ ព្រោះគេយល់ថាអ្នកមានបណ្តាសក្តិ អាចសេពសោយវត្ថុនេះបាន ឯអ្នកហែហមមិនហ៊ានហូបចូលអ្នកធំទេ ។ នៅចាំខាងក្រៅបានជាចាប់ដាក់ក្នុងពែ ដើម្បីឱ្យអ្នកហែហមបានហូបផង ។

- ភ្លេងលេងបទសែនពែ អ្នករបាំពីរនាក់រាំចាប់ពែសែងយកទៅតាមទិស ដែលអាចារ្យកំណត់ ។

- មហាទៅជំរាបលោកមេបា ពីកិច្ចការដែលខ្លួនធ្វើ ហើយសូមលោកមេបាបានបញ្ជាទៀត ។

- លោកមេបាបង្គាប់ចូលស្តីងណ្តើង ដើម្បីញាតិមិត្តជិតឆ្ងាយ មិនទាន់ដឹង បានដឹងផង ។

**២. ពិធីស្តីងណ្តឹង :**

- ពិធីនេះដូចមុន តែសង្ខេបខ្លីជាង ថ្នាយ និង មហាចូលនិយាយការជាមួយលោកមេបាឡើងវិញ ។ សំខាន់លោកមេបាចង់ឱ្យនិយាយពីការបង្គាប់ផ្ទះប្រាក់ ឬ មាស ដើម្បីមហាលើកវត្ថុនេះជូនលោកមេបា ។



www.elibraryofcambodia.org

- មហាស្មើសុំ លោកមេបាបញ្ជាអាជ្ញាកណ្តាល ទៅពិនិត្យភស្តុភារបណ្ណាការ ខ្វះមុខណាមហាបង្គាប់ ។

- មេបាចាត់មនុស្សទៅពិនិត្យ ជាបង ឬ ម្តាយមីងបង្កើត ឱ្យទៅពិនិត្យបណ្ណាការដែលគេរៀបនៅរោងការ ។

- អាជ្ញាកណ្តាលចាប់មួយមុខពីរ១ទៅជូនលោកមេបាពិនិត្យ បើគ្រប់ហើយមេបាបញ្ជាថា ឱ្យហែកំណត់មកចុះ ។

**៣. ពិធីហែកំណត់ :**

ពីដើមហែកំណត់នេះមានតែភស្តុភារ បណ្ណាការគ្មានកូនប្រុសទៅជាមួយទេ ។ សព្វថ្ងៃមានកូនប្រុសទៅជាមួយ ។

- ហែដល់មាត់ជណ្តើរ មានបុរសពីរនាក់ឃាត់សួរហេតុការណ៍ ។

- មហាជំរាបសព្វប្រការ ទើបអ្នកចាំជណ្តើរ អនុញ្ញាតឱ្យឡើងផ្ទះ ។

- រៀបចំជំនូនហើយ លោកមេបាហៅអាជ្ញាកណ្តាល ពីរនាក់ពិនិត្យឡើងវិញ ។ បើគ្រប់ហើយថាគ្រប់ បើមិនទាន់គ្រប់អាជ្ញាកណ្តាលប្រាប់លោកមេបាថាមិនទាន់គ្រប់ ។

- លោកមេបាថា គ្រប់ហើយ

- លោកមហាសួរ " តើពិធីជូនពេលា និង ពិធីស៊ីស្លា លោកមេបាអនុញ្ញាតឱ្យធ្វើពិធីណាមុន ? " សូមទានមេត្តាបង្គាប់មកចុះ " ។

- ពិធីនេះស្រេចតែមេបាបង្គាប់ណាមុនក៏បាន ។

- ពិធីទាំងពីររួចហើយ លោកមេបាបញ្ជា ឱ្យរៀបពិធីជូនភស្តុភារ



www.elibraryofcambodia.org

បណ្ណាការ ។

*បណ្ណាក់* : មេបាច្រើនឱ្យរៀបពិធី ជូនភស្តុការបណ្ណាការមុន ដើម្បីឱ្យយកចេញទុកស្រឡះកន្លែង និង យកវត្ថុនោះទៅប្រើប្រាស់ផង ។

- ពិធីសុំស្លាពីដើម ឱ្យឪពុកម្តាយខាងប្រុស ឬ បងប្អូនខាងប្រុសលើកជូនទៅឪពុកម្តាយខាងស្រី តែឥឡូវឃើញកូនមហាជូនវិញ ។

- លោកមេបាបង្គាប់ទៅមហាឱ្យរករបាំមួយគូ រាំសង្កត់ស្លាដក់ ស្លាកន្សែង ។ បើរកបានហើយ លោកមេបាឱ្យរាំសាកដៃសិន ។ បើរាំត្រូវ អនុញ្ញាត បើមិនត្រូវមេបាបង្រៀន ។ បើនៅតែមិនត្រូវ ឱ្យរកអ្នកផ្សេងមួយគូទៀត ។

*បន្ទាប់មកលោកមេបាបង្គាប់បន្ត* :

- រាំសង្កត់ស្លាដក់ស្លាកន្សែង
- អាផ្ងាស្រោ
- ដងស្រាដំណើរ
- អូសស្លា
- ពោះហិប
- រាំខ្មែងពែង
- ផឹកប្រាំ ហ៊ោប្រាំ
- ដោះក្រាល
- លប់ជើងមួយ



www.elibraryofcambodia.org

- មេបញ្ជារហូតចប់ ទើបឱ្យមហារៀបពិធីបញ្ចូលក្រយា ។

- មហាចាត់ចែងរកផ្តិលទឹក បាយ ម្ហូប ចង្កឹះ ស្លាបព្រា មកដាក់កន្លែងសមគួរ ។

- ភ្លេងលេងបទសុរិន្ទខ្ចងកំ ច្រៀងបទអង្គរករ លោកមេបាឱ្យចាប់ផ្តើម ទឹកខ្ទុរមាត់ ចាប់ស្លាបព្រា ចង្កឹះ ពិសាភោជនាហារ ។

- លោកមេបាបញ្ជាមហា ឱ្យហែកូនប្រុសទៅកាត់ផ្កាស្លា ឬ ផ្កាដូង ។ មហាទៅជំរាបអាចារ្យ មាតាបិតានិងញាតិមិត្ត តាមពេលម៉ោងមេបាកំណត់ ។

៤. ពិធីកាត់ផ្កាស្លា :

ដល់ពេលហើយអាចារ្យទៅដល់ទីកន្លែង ដើមដូងឬស្លា មើលស្ថានភាពទីកន្លែងត្រូវក្រាលកន្ទេលឈមមុខទៅទិសណា ឱ្យស្របទៅតាមកម្លាំងថ្ងៃ ។

- ក្រាលកន្ទេលដាក់ខ្នើយ លើកកន្ទេល ក្រាលសំពត់សលើខ្នើយ រកជើងពានទ្រផ្កាស្លា ឬ ដូង រកអំបោះពណ៌ស សំរាប់ចងដៃ និង ចងដើមដូង (អំបោះអៅសសុទ្ធ)

- បានសព្វគ្រប់ហើយ អាចារ្យឱ្យមហា ឬ អាចារ្យខ្លួនឯង ហែកូនប្រុសចេញពីរោង ឬ ពីកន្លែងកូនប្រុសស្នាក់នៅ មកកន្លែងពិធី ។

- អាចារ្យឱ្យកូនប្រុសអង្គុយលើកម្រាល

- អាចារ្យអុជធូប ទៀន បាយសំណែន និយាយបួងសួង ដល់ភូមិករ ព្រះធរណី មេមត់ចាស់ស្រុក សុំផ្កាស្លា ឬ ដូង យកទៅធ្វើជាមង្គល សិរីសួស្តីក្នុងពិធីមង្គលការ ។

- រួចហើយមកអាចារ្យសូត្រ ជយន្តោ ប្រសិទ្ធិពរឱ្យកូនប្រុសរួចហើយ

www.elibraryofcambodia.org

**បញ្ជាក់** : ពីដើម អ្នកឡើងដើរទៅមុខ ដល់ត្រង់កដូង ហើយត្រឡប់ក្បាលឡើង ។ ដល់ចុះមកក៏ចុះក្បាលមកមុន ។ ការកាប់នេះប្រយ័ត្នបំផុត មិនឱ្យបែក ឬ ប្រេះទេ ។

- ពេលចុះជិតដល់ដី អាចារ្យយកជើងពាន ដែលចងភ្ជាប់ ដោយចិញ្ចៀន និង ដាក់ប្រាក់ជាទ្រនីរ លើកជើងពានសំរាប់ជូនអ្នកឡើង ហុចឱ្យកូនប្រុស ។
- កូនប្រុសយកជើងពានទទួលផ្កាស្លា ជានិមិត្តរូប សុភមង្គលរបស់ខ្លួន អ្នកឡើងពាបជើងនឹងដើមស្លា ឬ ដូង ឱ្យជាប់ យកដៃស្រាយបង្ហិចក្រមា រុំផ្កាស្លា ឬ ដូង ដាក់ស្រាលលើជើងពាន រួចយកប្រាក់ដែលគេដាក់ជាទ្រនីបលើជើងពាននោះ ។
- បានផ្កាស្លា ឬ ផ្កាដូងហើយ អាចារ្យហៅកូនប្រុសមកវិញ
- អាចារ្យបង្គាប់ឱ្យមហារៀបចំពិធីកាត់សក់ ។

**៩. ពិធីកាត់សក់ :**

ការកាត់សក់នេះពីដើម កូនប្រុសកាត់នៅរោងការបែរមុខ ទៅខាងកើតចំរានទេវតា ដែលអាចារ្យបានរៀបចំទុក ។ ការកាត់ គឺកាត់មែនទែនជ្រងផ្កាថ្កូវ ។

ឯកូនស្រីកាត់លើផ្ទះ អង្គុយនៅល្វែងចន្ទបែរមុខទៅកើតដូចគ្នា ដោយអាចារ្យខ្មែរជាអ្នកចាត់ចែង ។ ពិធីនេះកាត់ពេលជាមួយគ្នា ដោយបញ្ជាពីអាចារ្យពេលា ។ តែកូនស្រីគ្រាន់តែកោរោម បំណ្ណោះ ទុកសក់បួង ។

- ការអង្គុយចាំបាច់កូនស្រីត្រូវអង្គុយ ខាងស្តាំ ។

www.elibraryofcambodia.org

- សព្វថ្ងៃ យើងឱ្យកូនស្រីអង្គុយជាមួយកូនប្រុសតែម្តង នេះក៏ល្អម្យ៉ាងដែរ ដោយឱ្យអង្គុយទន្ទឹមគ្នា ។ តែប្លែកត្រង់ឱ្យកូនប្រុសអង្គុយខាងស្តាំវិញ ។ វាខុសពីពិធីបូរាណ ។

- សម័យបូរាណអាចារ្យរៀបជាវគ្គ១មាន កាត់សក់ មុជទឹក លាបប្រេងម្សៅ ប្រសិទ្ធិពរជ័យ ។

*ក. វគ្គកាត់សក់ :*

- អាចារ្យរៀបចំអាសនៈ មានតុ កៅអី បែរមុខទៅរករានទេវតា ក្រាលកន្ទេលដាក់ខ្នើយ នៅមុខតុ កៅអី បែរមុខទៅរករានទេវតា រៀបសក្ការៈលើរានទេវតា មាននំអន្សម ផ្លែឈើ ស្លាធម៌ បាយសី ចងឆ័ត្រមួយគូបាំងរានទេវតា ។

- រៀបរួចអាចារ្យឱ្យភ្លេងលេងបទ ចៅព្រាម ឬ ប៉ុកពើក ។

- មហាហែកូនប្រុសមកអង្គុយលើកម្រាល បែរមុខទៅរករានទេវតា

- មហាអញ្ជើញមេបា មាតា បិតា បងប្អូនចូលរួម ។

- អាចារ្យអុជធូបទៀន នាំនមស្ការព្រះរតនត្រៃ ។

- នមស្ការចប់អាចារ្យ ឱ្យឪពុកម្តាយកូនប្រុស អង្គុយបែរមុខទៅរកកូនខ្លួន ។

- អាចារ្យចាប់ដៃកូនប្រុសឱ្យស្គាល់គុណរបស់ មាតា បិតា សូមខមាទោសមាតា បិតា សុំអនុញ្ញាតមាតា បិតា អង្គុយលើកៅអីកាត់សក់ ។

- អ្នកភ្លេងលេងបទសារិកាកែវឬបទណាមួយដែលលោកមេបាបញ្ជា



www.elibraryofcambodia.org

- ពីបូរាណអ្នកកាត់ គេរើសយកមាបង្កើត ឬ បងប្រុសបង្កើត បើមិនចេះកាត់ គេគ្រាន់តែចូលកាត់ជើងសក់ពីរកន្ត្រៃ រួចប្រគល់ឱ្យជាងវិញ ។

- ពីដើម គ្មានប្រកាសលក់កន្ត្រៃទេ តែឥឡូវមានក៏ល្អណាស់ដែរ ព្រោះជាប្រផ្នូលបានព្រះឥន្ទផ្តល់ ក្រាស់ កន្ត្រៃ កាំបិតកោរ ប្រេងម្សៅ ដល់គូស្វាមីភរិយាថ្មី ។ តែសូមប្រើពាក្យពេចន៍ឱ្យបានល្អៗ ជៀសវាងអាសអាភាស នាំខូចប្រពៃណី ។

- កាត់សក់រួចមេបា ឱ្យទៅទាក់ដរី បញ្ជិះកូនប្រុសទៅមុជទឹកស្ទឹង ហៅថា ស្ទឹងអនោមា ( តាមលិទ្ធិព្រាហ្មណ៍ )

ខ. វត្តមុជទឹក :

- ធម្មតាកាត់សក់រួច ត្រូវមុជទឹក ស្ទឹង បឹង អណ្តូង ត្រពាំង ស្រះពាង ដើម្បីសំអាតកាយ ។

- បូរាណឱ្យទៅមុជទឹកជិត១ផ្ទះ ដើម្បីលើកដម្កើងកូនប្រុស គាត់ឱ្យជិះដរី មានហែហមមុខក្រោយកិត្តិយសណាស់ ។ បើគ្មានដរីក៏យកសេះឬក្របីក៏បានដែរ តែត្រូវប្រើពាក្យថាដរី ។

- មេបាបញ្ជាឱ្យទៅរកដរី

- ភ្លេងលេងបទទាក់ដរី

- បុរសពីរនាក់ធ្វើរបៀបចេញដំណើរ លេចវាលចូលព្រៃ រៀបរាប់ទេសភាព ។ បើខ្លាចជួបឧបស័គ្គ គេច្រៀងបែរបន់ សុំមេមត់ព្រៃ ដែលថែរក្សាដរី សុំអនុគ្រោះដល់ខ្លួន ។

- ភ្លេងលេងបទសុរិន្ទខ្នងភ្នំ



www.elibraryofcambodia.org

- ទាក់ដីវបានហើយ បង្គាប់កូនប្រុសឱ្យជិះដីរទៅមុជទឹក ដោយអាចារ្យដើរមុខ អ្នកហែហមដើរក្រោយ ។

- ភ្លេងលេងបទស្តេចយាង

- ដល់ម្ងួតទឹកភ្លេងលេងបទត្រពាំងពាយ ។

- មុជទឹកហើយត្រលប់មកវិញ ផ្លាស់សំលៀកបំពាក់ អង្គុយលើកៅអី លាបប្រេងម្សៅ និង ប្រសិទ្ធិពរជ័យ ។

ឥ. **លាបប្រេងម្សៅ :**

- អង្គុយលើកៅអីហើយ ភ្លេងលេងបទជ្រង ឬ បទណាមួយដែលលោកមេបាបង្គាប់ ។ ច្រៀងសរសើរពីរូបសម្បត្តិ កូនប្រុស រួចច្រៀងជូនពរ ។

- អាចារ្យសូត្រ **ជយន្តោ** និង អប់រំកូនប្រុស ។

- អាចារ្យបង្គាប់ឱ្យសូត្រមន្ត ។

**៦. ពិធីសូត្រមន្ត :**

- ពីដើមសូត្រមន្តដោយឡែកពីគ្នា ។ ខាងស្រីសូត្រលើផ្ទះ ខាងប្រុសសូត្រក្នុងរោង ។

- ព្រះសង្ឃយ៉ាងតិច៤អង្គ ដោយសូត្រមន្តខាងស្រីមុន ទើបមកសូត្រខាងប្រុសជាក្រោយ ។

- ព្រះសង្ឃនិមន្តដល់លើផ្ទះ កូនស្រីត្រូវចេញមកអង្គុយត្រង់ល្វែងចន្ទ

- អាចារ្យរៀបចំគ្រឿងសក្ការៈ នមស្ការ សុំសីល និងអារាធនា ព្រះសង្ឃចំរើនព្រះបរិត្ត ។ ចប់ខាងស្រីទើបអាចារ្យ និមន្តព្រះសង្ឃ ទៅសូត្រខាង



www.elibraryofcambodia.org

ប្រុសទៀត ។

- ឥឡូវនេះគេសូត្រមន្តជាមួយគ្នាតែម្តង គឺនៅលើផ្ទះខាងស្រី ។

- សូត្រមន្តជាមួយគ្នានេះ កូនប្រុសមិនអាចអង្គុយជាមួយកូនស្រីនៅ ល្វែងចន្ទបានទេ ត្រូវអង្គុយនៅល្វែងឆៀង ។

- ការអង្គុយកូនស្រីអង្គុយខាងស្តាំជានិច្ច ។

**៧. ពិធីសែនគូចដៃ :**

- ពិធីនេះគឺគេគោរពវិញ្ញាណក្ខន្ធ ជីដូនជីតា និង សុំឱ្យគាត់ ទទួលស្គាល់ថាខ្លួនបាន រៀបអាពាហ៍ពិពាហ៍ និង គោរពជីដូនជីតា នៅរស់ ឱ្យគាត់យកអំបោះចងដៃទទួលស្គាល់ ថាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។

- ពីបូរាណគូចដៃគឺ ជីដូនជីតា មាតាបិតា ម្តាយធំ ឪពុកធំ និង បងប្អូនទាំងអស់ ចាប់អំបោះឆៅពណ៌ស ចងដៃកូនប្រុសស្រី ។ ហើយមានវត្ថុមានតម្លៃផ្សេងៗទៀត ដូចជា មាស ប្រាក់ គោ ក្របី ដីស្រែចំការជាដើម ទៅចងដៃជានិមិត្តរូបល្អបំផុត ។

- ពីដើមគេធ្វើឱ្យកូនស្រីរួច ទើបចុះទៅធ្វើឱ្យកូនប្រុសនៅឯរោង ។

- ក្រោយមកឱ្យកូនប្រុស អង្គុយល្វែងឆៀង លើផ្ទះកូនស្រី ធ្វើខាងកូនស្រីមុន ទើបធ្វើខាងកូនប្រុស ។

- អាចារ្យរៀបចំក្រាលកន្ទេល ប្រឈមមុខទៅទិសត្បូង ដាក់ខ្នើយក្រាលសំពត់សពីលើខ្នើយ ផ្តិលទឹកមានអំបោះឆៅពណ៌សសម្រាប់ចងដៃ មាន់ស្ងោ ឬ ក៏ទាស្ងោមួយគូ បាយសម្ល ទឹកតែ ស្រា ទៀន ធូប ជាដើម ។

- ភ្លេងលេងបទនាងនាគ អញ្ជើញកូនស្រីមកចងដៃ ។ កូនស្រីចេញ



www.elibraryofcambodia.org

មកអង្គុយលើកក្រោលបែរមុខទៅត្បូង ។

- មេបា ឱ្យភ្លេងលេងបទកងសោយ

- អាចារ្យចាប់សែននាំមុខគេ ទើបមេបាទាំងអស់ចាប់សែនទាំងអស់គ្នា ។ សែនរួចភ្លេងលេងបទបាយខុន អាចារ្យ មាតាបិតា .......ចូលចងដៃ ។

( សព្វថ្ងៃគេហៅ គូទាំងពីរទៅសែន ហើយគូចដៃតែម្តង )

( សែនបើមានលទ្ធភាពល្អអាចធ្វើធ្មេញបំពេញលក្ខ )

## ៨. ពិធីធ្វើធ្មេញ :

ពីបូរាណ ពិធីធ្វើធ្មេញនេះ ត្រូវគេនិយមធ្វើមកច្រើនណាស់ ស្ទើរគ្រប់មនុស្ស ព្រោះគេយល់ថា បន្ទាប់ពីធ្វើធ្មេញរួច កូនស្រីរបស់គេ នឹង បានឡើងជានារីគ្រប់លក្ខណៈ មានចរិយាល្អ ស្គាល់ខុសត្រូវ មនុស្សម្នាទាំងពួងទទួលស្គាល់ថានារីមានលក្ខណៈសម្បត្តិល្អប្រពៃ ។ និយាយជារួមសង្គមខ្មែរពីដើម គេធ្វើធ្មេញទាំងបុរសផងដែរ ដើម្បីឱ្យបានជាបុរសគ្រប់លក្ខណៈ ចំពោះតែអ្នកមិនបានបួសប៉ុណ្ណោះ ។ បើបានបួសហើយដល់ពេលរៀបអាពាហ៍ពិពាហ៍ មិនបាច់ធ្វើធ្មេញទេ ។

## ក. ពិធីក្រាលអង្កររាប :

ពិធីនេះបើកូនច្បង និង កូនពៅ យកអង្ករ ៦ តៅ ឯកូនកណ្តាលយកអង្ករ ៣ តៅ ។ លោកអាចារ្យរៀបចំពិធីនៅល្វែងចន្ទៀងខាងត្បូង ។ អាចារ្យរៀបចំក្រាលកន្ទេល រួចក្រាលសំពត់សលើកន្ទេល រកនាឡិ ពែង ត្រល់សម្រាប់វាល់អង្ករ ។ យ.យខ្វៃយកនាឡិវាល់អង្កររាប់តាមអាយុ ។ កន្លែងខ្លះឱ្យកូនស្រីវាល់ ព្រោះពិធីនេះជាពិធីសង់ភូមិថ្មី បើកូនស្រីវាល់ ល្អប្រសើរជាង ។



www.elibraryofcambodia.org

ឯអង្គរនេះមិនត្រូវជូនអាចារ្យទេ ត្រូវទុក ព្រោះជារបស់មង្គល ។ កន្លែងខ្លះបែរជាជូនអាចារ្យវិញ ។ ( ប្រហែលជាគេគ្មានអីជូន ឬ យ៉ាងណា ? ) រាស់អង្កររួចហើយ ម៉ែឪ បងប្អូនយកវត្ថុផ្សេងៗ មានមាស ប្រាក់ ត្រល់ ។ល។ ទៅកប់ក្នុងអង្ករដើម្បីផ្សងព្រេងវាសនាកូនស្រី ។ យាយខ្មែរាសអង្ករឱ្យរាបល្អ ជាបួនជ្រុង រួចទាញសំពត់សគ្របលើអង្ករ ។ អ្នកភ្លេងបួនអ្នកឈរគ្រប់ចែងទាំងបួន ច្រៀងរាំខ្មែងអង្ករាប និង ខ្មែងពែង ។

### ក.១. ពិធីរាំខ្មែងអង្ករាប :

រៀបចំស្រេចហើយ អ្នកភ្លេងបួននាក់ ឈរចែងអង្ករទាំងបួន បែរមុខរកគ្នា ដៃចាប់ស្បូវភ្លាំងតាមចង្វាក់ភ្លេង ។ ច្រៀងចប់ ដាក់ស្បូវភ្លាំងចុះ ដោយយកគល់ដាក់ចំចែង ខ្លួនឈរ និង ចុងទៅចែងម្ខាងទៀត ។ អ្នកទាំងបួននាក់ដាក់ដូចគ្នា ច្រៀងដូចគ្នា ។ ច្រៀងចប់បន្តច្រៀងខ្មែងពែងទៀត ។

### ក.២. ពិធីរាំខ្មែងពែង :

អ្នកភ្លេងបួននាក់ឈរនៅចែងអង្កររាប កាន់ពែងស្រាមួយម្នាក់ មានស្រាពេញ ច្រៀងចប់មួយវគ្គផឹកបន្តិច រួចហុចពែងស្រាប្តូរគ្នាទៅមក ។ ធ្វើបែបនេះបីដង ។ បន្ទាប់មកលោកមេបាបង្គាប់ឱ្យនាំកូនស្រី មកអង្គុយលើអង្កររាប ។

### ខ. ពិធីអង្គុយលើអង្កររាប :

អ្នកភ្លេងម្នាក់មានសម្លេងពីរោះ ឈរនៅមុខបន្ទប់កូនស្រី តោងខ្សែច្រៀងប្រាប់កូនស្រី អំពីពេលវេលា និង ករណីយកិច្ចកូនស្រីត្រូវធ្វើបន្តទៀត ស្រើសត្រឡង ចេញមកពីក្នុងមកអង្គុយលើអង្កររាប ស្រើសសុភាពមកអង្គុយ



www.elibraryofcambodia.org

លើអង្ករាបបំពេញលក្ខណៈកូនស្រី ........." ។ ច្រៀងចប់យាយខ្មែចាប់ដៃកូនស្រីមកអង្គុយលើអង្ករាប ។ កូនស្រីអង្គុយហើយ លោកមេបាបញ្ជាឱ្យរៀបពិធីគាស់ខ្នែរ ។

**គ. ពិធីគាស់ខ្នែរ :**

ខ្នែរជារបស់រមាស់ ការគាស់ខ្នែរសំគាល់ថា ពីថ្ងៃនេះទៅមុខ គ្មានការស្មៀបរមាស់ទៀតទេ ។ គឺជាពិធីមួយហាមកូនស្រី បើមានប្ដីហើយកុំឱ្យរមាស់គូថ អង្គុយនៅផ្ទះមិនបានដើរតែផ្ទះគេ ។កុំរមាស់មាត់ ដើរនិយាយដើមគេ កុំរមាស់ជើងដើរគ្រប់ច្រកល្ហកមិននៅផ្ទះ កុំរមាស់ដៃលួចកាន់យកទ្រព្យសម្បត្តិគេជាពិធីឱ្យកូនស្រីក្លាយជាស្រីគ្រប់លក្ខណៈ ........ ។

*របៀបគាស់ខ្នែរ :* ត្រូវរកឫសអ្វីមួយរាងដូចខ្នែរ មកដាក់ជុំវិញអង្ករាបដែលកូនស្រីអង្គុយ ។ អ្នកភ្លេងបួននាក់កាន់ចបជីកម្នាក់មួយៗ ដើរជុំវិញកូនស្រី ធ្វើដំណើរទៅគាស់ខ្នែរ និង ច្រៀងថា :

តាខ្មែរយាយខ្មែរ ផ្លែដៃផ្លែជើង
បានអ្វីឱ្យយើង យើងគាស់ខ្នែរឱ្យ
ឱណាកែវណា យើងគាស់ខ្នែរឱ្យ ។
គាស់ដល់ ឫសខាងៗ ខ្ញុំជីកលោកអើយ
អស់ហើយ ដល់ឫសខាងៗ ខ្ញុំជីកអស់ហើយ
ឫសកែវៗនៅឡើយ ជីកបង្ហើយក្រោយគេ ។
ឱណាកែវណា ជីកបង្ហើយក្រោយគេ
អញ្ចឹងថាជីកៗ ជីកៗ រំពឹង ជីកឱ្យរលីង លើកមង្គលកូនស្រី ។



www.elibraryofcambodia.org

គេច្រៀងបាន ៣ដង ទើបយកចុងចបជីកឆ្កឹះ ឫស ខ្មែរទម្លាក់ចេញពីលើអង្គរវាប ។ ការនេះហាមដាច់ខាតមិនឱ្យប៉ះកាយ ឬ លើករំលងកូនស្រីទេ ។ រួចគេដាក់ចបជីកយកដៃប្រមូលខ្មែររួចយកផ្តិលទឹកទៅសូត្រពរជ័យដល់កូនស្រី ។ បន្ទាប់មកលោកមេបាឱ្យទៅរកលក្តជុំកន្លង់ នៅព្រៃហេមពាន្ត ខ្លះថាព្រៃសម្បុកសម្បូរណ៍ ខ្លះថាភ្នំកៃលាស ដើម្បីមកធ្វើធ្មេញឱ្យកូនស្រី ។

## ឃ. ពិធីរកល័ក្ខជុំកន្លង់ :

អ្នកក្លេង ២ឬ៤នាក់ ធ្វើដំណើរលេចវាល ចូលព្រៃច្រៀងរៀបរាប់ទេសភាពតាមផ្លូវ ។ ដល់កន្លែងមានល័ក្ខ ពិតមានឧបស័គ្គ បេះយកមិនបានទេ អ្នកភ្លេងលេងបទសុរិន្ទខ្លងភ្នំ ច្រៀងអង្វរករ ខ្មោច អ្នកតា សូមឱ្យអនុគ្រោះ ។ បានល័ក្ខហើយ លោកមេបា បានបង្គាប់ឱ្យរកឈើធ្វើត្បាល់ អង្រែ បុកល័ក្ខ ។

## ង. ពិធីកាប់ឈើធ្វើត្បាល់អង្រែ :

អ្នកក្លេង ២ឬ៤នាក់ ឈរលីដឹង ឬ ពូថៅ ធ្វើដំណើរចូលព្រៃរកមើលឈើណាគួរធ្វើត្បាល់ និង អង្រែបាន ។ រួចគេច្រៀងហាក់ដូចជាកាប់ឈើ ។ កាប់ឈើបានហើយនាំគ្នាលី ឬ សែង៧យកមកផ្ទះធ្វើពិធីកាប់ ចាំង ដាប់ ឈូស ធ្វើត្បាល់ និង អង្រែ ។ រួចមេបាឱ្យបុក ល័ក្ខ ។

## ច. ពិធីបុកល័ក្ខ :

អាចារ្យខ្មែរយកត្បាល់ និង អង្រែមកដាក់ចំកណ្តាល ពីមុខអង្គរវាប ។ យកក្មេងព្រហ្មចារី ស្រី២នាក់ ប្រុស២នាក់ មកអង្គុយជុំវិញ ។ អាចារ្យយកតៅ និង ថាស សំរាប់ត្រងល័ក្ខ ដាក់ក្បែរត្បាល់ ។ យកកូនក្អមមួយ ទឹកពេញមកដាក់ពីមុខក្មេងម្នាក់មួយៗ យកល័ក្ខជុំកន្លង់មកដាក់ក្នុងត្បាល់ ។ យកអំបោះ



www.elibraryofcambodia.org

ពណ៌សមកចងចង្កូរដៃក្មេង ព័ទ្ធជុំវិញ កូនស្រី និង ត្បាល់ ៩ជុំ គឺព័ទ្ធសីមា ។

អាចារ្យខ្មែរឱ្យកូនស្រីយកអង្រែបុកល័ក្ត ។ ភ្លេងលេងបទប៉ុកពើកឬបទអ្វីដែលមេបាបង្គាប់ ។ រួចអ្នកភ្លេង ៤នាក់ ដើរច្រៀងអប់រំកូនស្រីថា :

"បើនាងបុកល័ក្ត ១ទាក់ឱ្យខែ .មង្គលជោគជ័យសួស្តី កើតមានដល់កូនស្រីគ្រប់ពេលវេលា ......." ។ និងធ្វើកាយវិការដូចជាខ្លួនបុកល័ក្តដែរ ។ កូនស្រីបុកបានហើយអាចារ្យខ្មែរ ឱ្យជីកស្រះ ឬ អណ្តូងយកទឹកលាយល័ក្ត ។

## ឆ. ពិធីជីកស្រះ ឬ អណ្តូង :

អ្នកភ្លេងបួននាក់ ឈរច្រៀងរៀបរាប់ ពីការជីកស្រះ ឬ អណ្តូងនោះ ។ ធ្វើកាយវិការដូចជាហត់ខ្លាំងណាស់ ។ បានទឹកហើយយកមកឱ្យលោកមេបា ។ មេបាយកទឹកលាយល័ក្ត ។ លាយរួចហើយខ្វះកន្ទោង ឱ្យកូនស្រីខ្ទាក់ល័ក្តដាក់ក៏បញ្ជាឱ្យទៅព្រៃហេមពាន្ត រកស្លឹកធ្វើកន្ទោង ។

## ជ. ពិធីកាត់ស្លឹក :

អ្នកភ្លេង ២ឬ៤ នាក់ចូលព្រៃ ត្រូវជួបឧបស័គ្គអ្វីមួយ គេរៀបចំសែនអ្នកតាព្រៃភ្នំ ។ កាត់ស្លឹកបានជូនលោកមេបា ។ ធ្វើកន្ទោង កន្ទោងនេះយាយខ្មែរ ជូនលោកមេបា ឱ្យរៀបចំធ្វើធ្មេញ ។

## ឈ. ពិធីធ្វើធ្មេញ :

គេរកអ្វីដែលមានជាតិចត់ ជូរ ល្វីង ហិរ ប្រៃ ដូចជាល័ក្ត ជុំអន្លង់ សាច់ជូរ អំបិល ម្រេចមកស្ងោរលាយគ្នាឱ្យខាប់ ល្វីងខ្លាំង ជូរខ្លាំង ហិរខ្លាំង ។ គេត្រូវរកចង្ក្រានទុកជាស្រេចសំរាប់ស្ងោរ ។ ស្ងោរហើយអាចារ្យខ្មែរ ចាក់ដាក់ពែងទុកឱ្យត្រជាក់ល្មមបៀមបានរួច ឱ្យកូនស្រីបៀម ហាមមិនឱ្យលេបចូលជា



www.elibraryofcambodia.org

ដាច់ខាត ។ ទឹកមាត់ពេលបៀមក៏មិនត្រូវលេបដែរ ។ បៀម ៣ឬ៤ នាទី ឱ្យខ្ទាក់ដាក់កន្ទោង ។ ធ្វើ ៣ ដងទើបចប់ ។ សំខាន់កូនស្រីត្រូវដឹងថា អញត្រូវទទួលពាក្យ ល្វីង ជូរ ចត់ ហឹរ ប្រៃ ពីអ្នកដទៃ ជារឿងរហូត ។ អញមិនត្រូវលេបចូលក្នុងពោះទេ អញបៀមខ្ទាក់ចោលទៅទី កំបាំង លុបចោលឱ្យជិតកុំឱ្យសាយភាយទៅក្រៅ ។ សំខាន់មិននិយាយពីមួយទៅមួយ ដែលជាការពាំនាំពាក្យសូរចុះឡើងបណ្ដាលឱ្យកើតរឿង ។ រួចមេបាឱ្យមហាធ្វើពិធីប្រតប់ធ្មេញ ។

## ៣. ពិធីប្រតប់ធ្មេញ :

គឺធ្វើធ្មេញជាប់ស្អាតល្អ អស់ពិស អស់ចង្រៃ ឧត្បាត កាឡកណ្ណី ចេញពីខ្លួន ។ អាចារ្យយកចានថ្មីល្អ វាយបំបែក យកអំបែង កោសធ្មេញជាច្រើនដង រហូតធ្មេញស្អាត ។ បន្ទាប់មកលោកមេបា បង្គាប់ធ្វើពិធីឱ្យបាយព្រលឹង ។

## ៤. ពិធីធ្វើបាយព្រលឹង :

យកដូងខ្ចីចំណាស់បន្តិច កាប់បើកលលាដ៏នារីព្រហ្មចារីម្នាក់យកអង្ករស្រូវដំណើប ដាក់ក្នុងដូង ដាក់ស្ករ ខ្ទិះដូងទឹកដោះគោ រួចបិទគ្រិតទៅដុតលើចង្ក្រានទាល់តែឆ្អិន ។ ភ្លេងលេងបទសុរិន្ទ បួងសួងឱ្យព្រះព្រហ្មចុះមកប្រសិទ្ធិពរជួយថែរក្សាបាយព្រលឹង ឱ្យមានប្រសិទ្ធិភាពល្អ ។

បាយឆ្អិនហើយអាចារ្យខ្មែរ ចាប់បួងសួងរួចយកបាយព្រលឹងបញ្ចុកកូនស្រីពាស្លាបព្រា ។ ភ្លេងលេងបទជ្រងសរសើរគុណភាពបាយព្រលឹង ថានារីណាបានហូបបាយព្រលឹងហើយ នារីនោះនិងបានសិរីសួស្ដី ជ័យមង្គលពិតប្រាកដណាស់ ។ រួចមេបាឱ្យធ្វើពិធីបរសេះបញ្ជាន់ភូមិ ។

## ៥- ពិធីបរសេះ :



www.elibraryofcambodia.org

អាចារ្យទៅសូត្ររំលាប់ រួចបរសេះឬ ដើរបញ្ជាន់ភូមិបណ្ដេញសត្រូវ បីសាច ។ អ្នកភ្លេង ៤នាក់ ឡើងពរកាន់រូបសេះ (ធ្វើពីធាងចេក ដើរប្រទក្សិណយ៉ាងស្វាហាប់ស្រែកច្រៀង ស្រែកហ៊ោរ ដូចជាស្រែកដេញសត្រូវ ដេញបីសាច......។ ចុងក្រោយអ្នកច្រៀងម្នាក់ មានសំឡេងពិរោះ ស្រែកច្រៀងខ្លាំងៗនៅមុខអង្គររាប គឺនៅមុខកូនស្រី តោងខ្សែស្រែកភ្លោងឡើងរួចទន្ទ្រាំជើង ខ្លាំងៗ (ពីដើមផ្ទះរនាបគេធាក់បំបាក់រនាបមួយ) ឥឡូវផ្ទះថ្មី ឬ រនាបក្ដារគេត្រូវរករនាបមួយមកទុកជាស្រេច ពេលធាក់ត្រូវឱ្យបាក់មួយកំណាត់ភ្លាម បើសេះធាក់មិនបាក់នាំឱ្យមានចង្រៃ ។ ចប់លោក មេបាឱ្យធ្វើពិធីកាត់ខាន់ស្លា ។

**ឌ. ពិធីកាត់ខាន់ស្លា :**

អាចារ្យបញ្ជាឱ្យទៅរកផ្លែឈើ នៅព្រៃហេមពាន្ត មកជូនត្រកូលរៀមច្បង គឺញាតិខាងឪពុកម្ដាយកូនស្រី ។ បើបេះផ្លែឈើបានហើយ មហាពិភាក្សាជាមួយមេបា ពីបញ្ហា ៣ប្រការ ប្រាក់ ខាន់ស្លា ស្លាប់ទឹកដោះ និងផ្កាស្លា៣ តើលោកមេបា ពិសាណាមុន (ធ្វើណាមុន) មេបាឱ្យធ្វើប្រាក់ ខាន់ស្លាមុន រួចស្លាប់ទឹកដោះ និង ចងផ្កាស្លាបី ។

*ឌ-១- ពីធីកាត់ខាន់ស្លា :*

តំលៃខាន់ស្លាមិនឯកភាពគ្នាទេ តាមតំបន់ ។ ពីដើមគិតតាមស័ក្តិ :

ក. រាជស័ក្តិ គឺជាប់វង្សស្ដេច ប្រហែល ១០៥.៥០៛ ពីជាន់មុន ។

ខ. ឧត្តមស័ក្តិ គឺកូនមន្ត្រី ៩១.៩០៛ (ជំនាន់មុន) ។

គ. បុរាណស័ក្តិ ត្រឹមក្រសួងមន្ទីរចៅហ្វាយស្រុក ៤១.៤០៛

ឃ. ភព្វស័ក្តិ អ្នកស្រុកធម្មតា ១៩.៧០៛ជំនាន់នោះ ។



www.elibraryofcambodia.org

*ខ-២- ប្រាក់ស្អាប់ទឹកដោះ :*

ជាតំលៃប្រាក់មាតាចិញ្ចឹមកូន ដោយទឹកដោះ ។ មេបាទទួលពីមហា ហើយត្រូវជូនទៅម្ដាយកូនស្រីវិញ ។ បើម្ដាយស្លាប់ជូនឪពុក ។ បើគ្មានម្ដាយឪពុកជូនអាណាព្យាបាល ។

*ខ-៣- ផ្កាស្លាបី :*

យកនារីគ្រប់លក្ខណ៍មកចងជាបី :

ក. ផ្កាស្លាធំ ឬ ច្បង សំរាប់សងគុណឪពុក យកផ្កាស្លា ២១ទង យកម្លូ ២១សន្លឹក មករុំផ្កាស្លា យកអំបោះពណ៌ស មករុំ រួចដាក់ក្នុងស្រាព ឬ កែវយកផ្លែស្លា ២១ ផ្លែ មកដោតព័ទ្ធជុំវិញ ។

ខ. ផ្កាស្លាកណ្ដាល សងគុណម្ដាយ យកផ្កាស្លា១២ទង ម្លូ១២សន្លឹក មករុំនឹងអំបោះឆៅ ពណ៌ស មករុំដាក់ក្នុងកែវ ឬ ស្រាពយកផ្លែស្លា ១២ ផ្លែ ដោតព័ទ្ធជុំវិញ ។

គ. ផ្កាស្លាពៅសងគុណបង យកផ្កាស្លា៦ទង ម្លូ៦សន្លឹក ផ្លែស្លា៦ ធ្វើដូចខាងលើ ។ ពេលចងផ្កាស្លាភ្លេងលេងបទនាង ទក់ សំពោង ,ដីរយោលដៃ ។

- ការចងផ្កាស្លាឱ្យចងលើផ្ទះកូនស្រីតែម្ដង ចៀសវាងមេបាលំបាក ។

- ចំពោះប្រាក់ស្អាប់ទឹកដោះ ធ្វើយ៉ាងណាមិនឱ្យហួសសមត្ថភាព តែត្រូវយកប្រាក់នេះទៅធ្វើបុណ្យឧទ្ទិសផល យ៉ាងហោចណាស់បានប្រាក់សង្ឃទានមួយព្រឹកដែរ ។ មិនមែនយក ប្រាក់ទៅទុក ទេតីធ្វើបុណ្យ ។

**ឈ. ពិធីកប់ល័ក្ខ :**

គេយកកន្ទោងល័ក្ខទៅកប់ ស្រែណាដែលម្ដាយឪពុកបំរុងចែកឱ្យកូនស្រី



www.elibraryofcambodia.org

អាចារ្យទៅមើលកន្លែង ។ មេបាឱ្យជីកដីត្រឹមជង្គង់ (ក្រោយមកឱ្យជីក ត្រឹមជង្គង់) រួចមេបា អាចារ្យ មបា មាតា បិតា ញាតិ មិត្ត ហៃកូនស្រីទ្រកន្ទោង ល័ក្ខទៅកន្លែងនោះ ។ អាចារ្យឱ្យកូនស្រីដាក់ចានទ្រកន្ទោងទៅកន្លែងនោះ អាចារ្យឱ្យកូនស្រីដាក់ចានទ្រកន្ទោង ទៅក្នុងរណ្តៅ រួចអាចារ្យ ឱ្យកាយដីកប់បង្ហាប់ឱ្យជិត ។ អាចារ្យប្រាប់ថា : ពីពេលនេះតទៅនាងត្រូវទទួលពាក្យសរសើរ ឬ រិះគន់មិនខានទេ បើសរសើរញញឹមទុកក្នុងពោះកុំដើរអួត ។ បើរិះគន់ នាងត្រូវបៀមទុកក្នុងមាត់ កុំនិយាយប៉ប៉ាច់ប៉ប៉ោច ឮ ដល់អ្នកដទៃ ។ ដូច្នេះទើបនាងឡើងជាស្ត្រីគ្រប់លក្ខណ៍ ។ រួចមេបាឱ្យធ្វើពិធីយកពេលា ។

ចប់នាទីអាចារ្យខ្មែរ ត្រឹមកប់ល័ក្ខ ដល់វេនអាចារ្យពេលាវិញម្តង ។

៩. <u>ពិធីយកពេលា</u> :

ពិធីនេះមាន ៤ គឺ :

- ពេលាសត្វ
- ពេលាស័ព្ទអក្សរ
- ពេលាព្រះច័ន្ទពេញវង្ស ឬ ពេលាព្រះអាទិត្យពេញវង្ស
- ពេលាជាន់ឆាយា ។

ក. ពេលាសត្វ : យកពេលរំលងអាធ្រាត រហូតម៉ោង ៤ កន្លះថ្មើណាក៏បាន

ខ. ពេលាស័ព្ទអក្សរ : ពេលមើលអញ្ចាញដៃឃើញ

គ. ពេលាព្រះច័ន្ទពេញវង់ : ពេលថ្ងៃរះពេញវង់

ឃ. ពេលាជាន់ឆាយា : ពេលថ្ងៃត្រង់ ។ តែជាន់ឆាយានេះអាចារ្យ



www.elibraryofcambodia.org

ខ្លាចគេពោសមិនបានធ្វើទេ ទាល់តែអ្នកចេះកម្មដ្ឋានទើបបាន ព្រោះខ្លាចអន្តរាយ តែបើបែរជាធ្វើបានល្អ បំផុត ។

- ដល់ពេលហើយអាចារ្យ មាតាបិតា ញាតិមិត្តទាំងកូនប្រុស អង្គុយលើកផ្ទៀលបែរមុខទៅរានទេវតា មានបាយសី ៣ វួត ៥វួត ៩វួត តាមរាសីកូនប្រុស ចងឆត្រមួយគូ និង ប្រដាប់ផ្សេងទៀត ។

- អាចារ្យនាំកូនប្រុសថ្វាយបង្គំព្រះរតនត្រៃ រួចឱ្យកូនប្រុសទន្ទេញធម៌តាំងចិត្តបរិសុទ្ធ ។ អាចារ្យសូត្រធម៌ផ្សំធាតុ ឱ្យមានលក្ខណៈល្អប្រពៃ ។ ល្អហើយអាចារ្យវាយ គងជាសញ្ញាថា សុភមង្គលកើតមានហើយ ។ រួចមេបាឱ្យសំពះផ្ទឹម ។

១០. **ពិធីសំពះផ្ទឹម :**

យកពេលាបានហើយ មហាទៅប្តឹងសូមអនុញ្ញាតធ្វើការងារបន្ត ។ មេបាឱ្យហៅកូនប្រុសទៅផ្ទឹម ។

ក. កូនប្រុសត្រូវត្រៀមវត្ថុមានតំលៃ តាមខ្លួនឱ្យហើយស្រេចដល់លើផ្ទះកូនស្រីកូនប្រុសឈរលើថ្ម ដែលគេរៀបទុកស្រាប់ ។

- មហាសុំអនុញ្ញាតមេបា សូមកូនស្រីមកលាងជើងកូនប្រុស ។

ខ. មេបាឱ្យកូនស្រីចេញមកលាងជើងកូនប្រុស ( បូរាណកំណត់ថា ប្រុសជាធាតុថ្ម ស្រីធាតុទឹកនៅជាមួយគ្នាត្រជាក់ត្រជំណាស់ )

- ខាងស្រីរកផ្តែដូងឡៅទុកស្រេច រកសំឡីកូនកន្សែងថ្មីទុកស្រេច ។ អ្នកដឹកដៃកូនស្រីមកមុខកូនប្រុស លុតជង្គង់សំពះកូនប្រុស ។ កូនស្រីយកសំឡីឬកន្សែងជ្រលក់ទឹកដូងជូតជើងកូនប្រុស ។ ជូត ៣ ដង ។ រួចកូនស្រីសំពះម្តង



www.elibraryofcambodia.org

ទៀត ។ កូនប្រុសយក វត្ថុមានតំលៃ បំពាក់ជូនកូនស្រីជានិមិត្តរូបសុភមង្គល ។ កូនស្រីចូលក្នុងវិញ ។ កូនប្រុសចូល ទៅសំពះផ្កាស្លាបី គោរពជីដូនជីតា ។

**ឆ. ពិធីសំពះផ្កាស្លា :**

កូនប្រុសអង្គុយត្រឹមត្រូវហើយ អាចារ្យពេលា បួងសួងទឹកគុណជីដូនជីតា មកជួយប្រសិទ្ធិពរជ័យ កូនប្រុសស្រី ក្នុងពេលកូនប្រុសលើកផ្កាស្លាបី គោរពលោកមេបា មាតាបិតាទាំងអស់ ។ មហាសុំអនុញ្ញាតឱ្យកូនស្រីសំពះផ្ទឹម ។

**ឃ. ពិធីសុំកូនស្រីមកសំពះផ្ទឹម :** ( រាំបើកវាំងនន )

អ្នកភ្លេងប្រុសម្នាក់ដើរបណ្តើរច្រៀងបណ្តើរ ស្នើសូមលោកមេបាតូចធំក្រមុំ កម្លោះ បើកផ្លូវឱ្យខ្លួនបានចូលទៅរាំបើកវាំងនន ។ ដល់វាំងននអ្នកច្រៀងរៀបរាប់ថា "ពេលាបានហើយសូមបើកវាំងនន សូមអនមកផ្ទឹម" ។ អ្នកដឹកដៃកូនស្រីត្រូវមានលក្ខណសម្បត្តិល្អណាស់ទើបបាន ។

កូនស្រីអង្គុយត្រឹមត្រូវហើយ រៀបចំសែនដូនតា ។

**ង. ពិធីសែនដូនតា :**

គេហៅជីដូនជីតា ទាំងខាងស្រី ទាំងខាងប្រុស មកជួបជុំតែម្តង ។ សាមីខ្លួនអង្គុយស្រួលហើយមហា អាចារ្យ មេបា ឪពុកម្តាយ អុជធូបទៀន បួងសួងបន់ស្រន់ឱ្យ វិញ្ញាណក្ខន្ធដូនតាមកសេពសោយ ក្រយាស្ងោយ សំណែន និង ឱ្យលោកទទួលស្គាល់ អ្នកទាំងពីរជាស្វាមីភរិយា និង សូមសេចក្តីសុខចំរើន ។ រួចធ្វើពិធីចាប់ដៃផ្សំផ្គុំ ។

**ច. ពិធីចាប់ដៃផ្សំផ្គុំ :**

អាចារ្យឱ្យកូនស្រីលើកដៃសំពះផ្ទឹមគ្នា ។ អាចារ្យលុតជង្គង់អធិដ្ឋាន



www.elibraryofcambodia.org

ទឹកគុណព្រះរតនត្រ័យ ព្រះឥន្ទ ព្រះព្រហ្ម ទេវតា អ្នកតា សូមមកសណ្ឋិតលើបាតដៃខ្លួន ។ ពេលចាប់ដៃកូនប្រុសស្រី សូមឱ្យអ្នកទាំងពីរបានសុខចំរើន អាចារ្យចាប់ដៃអ្នកទាំងពីរទន្ទឹមគ្នា ទាញដៃឱ្យអង្គុយទ្រេតលើខ្នើយ រួចហើយ ធ្វើពិធីរាំបើកបាយស្រី ។

ឆ. ពិធីរាំបើកបាយស្រី : (បើកឡេប)

អ្នកភ្លេងប្រុសម្នាក់ ច្រៀងរាំបើកបាយស្រីមាន៣វគ្គ

១. រាំហូតដាវ : អ្នកច្រៀងដៃម្ខាងកាន់ដាវ ដៃម្ខាងកាន់ស្រោម រួចហូតដាវ . ច្រៀងបញ្ជាក់ពីមហិទ្ធិរិទ្ធនៃដាវ ដែលលោកអាចារ្យប្រគល់ សំរាប់ការពារសត្រូវ ។

២. យកសំពត់ស្បៃ ៥ហត្ថមក ក្រវាត់ច្រៀងបញ្ជាក់ចិត្តក្លាហាន របស់បុរសដែលមានដើមទ្រូង ៥ហត្ថ ។

៣. រាំបើកឡេបមួយគូ : ច្រៀងបញ្ជាក់ពីគុណភាពឡេប មួយគូថាជាឡេបមានដំលៃ គ្មាននរណាម្នាក់ក្រៅពីលោកមេបា បញ្ជាឱ្យបើកបានទេ លុះចប់ ពិធីនេះហើយ រៀបចំពិធីចងដៃកូនប្រុសស្រី ។

ជ. ពិធីចងដៃកូនប្រុសស្រី :

មេបាតូចធំ ចាប់អំបោះសដែលគងលើមាត់ផ្តិល មកចងដៃកូនប្រុសស្រីប្រសិទ្ធិពរជ័យ និង ទទួលថាអ្នកទាំងពីរ ពិតជាបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីពិតប្រាកដមែន ។ ចប់ហើយធ្វើពិធីបង្វិលពពិល ។

ឈ. ពិធីបង្វិលពពិល :

អាចារ្យយកមនុស្ស ៩នាក់ ស្រី ៤នាក់ ប្រុស ៥នាក់ ដែលមានខាន់ស្លា



www.elibraryofcambodia.org

ហើយនៅរស់ទាំងអស់គ្នា មកអង្គុយព័ទ្ធសីមាកូនស្រី ។

អាចារ្យបិតទៀនពពិល ៣ រួចអុជទៀនឱ្យឆេះស្មើគ្នា អាចារ្យសូត្រ ថយទ្នោ រួចហុចពពិលម្តងមួយៗ ទៅឱ្យមនុស្សដែលនៅឆ្វេងខ្លួន ។ អ្នកទទួលទៀនពីអាចារ្យ ត្រូវយកដៃបក់ផ្សែងទៀន បញ្ចូលទៅរកកូនប្រុសស្រី ដែលអាចារ្យកំណត់ ។

បង្វិលពពិលចប់អាចារ្យ ពន្លត់ទៀននៅមុខកូនប្រុសស្រី ហើយបង្គាប់ឱ្យកូនប្រុសស្រីហាមាត់ស្រូបយកផ្សែងមង្គល ដែលលោកអាចារ្យយកស្លឹកម្លូ១៩ សន្លឹក ជាតំណាងព្រលឹងទាំង១៩ មកបក់ផ្សែងទៀនពពិល បញ្ចូលក្នុងមាត់កូនស្រី ។ បង្វិលពពិលចប់អាចារ្យចាប់ដៃកូនប្រុសស្រី ឱ្យអង្គុយធម្មតា ។ អាចារ្យនិយាយផ្តែផ្តាំកូនប្រុសស្រីរួច ប្រគល់វត្ថុជាសេរីសួស្តី ដូចជា ចែកពេលាទៀនពេលា ទៀនបង្វិលពពិល អង្ករបង្វិលពពិល ឱ្យទៅកូនស្រី និង បញ្ជាក់ពីពិធីយកវត្ថុមួយៗ ទៅប្រើប្រាស់ផងរួចធ្វើពិធី ហែកូនប្រុសស្រីទៅកាន់បន្ទប់ ។

**៣. ពិធីហែកូនប្រុសស្រីចូលកាន់បន្ទប់ :**

ដំបូងអាចារ្យប្រាប់កូនប្រុសស្រី ឱ្យដើបឈរ គឺដើបតំណាលគ្នា ព្រមគ្នា កុំមុនក្រោយ ។ ដើបស្រួលបួលហើយ កូនស្រីទ្រនូវវត្ថុសេរីសួស្តី ។ គេចាប់ហុចកន្ទុយស្បៃ កូនស្រីឱ្យកូនប្រុស កាន់តោងដើរតាមក្រោយ ។ ដល់ក្នុងបន្ទប់ ហើយមេបាស្រីៗមានវៃឆ្លាត ចូលទៅណែនាំកូនស្រី អំពីការរៀបចំបំរើប្តី មានការដោះសំលៀកបំពាក់ជាដើម ។ រួចមេបាឱ្យរៀបចំពិធីរាំលុបជើងពីរ ។

**១១. ពិធីរាំលុបជើងពីរ :**

កូនស្រីចូលបន្ទប់ផុតហើយ មេបាឱ្យអ្នកភ្លេងលេងបទរាំលុបជើងពីរ បំ



www.elibraryofcambodia.org

បាត់ចង្រៃ ។ អ្នកភ្លេងលេង អ្នកច្រៀងអង្គុយចោងហោងស្រែកច្រៀង យកដៃវាសលុបស្លាមជើង ខិតថយក្រោយដូចជាលុបស្នាម ជើងមនុស្សម្នែ១ ។ រួចមេបាឱ្យរាំសាកខ្នែល ។

**១២. ពិធីរាំសាកខ្នែល :**

មេបាឱ្យអ្នកភ្លេងមូរកន្ទេល ។ ភ្លេងលេងបទស្មោង ឬ អុំទូក ។ អ្នកច្រៀងសរសើរគុណសម្បត្តិកន្ទេល ។ បើអ្នកមានវាសនាល្អ បានដេក និង កើតមាសដូចគេចាក់ កើតប្រាក់ដូចគេគរ រួចយកដៃចាប់កន្ទេលមូរសន្សឹម១ រហូតបានសំរេច យកកន្ទេលមកលីលើស្មា ។

**១៣. ពិធីលក់កន្ទេល :**

អ្នកភ្លេងពីរនាក់ ដើរប្រទក្សិណ កន្លែងសំពះផ្ទឹម រួចច្រៀង ពោលសរសើរគុណសម្បត្តិ កន្ទេលដែលខ្លួនលីថា : បើលោកអ្នកណាបានសម្រានលើកន្ទេលនេះ នឹង ឡើងបុណ្យ និង មានទ្រព្យសម្បត្តិច្រើន ។ សាមីខ្លួនទាំងពីរនាក់ ស្លៀកពាក់ស្អាតបាតមកអង្គុយក្បែរ រង់ចាំទិញកន្ទេលនេះ តាមការពេញចិត្ត ។ (គេចូលក្នុងផ្លាស់សំលៀកបំពាក់ផ្ទឹមចេញ រួចស្លៀកពាក់ធម្មតាតែស្អាត)

**១៤. ពិធីសំពះផ្ទឹមខាងប្រុស :**

ចប់ពិធីនេះលើផ្ទះកូនស្រីហើយ មេបាចាស់ទុំទាំងអស់ នាំកូនប្រុសស្រីទៅសំពះផ្ទឹម គោរពជីដូនជីតាខាងប្រុស នៅរោងខាងប្រុសម្តងទៀត ។ ខ្លះថាសំពះផ្ទឹមសង្កត់រោង ។

**១៤. ពិធីផ្សំដំណេក :**

ម៉ោង៨-៩ យប់ពិធីផ្សំដំណេក កន្លែងកូនស្រីដេក ។ គេរើសរកនារីពីរ



www.elibraryofcambodia.org

នាក់ដែលមានខាន់ស្លាមិនអភព្វ៍ មានអាយុច្រើន និង ត្រូវជាញាតិខាងស្រី ជាអ្នកចេះដឹងពីពិធីផ្សំដំណេកច្បាស់លាស់ ។

គេរៀបចំបាយសីមួយគូ ចំអាបមួយថាស បង្អែមមួយថាស និង ដូងខ្ចីមួយសែនជូនតា ។

គេជូសទឹកដូងបញ្ចុកកូនប្រុស ពាស្លាបព្រា រួចបង្គាប់ឱ្យកូនស្រីយកចេកពេលាដែលអាចារ្យប្រគល់ឱ្យ បញ្ចុកកូនប្រុស រួចឱ្យកូនប្រុសយកចេកបញ្ចុកកូនស្រីវិញ ជានិមិត្តរូបនៃការស្រឡាញ់គ្នា ។

នារីពីរនាក់ផ្តែផ្តាំ ប្រដៅតាមប្រពៃណី ផ្តាំឱ្យកូនប្រុសដេកខាងស្តាំ កូនស្រីដេកខាងឆ្វេង ។ ផ្តាំចប់នារីពីរនាក់ចេញក្រៅ ទុកឱ្យតែគូថ្មីពីរនាក់ នៅក្នុងបន្ទប់ ។



www.elibraryofcambodia.org

## របៀបរកថ្ងៃ ពិលា

*ឧទាហរណ៍ :* ម្នាក់ឈ្មោះ សុខ កើតថ្ងៃ អាទិត្យ ឆ្នាំ រក ស្រីម្នាក់កើតថ្ងៃ ចន្ទ ឆ្នាំខាល ។ យើងពិនិត្យឃើញទៅឈ្មោះ សុខ ឆ្នាំ វក អន្សា ចន្ទ ខាល អន្សា អង្គារ ។

*ពេសរសេរ*

| | | | | | | |
|---|---|---|---|---|---|---|
| ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
| ២ | ៣ | ៤ | ៥ | ៦ | ៧ | ១ |
| ជយោ | សុខា | អន្តរាយោ | លាភី | សិទ្ធី | កម្មំ | មរណំ |
| អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ | ចន្ទ |
| ៣ | ៤ | ៥ | ៦ | ៧ | ១ | ២ |
| ជយោ | សុខា | អន្តរាយោ | លាភី | សិទ្ធី | កម្មំ | មរណំ |

មនុស្សឈ្មោះ សុខ ប្រុស ឆ្នាំ វក អន្សា ចន្ទ យើងរាប់អាទិត្យទី១ ចន្ទទី ២ ............. សៅរ៍ទី ៧ ដូច្នេះឆ្នាំវក អន្សាចន្ទ ថ្ងៃ ចន្ទទី ២ យើងដាក់ត្រង់ជយោ ថ្ងៃចន្ទក៏បាន ដាក់លេខ២ក៏បាន ។

ដល់មកមនុស្សស្រី ខាល អន្សា អង្គារ ។ អង្គារលេខ ៣ យើងមើលតើពីរនាក់នេះ អាចបានពិលាសំពះថ្ងៃណា ? ព្រោះបុរាណលោកយកល្អតែ ៣ទេ គឺ សុខោ លាភី សិទ្ធី ។ យើងមើលពីរនាក់នេះ មានថ្ងៃសុក្រមួយខាងប្រុសសិទ្ធីខាងស្រី លាភី ក្រៅពីនេះបានម្ខាងល្អ ម្ខាងអាក្រក់ ។

ឧទាហរណ៍ : ព្រហស្បតិ៍ ប្រុស លាភី ល្អ តែស្រី ព្រហស្បតិ៍ ត្រូវអន្តរាយ អាក្រក់ ។ ម្ល៉ោះហើយមង្គលគូនេះ ត្រូវថ្ងៃសុក្រ ព្រោះម្ខាងសិទ្ធី



www.elibraryofcambodia.org

ម្យ៉ាងទៀត លោកី ។ កូនេនះបានពេលាសំពះថ្ងៃសុក្រល្អ ។ អាចារ្យត្រូវមើល ថ្ងៃសុក្រក្នុងខែណាមួយ តើថ្ងៃសុក្រនោះ ប៉ះខ្នើតឬរនោច ហើយចាំថ្ងៃដែល បុរាណបានកំណត់ គឺខាងខ្នើតបាន ៣ថ្ងៃ , ថ្ងៃ៧ , ថ្ងៃ១០ , ថ្ងៃ១៣ ។ ឯ រនោចបាន ៤ថ្ងៃ គឺថ្ងៃ ៤ , ថ្ងៃ១០ , ថ្ងៃ១១ , ថ្ងៃ១៤ ។ តែបើចាំបាច់ណាស់ បុរាណលោកបានអនុញ្ញាត ថានឹងធ្វើទៅបាន ខាងខ្នើតឱ្យជៀសវាងថ្ងៃ២ ,៣ ១២ , ១៤ ។ ឯរនោចឱ្យជៀសវាងថ្ងៃ២ , ៣ , ៥ , ៨ , ១២ ។ ម្យ៉ាងទៀត ចំពោះថ្ងៃ ៨រោច បើត្រូវពេលារបស់អ្នកណាមួយគឺអាចធ្វើបានពិធីបើករកស៊ីដំបូង ជាការល្អប្រសើរ ។

*បញ្ជាក់ :* គួខាងលើនេះបានពេលាថ្ងៃសុក្រ តែក្នុងក្បួនបុរាណ ថ្ងៃដែលត្រូវហាម ថ្ងៃសុក្រហាមផ្សំដំណេក ត្រង់ចំណុចនេះ អាចមានអាចារ្យឬសាមីខ្លួនខ្លះ សួរថា បើពេលាថ្ងៃសុក្រត្រូវតែផ្សំដំណេកថ្ងៃសុក្រ តែក្នុងក្បួនហាមថ្ងៃសុក្រផ្សំដំណេកមិនបាន ឱ្យពន្យាទៅថ្ងៃផ្សេង ។ យើងខ្ញុំពុំហ៊ានអះអាងទេ ព្រោះបុរាណ លោកកំណត់ដូច្នេះ ចំណេះរបស់យើងខ្ញុំ មិនអាចដឹងអំពីឫក្សផ្កាយទាំងឡាយ មានផ្កាយព្រះសុក្រជាដើម តើមានឥទ្ធិពលយ៉ាងណាចំពោះការផ្សំដំណេកជាដំបូងរបស់គូស្វាមីភរិយាថ្មីក្នុងថ្ងៃសុក្រនោះឡើយ ។ ប៉ុន្តែក្នុងការហាម គឺហាមតែថ្ងៃសុក្រដំបូងទេ ឯថ្ងៃសុក្រដទៃទៀតជាធម្មតា ។

## ថ្ងៃត្រូវគ្នា និង មិនត្រូវគ្នា

| | | | |
|---|---|---|---|
| អាទិត្យ | + | អាទិត្យ | ក្តៅក្រហាយ |
| ចន្ទ | + | ចន្ទ | ល្អទ្រព្យច្រើន |
| អង្គារ | + | អង្គារ | ប្រពន្ធឆាប់ងាប់ចោលប្តី |



www.elibraryofcambodia.org

| | | | |
|---|---|---|---|
| ពុធ | + | ពុធ | ក្តៅដូចភ្លើង |
| ព្រហស្បតិ៍ | + | ព្រហស្បតិ៍ | អាចចិញ្ចឹមជីវិតបាន |
| សុក្រ | + | សុក្រ | ត្រជាក់ត្រជុំ |
| សៅរ៍ | + | សៅរ៍ | រកស៊ីមានបាន |

ដូចនេះបុរាណហាមកុំឱ្យប្រុសស្រីយកជាប្តីប្រពន្ធ ចំពោះអ្នកកើតថ្ងៃ អាទិត្យ + អាទិត្យ , អង្គារ + អង្គារ , ពុធ + ពុធ ។

## ពិធីមើលទិស ដីកចង្ក្រានមង្គលការ

របៀបមើលទិសធ្វើចង្ក្រាននេះ បុរាណលោកកំណត់យកទិសដៅ "កណ្តាល" គឺលំនៅរបស់យើង ។ ឯជុំវិញទាំង ៨ទិស ចូរមើលតាមអក្សរ បើសរសេរថា "បាន" នោះទើបជាទីដាក់ចង្ក្រាន ។ ឯពិធីដាក់គិតតាមថ្ងៃ ដែលយើងផ្តើម ដាំស្លតែម្តង ។ ឧទាហរណ៍ : យើងបានពេលាមង្គលការ គឺ ហូបថ្ងៃអាទិត្យ សំពះថ្ងៃចន្ទ ដូច្នេះថ្ងៃអាទិត្យដាំស្ល ចូរបើលថ្ងៃអាទិត្យពើ ដាក់ទិសណោបានខ្លះ ? ។

## តទៅនេះ ចូរមើលរូបគំនូរដូចខាងក្រោម



www.elibraryofcambodia.org

ខាងកើត

អាទិត្យ

ខាងជើង

ខាងត្បូង

| | | |
|---|---|---|
| បាន | បូពិទេព្តា ត្បូងនាគ | បាន |
| អារក្សធំ ដង្ហើមធំ | ១ | ដង្ហើម ស្លាប់ |
| អត្តេយ៍ កំសួលនាគ | ម្រឹត្យូវ | បាន |

ចន្ទ

| | | |
|---|---|---|
| ដង្ហើម ស្លាប់ | បូពិ-អត្តេយ៍ ត្បូងនាគ | ត្បូងនាគ |
| បាន | ២ | បាន |
| បាន | ទេព្តា | អារក្សធំ ដង្ហើមរស់ |

អង្គារ

| | | |
|---|---|---|
| ទេព្តាដង្ហើម រស់អារក្សធំ | បាន | បាន |
| បាន | ៣ | ត្បូងនាគ |
| បាន | បាន | អត្តេយ៍ចាក់ ដង្ហើមរស់ |

ខាងលិច



www.elibraryofcambodia.org

ខាងកើត

ពុធ

| | | |
|---|---|---|
| ដង្ហើមរស់ | បូព៌ អារក្សធំ | បាន |
| ម្រឹត្យូវ អគ្គេយ៍ចាក់ | ៤ | ទេព្តា |
| បាន | បាន | ដង្ហើម ស្លាប់ |

ព្រហស្បតិ៍

| | | |
|---|---|---|
| បាន | ដង្ហើមរស់ | អារក្សធំ |
| ទេព្តា | ៥ | ម្រឹត្យូវ.អគ្គេយ៍ ចាក់.កំសូលនាគ |
| បាន | ដង្ហើមស្លាប់ ត្បូងនាគ | បាន |

ខាងជើង

ខាងត្បូង

សុក្រ

| | | |
|---|---|---|
| បាន | បូព | ទេព្តា ដង្ហើមរស់ |
| បាន | ៦ | អារក្សធំ |
| ម្រឹត្យូវ.ដង្ហើម ស្លាប់.ត្បូងនាគ | អាគ្គេយ៍ កំសូលចាក់ | បាន |

សៅរ៍

| | | |
|---|---|---|
| ម្រឹត្យូវ | បូព | អាគ្គេយ៍ ចាក់ |
| ដង្ហើមស្លាប់ ត្បូងនាគ | ៧ | ដង្ហើមស្លាប់ |
| បាន | អារក្សធំ | ទេព្តា |

ខាងលិច



www.elibraryofcambodia.org

## វិធីមើលធ្វើរោងផ្កាស្លា និងពិធីខ្លះៗ

អាចារ្យមុននឹងឱ្យគេធ្វើរោង ត្រូវមើលក្បាលនាគ កន្ទុយនាគតាមខែ ។ ក្នុងមួយឆ្នាំមាន ១២ខែ ចែកជា ៤ក្រុម ។ ក្រុមនិមួយៗមាន ៣ខែ។

- មិគសិរ បុស្ស មាឃ ក្បាលនាគនៅទិសខាងលិច ធ្វើរោងទិសទក្សិណ អាចទិសបស្ចឹមបានខ្លះ ។

- ផល្គុណចេត្រ ពិសាខ ក្បាលនាគនៅទិសខាងលិច ធ្វើនៅទិសខាងលិច និងទិសឧត្តរ ។

- ជេស្ឋ អាសាធ ស្រាពណ៍ ក្បាលនាគនៅទិសខាងជើង ធ្វើនៅទិសឥសាន្ត ។

- ភទ្របទ អស្សុជ កត្តិក ក្បាលនាគនៅទិសខាងកើត ធ្វើនៅទិសខាងកើត ។ ( ចំពោះខែមាឃ ( ធំ ) មង្គលជៀសថ្ងៃសុក្រ )

បើយកតាមវិធីពិតប្រាកដនៃបុរាណចំៗ ក្នុង ១២ខែ យើងដេញបានតែ ៦ ខែទេ ព្រោះ ៦ខែ ទៀតមានតែ ២៩ ថ្ងៃ ហៅគោរបី បុរាណមិនដេញពេលាទេ លោកថា ខែមិនពេញ ។ បុរាណថា : ពេលរួមខ្នើយល្អខែណាមាន ៣០ថ្ងៃ ( ផល្គុណ ពិសាខ អាសាធ ភទ្របទ កត្តិក បុស្ស ) ។

### ថ្ងៃសំរាប់រួមខ្នើយ គឺថ្ងៃសំពះផ្ទឹម

ផ្នែកខ្នើត ៧កើត ១០កើត ១៣កើត

ផ្នែករនោច ៤រោជ ១០រោជ ១១រោជ ១៤រោជ ។



www.elibraryofcambodia.org

# វេលាសំពះពិលា

អាទិត្យ ម៉ោង ១ . ៣ . ៨ . ១០

ចន្ទ័ ម៉ោង ២ . ៤ . ៧ . ៩ . ១១

អង្គារ ម៉ោង ១ . ៣ ៥ . ៨ . ១០ . ១២

ពុធ ម៉ោង ២ . ៤ . ៦ . ៩ . ១១

ព្រហស្បត៍ ម៉ោង ៣ . ៥ . ៧ . ១០ . ១២

សុក្រ ម៉ោង ១ - ៤ - ៦ - ៨ - ១១

សៅរ៍ ម៉ោង ២ . ៤ . ៧ . ៩ . ១២

ចំពោះម៉ោងពេលមានមែនពិត តែត្រូវមើលតាមឫក្សពេលរបស់ថ្ងៃទៀតទើបបាន ។ ព្រោះក្នុងថ្ងៃនិមួយៗ មាន ៥ពេល គឺព្រឹក ពេញពន្លឺ ត្រង់ រសៀល ល្ងាច ។ ឯលេខមាន ៤ កាកបាទ . ០ . ២ . ១ . ៤ ។ ឯលេខដែលធ្វើបានល្អ គឺលេខ ៤ លេខ ២ និងលេខសូន្យ ព្រោះបុរាណថាផ្លូតអាចមិនល្អ មិនអាក្រក់ ។ ហាមលេខ ១ និង កាកបាទ ។

## សូមមើលគំរូតារាងខាងក្រោម

| | ព្រឹក | ពេញពន្លឺ | ថ្ងៃត្រង់ | រសៀល | ល្ងាច |
|---|---|---|---|---|---|
| អាទិត្យ | ៤ | X | ០ | ២ | ១ |
| ចន្ទ័ | ១ | ៤ | X | ០ | ២ |
| អង្គារ | ០ | ១ | ៤ | X | ០ |
| ពុធ | ០ | ២ | ១ | ៤ | ០ |
| ព្រហស្បត៍ | X | ០ | ២ | ១ | ៤ |
| សុក្រ | ៤ | X | ០ | ២ | ១ |
| សៅរ៍ | ១ | ៤ | X | ០ | ២ |



www.elibraryofcambodia.org

លេខ ១ ព្រួយអាត្មា កុំយាត្រានាំបរាជ័យ

លេខ ២ មានសួស្តី គួរគប្បីយាត្រាចុះ

លេខ ៤ ជូនលាភជោគ កើតទ្រព្យភោគឥតមានទោស

កាកបាទអប្រិយយស កុំគប្បីចរលីលា

ផ្លូតសូត្រឥតលាភី ឥតទុក្ខាគ្មានវិបត្តិ ។

## ថ្ងៃអន្សា

| | | | | |
|---|---|---|---|---|
| ជូត | + | មមែ | អន្សា | អាទិត្យ |
| រកា | + | ឆ្លូវ | អន្សា | ចន្ទ |
| ខាល | + | រកា | អន្សា | អង្គារ |
| ថោះ | + | ច | អន្សា | ពុធ |
| រោង | + | កុរ | អន្សា | ព្រហស្បតិ៍ |
| ម្សាញ់ | + | | អន្សា | សុក្រ |
| មមី | + | | អន្សា | សៅរ៍ |



www.elibraryofcambodia.org

## បំរាមបុរាណ

អាទិត្យ ចុះក្តៅ ហាមកប់ខ្មោចថ្ងៃអាទិត្យ

ចន្ទ ចុះផ្លូវ ហាមលើកផ្លូវថ្ងៃចន្ទ

អង្គារ ចុះភ្លើង ហាមដុតខ្មោចថ្ងៃអង្គារ

ពុធ ចុះភូមិ ហាមលើកភូមិធ្វើលំនៅឋានថ្ងៃពុធ

ព្រហស្បតិ៍ ចុះព្រៃភ្នំ ហាមកាប់ឈើ ឬ ទិញឈើព្រៃធ្វើផ្ទះ ថ្ងៃព្រហស្បតិ៍

សុក្រ ចុះដំណេក ហាមផ្សំដំណេកថ្ងៃសុក្រ

សៅរ៍ ចុះទឹក ហាមចុះរកស៊ីតាមផ្លូវទឹកថ្ងៃសៅរ៍

*សម្គាល់* : ហាមនេះ គឺបើចង់លើកផ្លូវ ឬ ទិញឈើ ឬ ផ្សំដំណេកជាដើម មិនមែនហាមដាច់ខាត ក្នុងថ្ងៃនេះទេ គឺថ្ងៃចាប់ផ្តើមដំបូង កុំឱ្យចំថ្ងៃនេះ ក្រោយៗមកទៀតចំថ្ងៃនេះ ក៏មិនអីដែរ ។



www.elibraryofcambodia.org

## ធាតុ + ពង្ស

| | | | |
|---|---|---|---|
| ជូត | ធាតុ ទឹក | សត្វកណ្ដុរ | ពង្សទេវតាស្រី (ក) |
| ឆ្លូវ | ធាតុ ដី | សត្វគោ | ពង្សមនុស្សប្រុស |
| ខាល | ធាតុ ឈើ | សត្វខ្លា | ពង្សយក្សប្រុស (ខ) |
| ថោះ | ធាតុ ឈើ | សត្វទន្សាយ | ពង្សមនុស្សស្រី |
| រោង | ធាតុ ដី (ក) | សត្វពស់នាគរាជ | ពង្សទេវតាស្រី (ក) |
| ម្សាញ់ | ធាតុ ភ្លើង | សត្វពស់ | ពង្សមនុស្សស្រី (ក) |
| មមី | ធាតុ ភ្លើង | សត្វសេះ | ពង្សទេវតាប្រុស (ខ) |
| មមែ | ធាតុ ដី (ក) | សត្វពពែ | ពង្សទេវតាប្រុស (ខ) |
| វក | ធាតុ ដែក | សត្វស្វា | ពង្សយក្សប្រុស |
| រកា | ធាតុ ដែក | សត្វមាន់ | ពង្សយក្សស្រី (ក) |
| ច | ធាតុ ថ្ម (ខ) | សត្វឆ្កែ | ពង្សយក្សស្រី |
| កុរ | ធាតុភ្លើង | សត្វជ្រូក | ពង្សមនុស្សប្រុស |

**( ពាក្យខុសពិភេទហោរាច្បាប់ដើម )**

(ក) ច្បាប់ខ្លះថាប្រុស ។ (ខ) ច្បាប់ខ្លះថាស្រី

(ក) ច្បាប់ខ្លះថាធាតុមាស ។ (ខ) ច្បាប់ខ្លះថាធាតុដី



www.elibraryofcambodia.org

# ពិធីរៀបចំសព

នេះជារបៀបមួយតាមរបៀបបុរាណសុទ្ធសាធ ដែលខ្ញុំបានដកស្រង់ចេញពីសាស្ត្រាស្លឹករិត ដែលមានសេសសល់មួយក្បាល យកមកពីវត្តបារាយខាងកើតឃុំបារាយ ស្រុកកំពង់លាវ ខេត្តព្រៃវែង និងកែសម្រួលពាក្យពេចន៍ខ្លះៗ ។ ធម្មតាអ្នកជំងឺ ដែលមិនអាចព្យាបាលតទៅទៀត នោះច្បាស់ជាស្លាប់ពុំខានឡើយ គេក៏រកអាចារ្យអ្នកចេះដឹង មកស្ថិតស្ថេរជាមួយអ្នកជំងឺ ដើម្បីណែនាំគ្រប់វិធីផ្សេងៗ តាមទម្លាប់មូលដ្ឋាននោះៗ ពិតជារបៀបរបស់បុរាណខ្មែរ ។ អាចារ្យដឹងថា មនុស្សឈឺធ្ងន់ពិតជាស្លាប់ គាត់ត្រូវរកក្រណាត់សប៉ុន១បាតដៃ ឬ ធំជាងបន្តិចមកសរសេរបាលី ដូចតទៅនេះ ៈ

- **ចក្ខុសង្ខស្សថា១ សោតសង្ខស្សថា១ ឃានសង្ខស្សថា១ ជិវ្ហាសង្ខស្សថា១ កាយសង្ខស្សថា១ មនោសង្ខស្សថា១** ដាក់ក្រណាត់មួយផ្ទាំងតូចនោះសរុបប្រាំមួយផ្ទាំង រួចហើយត្រូវដាក់នៅក្បាលដំណេកអ្នកជម្ងឺ ទុកត្រៀមដល់កម្លាំងខ្សោយខ្លាំងទើបយកចេញ ។

- ឱ្យរៀបចំ ទៀនធូប ស្លាត្រូយមកដាក់ទុកបង្កាសម្រាប់ពេលស្លាប់ ដាក់ឱ្យអោបប្រណម្យ ។ អាចារ្យត្រៀមក្រណាត់សប្រាំហត្ថ ឬលើសក៏បានមកចងជាទង់ព្រលឹងឱ្យហើយស្រេច ។ ពេលចងទង់ព្រលឹង សូត្របាលីថា **ឥមំ ធជបដាកំ តាវតឹស ភវនេ ចេតិយស្ស ឧយ្យោរជេមិ ឥមិនា និស្សន្ទេន ៗ** សរសេរស្រេចហើយត្រូវដាក់ជាមួយនឹង ព្រះពុទ្ធរូបមានខ្សែតពីទង់នោះមកជាប់ជាមួយស្លាត្រូយ ដែលយើងត្រៀមឱ្យអ្នកជម្ងឺប្រណម្យនោះមិនឆ្ងាយមិនជិតល្មមអ្នកជម្ងឺមើលច្បាស់ ។ បន្ទាប់មកអាចារ្យក៏



www.elibraryofcambodia.org

ហៅកូនចៅ ញាតិផៅសន្តានរបស់អ្នកជម្ងឺមកជួបជុំដើម្បីឱ្យសុំស្មាលាទោសនឹងអ្នកជម្ងឺសុំអភ័យទោសផ្សេងៗ និយាយតែពាក្យល្អៗដល់អ្នកជម្ងឺ នេះជាវិធីដែលអ្នករាល់គ្នាជួយជូនកុសលផលបុណ្យដែលខ្លួនបានធ្វើទាំងប៉ុន្មានទៅឱ្យអ្នកជម្ងឺ រួចមកឱ្យអាចារ្យទូន្មាន ប្រៀនប្រដៅថា : ហៃអ្នកមានវាសនាទាំងឡាយចូរអ្នកតាំងចិត្តឱ្យស្អាតបរិសុទ្ធ កុំឱ្យអ្នកមានចិត្តខឹងសម្បារអ្វី ឬ គុំគួនចងពៀរវេរា នឹងអ្នកដទៃណាមួយឡើយ ។ អ្នកអើយ រូបយើងគេទាំងអស់គ្នាសព្វថ្ងៃសឹងប្រកបដោយសេចក្តីស្លាប់ មកគ្របដណ្តប់ជាប៉វិលវល់ក្នុងវដ្តសង្សារ កើតស្លាប់ៗកើត មានតែយើងទាំងអស់គ្នា តាំងចិត្តយកព្រះនិព្វានជាអារម្មណ៍ទេ ទើបយើងបញ្ចប់ការវិលវល់កើតស្លាប់យ៉ាងនេះ ។ រីឯរូបអ្នកត្រូវតាំងចិត្តរឹងប៉ឹងមានតែព្រះពុទ្ធព្រះធម៌ព្រះសង្ឃទេទើបជាទីពឹងដ៏ឧត្តម ។ អ្នកកុំគិតមមៃស្រមៃមកប្រពន្ធកូនទ្រព្យសម្បត្តិអ្វីឡើយ មានតែតាំងចិត្តថ្វាយបង្គំព្រះពុទ្ធព្រះធម៌ព្រះសង្ឃនិងនឹកគុណមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ។ មិនតែប៉ុណ្ណោះអ្នកមានគុណក្តីក៏សូមស្មាលាទោសទាំងអស់ កុំឱ្យមានពៀរវេរាកម្មតទៅមុខទៀត ។ អាចារ្យប្រាប់អ្នកជម្ងឺទៀតថា : ទៀន ធូប ស្លាធ្មេញ ទាំងនេះយើងរៀបចំជូនដំណើរឱ្យអ្នក ពេលរំលាយបញ្ចុះខន្ធទៅហើយ 'ចូរអ្នកយកទៅថ្វាយបង្គំព្រះចូឡាមណីចេតិយ នៅស្ថានត្រៃត្រឹង្សពិភព ឯសំពត់យើងចងជាទង់ព្រលឹងនេះ ជូនឱ្យអ្នកយកទៅថ្វាយបង្គំព្រះចូឡាមណីចេតិយផង ។ ម្យ៉ាងក្រែងអ្នកមានវេរាកម្មឯណាមួយហើយកម្មនោះមករារាំង ឃាំងឃាត់ទារបំណុល ធ្វើឱ្យអ្នកវង្វេង គឺមានទង់នេះជួយដល់អ្នកមានកម្មអាក្រក់នេះ មិនឱ្យមកជិតដល់អ្នកទេ ។ ហើយអ្នកចូរភាវនាជាប់ជានិច្ចថា : **ពុទ្ធោអរហាំ** ដៃ



www.elibraryofcambodia.org

ស្លាំក្លាប់ទង់ព្រលឹង ដៃឆ្វេងកាន់យកទៀន ធូប ស្លាត្រួយ តាំងចិត្តចំពោះព្រះចូឡាមណីចេតិយនៅឋានត្រៃត្រឹង្សពិភព ។ ពេលទៅដល់ហើយអ្នកត្រូវដំឡើងទង់នេះលើកឡើងថ្វាយព្រះចេតិយ ។ រួចស្រេចហើយអ្នកឡើងទៅឈប់នៅស្ថាន តុសិតពិភព ជាទីសំណាក់អាស្រ័យនៃអ្នកប្រាជ្ញទាំងឡាយមានព្រះពោធិសត្វជាដើម ។ល។ ផ្តាំស្រេចហើយអាចារ្យយកក្រណាត់ដែលបានចារពីមុនទុកលើក្បាលជំណោកនោះ មកគ្របទ្វារទាំងប្រាំមួយគឺ ចក្ខុសម្ផស្សជា ដាក់នៅថ្ងាស. សោតសម្ផស្សជា ដាក់សឹកក្រោមក្បាល. ឃានសម្ផស្សជា ដាក់គ្របបបូរមាត់ខាងលើ. ជិវ្ហាសម្ផស្សជា ដាក់នៅចង្កាខាងក្រោម. កាយសម្ផស្សជា ដាក់នៅដៃប្រណម្យ. មនោសម្ផស្សជា ដាក់នៅទ្រូង ។

អាចារ្យត្រូវពិនិត្យបើដង្ហើមខ្យល់ព្រះអភិធម្មដង្ហក់ញាប់ឡើង១ ត្រូវអុជទៀន ធូប ថ្វាយបង្គំព្រះ រួចហើយអាចារ្យតាំងភាវនា នវហារាទិគុណនិងវត្តគុណ គឺសូត្រ **អត្ថិឥមស្មឹចិតន្ត** និងសូត្រព្រះពុទ្ធគុណ សារចុះឡើងតែឱស្សាហ៍ផ្ទៃត្រចៀកអ្នកជម្ងឺឱ្យរឿយ១ ។ បន្ទាប់មកសូត្រជាប់រហូតដូចជាកៅវិជា ធម៌ផ្សេង១ទៀតតាមដោយប្រាជ្ញាខ្លួនចេះចាំស្ទាត់ ។ ពេលនេះអ្នកខ្លះស្ទាត់កម្មដ្ឋានក៏ឱ្យអង្គុយកម្មដ្ឋាន បញ្ជូនកុសលឱ្យបុគ្គលនោះទៅ ។ ក្រៅពីនេះមានប៉ុន្មាននាក់ឱ្យស្រែកឡើងទាំងអស់គ្នាថា : **ពុទ្ធោរអរហំ** ឱ្យព្រម១គ្នាធ្វើយ៉ាងណាកុំឱ្យឮសព្ទសំលេង មាន់ ទា ឆ្កែ ឆ្មា ឬសំលេងទួញយំសោកសៅឡើយ ឱ្យឮតែស័ព្ទព្រះធម៌ដ៏វិសេស ។

លុះដល់ខ្យល់ព្រះអភិធម្មមកដល់ដើមក ( ដកចង្កាមាន់ ) ឱ្យអុជទៀន កាល្បមួយ ។ ទៀនយើងយកប្រវែងចង្អុលដៃមកក្រិតជា ៣ អន្ទើ ( ធ្វើរបៀប


www.elibraryofcambodia.org

យេះចាស់ៗគេរំដឹងថាតើមនុស្សធ្វើកុកួររស់រុំនាទក្រិតនេះ ) ពេលបុគ្គលនោះផុត
រលត់ហើយ ឱ្យគ្របមុខទុកកុំអាលប៉ះពាល់ខ្លួនឡើយ លុះដល់គិរិតមួយឱ្យយក
ក្រណាត់សរសេរអក្សរ ដែលយើងដាក់នោះចេញពីកន្លែងផ្សេងៗមានថ្វាសឬ
ចង្កាជាដើម ។ ឱ្យនិមន្តព្រះសង្ឃ៤អង្គឬ២អង្គតាមលទ្ធភាព បើគ្មានព្រះសង្ឃ
អាចារ្យក៏បាន រួមនិងអ្នកឯទៀតដែលចេះធម៌ឱ្យពរទឹកនោះ សូត្រ **ភវតុ...**
បីចប់ ។ រួចអាចារ្យឬក៏ឱ្យកូនចៅបិទមាត់ត្រឡប់ភ្នែក បន្ទាប់មកលើកឡើង
ចំអាស់ទឹកឱ្យជ្រះស្អាត ដោយយកទឹកសំបួរ ទឹកម្ទូរ ស្រោចជាក្រោយ ។
រួចមកយកក្រាស់ធ្វើពីឫស្សីសិតសក់ទៅក្រោយបីដង រួចចោលក្រាស់នោះចេញ
ទៅ ( ចាស់ៗថាដើម្បីកើតធម្មសង្វេគរាល់ៗគ្នា ) ថាគេត្រឡប់ទៅវិញហើយ
យើងទាំងអស់គ្នាតែងតែទៅទាំងអស់គ្នាជាមិនខាន ។ ស្រេចកាលណាហើយ
យកប្រេង ម្សៅ គ្រឿងក្រអូបលាបអស់ទាំងខ្លួន ។ បន្ទាប់មកហែកក្រណាត់
ស៤ហត្ថស្លៀកដណ្តប់ផ្ទក់ទៅមុខ ៤ហត្ថទៀត ស្លៀកផ្ទក់ទៅក្រោយយក៤ហត្ថ
ទៀតពានាឆៀងស្មា យកកន្សែង ១ចំអាមគ្របមុខ យកក្រណាត់ស ១២ហត្ថ
ក្រាលជាសំពត់ស្នប់ ដោយ ដាក់រុំអំបោះជាខ្សែបាស ខាងក្រោមខណ្ឌនៅ ក ១
ដើមទ្រូង ១ ចង្កេះ ១ ជើង១ ។ រួចមកលើកបុគ្គលដាក់លើស្នប់ លើកដៃឱ្យបង្គំ
ប្រណម្យកាន់ស្លាត្រួយ ទៀន ធូប និងយកប្រាក់សាច់ឬមាសតាមលទ្ធ ភាពបង់
ក្នុងមាត់គ្របរុំឱ្យណែនដោយយកម្ជុលមកខ្ទាស់ក៏បាន ទើបចងខ្សែបាសសំឡាប់
មុខទាញប្រទាក់ គ្នាពីលើមកក្រោមទៀត ។ ពេលចងខ្សែបាសអាចារ្យសូត្រថា
**សព្វេពុទ្ធា ពលប្បត្តា ...... ៕**

បន្ទាប់មកអ្នកម្ចាស់ផ្ទះត្រូវសំពះរកអាចារ្យយោគី និងយោគី ( ភ្លក )



www.elibraryofcambodia.org

រកអ្នកហោចេះដឹងការរាក់ជ្រៅទោះចាស់ក្ដីក្មេងក្ដីតាមតែបាន ។ បន្ទាប់មករៀបគ្រឿងប្រឡងមួយចំណែក គ្រឿងបញ្ចុះកំពង់ ( អាហារចំណី ) មួយចំណែក ។ គ្រឿងប្រឡងបានទៅព្រះសង្ឃ ។ គ្រឿងបញ្ចុះកំពង់បានទៅយោគី ។ ឯប្រដាប់ទាំងនោះអាស្រ័យធនធាននៃគ្រួសារមាន ក្រ ។ ឯទង់បង្ហូតអាស្រ័យមូលដ្ឋាន មួយក្ដី ពីរក្ដី តាមលទ្ធភាព ។

បន្ទាប់មកកូនចៅកោរសក់ស្លៀក ស កាន់ទុក្ខ និមន្តព្រះសង្ឃ ៤ ឬ ៨ អង្គ សូត្រធម៌អនិច្ចា មាតិកា កុសលា អភិធម្ម បង្សុកូល ។ រួចហើយឱ្យលើកបុគ្គលដាក់ក្ដារមឈូស ។ ឯអាចារ្យយោគីសមាទានសីល ៨ ឱ្យជាប់ ។ រួចហើយអុជទៀនត្បូង ។ ប្រដាប់រៀបទៀនត្បូងមាន ៖ ស្រូវមួយកញ្ជើ ប្រាក់តាមលទ្ធភាព សំពត់ ៥ ហត្ថ ចេកទុំមួយស្និត កាំបិតស្លាមួយ ចង្កៀងប្រេងមួយ ក្អមទឹកមួយដាក់លើស្រូវក្នុងកញ្ជើ ។ អាចារ្យយោគីអុជប្រទីបនោះឡើងសន្មតថា ជាទៀនត្បូង ។ ពេលអុជប្រទីបសូត្រថា ៖ **ឥមំ ទីបបទីបំ ឧយ្យោជេមិ** ៣ ចំពោះទៀនត្បូងនោះ អាចជាចន្លុះខ្លាញ់ក៏បាន ( ពីដើមអុជចន្លុះរកមនុស្សម្នាក់មកអង្គុយចាំកៀសចន្លុះ ទោះប្រុស ស្រី ក្មេង ចាស់ក៏បាន ) អាចារ្យផ្ដាំអ្នកកៀសទៀននោះ ។ ឯវត្ថុទាំងនោះត្រូវបានអ្នកអង្គុយចាំកៀសនោះ បន្ទាប់មកនិមន្តព្រះសង្ឃឬគ្រហស្ថសូត្រធម៌កំដរចាំបុគ្គលនោះ ។ អាចារ្យយោគីត្រូវឧទ្ទិសផលកុសលដល់សព អ្នករក្សាសីល ៨ក្ដី អ្នកចាំរក្សាទៀនត្បូងក្ដី អ្នកកាន់ទង់ព្រលឹងក្ដី អ្នកសូត្រធម៌កៅវដាក្ដី បានន័យថា ប្រមូលអានិសង្សនៃអ្នកខំប្រឹងប្រែងទាំងអស់ជូនដល់បុគ្គលស្លាប់នោះ ។ បន្ទាប់មកត្រូវរកយោគី ( ភ្លុក ៤នាក់ ) មកឱ្យអាចារ្យយោគីប្រដៅទូន្មានធម៌ថា អ្នក



www.elibraryofcambodia.org

ទាំងអស់វិញ យើងជាអ្នកកាន់បុគ្គល ៖ ចូរអ្នកដណ្តប់ចិត្តឱ្យជាប់និងភាវនាថា **ពុទ្ធានុស្សតិ** .......... កុំឱ្យដាច់ ហាមក្រមាច់ក្រមើម សើចលេងព្រោះអំពើនេះមិនចំរើនដល់អាត្មាយើងឡើយ ។ បន្ទាប់មកពិធីរំកិលបុគ្គលចេញពីផ្ទះ បើបុគ្គលនេះធុំក្លិនហើយ អ្នកនៅផ្ទះទាំងអស់ត្រូវអនុញ្ញាតឱ្យភ្លុក សុំបើកជញ្ជាំងក្បាលដំណេកឬជញ្ជាំងចុងជើង ដោយសមគួរដល់ធម៌ ។ រួចមកឱ្យនិមន្តព្រះសង្ឃបង្សុកូលបុគ្គលនៅលើផ្ទះម្តង លុះព្រះសង្ឃនិមន្តចេញហើយ ភ្លុកយោគីអុជទៀនបង្វិលពពិល ជា **ឧត្តរាវត្ត** ដោយថា ៖ **ពុទ្ធានុស្សតិ...... អានាបានស្សតិ** ទាំង១០នោះឈ្មោះថា អនុស្សតិកម្មដ្ឋាន ។ បង្វិលពាជុំរួចហើយបង្វិលបុគ្គលចេញចាកផ្ទះ ។ ម្ចាស់ផ្ទះយកក្អមទឹកស្រោចលើថ្មជើងក្រានក្តៅរួចធាក់ទម្លាក់ទៅដីដើម្បីរម្ងាប់កម្មពៀរវេរាផ្សេងៗ ( ទំនៀមថា ជាការកើតធម្មសង្វេគដល់អ្នកនៅរស់ ។

**តទៅនេះនិយាយពីវិធីបង្វែបុគ្គល**

របៀបហែបុគ្គលទៅកាន់ទីបាឆាដើម្បីបូជាត្រូវនិមន្តព្រះសង្ឃមួយអង្គកាន់ធ្វីព្រះអភិធម្ម និងមានព្រះសង្ឃ អមបុគ្គលសូត្រមាតិកា ។ អាចារ្យយោគីកាន់ទង់ព្រលឹង ដើរបន្ទាប់ពីលោកអភិធម្មដោយភាវនាថា **រត្តានុបស្សនា**...ដោយសូត្រមិនដាច់ឡើយ ។ អ្នកប្រាយលាជ ដើរបន្ទាប់ពីអាចារ្យយោគីដៃចាប់លាជបាចទៅមុខ ក្រោយ ឆ្វេង ស្តាំ ឱ្យកើតសង្វេគថា រូបយើងទាំងឡាយកើតមកហើយ ស្លាប់ចោលឆ្អឹង ស ស្វាចនៅលើមហាប្រថពី ដូចដែលលាជនេះត្រឡប់ពុំបានឡើយ ។ អ្នកប្រាយលាជភាវនាថា៖ **មរណានុស្សតិ មរណំ អនតីតោ** កុំឱ្យភ្លេចឡើយ ។ ឯអ្នកបួសមុខភ្លើងត្រូវឱ្យទូលខ្សែ


www.elibraryofcambodia.org

ស្បូវភ្លាំង បន្ទាប់ពីអ្នកប្រាយលាជ ក៏ឱ្យភាវនាថា : មរណចមេ្ចាត្តិ មរណំ អនតិតោ កុំឱ្យភ្លេចឡើយ ។ ត្រូវរំពឹងថា : យើងម្នាក់ៗមានសេចក្ដីស្លាប់ជាធម្មតា គ្មាននរណានឹងកន្លងបានឡើយ យើងចេញសាងបញ្ញា និង ស្វែងរកកុសលក្នុងព្រះនិព្វានឱ្យឃើញច្បាស់ហើយប្រោសអ្នកដ៏មានគុណឱ្យរួចផង ។ ចំពោះភ្លុកទាំង៤សែងបុគ្គលនោះក៏ភាវនាថា: រូបំ អនិច្ចំ វេទនា អនិច្ចា-សញ្ញា អនិច្ចា សង្ខារាអនិច្ចា វិញ្ញាណំ អនិច្ចំ ឯអ្នកដទៃទៀតដែលជួយសែងរាល់គ្នា ក៏រួមពិចារណាដូចគ្នាដែរ ។ ពេលសែងបុគ្គលត្រូវសែងក្បាលទៅមុខ ។ ដល់ទីប៉ាឆាត្រូវដាក់បុគ្គលនោះចុះ អាចារ្យយោគីសែនបូលសុំទីកដី ។

**វិធីរៀបចំសែនសុំទីកដី:**

ស្លាជម ៨.សំពត់ ស មួយ អាវ កាសមួយត្រហោត( ពីដើមប្រើកាសដោតជាត្រណោតឥឡូវយើងដាក់ប្រាក់នោះបានហើយ) ផ្លែឈើរួមមានកប្បាសសំឡីផង ។ តែបើបូជាក្នុងសាលាមេរុ ឬកន្លែងប្រាសាទនោះមិនសុំទេ ព្រោះទីនោះមុននឹងធ្វើគេក្រុងពាលីរួចហើយ ។ ពេលអាចារ្យយោគីសែនសុំទីកដីហើយក៏ត្រូវចាប់ជើងថ្ករ សូត្ររម្ងាប់ថា : សិរោមេ ពុទ្ធទេវញ្ចលលាតេ-ព្រហ្មទេវតា ហទយំ នារាណញ្ចេ ហត្ថេចារមី សុរាបាទេ ពិស្ណុ-កញ្ចេវ សព្វកម្មំ បសិទ្ធិមេ រួចហើយយកចុងជើងថ្ករចុចដោតទៅដីទាំង៤នោះ ដោយដោតម្ដងមួយជាឧត្តរាវដ្ដ ។ (ឥឡូវមិនសូវប្រើជើងថ្ករទេ ព្រោះគេមានកន្លែងដុត ឬ បើកន្លែងកណ្ដាលវាលក៏ពុំសូវប្រើដែរដោយគេយល់ថា បើជើងថ្ករនេះមិនអស់នាំឱ្យខ្មោចលង ) ដូច្នេះបាលីសូត្រខាងលើនេះត្រូវ



www.elibraryofcambodia.org

តែសូត្រដើម្បីសុំទឹកជីដុតខ្មោច ។ ឯអណ្តាប់បូលភូមិនោះបានអ្នកភ្លុកទាំង៤នោះចែកគ្នាទៅ ។

បន្ទាប់មកអាចារ្យយោគី កាន់ទង់ព្រលឹងដៃខាងឆ្វេង កាន់ចបដៃស្តាំដើរមុខ អ្នកសែងបុគ្គលដើរតាមក្រោយដោយដើរជាឧត្តរាវដ្ត ពេលដើរអាចារ្យយោគីសូត្រ : **ឱ្យទេតយញ្ញ** គ្រប់ បីជុំហើយលើកបុគ្គលដាក់ជើងថ្ករ យកក្បាលទៅកើត ។ យោគីឈរលើក្បាលបុគ្គលដៃជាប់ជើងថ្ករ សូត្រ **អមេត-យញ្ញ.....** ដល់កាត់ខ្សែបាសឱ្យសូត្រថា : **អហិរិកំ អនោត្តប្បំ ទិចិ-កិច្ឆា ជោរតិបរិ យន្តិ តុសិតតទនំ គច្ឆន្តុ** សូត្រចប់ កាត់ខ្សែបាសទាំងអស់ចេញ ។ ឯកាំបិតកាត់ខ្សែបាសបានទៅអាចារ្យយោគី ។ បន្ទាប់មកភ្លុកទាំង៤ទាញបុគ្គលផ្សេងឱ្យប្រែមុខទៅជើង ។ អាចារ្យនិងភ្លុកទាំង៤ឈូលភ្លើង ដើរជាឧត្តរាវដ្ត សូត្រ **អមិជ្ជាបច្ចយា** សូត្រចប់ឈូលភ្លើង ។

**របៀបឈូលភ្លើង** បើខែស្រាពណ៍ មិគសិរ ចែត្រឈូលពីឧត្តរមុន ។ ជេស្ឋ អស្សុជ មាឃឈូលពីទក្សិណមុន ។ អាសាធ កត្តិក ផល្គុណ ឈូលពីបស្ចិមមុន ។ ពិសាខ ភទ្របទ បុស្សឈូលពីបូពិមុន ។ បន្ទាប់មកភ្លុកទាំង៤ទៅថែទាំរក្សាភ្លើងដោយភាវនាថា : **អយំ ខោមេ កាយោ ឯវមេទំ-អនតីតោ** ឱ្យរំពឹងពិចារណាថា : រូបកាយអញអើយសឹងដូច្នេះឯងគ្មានអ្នកឯណានឹងកន្លងបានឡើយ ពេលពិចារណាដូច្នេះ នឹងបានផលានិសង្សពីការដុតខ្មោចនេះដូចព្រះយសកុលបុត្រនិងសម្លាញ់ទាំង៤ជាអ្នកដុតខ្មោចស្រីម្នាក់ ហើយពិចារណាអនិច្ចសញ្ញាសេចក្តីសង្វេគរាល់គ្នា លុះលះជាតិទៅ បានសោយសម្បត្តិក្នុងសុគតិសួគ៌ ទាំងអស់នោះអំពីសាសនាព្រះពុទ្ធ **វិបស្សីសម្មាសម្ពុទ្ធ** ។ លុះ



www.elibraryofcambodia.org

ដល់មកសាសនាព្រះពុទ្ធជាម្ចាស់យើងនេះពលោរោរាប់ពាន ៩១ កប្ប ដោយផែក និសង្សដែលជុតខ្មោចនេះឯង ។ តែបើភ្លុកក្រមាច់សើចលែង ផ្ដេសផ្ដាស និង នាំខ្លួនទៅកាន់អបាយភូមិទាំង ៤ ពុំលែងឡើយ ។

ចំពោះយោគីលើកទង់ព្រលឹងឡើងបង្ហូតឱ្យសូត្រថា: **ឥមិនា និស្សន្ទេន ឥមំ ធជបដាកំ មយាតារិតំ បត្តិតំបុគ្គលស្ស ឧទ្ទិស្សាមិ** ដោយអំណាចផលបុណ្យដែលខ្ញុំបានធ្វើទូវទង់សំពត់នេះ ឧទ្ទិសផលដល់បុគ្គល ដែលបានស្លាប់សូមកុសលនាំផលបុណ្យនោះទៅដល់ដាក់ច្បដីសូតិទេវលោក ។ លុះភ្លើងឆេះប្រមាណពេញកំឡោះ ឱ្យនិមន្ដលោកបង្សុកូល ។ ពេលនេះ លោកក៏បានពិចារណា **អសុភកម្មដ្ឋាន** និងពិធីបំបួសមុខភ្លើង ។ បំបួស ហើយឱ្យសាមណេរនោះទៅឈរខាងក្បាលបុគ្គល អង្គុយក៏បាន ប្រមាណ ចម្ងាយល្មមភ្លើងក្ដៅមិនដល់ ឱ្យសាមណេរប្រមើលមើលរូបបុគ្គលចំរើនក្នុង កាយគតាសតិកម្មដ្ឋាន ។( ចំពោះការបួសសព្វថ្ងៃគេនិយមទៅបួសក្នុងព្រះវិហារ ជាមុនព្រោះក្នុងព្រះវិហារមានសីមាត្រឹមត្រូវ រួចទើបមកពិចារណានៅកន្លែងប៉ា ឆា ) ។ ចំពោះសាមណេរអ្នក ភាវនានោះថា : **កេសា លោមា នខា ទន្តា តចោ** ជាអនុលោម បដិលោម ដរាបដល់ភ្លើងរម្ងាប់ទើបច្រូច ទឹក បញ្ជូនកុសលឱ្យបុគ្គលនោះ រួចចាកចេញទីនោះ ទើបហៅពេញជា បួស មុខភ្លើងសងគុណម៉ែហោង លុះភ្លើងឆេះពាក់កណ្ដាលក៏ឱ្យនិមន្ដលោកទេសនី មុខភ្លើងត្រង់គម្ពីរ អរិយបុគ្គលក៏បាន ព្រះត្រៃលក្ខណ៍ក៏បាន ព្រះវិសុទ្ធិមគ្គក៏ បាន ។ លុះភ្លើងឆេះបុគ្គលសុះហើយ ឱ្យចោលសំពត់ដែលគ្របក្ដារមឈូស រម្លង ៣ដង ស្រេចចោលហួសទៅដើម្បីរម្ងាប់ចង្រៃ ឱ្យកូនចៅយកទៅប្រើ



www.elibraryofcambodia.org

ប្រាស់ទៀតក៏បាន ។

ពេលដុតសុះអស់ហើយអាចារ្យកាន់ទឹកសំបូរមួយផ្តិល អ្នកភ្លុក ៤នាក់ កាន់ទឹកក្អមគ្រប់គ្នាដើរប្រទក្សិណជាឧត្តរាវដ្ត ស្រោចរំលត់ភ្លើង ដោយសូត្រថា : **អចិរំ វតយំ កាយោ** ...... សូត្របណ្តើរដើរពទ្ធ ៣ ជុំជាឧត្តរាវដ្តស្រេចអាចារ្យប្រមូលរូបខាងក្បាលទៅទិសខាងលិចរូចឧបកិច្ចថា ដូចឬទេ ល្អឬទេ ? ថាមិនល្អទេ មិនដូចទេ ។ អាចារ្យរំលាយក្បាលនេះចេញ ធ្វើថ្មីដាក់ក្បាលទៅកើតវិញ សួរទៀត បើថាល្អហើយដូចហើយឱ្យសែនឧបកិច្ចដោយយកស្លឹកចេកមួយផាងមកគ្របពីលើរូបនោះយកសំពត់សប្រាំហត្ថគ្របស្លឹកចេកនោះទៀត និមន្តលោកបង្សុកូល បើគ្មានលោកគឺអាចារ្យយោគី ឬ ភ្លុកបង្សុកូលនោះក៏បាន រួចទើបរំលាយរូបនោះចេញរើសធាតុលាងទឹកឱ្យស្អាតជ្រះស្រេចហើយលាងទឹកសាប៊ូជាខាងក្រោយ បន្ទាប់មកយកដូងខ្ចីលាងទៀត ជាសំរេចបរិបូរណ៍ហោង ។

ពេលរើសធាតុហើយអាចារ្យយោគីគាស់ជើងថ្ករ កុំឱ្យភូតបិសាចនៅចាំជើងថ្ករ ក្រែងនឹងលងដល់អ្នកដទៃ ។ គាស់ជើងថ្ករឱ្យសូត្រថា **អចិរំ វត‌យំ កាយោ....** ២ រួចសូត្រមន្តថា **ឥមំចតុគ្គំ អះបេហិ** ២ រីឯចបបានទៅអាចារ្យយោគីសំពត់ទង់ព្រលឹងឱ្យយោគីកាត់ចេញ បោកជ្រះស្អាតធ្វើជាទង់កន្ទុយវែង ប្រគល់ឱ្យអ្នកដើមការដើម្បីយកទៅបង្ហូតថ្វាយទីណាមួយដែលមានព្រះចេតិយទើបគួរ ។

<u>បញ្ចាក់គួរចងចាំ</u> បូជានិងភ្លើង ឱ្យដាក់ក្បាលទៅកើត បោះបណ្តែតទឹកឱ្យដាក់ក្បាលទៅត្បូងកប់ក្នុងដី ឬ ដម្កល់មឈូសទុកក្តី ឱ្យដាក់ក្បាលទៅលិច



www.elibraryofcambodia.org

បើទុកមើរលើចុងឈើ ឬ ក្បាលដំបូកដាក់ក្បាលទៅជើង បើដាក់ក្នុងកោដ្ឋដាក់ក្បាលឡើងលើ វិធីបញ្ចុះធាតុនឹងរកថ្ងៃខែក្រុងពលី ត្រូវរកអ្នកចេះដឹងមើលទីដីបញ្ចុះឱ្យច្បាស់លាស់ ទោះបីបញ្ចុះនៅត្រង់ណាក៏ដោយ ក៏ត្រូវមើលថ្ងៃអណ្តែតសិរិទ្ធិជោគ ឯថ្ងៃទាំង៧បានតែថ្ងៃ ៤ - ៦ - ១ គឺពុធ - សុក្រ និងអាទិត្យ ។

បើរកដីល្អបាន រកថ្ងៃល្អបាន ត្រូវរកប្រដាប់ក្រុងពលី រួចមកជីករណ្តៅជ្រុងបីក៏បាន ជ្រុងពីរក៏បាន ។ ចំពោះជ្រុងរណ្តៅបីដូចហោជាងផ្ទះ ឯជ្រុងពីរដូចខែចំហៀង ។ ឯរណ្តៅជ្រុងពីរនេះត្រូវជីកតាមទំនួលខែ :

- ផល្គុណ ចេត្រ ពិសាខ កោងទៅបស្ចឹម ជ្រុងទៅបូព៌ បារដីទៅឧត្តរ ដាក់មាត់កោដ្ឋផ្ទៀងទៅទិសពាយព្យ ។

- ជេស្ឋ អាសាឍ ស្រាពណ៍កោងទៅទិសឧត្តរ ជ្រុងទៅទិសទក្សិណបារដីទៅបូព៌ផ្ទៀងមាត់កោដ្ឋទៅឦសាន ។

- អស្សុជ កត្តិក ភទ្របទ កោងទៅបូព៌ ជ្រុងទៅបស្ចឹម បារដីទៅទក្សិណ ផ្ទៀងមាត់កោដ្ឋទៅអគ្នេយ៍ ។

- មិគសិរ បុស្ស មាឃ កោងទៅទក្សិណ ជ្រុងទៅឧត្តរ បារដីទៅបស្ចឹម ផ្ទៀងមាត់កោដ្ឋទៅនិរតី ។ ជីករណ្តៅស្រេចហើយយកគ្រឿងសំរិត បើគ្មានយកឪទិន ឬពាងក៏បាន ដាក់ទឹកឱ្យពេញប្រៀបដាក់ក្នុងបាតរណ្តៅទើបយកកោដ្ឋ ទៅដាក់លើមាត់ពាងឬឪទិននោះ លុបដីនិមន្តព្រះសង្ឃបង្សុកូល យកទឹកច្រូច យកទឹកអប់មកស្រោចពីលើ ត្រដាក់ត្រជុំហោង ។

✳ តើបុគ្គលិកលក្ខណៈដូចម្តេចដែលធ្វើអាចារ្យយោគី ?



www.elibraryofcambodia.org

ត្រូវប្រកបដោយធម៌៤ប្រការគឺស្ថិតក្នុងសីល ៥ឬ៨មួយ, មានចិត្តមេត្តាអាណិតអ្នកទីទាល់ក្រលំបាក ខ្វះទ្រព្យធនកុំឱ្យយោគីបង្គាប់ តាមក្បួនគឺឱ្យជួយរំលាយបុគ្គលយកបុណ្យកុសលមួយ , **អលោភោ** កុំលោភលន់ ក្រៅតន្លងមួយ **ធម្មសណ្ឋវាចា** គឺចេះពោលពាក្យពីរោះ ចេះស្រដីទូន្មានពីរោះប្រដៅអ្នកជំងឺឱ្យមានតម្រេកក្នុងធម៌មួយ ។

※ អ្នកធ្វើយោគីបានអានិសង្សបីប្រការ អាយុវែងមួយ មានញាតិសន្តាននឹងបរិវារច្រើនមួយ និងបានប្រាជ្ញាទិព្វមួយ តែបើធ្វើយោគីមិនល្អ មិនប្រកបដោយធម៌ទេ មានទោសបីប្រការ មានសេចក្តីគរហានិន្ទាមួយ កើតជាអ្នកហិនហោចអាប់ប្រាជ្ញាមួយ មានទ្រព្យបានត្រឹមរក្សាទុកឱ្យគេមើលតែប៉ុណ្ណោះមួយ ។

## ពិធីមើលត្បូងកន្ទុយនាគ

ពេលបញ្ចុះធាតុ ជីករណ្តៅជ្រុងបីមើលទីស្ថានល្អ ត្រូវមើលត្បូងនាគកន្ទុយនាគរួចហើយអាចារ្យយោគីយកស្លាត្រួយថ្វាយព្រះធរណីសូត្រថា **មោ-ករំ បិតាធាបំ វិនាសន្តិ** ២ សូត្រ ២០ ដងទើបជីករណ្តៅជា ៣ជ្រុងស្មើជម្រៅ១ហត្ថ ទើបយកទៀន ធូប អុជអមរណ្តៅ រួចហើយសូត្រផ្ចាញ់មារថា : **បញ្ចមារេ ជិនោ នាថោ សម្ពោធិមុត្តមំ ឯតេន សច្ចវជ្ជេន បញ្ចមារា បលាយន្តិ** សូត្រ ៣ ចប់ បន្ទាប់មកសូត្រដម្កល់ព្រះធរណីថា : **បមំវីពលិសព្វពោធិមណ្ឌលា អសំខេយ្យា មារសេនំ ជយន្តុ ជេយ្យំ មំ តុលំ** យកទៀនធូបមកកាត់ប្រវែងចង្អុលដៃ ជាបួនយកកន្លះដោតទៀន អុជទាំងបួនដោតទៅបាយបំនួតទាំងបួន នោះយកទៅដាក់ទាំងបួន



www.elibraryofcambodia.org

ទិសទៅរល្ដៅ ទើបស្រាយធាតុដាក់ជាកណ្ដាលដោយសូត្របាលីថា **គឹស អា-គច្ឆន្តិ មេរាអ បថវីធាតុ បតន្តិ តទេ** សូត្រ១២ដង ។ រួចសូត្របន្តថា : **គឹស អាគច្ឆន្តិ មេរាអ បថវីធាតុ បតន្តិ តទេ** សូត្រ២១ចប់ រួចសូត្របន្តទៀតថា : **អាគច្ឆន្តិ ពុរតេជោធាតុ បតន្តិ តទេ** សូត្រ ១០ដងហើយសូត្រទៀតថា : **ចតុត្ថោហភូតំ ធាតុតំ តទំ សន្តិម្ពិ-សិនោ** សូត្រ៣ដង រួចតមកយោគីផ្តាំអស់កូនចៅគ្រប់ៗគ្នា ឱ្យខមាទោស អាចារ្យយោគីបង្គាប់ឱ្យថាតាមដូចតទៅ **ឱកាស អតីតំ ទោសំ អនាគតំ ទោសំ ខេក កម្មំ បាបសព្វំ ឧប្បជ្ជន្តុ នោ អហោសិកម្មំ សំវរោតិ កាយកម្មំ មនោកម្មំ វចីកម្មំ មេ ទោសំ អនាគតំ មេ ទោសំ បច្ចុប្បន្នំ មេ ទោសំ សព្វ ទោសំ ខមាមិហំ ម**

អាចារ្យយោគីបន្តថា អស់បងប្អូនកូនចៅញាតិផៅ នាំអ្នកមកបញ្ចុះនេះកុំឱ្យអ្នកគិតរឮកមកដល់បងប្អូនកូនចៅ នូវអស់ទាំងទ្រព្យធនទាំងឡាយឡើយ ។ ព្រោះអ្វីៗសុទ្ធតែអស់ខ្លឹមសារ គ្មានអ្វីស្ថិតស្ថេរទេ សូម្បីភ្នំព្រះសុមេរុកំពស់ ៨៤ . ០០០ យោជន៍ក្តី មហាប្រថពីកម្រាស់ ២៤០ . ០០០ យោជន៍ក្តី ទឹកនព្វមហាសមុទ្រជំរៅ ៨៤, ០០០ យោជន៍ក្តីបើដល់ភ្លើងប្រល័យកប្បហើយសឹងឆេះវិនាសអស់ហោង ។ មិនត្រឹមតែប៉ុណ្ណោះសូម្បីទេវតាឥន្ទព្រហ្ម តែដល់កំណត់ហើយ សឹងតែឆេះឯង ។ ប៉ុន្តែទេវតាឥន្ទព្រហ្មនេះជាកន្លែងសុខមួយរយៈវែងមុនដល់ភ្លើងឆេះកាល្ប ។ ដូចនេះបើអ្នកបានទៅកើតនៅស្ថានទេវតាឥន្ទព្រហ្មនោះហើយ សូមឱ្យពរកូនចៅញាតិផៅនៅធ្វើការរកស៊ីត្រជាក់ត្រជុំសុខដុម កុំឱ្យជំងឺដម្កាត់ ឬ ភិតភ័យមោះមៃអ្វីឡើយ ។ សូមឱ្យមានអាយុ



www.elibraryofcambodia.org

វែង ។ អាចារ្យយោគីនិយាយចប់ឱ្យបងប្អូនកូនចៅជិតនោះទទួលថា : សាធុៗព្រមៗ រួចហើយកូនចៅយកស្លាដាក់ទៅក្នុងរណ្តៅគ្រប់ៗគ្នា រួចមក អាចារ្យយោគីយកអំបោះទាញជាខ្សែស្ទូរ ដាក់លើមាត់រណ្តៅទុកចុងប្រវែង ចង្អុលដៃទើបលុបដីដោយសូត្រថា (**ព្រះធរណី ព្រះគង្គា ចៅទេយ្យ យុរិមិយំ សេយ្យាតំលោហិន្ទុ ពុទ្ធោ អនន្តឃោសោ ចក្រវាឡ សំយោ និព្វានំ បរមំ សុខំ មេត្តញ្ច សព្វលោកស្មឹ មានសម្ភា- ទយេ សព្វេ សត្តា អវេរាហោន្តុ**) បន្ទមកលុបជាខ្នង អណ្តើកស្រេច ហើយ រយៈពេល៧ថ្ងៃឱ្យកូនចៅទៅមើលទីស្លាន បើស្រុតឱ្យលុបថែម ។

**<u>កំណាត់ទំណាំ</u>**

ឯទៀន ៥ ធូប ៥ ម្លូព្រួយ ៥ នេះកូនចៅបុគ្គលផ្ទាល់ទុកយកស្មាលា ទោសពីបុគ្គលនោះ ។ ឯទៀនកាល្បមួយ ធូបមួយ ព្រួយមួយ ផ្កា អុជ ថ្វាយទៅព្រះពុទ្ធគុណនោះឯង ដោយសូត្រថា : **ឱកាស អតិពហុបូជា ឥមំ ទីបធូបំ ពុទ្ធគុណំ ករោមិ** ៕ ឯទៀន ៥ ធូប ៥ ផ្កា ៥ នេះអុជ ថ្វាយទៅធាតុទាំង ៥ ដើម្បីនាំបុគ្គលទៅហោង ។ ដោយសូត្រថា : **ឱកាស អតិពហុបូជា ឥមំ ទីបធូបំ បុជំ ធាតុគុណំ ករោមិ** ៕ ឱ្យលោក នាំសោយសម្បត្តិនាយហោង ។ ន ច ក គាថា នេះបើសរសេរទង់ព្រ លឹងសូត្រ ៣ ចប់ **នកទេសិៗកិករនាន់អបាំបិតព្ទនាមិ** ។ គាថានេះសរសេរ ដាក់ជាយទង់ព្រលឹងទាំង ៤ សិ ភ ច សុ ឱ រ សុ ។ គាថានេះ សរសេរដាក់កណ្តាលទង់ព្រលឹងថា : ន្ធ រ ឡិ ហ ខ ( សក់ឱនេះគូចជា៨ ជាន់) ។ កាលលើកបុគ្គលជិះទឹក សូត្រ **អត្ថិ ឥមស្មឹ** ចប់ស្រោចទឹកទៅ ។



www.elibraryofcambodia.org

សំ ទិ ធះ បុ ក យ ម សូត្រកាលប្រែរូបបុគ្គល ។ នះមោពុទ្ធាយ នេះសូត្រសូទ្យូរបធ្វើជាម្រាមដៃជើងទោះហោង ។

- ចក្ខុសម្ផស្សជា សោតសម្ផស្សជា ឃានសម្ផស្សជា ជិវ្ហាសម្ផស្សជា កាយសម្ផស្សជា មនោសម្ផស្សជា ទាំង ៦ បទនេះចារដាក់ ចង្កាបុគ្គល ។

- ឥតិបិសោ នះមោពុទ្ធាយ ចារដាក់ថ្ងាសបុគ្គល ។

- ឥតិបិសោ ចាតុមហា រាជិកានំ ទេវានំ រក្ខន្តិ ចារដាក់ទ្រូងបុគ្គល ។

- ឥតិបិសោភគវា តាវតឹសានំ ទេវានំ រក្ខន្តិ ចារដាក់បាតដៃស្តាំបុគ្គល ។

- អ ម ឧ អ ម ឧ ឧ ម អ ចារដាក់ក្រោមខ្នើយបុគ្គល ។

- សោ សោ អ អ អា អា ន នេ ចារដាក់បាតដៃឆ្វេងបគ្គល ។

ពេលអ្នកជំងឺមិនទាន់ស្លាប់អ្នកនៅអងត្រចៀកឆ្វេងអ្នកជំងឺ ឱ្យភាវនាផ្លុំត្រចៀកថា សតិបដ្ឋានសតិបដ្ឋាន " ១០០ ចប់ ។ ឥតិបិសោភគវាកឹករណី តាវតឹង្សា ភវនំ គច្ឆន្តិ ១០០ ចប់ ឥតិបិសោកឹករណីទេវា រក្ខន្តិ ១០០ ចប់ បែរមុខទៅឰសាន ឱ្យព្រះបាទកំករណាឱ្យបើកផ្លូវ ។ មគ្គរាជ្ជ សំវានិតានំ ម អ ឧ ខ

ឧប្បចានំ រាជាតិ បរិយន្តិ មហា តុសិត ភវនំគច្ឆន្តិ



www.elibraryofcambodia.org

សូត្រ ច្រូចទឹកឱ្យបុគ្គល ។

- បង្សុកូលលើផ្ទះ សូត្រ **ករុណា កុសលា មាតិកា ៥**
- ដាក់ក្នុងក្តារហើយក្តី នៅក្រៅក្តី បង្សុកូល សូត្រ **ឯកនាមកី កុសលា សត្តបករណ៍ ៥**
- ដុតហើយប្រែរូបបង្សុកូល សូត្រ **អវិជ្ជា បច្ចយា អវិជ្ជា-យតេ្វវ ពុទ្ធានុស្សតិ ៥**

## ចំពោះខ្មោចឆៅហោង

បើបញ្ចុះនៅទីណា ឱ្យបួជានៅទីនោះពេលដារ ត្រូវសូត្រពិស្តារ៧ចប់ ចំនួន១ព្រឹកឯចង្ហាន់រាប់បាត្រឱ្យយក រមៀត ១ ខ្ទឹ១ បុកត្រងយកទឹកលាយជាមួយអង្ករ យកទៅដណ្តាំបាយរាប់បាត្រ ។ ត្រូវមានកន្ទោង៤ដាក់ឱ្យភ្លុកទាំង៤ រាប់បាត្រហើយត្រូវដាក់ទៅកន្ទោងនោះផង ។ ពេលដារត្រូវបន់ជូនផលានិ-សង្សទៅព្រះកាលព្រះបាទទសមុខ ពេលដារសូត្រពិស្តារ ៦ ចប់ ។ ពេលយកចង្ហាន់ កន្ទោងនិងផ្លែឈើមកហើយ ឱ្យជីករណ្តៅកប់នៅក្រោមរានដែលយើងធ្វើនៅទិសអគ្នេយ៍ ។ រួចមកសូន្យរូបព្រះកាល រូបព្រះបាទទសមុខ ផ្តល់ខ្នងគ្នាដាក់លើរាន ។ ឯផ្លែឈើថ្វាយដាក់លើរានក្នុងតោកពីរ ឱ្យដុតរូបនោះដោយយកអំពិល ១ ក្រសាំង ១ សង្កែ ១ ទ្រមែង ១ ឱ្យយកប្រាំពីរៗកង់មួយមុខៗដើម្បីដុតរូបព្រះកាលនិងទសមុខនោះ រួចហើយយោគីសូត្ររម្ងាប់ដោយឈមមុខទៅទិសទាំង ៨ លុះត្រាតែរលត់ភ្លើងនោះហោង ។



www.elibraryofcambodia.org

ឯពេលគាស់ក្រុលឡើង ឱ្យនិមន្តព្រះសង្ឃ៤អង្គបែរមុខចេញក្រៅទិស ជុំវិញបុគ្គលឱ្យលោកសូត្រថា : **ចរន្តិ ទិសំ វេហាសំ សុខំ បរមំ សុខំ និព្វានំ បរមំ ភគា រូបក្ខន្ធោ ទុក្ខោ សុខំ និព្វានំ រូបក្ខន្ធោ អនិច្ចា សុខំ និព្វានំ រូបក្ខន្ធោ អនត្តា បរមំ សញ្ញា និព្វានំ សោ គគនា ឥតិ អរហំ** ៣ ចប់ ឬ ៧ ចប់ តាមជំពូកបុគ្គល ។ បាលីនេះ **យោ ជរា សម្មា សម្ពុទ្ធោ ធម្មោ ភត្តានំ វត្តយោ វភត្តានំ មនុ សន្តិ ចាយំ បហាយ មនុស្ស ទេហំ ទេវកាយំ បរិមតន្តិ** សូត្រ៣-៧ចប់ នេះជាបាលីសូត្រដាក់ក្រណាត់សក្រាលដាក់មនុស្ស ណាដែលស្លាប់ដោយព្រះកាល និងព្រះបាទទសមុខ ។ បើបានសូត្រ ៧ ចប់ហើយបែរបន់ថែមជូនព្រះកាល និងព្រះបាទទសមុខនោះបាត់បាបចង្រៃអ្វី ទាំងអស់ហើយ ។ បើពុំបានធ្វើដូចបង្គាប់នេះទេនោះកូនចៅអ្នករស់នៅមិនបាន រួចកម្មពៀរព្រះកាល និងព្រះ បាទទសមុខទេ ។

**យាយ ករោ ភាក លិច្ចោ វេយ យរិមិយំ លោកំ ឆៗ និ ខ**

**នេះនិងស្រមីតី** ស្លាប់ដោយម្រឹត្យូវ១ ស្លាប់និងជម្ងឺបូស១ ជម្ងឺហត់១ ជម្ងឺចុះផ្ទៃ១ ជម្ងឺអាបទាញង១ ជម្ងឺក្អក១ ជម្ងឺហឺត១ ក្អកក្អួតស្លាប់១ ស្លាប់និងជម្ងឺ១ ស្រាប់តែស្លាប់១ ស្លាប់ទាំងអំបាលនេះ សឹងបង្សុកូលចំអាសបានហោង ។ រីឯស្លាប់នឹងព្រះកាលគឺ រំបល់១ សំរាលកូនមិនរួច១ សំរាលកូនហើយឈឺស្លាប់១ នេះហៅថាស្លាប់ដោយព្រាយ មិនអាចចងទង់ព្រលឹងនឹងបង្សុកូលបានឡើយឱ្យយកខ្មោចទៅកប់ដោយប្រញាប់ ដាក់ក្បាលទៅជើង ។



www.elibraryofcambodia.org

## អំពីទង់ព្រលឹង

នៅគ្រប់ស្រុកក្នុងប្រទេសកម្ពុជា តែតែងនិយមប្រើទង់ក្រពើនិងទង់ព្រលឹង នៅពេលមានបុគ្គលស្លាប់ ។ កាលណាអ្នកជំងឺមានកម្លាំងតិចជិតនឹងអស់ខ្យល់ អស្សាសៈ បស្សាសៈហើយលោកអាចារ្យតែងយកសំពត់សប្រវែង៤ហត្ថ បត់ជាពីរ យកឈើឬបន្ទះឬស្សី ពីរកំណាត់ដាក់ខ្វែងគ្នាគឺមួយជាដង មួយជាឈើឆ្កាង រួចស៊កក្នុងផ្នត់សំពត់ រួចចងបង្រួមក្រសោបក្រោយសម្រាប់កាន់ មាន ឆ្នាំងបាយថ្មីមួយ ចងបន្តោងភ្ជាប់នឹងដងទង់នោះផងហើយអាចារ្យសរសេរបាលីនៅផ្ទៃនោះថា : **ឥមំ ធជំ បដាកំ នាគតីសគច្ឆេ ចេតិយស្ស ឧស្សាបេមិ ឥមិនា និស្សន្ទេន** ។ ឬសរសេរថា : **អាគាយ ទត ឥធ អយំ តុសិតគច្ឆំ អាគច្ឆន្តិ អសោមិកំ សុញ្ញំ គណ្ហាមិ** ។

ហើយអាចារ្យលើកទង់នោះទៅដាក់នៅក្បាលដំណេកបុគ្គលស្លាប់រួចផ្តាំបុគ្គល (ខ្មោច) នោះថា " ទង់ព្រលឹង " នេះជាសំបុត្រដើរផ្លូវរបស់អ្នកហើយចូរអ្នកកាន់ឱ្យជាប់ដើម្បីធ្វើដំណើរទៅថ្វាយបង្គំព្រះចូឡាមណីចេតិយព្រោះអ្នកទៅតែម្នាក់ឯងគ្មានអ្នកណានាំផ្លូវទេ ។

## ប្រវត្តិទង់ព្រលឹង

កាលពីអតីតកាលដ៏យូរលង់ មានបុរសម្នាក់មានកូនប្រុសមួយជាទីស្រលាញ់ បានសុំលាឪពុកទៅរៀនសិល្បសាស្ត្រឯនគរ **តក្កសិលា** លុះរៀនរួចក៏សុំលាអាចារ្យចេញទៅរកគ្រូផ្សេងទៀត ដើម្បីរៀនបន្ថែម ។ លុះដើរទៅបានជួបនិងព្រះ **បច្ចេកពុទ្ធ** មួយអង្គ ឃើញលោកប្រព្រឹត្តល្អតាមរបៀប



www.elibraryofcambodia.org

សមណេរៈ មាណេពនោះមានចិត្តស្រឡាញ់ជ្រះថ្លា ក៏ចូលទៅសុំរៀនក្នុងសំណាក់ព្រះបច្ចេកពុទ្ធ លោកក៏ឱ្យរៀនប៉ុន្តែលោកឱ្យបួសសិន ។ ( មាណពនោះបួសរួចហើយលោកបង្រៀនធម៌ **វិបស្សនាកម្មដ្ឋាន** ) ។

នៅរៀនយូរៗទៅមាណពនោះ បានសំរេចពោធិញ្ញាណជាព្រះបច្ចេកពុទ្ធមួយអង្គដូចព្រះបច្ចេកពុទ្ធជាគ្រូនោះដែរ ។ មិនយូរប៉ុន្មានមាណេពបច្ចេកពុទ្ធក៏ចូលបរិនិព្វានទៅទាំងវ័យក្មេង គួរឱ្យសោកស្តាយសំរាប់បុគ្គលជាបុថុជ្ជន។ អ្នកស្រុកភូមិនៅក្បែរនោះនាំគ្នាធ្វើបុណ្យបូជាសព ហើយកសាងចេតិយមួយបញ្ចុះអដ្ឋិធាតុព្រះបច្ចេកពុទ្ធអង្គនោះត្រង់ផ្លូវបំបែក ។ បុរសជាឪពុកបាត់កូនយូរពេកក៏ទៅតាមរកកូន ដល់ស្រុកនោះហើយក៏សួររក ។ អ្នកស្រុកក៏បានប្រាប់តាមដំណើររឿងថា ៖ កូនរបស់អ្នកឯងបានសំរេចជាព្រះបច្ចេកពុទ្ធមួយអង្គចូលបរិនិព្វានបាត់ហើយ ។ បុរសជាឪពុក ក៏យំសោកស្តាយអាល័យកូន ។ បន្ទាប់មកឪពុកក៏ទៅដងទឹកស្រោចស្រពទ្រនាប់ខ្សាច់ចេតិយ រួចយកក្រមាបង់ក ចងធ្វើជាទង់ ដោយឧទ្ទិសថ្វាយនៅមុខចេតិយ ហើយថ្វាយបង្គំលាវិលត្រលប់ទៅវិញ ។ ឃើញដូច្នោះអ្នកស្រុកនៅជិតនោះ ក៏យកតម្រាប់តាម ។

លុះចំណេរកាលតមកទៀត ក៏ក្លាយទៅជាទំនៀមទម្លាប់គឺពេលដែលហែខ្មោច អាចារ្យតែងលីទង់ព្រលឹងដើរមុខរហូតដល់ទីប៉ារ៉ា ទើបយកទង់នោះទៅដាក់នៅទិសព្វាសាន ជាសញ្ញាឱ្យខ្មោចនោះដឹងថាខ្លួនត្រូវចេញ ដំណើរទៅតាមទិសព្វាសាន ដើម្បីទៅថ្វាយបង្គំព្រះចុឡាមណីចេតិយ ។

## ប្រវត្តិទង់ក្រពើ (ទី១)

កាលព្រះសម្មាសម្ពុទ្ធ គង់ធរមាននៅឡើយ មានសត្វក្រពើញីឈ្មោល



www.elibraryofcambodia.org

១គូមានសេចក្ដីជ្រះថ្លា នឹងព្រះពុទ្ធសាសនា ក៏ចូលទៅសុំព្រះពុទ្ធអង្គបួស តែព្រះពុទ្ធអង្គពុំព្រមអនុញ្ញាត ព្រោះជាសត្វតិរច្ឆាន ។ ក្រពើក្រាបទូលព្រះអង្គថា យើងខ្ញុំព្រះអង្គទាំងពីររូបនេះពុំមាននិស្ស័យសាសនាព្រះអង្គទេតែដោយយើងខ្ញុំទាំងពីរនេះស្រឡាញ់ប្ដូរផ្ដាច់នូវសាសនាព្រះអង្គ យើងខ្ញុំព្រះអង្គសូមធ្វើសំណូមពរថា (បើយើងខ្ញុំស្លាប់ទៅសូមឱ្យគេយកស្បែកយើងខ្ញុំទៅដោតធ្វើជាទង់ថ្វាយចំពោះព្រះភក្ត្រព្រះអង្គទុកជាសក្ការៈបូជាកុំបីខានឡើយ) ។ ព្រះពុទ្ធអង្គទ្រង់ទទួលសំណូមពរនោះដោយព្រះមេត្តា ។ លុះក្រពើនោះស្លាប់ទៅគេក៏យកស្បែកក្រពើទៅដោតថ្វាយតាមសំណូមពរមែន ។

លុះព្រះសម្មាសម្ពុទ្ធទ្រង់ចូលនិព្វានទៅ ស្បែកក្រពើនោះក៏ពុករលួយអស់គេក៏នាំគ្នាយកសំពត់ស ឬក្រដាសមករចនាធ្វើជារាងស្បែកក្រពើ ដើម្បីជាដំណាងតទៅទៀត ។ ដូចយើងតែងឃើញគេដោតទង់ក្រពើនៅគ្រប់កន្លែងអាសនៈ ព្រះពុទ្ធរូបស្រាប់ ។

## ប្រវត្តិទង់ក្រពើ (ទី២)

កាលណាមានមនុស្សស្លាប់ គេតែងយកទង់ក្រពើទៅចងនៅពីមុខផ្ទះ ឬទីណាមួយដែលញាតិមិត្តបងប្អូនជិតឆ្ងាយអាចមើលឃើញបាន ។ គេចងទង់ក្រពើមួយឬពីរមិនកំណត់ហើយជាទំនៀមទម្លាប់របស់ខ្មែរយើងពេញទាំងប្រទេសទៅហើយ ។ នៅសម័យដើមឬសម័យនេះក៏ដោយ បើគ្រួសារខ្មែរយើងខ្លះនៅកាន់ទំនៀមទម្លាប់កប់សាកសពប៉ុណ្ណេះប៉ុណ្ណោះឆ្នាំ ទើបលើកយកឆ្អឹងមកបូជា គេតែងតែចងទង់ក្រពើនៅក្បែរផ្នូរខ្មោច រហូតដល់ទង់នោះដាច់ដោយខ្លួនឯង ។ ជូនអីដល់ថ្ងៃខួបនៃសពនោះដែលទទួលមរណភាពគេក៏ចង



www.elibraryofcambodia.org

ទង់ថ្មីមួយទៀតក៏មាន ។

## ការនិយាយបទងទង់ក្រពើនេះមានប្រវត្តិដូចតទៅនេះ

ក្នុងរាជស្តេចអង្គចន្ទ័ទី២ ( រាជធានីទៅឧដុង្គមានជ័យ ) ស្តេចមានបុត្រមួយព្រះអង្គ ប្រកបដោយរូបល្អ ព្រះនាមព្រះអង្គម្ចាស់ក្សត្រី **ក្រពុំឈូក** ប៉ុន្តែកាលទ្រង់ព្រះជន្មបាន ១៦ វស្សា ក៏ត្រូវក្រពើមួយដ៏ធំឈ្មោះ **អាធន់** ដែលក្លាយខ្លួនមកពីលោកនេនមួយអង្គឈ្មោះ **នេនធន់** បានចាប់លេបទាំងរស់ ។ ស្តេចបិតាទ្រង់ស្តាយណាស់បានចាត់ការផ្សងកន្ទោងខ្សែវដេញតាមក្រពើ នេនធន់ អស់ពេលវេលាច្រើនថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ក៏ចាប់ក្រពើនេះបាននៅខេត្តក្រចេះ ។ ដោយមាតានៃក្សត្រីក្រពុំឈូកនេះនឹកស្រឡាញ់កូនខ្លាំងពេកក៏ឱ្យគេវះពោះក្រពើយកបុត្រចេញមកភ្លាម ប៉ុន្តែក្សត្រីក្រពុំឈូកបានសុគតបាត់សង្ខារទៅហើយ ។ ស្តេចបិតាបានឱ្យគេសង់វិហារមួយត្រង់កន្លែងវះក្រពើនេនធន់នោះ ដោយធ្វើសសរដល់ទៅ ១០០ ។ នៅពីមុខវិហារសសរមួយរយនោះ ស្តេចឱ្យធ្វើចេតិយមួយយ៉ាងធំ ដើរចាប់ស្រីមានផ្ទៃពោះ២០នាក់មកសម្លាប់យកក្បាលធ្វើជាគ្រឹះចេតិយ ហើយឱ្យសាងរូបក្សត្រីក្រពុំឈូក ឈរលើចេតិយហើយឱ្យគេយកស្បែកក្រពើ នេនធន់ ទៅពន្លះឆ្លាងទាំងអស់នៅក្បែរចេតិយនោះផង ។ តាមសេចក្តីតំណាលរបស់អ្នកស្រុកថា កាលពីជំនាន់ដើមគ្មានអ្នកណាហ៊ានដើរកាត់មុខចេតិយនេះទេ បើស្ត្រីមានផ្ទៃពោះដើរកាត់មុខនឹងត្រូវស្លាប់ភ្លាម ។ សេចក្តីតំណាលខាងលើនេះ នាំឱ្យយើងយល់ថា ទង់ក្រពើនេះមានរឿងរ៉ាវឬបុព្វហេតុពីពេលនោះមក ។ ដូច្នេះបានជាគេហៅទង់នេះថា ទង់ក្រពើ ព្រោះដើមហេតុមកពីស្តេចអង្គចន្ទ័ទី២ បានឱ្យគេវះស្បែកក្រពើ



www.elibraryofcambodia.org

លេបធៅ យកមកចងមុខព្រះចេតិយ ព្រះម្ចាស់ត្រូវក្រពើលេបយកជាបុត្រនោះ ឯង ។

ទង់ក្រពើនេះមានរូបរាងដូចស្បែកក្រពើ ដែលគេបានពន្លះចងឆ្កាង មានក្បាលខ្លួន ជើងកន្ទុយ ប៉ុន្តែដោយហេតុថាសិល្បៈខ្មែរប្រភេទណាក៏ដោយ តែងមានការវិវត្តន៍ប្រែប្រួលជានិច្ច ដូច្នេះបានជាទង់ក្រពើនេះជួនអីមាន ជើងដល់ទៅ ៨ មានកន្ទុយ ២ ។ ក្នុងពិធីបូជាសពលោកគ្រូចៅអធិការវត្ត ឬព្រះឧបជ្ឈាយ៍ឬក៏លោកសង្ឃអង្គណាមួយដែលមានសមណស័ក្តិគុណសម្បត្តិខ្ពង់ខ្ពស់ គេតែងធ្វើទង់ក្រពើនេះធំវែងមានក្បាច់ច្រើន ហើយប្រើដោយក្រណាត់សំពត់ច្រើនពណ៌ថែមទៀត ។ ប៉ុន្តែតាមធម្មតាគេធ្វើត្រឹម ៥ ម៉ែត្រយ៉ាងវែង គេធ្វើដោយសំពត់សតែម្យ៉ាង ។ ទង់នេះគេច្រើនប្រើតែពីរប៉ុណ្ណោះប៉ុន្តែទង់តូចៗ ដែលគេដោតនៅជុំវិញឈាបនដ្ឋានជាដើម គ្មានកំណត់ថា ប៉ុន្មានៗឡើយ ។



www.elibraryofcambodia.org

## មតិគួរពិចារណា ! អំពី « ការប្រែរូប »

ចំពោះការប្រែរូបនេះ លោកអាចារ្យខ្លះធ្វើ ឯអាចារ្យខ្លះទៀតមិនធ្វើទេ ដោយយល់ថាមិនគប្បី ព្រោះអ្វី ? ព្រោះគូររូបហើយឱ្យឆ្លើយថា ត្រូវឬទេ ? ដូចឬទេ ? យោគីអ្នកឆ្លើយដំបូងថា : មិនដូចទេ ! លុបចេញគូរទៀត សួរថាដូចទេ ? ឆ្លើយថា : មិនដូចទេ ! ដល់លើកទី៣ លុបចេញហើយគូរជាថ្មី រួចសួរថាដូចទេ ? ទើបឆ្លើយថា ( ដូចៗ ) ។

ចំនុចប្រែរូបនេះមតិខ្លះយល់ថា ( ដីរក៏ខ្វះ ទ្រមាក់ក៏ឆ្គួត ) ។ ព្រោះថាបើមិនដូចឱ្យវាមិនដូចទាំង ៣ដងទៅ ! រឺថាបើដូចឱ្យវាដូចទាំង ៣ដងទៅ . ម៉េចក៏គូរបែបដដែលៗសោះ ទី១ ទី២ ថាមិនដូច ដល់លើកទី៣ បែរជាឆ្លើយដូចទៅវិញ ។

ឯការយល់របស់យើងខ្ញុំវិញយល់ថា : ដូចម៉េចដែលហៅថា ទំនៀមទម្លាប់ ? ពុំមែនជាព្រះពុទ្ធដីកាទេ តើយើងទៅរកសច្ចៈក្នុងពិធីប្រែរូបនេះ ប្រកែកប្រណាំងគ្នាយកកែស យកត្រអោន យកឈ្នះយកចាញ់ធ្វើអ្វី ?

ពាក្យថា ទំនៀមទម្លាប់របស់ខ្មែរ អ្នកស្រុកនិមួយៗ អ្វីក៏មានបែបឧបកិច្ចដែរ គឺគេធ្វើតាមទម្លាប់ គូរវាមិនមែនរូបមែនៗទេ អញ្ចឹងគ្រាន់តែឆ្លើយឧបកិច្ចថាដូច អញ្ចឹងចុងក្រោយទៅវាមិនខាតចំណេញអ្វី ។ ដូចជាពាក្យសែនព្រេនថា : អើ ! ខ្មោចជិតយកបាយ ខ្មោចឆ្ងាយយកអង្ករថែមទៀតទៅ ! មោសាជីទៅ ! រួចព្រោចអង្ករឈូរតែម្ដង ។ តើពិតឬទេ ? ឃើញខ្មោចស៊ីបាយ ឃើញវេចអង្ករទៅដែរឬទេ ? តែគេធ្វើជាឧបកិច្ចទម្លាប់មកយូរហើយ ! ព្រោះគំនិតយើងពីដំបូងឡើយ សាសនាព្រាហ្មណ៍ បានដក់នៅជាប់មុនហើយ ។ ម្យ៉ាងទំ



www.elibraryofcambodia.org

ទៀមប្រពៃណីរួ ពិធីផ្សេងៗ ដែលលាយឡំដោយសាសនាព្រាហ្មណ៍ និង ពុទ្ធសា-សនាមហាយាន បានកើតទៅជាទំនៀមប្រពៃណី របស់ស្រុកទេសជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ឯព្រះពុទ្ធសាសនាថេរវាទ ទើបតែប្រតិស្ឋានស៊ប់នៅប្រទេសខ្មែរក្នុង គ-ស ១៤៣១ ព-ស ១៩៧៥ ។ ដូច្នេះពិធីកម្មមួយចំនួនតាមរបៀបសាសនាទាំងពីរ អំពីបូរាណ ក៏ជាប់ជាប្រពៃណីខ្មែរតៗមក ។ ម្យ៉ាងទៀតយើងនៅជា បុថុជ្ជន ធ្ងន់ដោយកិលេស ក្រាស់ដោយកម្មនៅជាប់ក្រាស់ឃ្មឹក ដោយសីលព័ត្ត ។

ជាការពិតណាស់បើគិតពីការគួររូបគ្គី យើងគួរឬធ្វើដំបូងៗ គួរលើកទី១ លើកទី២ ពិតជាមិនទាន់ដូចមែន ទាល់តែធ្វើញយៗ ទើបរាងប្រហាក់ប្រហែល ឬរាងដូចខ្លះ ។ ឬដូចជាយើងរៀនអក្សរដំបូងនៅរឹងដៃ ឱ្យតែគូសតាមគ្រូក៏ពុំដូចផង តែថា ដោយការព្យាយាមសរសេរលប់ៗ ២-៣ដង ទើបអាចសរសេរពិត ។ យ៉ាងណាការគួររូបបែបពិធីឧបកិច្ចនេះ ក៏ដូចគ្នាដែរ គួរលើកទី១ លើកទី២ ថាមិនដូច ! ទោះដូចក៏ដោយមិនដូចក៏ដោយ ឱ្យឆ្លើយថា មិនដូចៗទៅដល់គួរលើកទី៣ ទោះមិនដូចក៏ឆ្លើយថា : ដូចៗជាចុងក្រោយដែរ នេះទើបហៅថា « ឧបកិច្ច » ។

ដូច្នេះ សៀវភៅដែលយើងខ្ញុំសរសេរនេះ គ្រប់ពិធីកម្មដែលជាទំនៀមទម្លាប់ក្រៅពីព្រះពុទ្ធដីកា ក្រៅពីលក្ខណៈលទ្ធិព្រះពុទ្ធសាសនាទាំងប៉ុន្មានគឺ ធ្វើតាម ( **លំអានទំនៀមខ្មែរបូរាណ** ) . អាស្រ័យ អាចារ្យដែលធ្លាប់ធ្វើទៅចុះ ព្រោះពិធីទាំងនេះ មិនមែនជាពុទ្ធប្បញ្ញត្តិទេ គ្រាន់តែជាទំនៀមទម្លាប់របស់ជនជាតិនិមួយៗ ប្រទេសមួយៗ តាមដំបន់និយម និគមជនបទនិមួយៗប៉ុណ្ណោះ ។



www.elibraryofcambodia.org

*បានជាយើងខ្ញុំធ្វើនិតមវចនៈយ៉ាងនេះពីព្រោះ :*

ក្នុងសៀវភៅដែលយើងខ្ញុំសរសេរនេះមាន២ពិធីគឺ :

១. ពិធីតាម ( **លំអានទំនៀមខ្មែរបុរាណ** ) ជាទម្លាប់ខ្មែរមួយភាគធំ

២. ពិធីធ្វើតាមបែបពុទ្ធសាសនិកជនក៏មានមួយភាគធំ ។

សូម្បីតែតាមវិធីកម្មបែបពុទ្ធនិយមក៏មានតាមផ្លូវព្រះសូត្រខ្លះ ហើយខ្លះទៀតតាមផ្លូវព្រះវិន័យសុទ្ធផងដែរ ។

សូមលោកអ្នកអានជួយរិះគន់ ស្ថាបនា .ដើម្បីអភិវឌ្ឍន៍ស្មារតី ។

---

## ពិធីបុណ្យឆ្លងផ្សេងៗទៀត

ឆ្លងថ្កល់ ស្ពាន សាលាឆទាន ដើមពោធិ៍ ឆ្លងអណ្តូង ស្រះជាដើម ។ល។ ពិធីទាំងនេះ មុនដំបូងអាចារ្យត្រូវរៀបចំពិធីក្រុងពលីជាចាំបាច់ រួចបន្តធ្វើពិធីផ្សេង១ តាមទម្លាប់នៃបុណ្យ ។

តែចាំបាច់ព្រះសង្ឃពេលឆ្លងត្រូវសូត្រ **ពហុំនេខា** ដារឆ្លង ។

ពិធីឆ្លងនេះគឺធ្វើតាមលំអាននាងវិសាខា បានប្រគេនភេសជ្ជៈ អង្កាស ចង្ហាន់រាប់បាត្រ ប្រគេនត្រៃចីវរ សាដកទៀតផង ។

យើងបានឮគេនិយាយថា បើដាំដើមពោធិ៍មិនឆ្លងនឹងកើតជាសត្វរាជសីហ៍រកស៊ីនៅក្រោមដើមពោធិ៍នោះ បើធ្វើស្រះ អណ្តូង មិនឆ្លង កើតជាតិក្រោយគ្មានទឹកផឹក ។ល។

បើពាក្យនេះក្លាយទៅជាជំនឿនោះ



www.elibraryofcambodia.org

រឿងនេះមិនមែនកើតឡើងដោយឯកឯងនោះទេ ព្រោះបុណ្យកើតដោយ ចេតនា ៣គឺ :

១. **បុព្វចេតនា** ត្រេកអរជ្រះថ្លាមុននឹងឱ្យ

២. **មុញ្ចនចេតនា** ត្រេកអរជ្រះថ្លាក្នុងពេលកំពុងឱ្យ

៣. **អបរាបរចេតនា** ឱ្យរួចហើយត្រេកអរជ្រះថ្លាជានិច្ចត្រូវតែនឹក ។

ដូច្នេះការធ្វើបុណ្យអ្វីមួយ បុណ្យតែងសំរេចដោយចេតនា ៣ នេះស្រេចទៅហើយ ។ មិនមែនបានបុណ្យព្រោះតែឆ្លង បើមិនបានឆ្លង ថាបែរជាមិនបានបុណ្យ ថែមទាំងបាបទៀតផងនោះទេ ។ ប៉ុន្តែការធ្វើអ្វីមួយចុងក្រោយត្រូវធ្វើបុណ្យឆ្លងនោះ ព្រោះចង់បន្ថែមកុសលឱ្យរឹតតែចម្រើនឡើងជាគ្រឿងរំលឹករញ្ចោសភាវតីបង្កើននូវអនុស្សតិនោះឯង ។ ដូចពុទ្ធភាសិតថា :

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ** : បើបុគ្គលធ្វើនូវបុណ្យនោះឱ្យញយ១ គប្បីធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះថែមទៀត ព្រោះការសន្សំបុណ្យតែងនាំមកនូវសេចក្តីសុខ ។

ដូច្នេះការធ្វើបុណ្យរឿយ១ ញឹក១នេះ ដើម្បីកុំឱ្យបាបមានឱកាសមកជ្រៀតជ្រែកចិត្តយើងបាន ។ ការដែលសូត្រធម៌ **ពាហុំនេខា** ព្រោះក្នុង **ពាហុំ** បញ្ជាក់ច្បាស់អំពីមង្គល៣៨ប្រការ ទើបលោកកំណត់ឈ្មោះថា ( **មង្គលសូត្រ** ) ។

*ពិធីរៀបចំឆ្លងនេះតាមទម្លាប់អាចារ្យមាន :*

ទឹកមួយផ្តិល និង បិតទៀន៤ដើមនៅមាត់ផ្តិល សប្បុរសជនគេដាក់ប្រាក់ឬវត្ថុមានតម្លៃក្នុងផ្តិលដោយបំណងផ្សងឱ្យរួចផុតពីទុក្ខទោស ។ ព្រោះឧបមាថា

- ទឹកផ្តិលទុកជាអន្លង់ ៤ គឺ អន្លង់កាម អន្លង់ភព អន្លង់វិជ្ជា អន្លង់



www.elibraryofcambodia.org

មិច្ឆាទិដ្ឋិ ។

- ទៀន ៤ ទុកជាធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ។

*ទៀនទាំង ៤ នេះតែងតែឆេះទៅ រលត់ទៅក្នុងអន្លង់នោះឯង ។*

ពេលចប់ពិធីអាចារ្យយកទឹកផ្តិលទៅស្រោចគល់ដើមពោធិ៍ ឬ ចាក់ក្បែរមាត់ស្រះ អណ្តូង ដែលយើងឆ្លង ។ ឯបច្ច័យវត្ថុមានតំលៃក្នុងផ្តិលច្រើនតែត្រូវបានគេជូនទៅ អាចារ្យ ។ អាចារ្យលើកឧបមាថា :

- ទឹកផ្តិល គឺជា ទឹកអម្រឹត ( អមតៈ ព្រះនិព្វាន )

- ទៀន ៤ គឺអន្លង់ទាំង ៤ ( កាម ភព ទិដ្ឋិ អវិជ្ជា ) តែងជាបច្ច័យនាំឱ្យសត្វកើតស្លាប់ ស្លាប់កើត គឺឆេះទៅរកទីបំផុតគ្មាន ក្តៅសន្ធោសន្ធៅ អន្លង់ទាំងនេះនឹងត្រូវរលត់បានដោយជ្រលក់ចូលក្នុងទឹកអម្រឹត ។ មានតែទឹកអម្រឹតអមតៈនេះទើបពន្លត់ទៀនមិនឱ្យកើត ឆេះទៀតបាន ។

---

## ពិធីចំរើនព្រះជន្ម

ពិធីនេះច្រើនសិស្សគណធ្វើប្រគេនព្រះគ្រូឧបជ្ឈាយ៍ ឬ អាចារ្យ ។ល។ ឬកូនចៅធ្វើជូនមាតាបិតាតាមដែលគេមានលទ្ធភាព ។

*ទីនេះខ្ញុំជំរាបជូនទម្លាប់មួយចំនួនដែលធ្លាប់ធ្វើគឺ :*

ដំបូងរៀបចំគណៈកម្មការមួយសំរាប់ចាត់ចែងការងារទូទៅ មានភារកិច្ចគ្រប់មុខជំនាញ មានជាអាទិ៍ :

- ក្រុមរៀបចំទេសនា



www.elibraryofcambodia.org

- ក្រុមរៀបចំប្រទីបជ្វាលា
- ក្រុមចាត់ចែងភេសជ្ជៈ
- ក្រុមចាត់ចែងភត្តាហារ
- ក្រុមចាត់ចែងហិរញ្ញវត្ថុ ( ចំណូលចំណាយ )
- ក្រុមចាត់ចែងព្រះសង្ឃ
- ក្រុមអញ្ជើញភ្ញៀវ
- ក្រុមទទួលភ្ញៀវ ។ល។

ដល់កំណត់ថ្ងៃ អាចារ្យរៀបចំបួងសួងទេវតា ( ទម្លាប់ហៅក្រុងពាលី ) របៀបរៀបដូចដែលក្រុងពាលីបញ្ចុះសីមា ឬ ពិធីផ្សេងៗទៀតដែរ ។

ឯខ្លឹមសារក៏ដូចពិធីបញ្ចុះសីមាដែរ ប្លែកតែចុងខាងក្រោម :

**ភោន្តោ ទេវសង្ឃា យោ** ............................ ព្រោះតាំងពីថ្ងៃនេះ យើងខ្ញុំទាំងអស់គ្នា ................ យល់ឃើញថា ........ លោក ........ មានជន្មាយុគម្រប់ ........... វស្សាថែមទាំងមានរោគាពាធផង ( បើមានរោគទើបយើងថា ) យើងខ្ញុំទាំងអស់គ្នាមានសេចក្ដីរំភើបយ៉ាងខ្លាំងចំពោះមេត្តា ករុណារបស់លោកចំពោះយើងខ្ញុំ ( តាមដែលគុណបំណាច់ធ្លាប់មាន យើងបញ្ចូលឱ្យច្បាស់ ) ទើបប្រជុំព្រមព្រៀងគ្នាធ្វើបុណ្យចំរើនព្រះជន្មនេះឡើង ។ ឥឡូវថ្ងៃទី ... ខែ ... ឆ្នាំ ... ម៉ោង ...... ជាពេលផ្ដើមពិធីបុណ្យ យើងខ្ញុំសូមអញ្ជើញទេព្ដា ដូចរៀបរាប់ខាងលើមកជាភ្ញៀវកិត្តិយសរបស់យើង សូមទេព្ដាទាំងឡាយអនុមោទនានូវកងការកុសលរបស់យើង ហើយជួយកំចាត់បង់នូវរោគាពាធ ( បើមាន ) ឱ្យខ្ចាត់ចេញពីរូបរាងកាយរបស់លោក ............... ឱ្យបានជ្រះស្រឡះក្នុងពេលនេះ ជាកម្រិតដោយ



www.elibraryofcambodia.org

ទេវតាទិព្វនិងបុណ្យកុសលដ៏ធំបរិបូរណ៍ក្នុងពេលនេះ ។

ម្យ៉ាងទៀតទេព្ដានោះ ដែលយើងរាប់អានកុំបីមានការធ្វេសប្រហែលឱ្យសោះក្នុងកិច្ចជួយអភិបាលរក្សាការពាររារាំងឃាត់ឃាំងនូវសត្រូវ និង សេចក្ដីអន្តរាយគ្រប់ប្រការកុំឱ្យមានមកប៉ះពាល់ដល់រូបកាយលោក ............. និងកិត្តិនាមកិត្តិយសរបស់លោកឡើយ ។

សូមទេព្ដាកុំព្រងើយកន្ដើយ សូមជួយទ្រទ្រង់លោក .......... ឱ្យមានជន្មាយុយឺនយូរ បានច្រើនជាងរយវស្សា ។ ( លោកអ្នកទាំងអស់ស្រែកថា សាធុៗព្រមៗគ្នា ) ។

បន្ទាប់មកនិមន្ត ឬ អញ្ជើញលោក ........... ឡើងលើអាសនៈ ឬបុស្បុកដោយមាន កម្រាលក្រាលដើរចូល ។

បន្ទាប់មកទៀតធ្វើពិធីសូត្រ **ជយន្តោ** ប្រសិទ្ធិពរបាចផ្កាវីកំស្រោចទឹកតាមជាក់ស្ដែងនៃលទ្ធភាពកន្លែងនិមួយៗ ។ ឯពិធីផ្សេងៗ បន្តសូត្រមន្ត ទេសនាធ្វើដូចពិធីបុណ្យចម្លាតទៅ ។

---

## បុណ្យវិសាខបូជា

លោកអាចារ្យនាំ ឧបាសក ឧបាសិកា ពុទ្ធបរិស័ទ នមស្ការ ព្រះរតនត្រ័យ សុំសីល ៨ សីល ៥ តាមទម្លាប់ បន្ទាប់មកធ្វើពិធីប្រកាសវិសាខបូជា អានមួយសង្កាត់ម្ដងៗ សម្រួលតាមឃ្លាល្បះឱ្យពុទ្ធមាមកទាំងអស់ថា តាមឱ្យព្រមៗគ្នាដូចតទៅ :

**នមោ** ......... ៣ ចប់ទាំងអស់គ្នា ។



www.elibraryofcambodia.org

សម្មាសម្ពុទ្ធោ ចត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មា សម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយ គោរព ។

( ក្រាបថ្វាយបង្គំម្តង )

និយ្យានិកោ ចត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។

ព្រះធម៌ណាដែលព្រះភគវន្តមុនីអង្គនោះទ្រង់ត្រាស់សំដែង ហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះធម៌នោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

សុប្បដិបន្នោ ចត តស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម ៖

ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័កនៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃមែនពិត យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។



www.elibraryofcambodia.org

( ក្រាបថ្វាយបង្គំ១២ )

បន្ទាប់មក លោកអាចារ្យអារាធនា ព្រះសង្ឃចំរើនព្រះបរិត្តក្រោយពេលអង្គាសភេសជ្ជៈ និង ធ្វើកិច្ចខាងលើរួចហើយនោះ ។ ព្រះសង្ឃចំរើន **ពុទ្ធចក្ក** ចប់ ឧបាសក ឧបាសិកា **យំកិញ្ចិ** ឧទ្ទិសកុសលតាមធម្មតា ។

ក្រោយពីសូត្រមន្តចប់សព្វគ្រប់ ព្រះសង្ឃទាំងភិក្ខុសាមណេរនិមន្តមកជួបជុំមុខព្រះពុទ្ធរូប នមស្ការនិងសូត្រធម៌តាមដែលលោកអាចសូត្របានមួយចំនួនមាន **អនេកជាតិ ចន្ទាមិចេតិយំ យោគេហ្មរកាជី ឥច្ចេចមច្ចន្ត ចន្ទាមិពុន្ធិ** ជាដើម ។ល។ បន្ទាប់មកទៀត អាចារ្យរៀបចំពិធីទេសនា ។ ទេសនារួច ធ្វើបទរហូតទល់ភ្លឺ តាមលទ្ធភាពនៃវត្តនិមួយៗ ។

ក្នុងការធ្វើ បទនេះលោកសង្ឃ ភិក្ខុ ឬ សាមណេរក៏ធ្វើ ឧបាសក-សិកាក៏ធ្វើ ។ គឺផ្ដើមឡើងបទបជ្ជាវត្តន៍ នមស្ការទាំង ៨ បទ ( អាចសូត្របទ នមោទាំង ៨ បទនេះច្រើនសារក៏បាន គឺចប់ហើយសារដើម ) ជូនក្រុមភិក្ខុ ជូនក្រុមសាមណេរ យ៉ាងច្រើន ៥អង្គ១ក្រុម ប៉ុន្តែតិចបំផុតមាន ៤អង្គដែរ ទើបពិរោះស្តាប់ បើតិចជាង ៤ ច្រើនជាង ៥ ឡើងទៅ មិនខុស តែពុំពិរោះស្តាប់ ។ ជូនកាលក្រុម ( សំឡេងធំ ) មួយឃ្លា ហើយក្រុមសាមណេរ ( សំឡេងតូច ) មួយឃ្លាផ្លាស់ប្តូរគ្នា ដល់ចប់ក៏មាន ជូនកាលក្រុមឧបាសកតាៗ ឬ យាយៗ ឧបាសិកាក៏បាន ។ ( សូមមើលក្នុងធម្មសង្វេគដែលមានលក្ខណៈគ្រប់គ្រាន់ដូចជា : **នមោ** ៨បទ **ឋានធំ** ៨កន្លែង **ពុទ្ធប្រវត្តិ** **បារមី១០** **អដ្ឋង្គិកមគ្គ គុណមាតាបិតា ប្រុសពន្ធក គិរីមានន្ទ ពិច្ឆាពិលាប ភស្តុតាង២៤ ទង្គីមមី បណ្ដាំមហាមាយា ពាក្យចៅ យោរវាអានន្ទ ល្បើកបុត្រី ត្រៃលក្ខណ៍**



www.elibraryofcambodia.org

ចំនួញនាងកិសាគោតមី រូបក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ អនិច្ចតាធម៌ ទុក្ខតាធម៌ អនត្តាធម៌ ធម្មសាស្ត្រ សង្វេគវត្ថុ៨យ៉ាង បដិតានកថា បរាភវសូត្រ ពិក្ខាវិយោគ ស្នាមព្រះបាទ៥កន្លែង អានិសង្សស្តាប់ធម៌៥ ពុទ្ធជ័យមង្គល៨បទ ឋានធំ៧កន្លែង វិសាខបូជារបស់សម្តេចជួនណាត ធបស្ការព្រះអានន្ទ អានិសង្សសីល អកតញ្ញូរបស់សម្តេចជួនណាត សហម្បតីព្រហ្ម ច្បាប់ក្រមង៉ុយ ច្បាប់ប្រមោថ៌នប្រុសស្រី ច្បាប់គោរពមាតាបិតា ពុទ្ធប្រវត្តិរបស់អ្វីធុង ច្បាប់ចាស់តឿនក្រើនរំលឹក ទសពិធរាជធម៌១០ ប្រមាទនិងមិនប្រមាទ គារវបុគ្គល១០ជំពូក ផលានិសង្សសុចរិត បុរាណភា-សិតសំដែងអំពីក្រ៥ ការតាំងខ្លួនឯងឱ្យផុតពីទល័ក្រ កតញ្ញូតាគឺការថាអ្នកពឹងគុណ តម្លៃនៃជីវិត សុភាសិត ។



www.elibraryofcambodia.org

# បុណ្យមាឃបូជា

អាចារ្យរៀបពិធីដូចគ្នា និងពិសាខបូជាដែរ តែប្លែកត្រង់ វេរសក្ការៈ មានលក្ខណៈដូចតទៅ ៖

ថ្ងៃនេះជាតិថីពេញបូណ៌មីខែមាឃ មានព្រះចន្ទពេញវង់ ត្រូវនឹងថ្ងៃនៃសាវកសន្និបាតរបស់ព្រះសក្យមុនីអរហន្ត សម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើង។ សាវកសន្និបាតនេះប្រកបដោយអង្គ ៤ គឺ ៖

- ថ្ងៃពេញបូណ៌មី ខែមាឃព្រះចន្ទចរចូលក្នុង មាឃនក្ខត្តឫក្សនេះជាអង្គទី ១ ។

- ភិក្ខុសង្ឃចំនួន ១.២៥០ អង្គ ឥតមានអ្នកណានិមន្ត ឬណាត់ពេលគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នា ក្នុងសំណាក់ព្រះបរមសាស្តានាវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ ក្នុង មគធរដ្ឋ នៅវេលាល្ងាច ។ នេះជាអង្គទី ២ ។

- ភិក្ខុសង្ឃទាំង ១.២៥០ អង្គនោះ សុទ្ធតែជា ឯហិភិក្ខុ ទាំងអស់នេះជាអង្គទី ៣ ។

- ភិក្ខុសង្ឃទាំង ១.២៥០ អង្គនេះសុទ្ធតែជាព្រះអរហន្តខីណា ស្រពទាំងអស់នោះ ជាអង្គទី ៤ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងឱវាទ បាតិមោក្ខក្នុងទីប្រជុំនៃភិក្ខុសង្ឃនោះ ។ ការប្រជុំសាវកបែបនេះ ហៅថា ចតុរង្គសន្និបាត គឺការប្រជុំប្រកបដោយអង្គ ៤ ។ មួយទៀតកាលព្រះបរមសាស្តានៃយើង ទ្រង់មានព្រះជន្មគ្រប់ ៨០វស្សា បើគិតតាម ឈ្មោះខែនៅខ្វះ ៤ខែ បើគិតតាមចំនួនថ្ងៃនៅខ្វះ



www.elibraryofcambodia.org

តែ ៨៨ថ្ងៃទៀតនឹងគ្រប់ ៨០ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់នូវព្រះជន្មាយុសង្ខារ ថា : « ម្នាលភិក្ខុទាំងឡាយតាំងពីថ្ងៃនេះទៅ នៅខ្វះតែ ៣ខែទៀតទេ តថាគត នឹងរំលត់ខន្ធចូលកាន់ព្រះនិព្វាន » កាលកំណត់ព្រះជន្មាយុនេះនៅថ្ងៃ ១៥កើត ខែមាឃដែរ ឱយមហៅថា : ថ្ងៃទ្រង់ដាក់ព្រះជន្មាយុសង្ខារ ។

ពិធីនេះជា **អភិលក្ខិត** សម័យមួយ ( សម័យត្រូវកំណត់ ) ក៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសំរាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជាចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ជាបរម ពុទ្ធោវាទ និងព្រះអរិយសង្ឃ សាវ័ករបស់ព្រះអង្គ ។ ឥឡូវយើងទាំងអស់ គ្នា ជាពុទ្ធមាមកជនបានមកប្រជុំគ្នារៀបចំគ្រឿងសក្ការបូជា មានទៀនធូប និងផ្កាជាដើម ក្នុងទីនោះដោយមានព្រះពុទ្ធរូបសួងព្រះអង្គ គង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខនៃ យើងទាំងអស់គ្នា ។ យើងខ្ញុំសូមថ្វាយ នូវសក្ការបូជាទាំងនេះ ចំពោះព្រះសម្មា សម្ពុទ្ធ ព្រះអង្គនោះព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ រតនៈត្រៃទាំងបីដោយ សេចក្តីគោរព ។ បពិត្រព្រះសក្យមុនី បរមគ្រូព្រះអង្គជា បូជារហបុគ្គលរបស់ ទេវតា និងមនុស្សលោកឥតមាន បុគ្គលណាមួយផ្ទឹមស្មើនិងព្រះអង្គឡើយ ទោះ បីព្រះអង្គទ្រង់យាងចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយអស់កាលយូរអង្វែងទៅ ហើយ ក៏ពិតមែនប៉ុន្តែទ្រង់បានប្រតិស្ថាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏ បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានពិត ប្រាកដ ទាំងព្រះសារីរិកធាតុនិងព្រះពុទ្ធរូបសួងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះមានបុណ្យជាបរមគ្រូ ទ្រង់ព្រះមេត្តាទទួលនូវគ្រឿងសក្ការបូជារបស់



www.elibraryofcambodia.org

យើងខ្ញុំព្រះអង្គ ដើម្បីយើងខ្ញុំព្រះអង្គទទួលបានឥដ្ឋមនុញ្ញផល វិបុលសុខ និង សេចក្តីចំរើនដ៏ធំទូលាយ អស់កាលជាយូរអង្វែងទៅហោង ។

( ក្រាបថ្វាយបង្គំ ៣ ដង )

ពពីនោះ របៀបសូត្រផ្សេងៗដូចពិសាខបូជាដែរ ។



www.elibraryofcambodia.org

# ប្រពៃណីទាក់ទងនឹងមនុស្សស្លាប់ថ្មីៗ

កាលបើមានបុគ្គលស្លាប់ថ្មីៗនៅលើផ្ទះ អាចារ្យយោគីត្រូវរកទឹកមួយក្អមតូច និងថ្មមួយដុំតូច ហើយអុជធូប ៣ សរសៃយកទៅដាក់ចុងជើងបុគ្គល រួចធ្វើឧបកិច្ចការពារកុំឱ្យអសុរកាយវាចូលក្នុងរូបបុគ្គលនោះបាន ។ បើមិនដូច្នេះទេ កាលណាមានសត្វឆ្មាសម្បុរខ្មៅលោតកន្លងបុគ្គលនោះអសុរកាយនឹងចូលក្នុងរូបបុគ្គលនោះបានពុំខាន ។ បើមិនបានធ្វើដូច្នេះ ត្រូវពទ្ធ័សីមា ។ បើបានពទ្ធ័សីមាហើយ ទោះមានឆ្មាខ្មៅលោតរំលងក៏មិនមានហេតុអ្វីដែរ ។

តាមជំនឿរបស់ខ្មែរថា អសុរកាយជាពួកបីសាចតែងត្រាច់រង្គត់រកស៊ីតំរង់ ហើយជួនកាលអាចបន្លាច មនុស្សផងក៏មានទើបគេត្រូវតែ ការពារបុគ្គលដោយវិធីផ្សេងៗ ។ គេតែងប្រាប់គ្នាឱ្យធ្វើកិច្ចផ្សេងៗចំពោះបុគ្គលស្លាប់ដូច្នេះ ដើម្បីជៀសវាងអន្តរាយដូចមានរឿងមួយដំណាលថា : នៅស្រុកមួយឆ្ងាយពីទីប្រជុំជនជាភូមិសំបូរដោយព្រៃស្ងាត់មានអាកាសធាតុត្រជាក់ ។ នៅតំបន់នោះមានផ្ទះមួយជាជំរកនៃមនុស្ស ៤នាក់ គឺឪពុកម្តាយនិងកូនប្រុស ២នាក់ដែលនៅក្នុងវ័យជំទង់ ។ ឪពុកចេញទៅរកស៊ីស្រុកឆ្ងាយ យូរៗទើបវិលមកផ្ទះម្តង ។ កូនប្រុស២នាក់នៅជាមួយម្តាយ ។ ថ្ងៃមួយជាចៃដន្យអ្វីនាងម្តាយនោះមានជំងឺយ៉ាងធ្ងន់ក៏ធ្វើមរណកាលទៅ ។ ប្រជាជនដែលនៅភូមិជាមួយគ្នា ប៉ុន្តែផ្ទះគេនៅឆ្ងាយៗ នាំគ្នាមកជួយចាត់ចែងបុណ្យធ្វើក្តារមឈូសដាក់សពរួចស្រេច ដល់ល្ងាចក៏ត្រឡប់ទៅផ្ទះគេវិញ ។ ផ្ទះសពនោះក៏ត្រូវនៅត្រមោចកំព្រា មានតែកូន២នាក់ អុជភ្លើងបំភ្លឺនៅចាំសព



www.elibraryofcambodia.org

ក្តាយរង់ចាំដល់ភ្លឺ និងបានអ្នកជិតខាងមកជួយទៀត ។ ឯសពនៅក្នុងក្តារមឈូសនោះពុំទាន់បានពន្ធ័សីមា ឬ ធ្វើកិច្ចអ្វីមួយឡើយ ព្រោះពេលក៏ខើច និងទៅរកអាចារ្យក៏ពុំទាន់ ហោមួយផ្លូវកាត់ព្រៃ ហើយត្រូវនិងពេលព្រលប់ជាពេល ដែលសត្វសាហាវចេញរកស៊ីផង ។

ក្នុងរាត្រីនោះ ក្មេងទាំងពីរនាក់បងប្អូនចេះតែនាំគ្នាភ័យព្រួយ យប់កាន់តែស្ងាត់ទៅ សត្វខ្លែងស្រាក លលកខ្មោចចេះតែបញ្ចេញ សំរែកគួរឱ្យព្រឺក្បាលដែលពួកវាតែងតែត្រាច់រង្គត់រកសាកសព សត្វព្រៃជាអាហារ ។ ឯពួកអសុរកាយក៏ធ្វើដំណើរដូចនេះដែរ លុះមកប្រទះឃើញខ្មោចនៅក្នុងក្តារមឈូសដែលមិនទាន់មានសីមាការពារនៅឡើយ ក៏រំលៀកខ្លួនចូលទៅស៊ិកក្នុងរូបសពនោះ ។ ខ្មោចដែលនៅស្ងួកស្ងឹងប្រៀបបាននឹងដុំឈើនោះ ក៏ស្រាប់តែបាក់ដូចជាមានវិញ្ញាណឡើងវិញ ហើយបំរះប្រវេរប្រវារចេញពីក្តារមឈូស កុមារបងប្អូនដេកនៅជិតក្តារមឈូស ប្អូនមិនទាន់ដឹងការអ្វីច្រើនក៏ដេកលក់ទៅ នៅតែកុមារដែលជាបង ចេះតែមានការព្រួយបារម្ភ ។ លុះឮសូរខ្មោចនោះរើក្នុងក្តារមឈូស វាចេះតែលួចសំលឹងទៅរកក្តារមឈូស ។ មិនយូរប៉ុន្មានស្រាប់តែខ្មោចនោះ អើតក្បាលពីក្តារមឈូសមកក្រូក កុមារបងឃើញដូច្នោះភ័យណាស់ កន្ត្រាក់ដៃប្អូនអូសរត់ចេញពីផ្ទះ ។ ប្អូនក៏ស្ទុះទៅតាមទាំងសើងម៉ើង ។ បងនិយាយបណ្តើរ រត់បណ្តើរ ប្រាប់ប្អូនកុំឱ្យងាកក្រោយឱ្យសោះ ។ ក្មេងទាំងពីទាក់រត់ទៅ មិនយូរប៉ុន្មានខ្មោចនោះក៏លោតចុះដេញតាមពីក្រោយទៅដែរ ។ ឃើញដូច្នោះ ក្មេងទាំងពីរខំរត់សំដៅទៅវត្តព្រោះគិតឃើញថា មានតែវត្តទេដែលអាចជួយខ្លួនឱ្យផុតអំពីភ័យអន្តរាយនេះ។ ឯអសុរ



www.elibraryofcambodia.org

កាយលុះទៅតាមដល់របងវត្តឃើញសីមាវត្ត វាមិនហ៊ានចូលក៏ចេញពីរូបសាកសពនោះទៅ ។ ឯសាកសព នោះក៏រលំដួលនៅច្រងាងក្នុងទីនោះឯង ។

លុះព្រឹកឡើង ព្រះសង្ឃនិងអ្នកស្រុកដឹងរឿងហើយ ក៏ផ្អើលមកមើល ហើយនាំគ្នាលើកខ្មោចនោះទៅបូជាធ្វើកិច្ចរំងាប់ចង្រៃគ្រប់បែបយ៉ាងទៅតាមទម្លាប់ ។ ដោយខ្មោចមានហេតុអាក្រក់ចែដន្យ ដូចរឿងដំណាលនេះឯង ហើយទើបចាស់ៗបុរាណបានបង្គាប់គ្នាឱ្យរៀបធ្វើកិច្ចផ្សេងៗ និងឱ្យព័ទ្ធសីមាជាការចាំបាច់ ដើម្បីការពារទុកជាមុន ។ របៀបនេះក៏បានជាប់ជាទំនៀមទម្លាប់រហូតមក ។

## ប្រវត្តិនាក់ពងនឹងទំនៀមទម្លាប់ដាក់ខ្មោច បែរក្បាលទៅទិសខាងលិច

រឿងនេះគេប្រកាន់តៗគ្នាមក តាំងពីកាលព្រះឥសូរកោរជុកឱ្យព្រះពិឃ្នេស ជាបុត្រ ដូចមានដំណាលក្នុងសាសនាព្រាហ្មថា ព្រះឥសូររៀបចំកោរជុក ព្រះពិឃ្នេស តែភ្លេចអញ្ជើញព្រះអង្គារ ។ ព្រះអង្គារខ្ញាល់ក៏បណ្តាលឱ្យកាំបិតកោរទៅកាត់យកក្បាលព្រះពិឃ្នេសបោះចោលទៅក្នុងមហាសមុទ្រ ។ ព្រះឥសូរក៏ប្រើព្រះវិស្សកម្មឱ្យចុះទៅរកក្បាលមនុស្ស ឬតិរច្ឆានណាដែលដេកដាក់ក្បាលទៅទិសខាងលិច ។ ព្រះពិស្ណុការទៅរកមើល ឃើញតែក្បាលដំរីពីរដេកបែរក្បាលទៅខាងលិច ក៏កាត់ក្បាលដំរីមួយទៅថ្វាយព្រះឥសូរៗក៏តភ្ជាប់ឱ្យព្រះពិឃ្នេស ទើបព្រះពិឃ្នេសមានក្បាលជាដំរី ។ ព្រោះហេតុនោះទើបមនុស្សបុរាណប្រកាន់ជឿថា ទិសខាងលិចជាទិសអពមង្គល បើកាលណាមានមនុស្ស ស្លាប់ទៅគេដាក់ឱ្យបែរក្បាលទៅទិសខាងលិច ហើយក៏ដាក់ជាប់ ជាទំនៀមរហូតមក ។



www.elibraryofcambodia.org

# ប្រវត្តិទាក់ទងនិងទំនៀមដាក់ប្រាក់កាក់

# ក្នុងមាត់បុគ្គលស្លាប់

មានរឿងបុរាណដំណាលត១គ្នាមកថា : មានបុរសម្នាក់នៅជាមួយប្រពន្ធ តាំងពីក្មេងដល់ចាស់ ខំរកស៊ីធ្វើការបានសល់មាសមួយបាទតែគ្មានកូនសោះ ។ ប្ដីប្រពន្ធនេះបានផ្ដាំគ្នាទៅវិញទៅមកថា (បើអ្នកណាស្លាប់មុនត្រូវយកមាសនេះដាក់ក្នុងមាត់អ្នកនោះ) ។ ចំណេរតមកមិនយូរប៉ុន្មាប្ដីស្លាប់ទៅប្រពន្ធក៏យកមាសដាក់ក្នុងមាត់ខ្មោចប្ដី ហើយយកខ្មោចប្ដីទៅធ្វើបុណ្យបូជា ។ ខ្មោចត្រូវភ្លើងឆេះអស់ ឯមាសវិញត្រូវភ្លើងឆេះរលាយនៅសល់តែពាស្លឹង ។ សម័យមួយព្រះមហាក្សត្រព្រះអង្គលោកមានចិត្តលោភគ្របសង្កត់ក៏ចេញព្រះរាជអាជ្ញាឱ្យរឹរយកមាសក្នុងមួយផ្ទះចំនួនមួយបាទជាកំហិត ។ យាយប្រពន្ធរបស់ខ្មោចតានោះ ភ័យក៏យកមាសពាស្លឹង ដែលគាត់រើសទុកនោះទៅថ្វាយព្រះមហាក្សត្រ ហើយក្រាបទូលថា "ក្រាបទូលព្រះករុណា !មាសនេះពីដើមនេះពេញមួយបាទតែខ្ញុំម្ចាស់យកទៅដាក់ក្នុងមាត់ប្ដី ពេលដែលស្លាប់តែប្ដីខ្ញុំម្ចាស់យកទៅពុំបាន ក៏ត្រូវភ្លើងឆេះអស់ខ្លះទៅ នៅសល់តែប៉ុណ្ណេះសូមព្រះករុណាមេត្តាដល់សត្វទាល់ក្រផង, ខ្ញុំព្រះអង្គទាល់មធ្យោបាយនឹងទៅរកមាសឯណា ឱ្យគ្រប់ចំនួនថ្វាយព្រះអង្គពុំបានឡើយ" ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ក៏កើតធម្មសង្វេគស្លុតព្រះទ័យ ទើបទ្រង់ប្រកាសឱ្យលើកលែងការរឹរយកមាសអំពីបណ្ដារាស្ត្រតទៅទៀត ។

អាស្រ័យរឿងនេះ ទើបបណ្ដារាស្ត្រទាំងអស់យល់ថា ប្រាក់ ឬ មាសដែលបង់ក្នុងមាត់ខ្មោចមានអានុភាពទៅលើទឹកចិត្តមនុស្សណាស់ សូម្បីព្រះ



www.elibraryofcambodia.org

មហាក្សត្រក៏ចុះចាញ់អានុភាពនេះដែរ ។ ម្យ៉ាងទៀតអានុភាពប្រាក់ឬមាស ដែលរបស់ក្នុងមាត់ខ្មោច ជាវត្ថុស័ក្តិ អាចជួយរំដោះគ្រោះថ្នាក់ក្នុងពេលមានអាសន្នបាន ។

ប៉ុន្តែអ្នកប្រាជ្ញពីបុរាណ ដែលឱ្យយកមាស ឬ ប្រាក់ដាក់ក្នុងមាត់ខ្មោច គឺដើម្បីជាប្រស្នាឱ្យពិចារណាថា សម្បត្តិទាំងអស់យើងអាចយកដាក់នឹងខ្លួនតែក្នុងវេលាមានជីវិត កាលបើស្លាប់ហើយយើងមិនអាចយកទៅបានទេ ។ រឿងនេះឯងបានជាជាប់ជាទំនៀមទម្លាប់រហូតដល់សព្វថ្ងៃនេះ ។

## ប្រវត្តិដាក់ធូបនិងទំនៀមដាក់ផ្កា និង ទៀនធូបក្នុងដៃ បុគ្គលស្លាប់

មានរឿងតំណាលថា ៖ មានភិក្ខុមួយរូបមានឈ្មោះមិនប្រាកដ ។ ញោមប្រុសរបស់លោកជាព្រានព្រៃសម្លាប់សត្វច្រើនណាស់ តាំងពីក្មេងដល់ចាស់ ។ លុះវេលាជិតនិងស្លាប់ គាត់ភ្លឹកស្មារតីទៅឃើញសត្វដែលខ្លួនបានសម្លាប់ ។ ដោយកុសលចិត្តក៏ស្រែកប្រាប់ ឱ្យភិក្ខុជាកូនជួយ ។ ភិក្ខុជាកូនថា ៖ (ញោមមានបាបកម្មច្រើនបានជាភ្លឹកទៅឃើញតែសត្វធាតុដូច្នេះ) ទើបឱ្យមនុស្សរកផ្កា ទៀន ធូប យកមកដាក់ក្នុងដៃញោមប្រុស រួចប្រាប់ថា (ចូរញោមខំសំឡឹងមើលផ្កា ទៀនធូប ជាគ្រឿងបូជាព្រះរតនត្រ័យនេះឱ្យជាប់) ញោមប្រុសនៃភិក្ខុនោះ កើតសទ្ធាជ្រះថ្លាមានចិត្តកុសលក៏ធ្វើតាមពាក្យកូន ។ លុះដល់ស្លាប់ទៅក៏ទៅកើតនៅនាស្ថានសួគ៌ ។ ព្រោះហេតុនោះ បានជាមនុស្សជាន់ក្រោយធ្វើតាមត។គ្នាមកដោយប្រាថ្នាឱ្យអ្នកជំងឺយកគុណព្រះរតនត្រ័យជាទីពឹង ។ ម្លោះហើយរឿងនេះ ក៏ជាប់ជាទំនៀម



www.elibraryofcambodia.org

ទម្លាប់រហូតមក ។

# ប្រវត្តិឆាក់ឆងនឹងលោកអភិធម្ម និងលោកមាតិកា នៅពេលដង្ហែសព

មានរឿងនិទានថា ក្នុងអតីតសម័យព្រេងនាយ មានព្រះរាជាមួយអង្គ ទ្រង់សោយរាជ្យនៅនគរ ណោងស្មោ ( ស្យាមប្រទេស ) ។ ព្រះរាជាអង្គនេះ ទ្រង់មានព្រះ រាជហឫទ័យជ្រះថ្លានឹងព្រះពុទ្ធសាសនាយ៉ាងក្រៃលែង តែងធ្វើ បុណ្យទានជាអចិន្ត្រៃយ៍ហើយទ្រង់មានព្រះទ័យរាប់អានស្និទ្ធស្នាល នឹងព្រះ សង្ឃដែលគង់នៅវត្តមួយក្បែរព្រះបរមរាជវាំងណាស់ ទ្រង់តែងផ្គត់ផ្គង់ព្រះ សង្ឃដោយខាទនីយាហាររាល់ថ្ងៃពុំដែលខាន ។ លុះកាលក្រោយមក ព្រះ រាជាអង្គនេះទ្រង់ប្រឈួនយ៉ាងធ្ងន់ ពេទ្យហ្លួងនានា ដែលអញ្ជើញមកព្យាបាល ជម្ងឺព្រះអង្គក៏ពុំអាចរកថ្នាំណាមកទ្រទ្រង់ជីវិតព្រះអង្គបាន ទ្រង់ក៏សោយទី វង្គតទៅ ។ នាម៉ឺនសព្វមុខមន្ត្រី ក៏ជំនុំគ្នានឹងរៀបចំដង្ហែសពនោះឱ្យសម តាមឋានៈព្រះអង្គ ។ និយាយអំពីភិក្ខុ ៥ អង្គដែលព្រះរាជាទ្រង់តែងតែ ប្រគេននូវចង្ហាន់ជានិច្ចកាល នោះក៏ប្រជុំប្រឹក្សាថា ( ព្រះរាជាអង្គនេះកាល ទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គតែងតែផ្គត់ផ្គង់រូបយើងទាំង ៥ នេះ ខ្លាំងណាស់ ឥឡូវនេះព្រះអង្គចូលទីវង្គតហើយតើយើងរាល់គ្នាត្រូវធ្វើកិច្ច ដូចម្តេច ដើម្បីជាសក្ខីភាពនៃការតបស្នងសងគុណព្រះអង្គនៅពេលដង្ហែព្រះ សពចេញទៅប្រទក្សិណទីក្រុងដោយយើងទាំង ៥ រូបជាអ្នកធម៌ស្រាប់គួរនិមន្ត លោកគ្រូចៅអធិការឱ្យគង់នៅមុខព្រះសព ហើយចំរើនធម៌ **អភិធម្មមា-តិកា** ឯ ៤ រូបទៀតគួរនៅគង់អមព្រះសពហើយចំរើន **សុត្តន្តមាតិកា**



www.elibraryofcambodia.org

ទៅចុះ ។ គិតគ្នាស្រេចហើយលុះដល់ថ្ងៃកំណត់ដង្ហែព្រះសព ព្រះសង្ឃទាំង ៤ អង្គ ក៏នាំគ្នាចូលទៅសុំពួកនាម៉ឺនចាត់ការបុណ្យ ដើម្បីឱ្យបានទៅអង្គុយហែតាមសេចក្ដីប្រឹក្សាគ្នាមកនោះ ។ ពួកមន្ត្រីចាត់ការបុណ្យក៏យល់ព្រមតាមការសុំរបស់ព្រះសង្ឃ ៥ អង្គ ។ ហើយភាវនាចមិរហូតដល់កន្លែងបូជាសព ។

តាមរឿងដូចបានពោលមកខាងលើនេះ ទើបកម្មវិធីបុណ្យខ្មោចមានលោកអភិធម្ម ១ អង្គនិងលោកមាតិកា ៤អង្គជាប់ជាតំណរហូតមក ។

## ប្រវត្តិនាក់ឆនឹងឆៀនភាណ្ឌនៅពេលមានមនុស្សស្លាប់

អតីតកាល មានបុរសម្នាក់ជាមនុស្សត្រឹមត្រូវណាស់ បើទៅកាន់ទីជំនុំចំណោមឯណា គេតែងរាប់រកទុកជាមនុស្សមានប្រាជ្ញាជាអ្នកដឹងខុសត្រូវ ។ អ្នកនៅភូមិផងរបងជាមួយ បើមានការអ្វីធំដុំតែងអញ្ជើញបុរសនោះមកជាប្រធានដើម្បីសួរជាយោបល់ឱ្យជួយអារកាត់រឿងដែលជាប់ជំពាក់ស្មុគស្មាញ ។

ថ្ងៃមួយក្នុងរដូវប្រាំង មាណពនោះបបួលបុរសពីរនាក់ទៀតដែលនៅផ្ទះក្បែរគ្នា ទៅរកឃ្មុំយកក្រមួននិងទឹកមកលក់ដើម្បីបំពេញសេចក្ដីខ្វះខាតក្នុងគ្រួសារ ។ បុរសទាំងពីរនាក់នោះក៏ស្រុះស្រួល សុខចិត្តទៅជាមួយគ្នា តែបណ្ដាអ្នកទាំងពីរនាក់នោះ អ្នកមួយជាមនុស្សចេះស្ដាប់បង្គាប់ ឯអ្នកមួយទៀតរបឹងរឹងរូសមិនសូវចេះស្ដាប់ចេះត្រង់ត្រាប់ពាក្យប្រៀនប្រដៅទេ ។

លុះដើរដល់ព្រៃ ឃើញខ្ទមអ្នកតាមួយដែលពួកធ្វើរព្រៃតែងបូជាដើម្បីសុំបើកព្រៃរួចទើបចូលទៅ ។ មកដល់ជិតកន្លែងអ្នកតានោះ ទើបអ្នកទាំង ៣ នាក់ នាំគ្នាធ្វើជំរកឈប់សំរាកបន្តិចសិនយកកម្លាំង នឹងដើរទៅមុខ



www.elibraryofcambodia.org

ទៀត ។ ក្នុងថ្ងៃនោះគេរកបានឃ្មុំមួយសំបុកមានចំនួន ១២ត់លីង ហើយត្រលប់មកជំរកវិញ នាំគ្នាដាំបាយដុតត្រីបរិភោគ ។ តែមុនបរិភោគគេចាប់បាយនិងត្រីខ្លះដាក់លើស្លឹកឈើ ថ្វាយអ្នកតាសុំសេចក្ដីសុខសប្បាយ ទឹងសុំឱ្យទៅរកឃ្មុំ បានប្រទះដូចក្ដីប្រាថ្នា ។ ឯបុរសម្នាក់ទៀតជាអ្នករឹងរូស នោះឃើញពីរនាក់ សែនអ្នកតាក៏ទឹកខ្នាញ់ក្នុងចិត្តតែមិនចេញស្ដី ។ លុះព្រឹកឡើងមុននឹងចេញទៅរកឃ្មុំទៀត គេនាំគ្នាដាំបាយស៊ី ហើយចាប់បាយបេះត្រីដាក់ថ្វាយអ្នកតាដូចថ្ងៃមុនទៀត ។ បុរសរឹងរូសទើសចិត្តណាស់ទ្រាំអត់ពុំបានក៏និយាយតំរោះថា (មិនដឹងជាថ្វាយស្អី ក៏ថ្វាយម្ល៉េះទេ ! ម្ហូបអាហារតិចផង យកទៅដាក់ចោលទៀត តើដាក់ឱ្យអាណាស៊ី !) ថាហើយក៏ងើបដើរទៅយកបាយរុកបញ្ចុកមាត់អ្នកតា ហើយនិយាយបែបចង់បញ្ឆោះឱ្យអ្នកដែលដាក់ថ្វាយនោះផងថា (ហ៎ ! ស៊ីទៅអ្នកតា ! ពីមុនថាគេមិនដាក់ដល់មាត់ ឥឡូវអញដាក់ដល់មាត់ហើយម្ដេចក៏មិនស៊ីទៅ ឃើញតែទុកចោលឱ្យស្រមោចរោម ម្ដងនេះតែមិនស៊ីឱ្យអញឃើញផងទេ លើកក្រោយលែងឱ្យទៀតហើយ) ។ អ្នកទាំងពីរទៀតឃើញបុរសនោះធ្វើមិនគប្បីក៏នៅស្ងៀម រួចបបួលគ្នាចេញដំណើរទៅ ។ ក្នុងថ្ងៃនោះគ្មានរកបានឃ្មុំមួយសំបុកសោះ ព្រោះបុរសរឹងរូសនោះ រវល់តែចុកពោះរមួលខ្លួនដើរមិនរួចទាល់តែសែងរហូតដល់ជំរកវិញ ។ មកដល់ហើយនាំគ្នាធ្វើម្ដេច ក៏ជំងឺនោះមិនស្រាកស្រាន្តឡើយ ។ លុះដល់កម្លាំងកាន់តែតិចទៅ បុរសឈឺនោះនិយាយនឹងសំឡាញ់ទាំងពីរថា : « ចូរឯងចែកក្រមួនមួយភាគផង ត្បិតខ្ញុំក៏បានទៅរកជាមួយដែរ » ។



www.elibraryofcambodia.org

បុរសពីរនាក់ឆ្លើយថា « ឯងចង់បានក្រមួនយកមកធ្វើអ្វី បើឯងជិតស្លាប់ទៅហើយយ៉ាងនេះ » ។ បុរសឈឺនោះឆ្លើយវិញថា ខ្ញុំយកទៅបានឱ្យតែឯងចែកមកឆាប់ឡើង បើឯងមិនឱ្យខ្ញុំទេ តើខ្ញុំបានអ្វីបំភ្លឺផ្លូវចេញពីព្រៃនេះរួច ។ លឺដូច្នោះ បុរសសំឡាញ់ពីរនាក់ ក៏នាំគ្នាថ្លឹងក្រមួនចែកជាបីភាគស្មើគ្នា ហើយយកស្លឹកឫស្សីងាប់ប្រវែងបង្គុយលលក ធ្វើជាប្រឆេះ ហើយយកក្រមួនមួយចំនែកទំងន់ប្រហែលជា ៤តំលឹងលៃជា ៤ភាគ យក៣ភាគ លញ់ធ្វើទៀនគោល ។ ក្រមួនសល់មួយភាគទៀត គេយកស្លឹកត្រែងស្ងួតមកធ្វើជាប្រឆេះលញ់ទៀនរាយ ៤ទៀន ហើយកាប់មែកឈើដាក់តងលើមាត់ត្រឡោក ។ លុះអុជទៀនរួច ក៏អោននិយាយដាក់ត្រចៀកបុរសដែលឈឺនោះថា « នែសំឡាញ់ ចំណែកក្រមួនរបស់ឯង យើងធ្វើជាទៀនអុជឱ្យឯង ចូលឯងយកទៅតាមខ្លួនគ្រាន់បានបំភ្លឺផ្លូវចេញពីព្រៃនេះទៅចុះ » បុរសឈឺទទួលថា អឺ ! ហើយក៏ដាច់ខ្យល់ស្លាប់ទៅ ។

បុរសជាមិត្តក៏នាំគ្នារកអុសភ្លើងមកដុតខ្មោចនោះ ហើយនាំគ្នាវេចខ្ចប់ធាតុយកមកឱ្យប្រពន្ធ ដោយប្រាប់តាមដំណើរតាំងពីរឿងឈឺ ដល់រឿងចែកក្រមួន ។ តែមកដល់ត្រង់នេះប្រពន្ធនៃសពមិនយល់ព្រមដោយអាងថា : ប្ដីខ្លួនស្លាប់ទៅហើយតើអាចយកក្រមួនទៅផងម្ដេចបាន ? បុរសសំ-ឡាញ់ពីរនាក់ពន្យល់យ៉ាងដូចម្ដេចនាងនោះក៏នៅតែមិនព្រម ទទូចយកតែចំណែក ក្រមួនតាំងពីថ្ងៃរហូតដល់យប់ ហើយចូលទៅដេករៀង១ខ្លួនទៅ ។ និយាយពីប្រពន្ធរបស់បុរសស្លាប់ លុះដេកលក់ទៅ ក៏យល់សប្ដិឃើញប្ដីកាន់ទៀនដើរចូលមក ។ នាងក៏ស្រែកទាំងអរផងថា " អ្នកអើយគេមកប្រាប់ខ្ញុំ



www.elibraryofcambodia.org

ថា អ្នកឯងស្លាប់ទៅហើយ ថែមទាំងបានចែកក្រមួនទៅអ្នកផងឥឡូវមានស្លាប់ឯណា ? អ្នកមកវិញហើយតើ ! " ឯខ្មោចនោះឆ្លើយមកវិញថា " បងស្លាប់មែន ហើយបងបានក្រមួនដែលគេចែកឱ្យនោះ ធ្វើជាទៀនអុជរកផ្លូវចេញមកផ្ទះ កុំអីមិនដឹងជាវង្វេងទៅណាទេ ! ។ ប្រពន្ធឮ ដូច្នេះក៏ស្រវាអោបប្ដីភ្ញាក់ទាំងខ្លួនឡើង ទើបដឹងច្បាស់ថាខ្លួនយល់សប្ដិ ។ លុះព្រឹកឡើងទៅប្រាប់បុរសទាំងពីរតាមដំណើរយល់សប្ដិ ហើយក៏ឈប់ប្រកាន់ឈ្លោះទៀតទៅ ។

ដោយហេតុមានរឿងដូច្នេះហើយ ទើបបុរាណប្រកាន់ជឿថា បើមនុស្សណាជិតស្លាប់ គេត្រូវតែធ្វើទៀនកាល្ប អុជដើម្បីឱ្យខ្មោចបានភ្លឺសំរាប់បំភ្លឺផ្លូវទៅរកឋានសុខ ។



www.elibraryofcambodia.org

# បុណ្យចូលឆ្នាំខ្មែរ ពូនភ្នំខ្សាច់ ស្រង់ព្រះ

ពេលវេលាចូលឆ្នាំខ្មែរ :

កាលដើមឡើយខ្មែរយើងប្រារព្ធធ្វើបុណ្យចូលឆ្នាំក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះ ជាខែដើមឆ្នាំ ។ នាសម័យព្រេងនាយ ឆ្នាំនិមួយៗចែកជា ៣ រដូវ តាមធម្មជាតិ ហេមន្តរដូវ គិម្ហរដូវ និងវស្សានរដូវ ។ បុរាណាចារ្យលោកគិតថា ហេមន្តរដូវជារដូវត្រជាក់ ត្រូវចាត់ទុកជារដូវដើមឆ្នាំ ប្រៀបបាននិងពេលព្រឹក ដែលផុតពីរាត្រីគឺជាដើមថ្ងៃ ។ គិម្ហរដូវ ជារដូវក្តៅត្រូវសន្មតទុកជាកណ្តាលឆ្នាំ ប្រៀបដូចជាពេលថ្ងៃត្រង់ ។ វស្សានរដូវជារដូវដែលមេឃមីរងងឹតមានភ្លៀងផ្គរ ត្រូវទុកជាចុងឆ្នាំ ប្រៀបបាននឹងពេលព្រលប់ ។

ចំណេរកាលក្រោយមក គ្រាដែលបុព្វបុរសខ្មែរយើងអនុលោម ប្រើចុល្លសករាជ ជាសំខាន់នោះ ( មិនដឹងជាប្រើនៅក្នុងរជ្ជកាល នៃព្រះរាជអង្គណាទេ ) ទើបការចូលឆ្នាំថ្មីមានការកែប្រែប្រួលហើយ កំណត់យកខែចែត្រជាដើមឆ្នាំវិញ ។ ឯថ្ងៃចូលឆ្នាំ តែងប្រព្រឹត្តទៅមិនមុនថ្ងៃ ៤កើត ខែចែត្រ និង មិនក្រោយថ្ងៃ ៤ កើត ខែពិសាខ ព្រោះបុព្វបុរសយើងយល់ថា នៅខែមិគសិរនេះប្រជាកសិករខ្មែរយើងរវល់មមាញឹកក្នុងរបរកសិកម្ម មានស្រែចំការជាដើម ទើបលោកកំណត់ពេលចូលឆ្នាំមក ធ្វើនៅខែចែត្រវិញ ដោយហេតុខែចែត្រកិច្ចការច្រូតកាត់ បោកបែនបានចប់សព្វគ្រប់ ហើយប្រជាពលរដ្ឋខ្មែរយើងទំនេរមានឱកាសធ្វើបុណ្យទានកំសាន្តសប្បាយតាមប្រាថ្នា ។ ការកំណត់នេះ ក៏ជាប់ជាប្រពៃណីរហូតដល់សព្វថ្ងៃ ។

និដ្ឋភាពបុណ្យចូលឆ្នាំខ្មែរ :



www.elibraryofcambodia.org

បុណ្យចូលឆ្នាំខ្មែរជាព្រឹត្តិការណ៍យ៉ាងធំក្នុងទឹកចិត្ត និង ជីវភាពខ្មែរ ។ មុនពេលចូលឆ្នាំថ្មីមកដល់គេនាំគ្នារៀបចំបោសសំអាត តុបតែងផ្ទះសម្បែង សំអាតទីធ្លាវត្តអារាម ផ្លូវថ្នល់ ចេតិយ រមណីយដ្ឋាន សង់រានទេវតា បុកអង្ករ រកអុស ដងទឹក ត្រៀមសំលៀកបំពាក់ថ្មីៗ ។ល។ ឱ្យហើយស្រេច ។ ពេលចូលឆ្នាំជាពេលជម្រះឧបទ្រពចង្រៃនៃឆ្នាំចាស់ឱ្យជ្រះស្រឡះ ដើម្បីទទួលឆ្នាំថ្មី ទេវតាថ្មីក្នុងក្ដីសោមនស្សក្សេមក្សាន្ត និង សុភមង្គល ។

ឆ្នាំថ្មីមកដល់ស្ងួស្ងាររគាំង សំលេងធមិពរជ័យលាន់ឮរន្ទឺអឹងកងចេញពីវត្តអារាម និង ពីភូមិករប្រជាជន ( ព្រោះកន្លែងខ្លះវត្តឆ្ងាយគេរៀបចំតុបតែងកន្លែងមួយក្នុងភូមិរបស់គេ រួចនិមន្តព្រះសង្ឃមក ) ភ្លើងទៀនឆេះព្រោងព្រាត ផ្សែងធូបហុយ ចេញពីគ្រប់រានទេវតា តាមដងផ្លូវមុខផ្ទះសំបែងវត្តអារាម ។ ចាស់ទុំក្រមុំ កំលោះ ក្មេងក្មាងតូចធំ ប្រដាប់ដោយសំលៀកបំពាក់ស្អាតៗ ចេញមកទទួលទេវតាឆ្នាំថ្មី ។ ម្នាក់ៗមានទឹកមុខរីករាយស្រស់ស្រាយ រំភើបក្រៃលែង ។ ក្រមុំ កំលោះ ក្មេងៗសប្បាយ ក្អាកក្អាយជាងគេព្រោះជា ឱកាសដ៏ពិសេសបំផុតសម្រាប់ពួកគេចូលឆ្នាំកំសាន្ត លេងល្បែងប្រជាប្រិយជាមួយគ្នាដោយគ្មានចាស់ទុំណាឃាត់ឃាំងអ្វីឡើយ ។

- ពេលព្រលប់គេនាំគ្នាទៅស្ដាប់ធមិអាថ៌ ដើម្បីផ្ដុំកុសលសម្រាប់ជីវិតជាតិនេះ និង ជាតិខាងមុខ ។ រួចក៏មកប្រមូលផ្ដុំគ្នា លេងល្បែងប្រជាប្រិយផ្សេងៗ តាមចំណង់ ។ គេនាំគ្នាលេងល្បែង ចាប់កូនខ្លែង លាក់កន្សែង ក្រុងមាន់ ទាញព្រាត់ ទាត់ដូង ឬ ច្រៀងចំរៀងប្រពៃណី ឬ លេងស្ដេចចង់ ឈូងអង្គុញ លោតអន្ទាក់ រាំវង់ ។ល។ យ៉ាងសប្បាយរីករាយ ។ សប្បាយយ៉ាង



www.elibraryofcambodia.org

ដូចនោះមែន តែពេពុំភ្លេចត្រៀមរៀបចំចង្ហាន់ ទៅប្រគេនព្រះសង្ឃ បង្សុកូល ឧទ្ទិសកុសលជូនបុព្វការីជន ញាតិសន្ដាន ដែលបានចែកស្ថានទៅកាន់បរលោក ហើយនោះទេ ។ គេនាំគ្នាជញ្ជូនដីដាក់វត្តពូនភ្នំខ្សាច់ រែកទឹកស្រង់ព្រះសង្ឃ និង ចាស់ព្រឹទ្ធាចារ្យ ។ ពេលត្រលប់ដល់ផ្ទះវិញគេអញ្ជើញមាតាបិតា ចាស់ទុំ មក ផ្ងូតទឹកជូនសំលៀកបំពាក់ថ្មីៗ នំចំណីដើម្បីជាកិច្ចតបស្នងសងគុណចំពោះបុព្វការី របស់គេជាទម្លាប់ ។ ដល់ថ្ងៃឆ្លងបុណ្យពិនិត្យឃើញតាមក្រោមម្លប់ឈើធំៗ មានក្រ សាលល្បែង ប្រជាប្រិយផ្សេងៗ តាមចំណង់ចំណូលចិត្ត ។ គេនាំគ្នាទៅទស្សនា កំសាន្តប្រាសាទបូរាណ រមណីយដ្ឋាន គោរពបូជាវត្ថុសក្តិសិទ្ធ ភ្ជាប់បរិយាកាសរីក រាយនេះទៅ នឹង បរិយាកាសសម័យ ព្រេងនាយដ៏រុងរឿង ។ តាមតំបន់ខ្លះពេល ចូលឆ្នាំម្តងៗ គេមិនមែនសប្បាយតែរយៈពេល ៣ ថ្ងៃប៉ុណ្ណោះទេ គេចាប់លេង សប្បាយរបៀបនេះមុន និង ក្រោយប៉ុន្មានថ្ងៃចូលឆ្នាំទៀតផង ។ គេនាំគ្នាធ្វើ បុណ្យកុសល ឱ្យអស់ចិត្ត សប្បាយឱ្យអស់ចិត្ត ដើម្បីអបអរសាទរចំពោះជីវិតថ្មី របស់គេ ដែលបានហែលឆ្លងកាត់ឧបសគ្គ ទទួលជោគជ័យក្នុងរយៈពេល ឆ្នាំចាស់ កន្លងទៅ និង ដើម្បីត្រៀមចាំបំពេញភារកិច្ចថ្មី ត្រៀមចាំរដូវដកស្ទូង ត្រៀមចាំ ទឹកភ្លៀងដែល នឹង បង្អុរចុះនាដើមវស្សានរដូវនៃឆ្នាំថ្មីដ៏ខ្លីខាងមុខ ។

## ជំនឿ និង ពិធីពូនភ្នំខ្សាច់ស្រង់ព្រះ :

១. **ជំនឿទេវតាឆ្នាំថ្មី** : ក្នុងចង្រ្កាន្តសូត្រនិទានថា ក្នុងដើមភទ្ទកប្ប នេះមានបុរសម្នាក់ ឈ្មោះធម្មបាលជាអ្នកប្រាជ្ញចេះចប់ត្រៃវេទ ព្រមទាំងចេះភា សាបក្សីសត្វផង ។ ធម្មបាលតែងសំដែងមង្គលដល់មនុស្សផងទាំងពួង ។ លុះ កបិលមហាព្រហ្ម ( សម័យនោះគេគោរពបូជាមហាព្រហ្ម ) ជ្រាបថា ធម្មបាល



www.elibraryofcambodia.org

កុមារជាអ្នកប្រាជ្ញក៏មកសួរប្រស្នា ៣ខ ហើយសន្យាថា : ប្រសិនបើធម្មបាលដោះស្រាយប្រស្នារួច កបិលមហាព្រហ្ម និង កាត់ក្បាលខ្លួនបូជាធម្មបាល តែបើធម្មបាលដោះស្រាយប្រស្នា មិនរួចទេ ត្រូវកាត់ក្បាលបូជាមហាព្រហ្មវិញ ។ ធម្មបាលសុំបង្អង់ ៧ថ្ងៃសិន ដើម្បីគិតប្រស្នា ប៉ុន្តែ ៦ថ្ងៃកន្លងផុតទៅហើយ នៅតែគិតមិនឃើញសោះ ធម្មបាលក៏ភៀសខ្លួនទៅពួននៅក្រោម ដើមត្នោតមួយគូ ដែលជាលំនៅនៃសត្វឥន្ទ្រី ។ ជាភព្វសំណាងល្អ យប់នោះធម្មបាលក៏បាន ឮ សត្វឥន្ទ្រីញី ឈ្មោលនិយាយគ្នាថា :

- ញី : ព្រឹកនេះយើងបានអាហារពីណាស៊ី ?

- ឈ្មោល : យើងនឹងបានស៊ីសាច់ធម្មបាល ដែលត្រូវកបិលមហាព្រហ្មសម្លាប់ព្រោះដោះប្រស្នាមិនរួច ។

- ញី : ប្រស្នានោះដូចម្តេច ?

- ឈ្មោល : (ខ១) វេលាព្រឹក សិរីស្ថិតនៅទីណា ? ត្រូវឆ្លើយថានៅមុខ ហេតុនេះមនុស្សទាំងឡាយត្រូវយកទឹកលាងមុខ ( ខ២ ) ថ្ងៃត្រង់សិរីស្ថិតនៅត្រង់ណា ? ត្រូវឆ្លើយថាស្ថិតនៅទ្រូង ហេតុនេះមនុស្សទាំងឡាយត្រូវយកទឹកលាងទ្រូង ។ (ខ៣) វេលាល្ងាចសិរីស្ថិត នៅត្រង់ណា ? ត្រូវឆ្លើយថានៅជើង ហេតុនេះមនុស្សទាំងឡាយ ទើបយកទឹកលាងជើង ។

ពាក្យពេចន៍ទាំងប៉ុន្មានរបស់ឥន្ទ្រី ក៏បានជាពន្លឺដល់ធម្មបាលដោះស្រាយប្រស្នាកបិលមហាព្រហ្ម រួចជៀសផុតពីក្តីមរណៈ ។ កបិលមហាព្រហ្មសុខចិត្តចុះចាញ់ព្រមកាត់ក្បាលបូជាធម្មបាល ។ មុននឹងកាត់ក្បាលកបិលមហាព្រហ្មហៅទេពធីតា ៧អង្គ ដែលជាបុត្រីរបស់ខ្លួន ឱ្យយកពានមកទ្រក្បាល (ព្រោះបើដាក់



www.elibraryofcambodia.org

ក្បាលលើផែនដី ផែនដីនឹងកើតជាភ្លើងឆេះលោកធាតុ . បើបោះទៅលើអាកាសមេឃរាំងស្ងួត . បើបោះចោលទៅក្នុងសមុទ្រទឹកនឹងរីងស្ងួតអស់ ) រួចហើយក៏កាត់ក្បាលឱ្យនាង **ទុង្សា** ជាកូនច្បង ។ នាង **ទុង្សា** យកក្បាលកបិលមហាព្រហ្ម ប្រទក្សិណភ្នំព្រះសុមេរុ អស់ ៦០ នាទី ទើបអញ្ជើញក្បាលនោះទៅ ប្រតិស្ឋានទុកក្នុងមណ្ឌបភ្នំកៃលាស ។ លុះដល់គម្រប់មួយឆ្នាំ សង្ក្រាន្តទើបនាងទេពធីតាទាំង ៧អង្គ ផ្លាស់វេនគ្នាមកដង្ហែរ ក្បាលកបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុជារៀងរាល់ឆ្នាំ។

*បុត្រីទាំង៧អង្គនោះគឺ :*

១. បើសង្ក្រាន្តចំថ្ងៃអាទិត្យត្រូវវេននាង **ទុង្សា**

២. បើសង្ក្រាន្តចំថ្ងៃចន្ទត្រូវវេននាង **គោរាគៈ**

៣. បើសង្ក្រាន្តចំថ្ងៃអង្គារត្រូវវេននាង **រាក្សសា**

៤. បើសង្ក្រាន្តចំថ្ងៃពុធត្រូវវេននាង **មណ្ឌា**

៥. បើសង្ក្រាន្តចំថ្ងៃព្រហស្បតិ៍ត្រូវវេននាង **កិរិណី**

៦. បើសង្ក្រាន្តចំថ្ងៃសុក្រត្រូវវេននាង **កិមិរា**

៧. បើសង្ក្រាន្តចំថ្ងៃសៅរ៍ត្រូវវេននាង **មហោទរា**

ដោយមានជំនឿបែបនេះហើយ ទើបខ្មែរយើងមានជំនឿហើយបានរៀបចំបូជាទេវតាដែលត្រូវវេនដង្ហែរក្បាលកបិលមហាព្រហ្ម និង ត្រូវអភិបាលពិភពលោករៀងរាល់ឆ្នាំចូលមកដល់ពុំដែលអាក់ខានឡើយ ។

២. **ជំនឿពិធីស្រង់ព្រះ** : មហាសំការសូត្រដែលមានមកក្នុងគម្ពីរសុត្តជាតក ជាមគធភាសា បាននិទានថា : ថ្ងៃសង្ក្រាន្តថ្មីជិតមកដល់ព្រះបាទ **បសេនទិកោសល** បានរៀបចំជាពារាំយ៉ាងស្អាតនៅឆ្នេរស្ទឹងមួយ ហើយក៏និមន្ត



www.elibraryofcambodia.org

ព្រះពុទ្ធ និង ព្រះសង្ឃស្រង់ទឹក រួចសមាទានសីល ប្រគេនភត្តាហារចំពោះព្រះពុទ្ធ ព្រមទាំងភិក្ខុសង្ឃនៅទីនោះ ។ គម្ពីរនេះដដែលបញ្ជាក់ទៀតថា អ្នកដែលបានស្រង់ទឹកព្រះសង្ឃមាតាបិតា គ្រូឧបជ្ឈាយ៍មានអានិសង្សច្រើនណាស់ អនាគតជាតិ នឹង បានទៅកើតក្នុងទេវលោក បានសេចក្តីសុខគ្រប់យ៉ាង ។

គម្ពីរបញ្ញាសជាតក ត្រង់ជាតកទី៣១ បានបញ្ជាក់អានិសង្សនៃការស្រង់ទឹកព្រះសង្ឃដូចមហាសំការសូត្រដែរ គ្រាន់តែខុសគ្នាត្រង់មិនបានបញ្ជាក់ថាតើនៅឱកាសចូលឆ្នាំ រឺនៅពេលណាប៉ុណ្ណោះ ។ លោកលើកឧទាហរណ៍ ដូចជាព្រះបាទបុប្ផរាជដែលបាននិមន្តព្រះឧសភត្ថេរក្នុងសាសនាព្រះពុទ្ធ សរណង្ករឱ្យស្រង់ទឹក ។ លុះអនាគតជាតិទៅបានទៅកើតក្នុងទេវលោក មានបុណ្យបារមីច្រើន ហើយទីបំផុតបានទៅជាស្តេចចក្រពត្តិក្នុងជម្ពូទ្វីបនេះ ។

នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ពេលចូលឆ្នាំម្តងៗតែតែងតែធ្វើពិធីមួយ ដោយនិមន្តព្រះពុទ្ធរូបមានមហិទ្ធិរិទ្ធ២៥អង្គដែលជាតំណាងអាណាខេត្តទាំងឡាយក្នុងព្រះរាជណាចក្រ មកធ្វើពិធីស្រង់ទឹកនៅប្រាសាទជ័យស្រី (ប្រាសាទព្រះខ័ន) រួចដង្ហែព្រះពុទ្ធរូបទាំងនោះជាក្បួនយ៉ាងមហាឡារិក មុននឹងយកទៅតំកល់នៅកន្លែងដើមវិញ ។

ដោយមានជំនឿ និងមានទំនៀមទម្លាប់របស់ដូនតាយើងដូចខាងលើនេះ ហើយបានជាមានទម្លាប់ជាប់ជាប្រពៃណី រហូតមកដល់សព្វថ្ងៃនេះ ។តែដល់ពេលចូលឆ្នាំម្តងៗ តែតែងធ្វើពិធីស្រង់ទឹកព្រះពុទ្ធរូប ព្រះសង្ឃ មាតាបិតា ជីដូនជីតា បុព្វការីជននៅតាមវត្តអារាម និងតាមភូមិស្រុក ។

ពេលដែលធ្វើពិធីស្រង់ទឹក យើងធ្វើតាមវិធីមួយដូចជា ÷



www.elibraryofcambodia.org

កូនចៅគប្បីត្រូវរំលឹកឱ្យ មាតាបិតា ជីដូនជីតា ។ល។ យើងគប្បីរៀប កន្លែងអានព្រះធម៌ជា កុស្សុក ពានពាងទឹក៤ តាមថែងព្រៃ រួចកូនចៅលុតជង្គង់ សុំខមាទោស មាតាបិតា ជីដូនជីតា អំពីកំហុសខុសឆ្គងដែលកូនចៅអនុវត្តខុស កន្លងមកជាសម្ដីក្ដី ឬ កូនចៅអាន ទំនាស់ទាស់ទែងបងប្អូនខ្លួន ប្រកាន់ពាក្យសម្ដី គ្នាដែលធ្វើឱ្យមាតាបិតា ជីដូនជីតាព្រួយបារម្ភ និងសុំពរជ័យពីគាត់ ។ រួចបន្ទាប់ មកថ្វាយបង្គំគាត់ សុំអញ្ជើញទៅស្រង់ទឹក ( តែគួរធ្វើពេលថ្ងៃក្ដៅ ចៀសវាងរងា ញាក់ នាំមានផលលំបាកព្រោះគាត់ចាស់ៗ ) ។ បន្ទាប់អញ្ជើញគាត់ផ្លាស់សំ- លៀកបំពាក់ ដែលកូនចៅបានជូនទៅគាត់ ។ រីឯពិធីស្រង់ព្រះ និង ភិក្ខុសង្ឃ លោកអាចារ្យណែនាំធ្វើតាមធម្មតា ដែលធ្លាប់ធ្វើទៅចុះ ។

៣. **ពិធីឡើងភ្នំខ្សាច់** : មហាសំការសូត្របានបញ្ជាក់ថា : ពេល សង្រ្កាន្តថ្មីជិតមកដល់ ព្រះបាទ **បសេនទិកោសល** បានទូលសួរថា ក្រោយ ពេលព្រះអង្គបរិនិព្វានទៅដល់សង្រ្កាន្តចូលឆ្នាំថ្មីម្ដងៗ តើខ្ញុំព្រះអង្គ គួរបំពេញកុ- សលអ្វីខ្លះ ? ព្រះពុទ្ធត្រាស់ថា ÷ គួរសាងវាលុកចេតិយ៍ នៅឆ្នេរស្ទឹងទន្លេ ហើយ នាំយកគ្រឿងសក្ការៈ ទៀន ធូប គ្រឿងក្រអូប ផ្កាជាដើមមកបូជាចុះ ។ ព្រះ អង្គបានបញ្ជាក់ អំពីអានិសង្សនៃការសាងវាលុកចេតិយ៍នោះថា មានអានិសង្ស ច្រើនវិសេសណាស់ ដូចគ្នា នឹង ស្រង់ទឹកព្រះសង្ឃដែរ ។

*គម្ពីរអានិសង្សវាលុកចេតិយ៍ ជាសាស្ត្រាស្លឹករិតភាសាខ្មែរមានតែមួយខ្សែ ហើយ មានបីនិទាន :*

និទានទី១ : ដំណាលពីបារិកពោធិសត្វ និង ពួកពាណិជដែលបានពូនភ្នំ ខ្សាច់ ឧទ្ទិសជាដំណោងចូឡាមណីចេតិយ៍ ដែលតម្កល់ព្រះចង្កូមកែវរបស់ព្រះ



www.elibraryofcambodia.org

ពុទ្ធពីបូរាណ ប្រតិស្ឋានទៅស្ថានត្រៃត្រឹង្សទេវលោកនោះ ។ លុះអនាគតជាតិបានទៅកើតក្នុងសុគតិភព កើតជាស្តេចចក្រពត្តិ ជាច្រើនជាតិ ហើយទីបំផុតបានត្រាស់ជាព្រះពុទ្ធយើងនេះ ។

និទានទី២ : ដំណាលពីនាយនេសាទម្នាក់ ( ឈ្មោះមិនប្រាកដ ) ដែលជាអ្នកសម្លាប់សត្វជាអាហារតាំងពីតូចមក ។ ថ្ងៃមួយអ្នកនេសាទនេះបានប្រគេនបាយមួយពំនូត ដល់ភិក្ខុមួយអង្គ ។ ពេលគាត់ស្លាប់ទៅ យមរាជយកទៅវាយសួរចម្លើយ ហើយចាប់បោះទៅក្នុងរណ្តៅភ្លើងនរក បែរជាមិនឆេះខ្ទាតចេញទៅវិញ ។ នាយយមបាលក៏វាយសួរម្តងទៀត ។ ទទួលពេលនោះនាយនេសាទក្រឡេកឃើញអណ្តាតភ្លើងនរកមានសម្បុរដូចចីពរលោក ក៏នឹកដល់ទានរបស់ខ្លួន ហើយដំរាបយមបាលតាមដំណាលរឿងធ្វើទាន ។ ពួកយមបាលក៏អនុញ្ញាតឱ្យបុរសទៅកើតក្នុងទេវលោកចំនួន ៧ថ្ងៃ ហើយសឹមត្រឡប់មកស្ថាននរកវិញ ។ ទេវបុត្រនេះឈ្មោះថា " **អគ្គំលោកវង្សិធី** " មានប្រពន្ធសំណប់ចិត្តឈ្មោះនាង " **សុវណ្ណឱរ៉ៃ** " ។ គាត់បាននិយាយរឿងរ៉ាវរបស់គាត់ដែលធ្លាប់ទៅនរកនោះប្រាប់ភរិយាដោយសព្វគ្រប់ ។ នាង សុវណ្ណឱរ៉ៃ ក៏ឱ្យស្វាមីរបស់ខ្លួនសាងវាលុកចេតិយ៍ ហើយឆ្លងឱ្យហើយស្រេចក្នុងថ្ងៃទី ៧ ។ លុះដល់ថ្ងៃទី ៨ យមរាជក៏តាមមកហៅ **អគ្គំលោកវង្សិធី** ទៅស្ថាននរកវិញ នាងប្រពន្ធក៏ចេញមកនិយាយតបថា : មិនបើកទ្វារឱ្យស្វាមីយើងទៅទេ ព្រោះស្វាមីយើងបានកសាងវាលុកចេតិយ៍ និង ធ្វើពិធីឆ្លងរួចហើយ បើទៅតែយកប្តីយើងទៅធ្វើទោសនោះ ចូរអ្នករាប់គ្រាប់ខ្សាច់នេះឱ្យអស់សិន ។ យមរាជក៏ចាប់ផ្តើមរាប់ខ្សាច់ពេញមួយព្រឹក ដល់ថ្ងៃត្រង់មិនចេះអស់សោះ ។ យមរាជក៏ទាល់តម្រេះហើយ



www.elibraryofcambodia.org

ត្រលប់ទៅស្ថាននរកវិញ ។

និទាននទី៣ ៖ ដំណាលពីចៅកំជិលខ្សាច់ម្នាក់ថា មានក្មេងម្នាក់ចេះតែពូនខ្សាច់នៅទីផ្ទុកខ្សាច់មុខផ្ទះ ហើយដេកនឿយលេងរាល់ៗថ្ងៃប្រឡាក់ប្រឡូសទៅដោយខ្សាច់មើលមិនយល់ គេក៏នាំគ្នាហៅថា ចៅកំជិលខ្សាច់ ។ ថ្ងៃមួយព្រះឥន្ទទតឃើញយ៉ាងនេះ ក៏ឱ្យនាងទេពធីតាម្នាក់ចុះមកធ្វើជាប្រពន្ធ ។ ក្រោយមកនគរមួយនោះព្រះរាជាត្រូវចូលទីវង្គត ហើយគ្មាននរណាស្នងរាជ្យ ពួកមន្ត្រីក៏ធ្វើបុស្បុកផ្សងរកអ្នកមានបុណ្យបារមី បុស្បុកក៏ទៅត្រូវលើចៅកំជិលខ្សាច់ ។ គេក៏នាំគ្នាអញ្ជើញចៅកំជិលខ្សាច់នោះទៅឱ្យសោយរាជ្យជាសុខតទៅ ។

ដោយមានជំនឿយ៉ាងនេះហើយ បានជាខ្មែរយើងជឿជាប់តរៀងរហូតមកដល់បច្ចុប្បន្ន ប៉ុន្តែភ្នំខ្សាច់នេះគេ មិនមែនធ្វើតែក្នុងឱកាសចូលឆ្នាំប៉ុណ្ណោះទេ សូម្បីតែពិធីផ្សេងៗក៏គេនិយមធ្វើដែរ ព្រោះជឿថា ជាការរំដោះកម្មពៀរវេរាដែលធ្វើអាក្រក់កន្លងមក ។ ប៉ុន្តែយើងពិនិត្យឃើញឥឡូវនេះ តាមវត្តមួយចំនួនគេយកស្រូវទៅពូនភ្នំខ្សាច់ដោយគិតថា ឱ្យផលចំណេញដល់ការសាងវត្ត ។ តែគេប្រើពាក្យពូនភ្នំខ្សាច់នេះក៏ល្អម្យ៉ាងដែរ ។ តែពិនិត្យឃើញ តាមកន្លែងមួយចំនួនគេចូលបុណ្យមានស្រូវផង អាចារ្យគ្រាន់តែជូនពរហើយ ឱ្យយកស្រូវទៅចាក់គរជាគំនរមួយជាការស្រេច ធ្វើរបៀបនេះមិន សមរម្យទេ ។ យើងជាអាចារ្យត្រូវចេះពិធីលើកស្ទួយកម្លាំងសទ្ធា ឱ្យគេកាន់តែកក់ក្តៅជឿជាក់ ដើម្បីមានអារម្មណ៍សប្បាយនឹងបុណ្យរបស់គេ ព្រោះស្រូវដែលចូល បុណ្យនេះគេថាពូនភ្នំខ្សាច់ យ៉ាងនេះហើយ អាចារ្យត្រូវធ្វើតាមរបៀបពូនភ្នំ ខ្សាច់ ។



www.elibraryofcambodia.org

# បុណ្យចូលវស្សាឬកាន់វស្សា

បុណ្យកាន់វស្សា គឺជាបុណ្យមានមកតាមផ្លូវព្រះពុទ្ធសាសនា ដែលសាវក័ផ្នែកបព្វជិត តែងចូលវស្សា តាមពុទ្ធានុញ្ញាតអស់រយៈពេល ៣ខែ ( មួយត្រៃមាស ) ក្នុងវស្សានរដូវ ហើយត្រូវចាំវស្សាដោយត្រឹមត្រូវ មិនឱ្យដាច់វស្សា បើធ្វើឱ្យដាច់វស្សាត្រូវទោសទុក្កដាបត្តិ ។ រីឯពុទ្ធបរិស័ទជាទាយកទាយិកា ឧបាសកឧបាសិកាវិញ ក៏នាំគ្នាប្រារព្ធធ្វើបុណ្យកាន់វស្សានោះដែរ ពិសេសគឺចាត់ចែងវស្សិកសាដក ( សំពត់សំរាប់ងូតទឹកភ្លៀង ) ដែលនិយមហៅថា សំពត់សាដកចំណាំវស្សា ព្រមទាំងប្រេងកាត ទៀន ធូប និងភេសជ្ជៈមួយចំនួនទៀតតាមលទ្ធភាព ។ ក្នុងវិន័យបិដក មហាវគ្គភាគ ៧ ត្រង់វស្សូបនាយិកក្ខន្ធកៈ លោកសំដែងថា ការចូលវស្សាមាន ២យ៉ាងគឺ ទី១ ហៅថា **បុរិមិកាវស្សា** ការចូលវស្សាមុនដំបូង ចាប់ពីថ្ងៃ ១រោចខែអាសាឍ ( បើឆ្នាំណាលើកខែអាសាឍពីរដងនោះចូលវស្សានេះនៅថ្ងៃ ១រោចខែ ទុតិយាសាឍ ) តទៅអស់ ១ត្រៃមាស ( ៣ខែ ) ទើបចេញវស្សា នៅថ្ងៃ ១៥កើតខែ អស្សុជ ។ ទី២ហៅថា **បច្ឆិមិកាវស្សា** ការចូលវស្សាលើកក្រោយ ( គឺក្រោយថ្ងៃចូលវស្សាលើកដំបូងចំនួន ១ខែ ) គិតចាប់ពីថ្ងៃ ១រោចខែស្រាពណ៍ តទៅដល់ថ្ងៃ ១៥កើតខែកត្តិកទើបត្រូវចេញវស្សា ។ ចូលលើកក្រោយនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតដល់សាវក័ គ្រែងមានកិច្ចវល់ប្រការណាមួយ ដែលពុំអាចចូលវស្សាទី១ឱ្យចូលវស្សាទី២បាន ។ ប៉ុន្តែទោះបី ការចូលវស្សាទី១ក្តីទី២ក្តី យើងមិនបានអធិប្បាយក្នុងទីនេះទេ ។ យើងនឹងបើកទំព័រនេះ តែអំពីពិធីចូលវស្សាតែប៉ុណ្ណោះ ។



www.elibraryofcambodia.org

## ពិធីចូលវស្សារបស់បព្វជិត :

នៅថ្ងៃ ១៥កើតខែអាសាឍ ជាថ្ងៃបណ្ណរសិកឧបោសថរបស់ភិក្ខុសង្ឃ ។ ពេលធ្វើឧបោសថចប់ហើយភិក្ខុសង្ឃទាំងឡាយ គប្បីនិយាយគ្នា ( គួរហៅសាមណេរចូលរួម ស្តាប់ផងជាការល្អ ) គឺលោកគ្រូចៅអាវាស ត្រូវរំលឹកអំពីថ្ងៃចូលវស្សា ស្អែកជាថ្ងៃ ១រោចខែ អាសាឍ ប្រាប់ឱ្យភិក្ខុសាមណេររៀនបាលីអំពីចូលវស្សា ឱ្យឯកភាពគ្នា , ប្រាប់ពេលវេលាតើពេលណាត្រូវជួបជុំគ្នាក្នុងព្រះវិហារ ( ឧបោសថាគារ ) សំខាន់ស្រោចស្រង់ជុសលាងសំអាតព្រះពុទ្ធរូបព្រមទាំងត្រៀមរៀបចំ អាសនៈ ឱ្យបានសមរម្យសំរាប់ធ្វើកិច្ចចូលវស្សាផង ។ ឯពេលចូលវស្សាភាគច្រើននិយមពេលល្ងាច ថ្ងៃ១រោចតែម្តង ។

ភិក្ខុសាមណេរដែលត្រូវចូលវស្សានេះ សុទ្ធតែមានស្មារតីភ្ញាក់រលឹកត្រៀមលក្ខណៈរួចជាស្រេចគឺ :

- ការបោកគក់ជ្រលក់ហាល ស្បង់ស្បៃត្រៃចីវរ ពីថ្ងៃមុនឱ្យហើយ ( ពីរបីថ្ងៃ ) មុន ការងារត្រូវធ្វើក្នុងថ្ងៃចូលវស្សា ។

- មិនគួរដើរហើរចេញដំណើរទៅណាឆ្ងាយៗ ( បើបានជាចេញទៅ ) ក៏ត្រូវតែត្រលប់មកឱ្យទាន់ថ្ងៃ ១៥កើត ខែអាសាឍនេះ ព្រោះថ្ងៃនោះត្រូវសង្ឃធ្វើឧបោសថ ប្រជុំអំពីបញ្ហាចូលវស្សាផងត្រូវជាថ្ងៃដែលឧបាសក-សិកាចំណុះជើងវត្ត គេត្រូវធ្វើបុណ្យកាន់វស្សាគឺប្រគេនបច្ច័យ ទេយ្យវត្ថុចំរើនបរិត្តផង ដើម្បីអបអរសាទរប្តេជ្ញាចិត្តទំនុកបំរុងព្រះសង្ឃដែលគង់ចាំវស្សានោះ ។ ព្រះអង្គជា **បមិត្តាហក:** គប្បីនៅជួបជុំ សំដែងសេចក្តីត្រេកអរចំពោះសទ្ធាចិត្តរបស់ទាយកទាយិកាវិញ ជាការគួរណាស់ ។ នៅថ្ងៃចូលវស្សា ក្រោយពីឆាន់



www.elibraryofcambodia.org

យាកូហើយ ពគប្បីធ្វើការដែលសង្ឃប្រគល់ឲ្យពីរឿងទាំងភិក្ខុទាំងសាមណេរ ។ នៅពេលរសៀលគប្បីរៀបចំក្រាលអាសនៈក្នុងព្រះវិហារ ដែលបានសំអាតរួចពីព្រឹក ហើយនោះនឹងតំកល់ទឹកប្រើប្រាស់ នឹងឆាន់ ព្រមទាំងមានគ្រឿងសក្ការបូជា (ទៀនធូបផ្កាភ្ញី) ជាដើមផង ។ ដល់ពេលវេលាបានកំណត់ (ជួងឬស្គរបន្លឺជាសញ្ញា) ភិក្ខុសាមណេរគ្រប់អង្គ ស្លៀកស្បង់គ្រងចីវរ សង្ឃាដី ក្រវាត់វត្តពន្ធ ជាបរិមណ្ឌលដ៏សមរម្យនិមន្តចូលព្រះវិហារ ពួកភិក្ខុសង្ឃគប្បីសំដែងអាបត្តិចេញ ។ ទាំងភិក្ខុទាំងសាមណេរ ធ្វើកិច្ច វន្ទា ខមាទោស ចំពោះព្រះសម្មាសម្ពុទ្ធ រួចបន្តនមស្ការថ្វាយបង្គំ ។ លុះចប់កិច្ចនមស្ការហើយ ក្រុមភិក្ខុសូត្របាលីចូលវស្សា គឺ អង្គុយច្រហោង ផ្គងអញ្ជលីប្រណម្យសូត្រព្រម១គ្នាថា :

**- នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

**- ឱកាស តំមស្មិំ អាវាសេ តេមាសំ វស្សំ ឧបេមិ** (៣ចប់) ។ បន្ទាប់មកក្រុមភិក្ខុ សំរួលឥរិយាបថទៅម្ខាង ហើយក្រុមសាមណេរសូត្របាលីចូលវស្សាម្តង (បើវត្តនោះមានសាមណេរដែរ) ។ មុននឹងសូត្រក្រុមសាមណេរ ត្រូវចូលទៅវន្ទាខមាទោសលោកចៅអាវាស និងសូត្រសុំនិស្ស័យអំពីលោក ដែលជាកិច្ចវត្តដ៏ល្អរបស់បុព្វជិត ទោះបីសាមណេរចូលមកស្នាក់អាស្រ័យក្តី ឬលោកដែលបួសក្នុងវត្ត ក្តីគឺ :

**- វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេ ភន្តេ** ។ល។

**ឱកាស ខមាមិ ភន្តេ ...............** ។ល។

**- ឱកាស អាចរិយោ មេ ភន្តេ ហោហិ** ... **និស្សយំ ទេថ មេ ភន្តេ អហំ**



www.elibraryofcambodia.org

ភន្តេ និស្សយំ យាចាមិ ( តតិ.តតិយម្បិ) រួចហើយ សូត្របាលី ចូលវស្សានៅចំពោះព្រះភក្ត្រលោកគ្រូចៅអធិការវត្តតែម្តងដោយសូត្រ ព្រមៗគ្នា ដូចក្រុមភិក្ខុសូត្រខាងដើម ។

ពេលសូត្រចប់ហើយក្រុមសាមណេរ ថយក្រោយមកសំរួលឥរិយាបថតាមកន្លែងសមគួរ ហើយលោកគ្រូចៅអាវាស (ឬលោកប្រគល់ឱ្យភិក្ខុឈ្លាសប្រតិពលអង្គណាមួយក៏បាន ) ប្រកាសប្រាប់អំពីសីមាវត្តកំណត់ទី មិនឱ្យនៅក្រៅអាវាស បណ្តោយឱ្យអរុណរះទាន់ ចាប់តាំងពីព្រឹកនេះទៅ ។

ណែនាំអំពីការចាំវស្សា ឱ្យបានត្រឹមត្រូវ មិនឱ្យដាច់ ត្រូវមកជួបគ្នាសូត្រធម៌ថ្វាយបង្គំ (សូត្រវេន) រាល់ល្ងាចម៉ោងប៉ុណ្ណេះ ពេលព្រឹកម៉ោងប៉ុណ្ណោះ ជារៀងរាល់ពេលឱ្យបានគ្រប់អង្គអស់រយៈពេល ៣ខែនេះ ពិសេសអំពីការរស់នៅក្នុងអារាមនិងការខិតខំសិក្សារៀនសូត្រ ។

**ពិធីបុណ្យកាន់វស្សារបស់ពុទ្ធបរិស័ទជាឧបាសក ឧបាសិកា**

យើងដឹងហើយថា ថ្ងៃ ១រោចខែអាសាធ ជាទិវាត្រូវចូលវស្សារបស់បព្វជិត ពុទ្ធសាសនាទាំងភិក្ខុទាំងសាមណេរ ជាការចាំបាច់តាមពុទ្ធានុញ្ញាត ។ រីឯទាយកទាយិកា ឧបាសក-សិកា ជាពុទ្ធសាសនិក ចំណុះជើងវត្តនិមួយៗក្រោមការដឹកនាំរបស់លោកអាចារ្យវត្តក៏ប្រារព្ធធ្វើបុណ្យចូលវស្សាឬកាន់វស្សាផងដែរ តែធ្វើនៅថ្ងៃ ១៥កើតខែអាសាធ មុនព្រះសង្ឃចូលវស្សា ១ថ្ងៃ ។ សេចក្តីថា កន្លះខែមុនថ្ងៃចូលវស្សា ឬថារាល់ថ្ងៃឧបោសថសីល (ថ្ងៃខែដាច់ខែជេស្ឋ ឬ ថ្ងៃ ៨កើត ខែអាសាធ ) លោកអាចារ្យតែងប្រកូកប្រកាសជំរាបពុទ្ធបរិស័ទឱ្យដឹងជាមុន អំពីថ្ងៃចូលវស្សាខាងមុខ (ប្រជុំពិភាក្សាឯកភាពក្នុង



www.elibraryofcambodia.org

ជូនអាចារ្យ គណៈកម្មការវត្ត ចាស់ ព្រឹទ្ធាចារ្យរួចហើយ ) ឱ្យពុទ្ធបរិស័ទត្រៀម លក្ខណៈប្រុងរៀបចំ **ចតុប្បច្ច័យ ទេយ្យវត្ថុ** មានសាដក ទៀន ធូប ប្រេង ចំណាំវស្សា..............ជាដើមសំរាប់ទំនុកបំរុងព្រះសង្ឃ ដែលគង់ចាំវស្សាក្នុងវត្ត និងជំរាបពុទ្ធបរិស័ទមកជួបជុំគ្នានៅថ្ងៃទី ១៥កើតខែអាសាធ ដោយនាំមក នូវ ទេយ្យវត្ថុផង ។ អាចារ្យ វត្តកន្លែងខ្លះមានឱ្យលិខិតដែលកំណត់ទេយ្យវត្ថុ អ្វីខ្លះក្នុងមួយកញ្ចប់និងប្រាកសង្កត់លើ ទេយ្យវត្ថុនោះ ចាត់ចែងស្វែងរកទៀន ធំ១ ហៅថា : ទៀនចំណាំវស្សា ( បើពុំមានអ្នកមានសទ្ធាណាបូជាទេ ) ទៀនធំមួយគូនេះ សំរាប់ដុតចាប់ផ្ដើមពីថ្ងៃ១រោចខែអាសាធ ជាថ្ងៃចូលវស្សា មិនពន្លត់ដល់ថ្ងៃ ចេញវស្សា ( ៣ខែ ) ។ នៅថ្ងៃ ១៥កើតខែអាសាធ ក្រោយពីសមាទានឧបោសថសីលរួចហើយ លោកអាចារ្យប្រកាសឱ្យពុទ្ធបរិស័ទ យករណ្ដាប់រណ្ដា វៀង១ខ្លួន ចូលបុណ្យដែលត្រូវជួបជុំគ្នានៅម៉ោង២រសៀល ដើម្បីធ្វើពិធីសូត្រ មន្តចូលវស្សា ។

នៅពេលរសៀល ពុទ្ធបរិស័ទមកជួបជុំគ្នា រួមទាំងកញ្ចប់ទេយ្យវត្ថុ ផង ក៏ធ្វើពិធីហែសាដកចំណាំវស្សានេះ ពីឧបដ្ឋានសាលាទៅព្រះវិហារដោយ និមន្តព្រះសង្ឃគ្រប់អង្គក្នុងវត្ត ទៅតែម្ដង ។ ពិធីចាប់ផ្ដើមនមស្ការព្រះរតន-ត្រៃ សមាទានសីល ហើយអារាធនាព្រះសង្ឃចំរើនព្រះបរិត្ត ។ ចប់ពុទ្ធមន្ត ហើយលោកអាចារ្យប្រកូកប្រកាស អំពីថ្ងៃចូលវស្សា ។ ( អំពីការចូលវស្សា របស់ទាយកទាយិកានេះ មិនមែនជាពុទ្ធប្បញ្ញត្តិទេ គឺជាចេតនាកម្មធ្វើដោយ សោមនស្សវេទនា ញាណសម្បយុត្ត ។



www.elibraryofcambodia.org

# បុណ្យបិណ្ឌភ្ជុំ

*អារម្ភបទ*

បុណ្យបិណ្ឌភ្ជុំ គឺជាបុណ្យដ៏ធំមួយរបស់ខេមរជន អ្នកកាន់ព្រះពុទ្ធសាសនា ។ ពុទ្ធសាសនិកតែងប្រារព្ធធ្វើ តាំងពីយូរណាស់មកហើយ ។ បុណ្យ នេះគេធ្វើមានពីរថ្នាក់គឺ ដំបូងពីថ្ងៃ ១ រោច ២ រោច ទៅរហូតដល់ថ្ងៃ ១៤រោចជាវារកភត្ត (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់ ។ មួយថ្នាក់ទៀតតែមួយថ្ងៃនៅថ្ងៃ ១៥រោចហៅថា បុណ្យភ្ជុំ ។ បុណ្យនេះក្នុងសម័យពុទ្ធកាលគេមិនហៅថា បុណ្យបិណ្ឌភ្ជុំ តែក៏មានលំនាំដូចគ្នាគឺធ្វើសង្ឃភត្តវារកភត្ត ដែលគេធ្វើរាល់ថ្ងៃ ឧបត្ថម្ភទំនុកបំរុងព្រះសង្ឃក្នុងវស្សា៣ខែនោះឯង ។

ដូចយ៉ាងលោកយាយមហាឧបាសិកា វិសាខា សូមពរពីព្រះជាម្ចាស់បាន ៨ប្រការ មានសូមប្រគេនវស្សិកសាដកដល់ព្រះសង្ឃជានិច្ចជាដើម ក៏ត្រូវបានជាប់ជាប្រពៃណីមកដល់សព្វថ្ងៃ ដែលពុទ្ធសាសនិកជននាំគ្នាធ្វើសាដក ចំណាំវស្សាថ្ងៃព្រះសង្ឃចូលវស្សានោះដែរ ។ ដំណើររឿងក្នុងព្រះពុទ្ធសាសនាយើងឃើញយាយមហាឧបាសិកាវិសាខា លោកតាមហាឧបាសកបិណ្ឌិកសេដ្ឋី ដែលលេចធ្លោជាងគេជាមហាឧបដ្ឋាកចំពោះសង្ឃជានិច្ចជាកាល ។

ក្រៅពីនេះក៏មានច្រើនទៀត ដូចយ៉ាងព្រះរាជាទាំងឡាយអគ្គមហេសីនៃព្រះរាជាទាំងនោះឬបសាទិកជនច្រើនទៀត និងរាជបណ្ឌិតជាដើមក៏តែងអង្គាសចង្ហាន់ច្រើនៗថ្ងៃដែរ ។ ត្រឹមតែនិច្ចភត្តរបស់លោកយាយមហាឧបាសិកាវិសាខាមួយនាក់ក៏អាចបញ្ជាក់បានដែរថា និច្ចភត្តគឺភត្តជាប់ជានិច្ចឬវារកភត្តភត្តរាល់ថ្ងៃរបស់គាត់ក៏ក្នុងវស្សា៣ខែដែរ ដែលឧបត្ថម្ភចំពោះ ព្រះសង្ឃមាន



www.elibraryofcambodia.org

លក្ខណៈប្រហាក់ប្រហែលនឹងបច្ចុប្បន្នហៅថាបុណ្យដាក់បិណ្ឌនោះ ។ ព្រោះអ្វី ព្រោះពាក្យថាៈ បិណ្ឌ=ដុំបាយ សំដៅបាយដែលដាក់ ចានឬឆ្នាំង យកទៅរាប់ បាត្រ១-២-៣ឬ១០-២០ បាត្រនោះឯង ឬថា ចង្ហាន់ជាស្រាក់ជាស្លកដែល ទាយកទាយិកា យកទៅប្រគេនព្រះសង្ឃនោះ ។ ម្យ៉ាងទៀត "បិណ្ឌៗ" មិន មែនសំដៅយកតែបាយមួយមុខឯណា គឺសំដៅដល់ ភត្តាហារ ឬ ចង្ហាន់ជាដុំជា វេនជាក្រុមជាពួកតាមថ្ងៃនោះៗ ដែលបញ្ជាក់នូវពាក្យថា "បិណ្ឌៈ" នេះឯង ។

ម្យ៉ាងទៀត បុណ្យបិណ្ឌភ្ជុំនេះ គឺជាបុណ្យ ទក្ខិណានុប្បទាន ក្នុង វស្សា៣ខែនោះតែម្តងគ្រាន់តែក្នុងសម័យពុទ្ធកាល លោកមិននិយមហៅថា បុណ្យបិណ្ឌភ្ជុំ ដូចយើងសព្វថ្ងៃប៉ុណ្ណោះ តាមគោលបំណងគឺជាបុណ្យឧទ្ទិស ផ្សាយឬបញ្ជូនកុសលដល់បេតជនដូចគ្នា ព្រោះតែក្នុងសម័យពុទ្ធកាលប្រារព្ធ នឹងព្រះបាទពិម្ពិសារមហារាជ ក្រុងរាជគ្រឹះដែលព្រះអង្គធ្វើទានហើយមិនបាន ឧទ្ទិសកុសលចែកជូនដល់ពួកបេតជនជាញាតិ មិនត្រឹមតែញាតិ៧សន្តានទេគឺ ជាប់តំណញាតិ មហាកប្បកន្លងច្រើនព្រះពុទ្ធទៀតផង ។ កាលដែលមិនបាន ឧទ្ទិសជូនទៅ នាំឱ្យញាតិទាំងនោះ ដែលរងកម្មក្រហល់ក្រហាយអត់ឃ្លាន យូរហើយ ស្រែកទ្រហោយំ កោលាហលពេញផ្ទៃក្រឡាបន្ទំក្នុងវាំងរបស់ព្រះ អង្គ ។ អតីត និទាននោះក៏បានជាប្រពៃណីនៃពុទ្ធមាមកជនធ្វើបុណ្យបិណ្ឌ ភ្ជុំដល់សព្វថ្ងៃដែរ ។

ក្នុងតិរោកុឌ្ឌសូត្រ លោកសំដែងថា ពួកបេតជន (គឺអ្នកស្លាប់ទៅ) ជាញាតិ ធ្លាក់ណាក៏ដោយដែលជ្រុលធ្វើបាបកម្ម ធ្លាក់ទៅសោយទុក្ខនាឋាន ។រករងទុក្ខតាមអាយុកម្ម ហើយសេសសល់ផលកម្ម ត្រូវបានមកកើតក្នុង



www.elibraryofcambodia.org

អបាយភូមិ ជាន់ស្រាលគឺ បេតវិស័យ (ពួកប្រេត) ក៏មាន ជូនពួកញាតិអ្នកធ្វើបាបកម្មល្មមនឹងធ្លាក់ទៅកើតសោយទុក្ខត្រឹមប្រេតតែម្តងក៏មាន ។ (បេតវិស័យ (ពួកប្រេត) ក៏មាន ជូនកាលពួកញាតិអ្នកធ្វើបាបកម្មល្មម និងធ្លាក់ទៅកើតសោយទុក្ខត្រឹមតែប្រេតម្តងក៏មាន) ។ បេតវិស័យទាំងនេះ មានជំពូកខ្លះត្រូវអត់ឃ្លានរង់ចាំតែ ចំណាយទានញាតិឧទ្ទិសឱ្យទៅ ត្រូវដើររកលំនៅញាតិទើបប្រេតខ្លះស្ថិតនៅក្បែរផ្លូវបែក ជា៣ ជា៤ ខ្លះនៅតោងជញ្ជាំងក្រៅផ្ទះ ខ្លះឋិតនៅតាមច្រកទ្វារ ។ល។ ពួកប្រេតជំពូកខ្លះ មានឱកាសតែក្នុងរដូវវស្សាច្រើនជាងរដូវដទៃៗទៀតព្រោះក្នុងរដូវវស្សា ងាយស្វែងរកអាហាររបស់ខ្លួនជាភក់ជ្រាំ ស្លេស្ម កំហាក ត៌រង់ សាកសព ដែលជាកាកសំណល់អសោចិ៍មានសំបូរខែភ្លៀងផ្គរជោគជាំ ពព្រេច ។ សាកសពផ្សេងៗនៅហើមប៉ោង រីកហូរខ្ទុះឈាម យូរជាងខែប្រាំងខែក្តៅដែលឆាប់ស្ងួតក្រៀមក្រញង់ មិនអាចក្លាយជាអាហាររបស់ពួកគេ ។ ព្រោះហេតុនោះ ទើបពុទ្ធសាសនិកជនអ្នក ច្រើនដោយមេត្តាករុណាធម៌ នាំគ្នាធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលក្នុងរដូវវស្សានោះឯងដែលខ្មែរយើងឱ្យឈ្មោះថា បុណ្យបិណ្ឌភ្ជុំហើយនិងផ្អែកតាមឬស្របទៅនឹង :

១- ពុទ្ធានុញ្ញាតឱ្យភិក្ខុសង្ឃចូលវស្សា ៣ខែ ក្នុងវស្សានរដូវហើយការចូលវស្សានេះ ព្រះអង្គឱ្យសាវក័សម្ងំនៅបដិបត្តិធម៌សិក្សារៀនសូត្រធម៌វិន័យក្នុងអាវាស មិនឱ្យគោចរចេញទៅណាមកណាររហេតរហូត រម្លងរាត្រីកាលអរុណោះទាន់ខ្លួននៅក្រៅសីមាទេ និងទ្រង់ណែនាំទៀតថា (បើនៅចាំវស្សាឯតំបន់ណាសូមឱ្យទាយកទាយិកាតំបន់នោះជួយទំនុកបំរុងដោយបច្ច័យ ៤ ដើម្បីជីវភាពរស់នៅ ៣ខែ ក្នុងវស្សា) ។ ពុទ្ធបរិស័ទបានដឹងពុទ្ធានុញ្ញាតនេះ ក៏



www.elibraryofcambodia.org

ញុំាងកុសលចិត្តឡើង កើតឡើងដោយបច្ច័យពាក្យកោរតាបស់ដោយគ្រួសារ ឬក្រុមជាវេន១ ( វារកភត្ត ) មួយថ្ងៃបន្តគ្នាក្នុងតំបន់ចំណុះជើងវត្តក៏មាន ។ កុដុម្ពិក ឬ សេដ្ឋី គហបតី អ្នកមានសទ្ធាគេធ្វើអស់មួយត្រៃមាស តែម្នាក់គេក៏មាន ។ សង្ឃភត្តនេះហើយដែលដល់បច្ចុប្បន្នយើងហៅថា ( **បុណ្យចាក់បិណ្ឌ** ) ដូច្នេះក៏បាន ។

២- រឿងអតីតនិទានស្តីពីពួកប្រេត ជាញាតិព្រះបាទ **មាគធសេនិយរាជពិម្ពិសារ** ជាឧទាហរណ៍ ។ ម្ល៉ោះហើយញាតិរបស់យើងក៏មិនខុសគ្នាដែរ ទើបពុទ្ធបរិស័ទកំណត់យកពេលវេលាព្រះសង្ឃចាំវស្សានេះ ធ្វើជាបុណ្យទក្ខិណានុប្បទាននិងទំនុកបំរុងព្រះសង្ឃជួយសំរាលការពិបាក គ្រាច់ចរកចង្ហាន់ក្នុងរដូវមានភ្លៀងផ្គរពព្រេច១នេះផង ដែលយើងសព្វថ្ងៃហៅថាបុណ្យបិណ្ឌភ្ជុំនេះក៏បាន ។

*បុណ្យបិណ្ឌភ្ជុំ ក្នុងសម័យពុទ្ធកាល*

ដូចបានជំរាបខាងលើហើយថា : កាលព្រះពុទ្ធគង់ចរមាននៅ ពួកពុទ្ធបរិស័ទបានធ្វើបុណ្យនេះគ្រាន់តែទម្លាប់ហៅថា បុណ្យបិណ្ឌភ្ជុំប៉ុណ្ណោះ គឺជាការធ្វើសង្ឃភត្ត ទំនុកបំរុងព្រះសង្ឃ ដែលគង់ចាំវស្សារហូតក្នុងវត្តរបស់ខ្លួនជារៀងរាល់ថ្ងៃ ចំនួន ៣ខែតាំងពីចូលវស្សារហូតដល់ថ្ងៃចេញវស្សា ។ លុះថ្ងៃចេញវស្សា ១៥កើតខែអស្សុជ គេកំណត់យក ១ថ្ងៃនេះធ្វើជាថ្ងៃបុណ្យដារឆ្លងគឺប្រមូលផ្តុំភ្ជុំបិណ្ឌដែលគេបានធ្វើរយៈ ៣ខែហើយនោះ ដារឆ្លងបញ្ចប់តែម្តងហើយគេធ្វើបត្តិទានគាថា : ឧទ្ទិសកុសលដល់ពពួកប្រេតជនជាញាតិនោះផងដោយអនុវត្តតាមសង្ឃគតាទក្ខិណាទាន ដែលព្រះបាទ **ពិម្ពិសារ** បាន



www.elibraryofcambodia.org

ធ្វើនោះដែរ ។ សេចក្ដីថា : ព្រះបាទ ពិម្ពិសារ ដែលក្រោយពីបានដឹងព្រះពុទ្ធដីកាប្រាប់ថា : ពួកញាតិរបស់ព្រះមហារាជបានធ្វើបាបកម្ម តាំងពីក្នុងសម័យពុទ្ធកាលនាមព្រះកកុសន្ធោមកម្ល៉េះ ដែលត្រូវរងផលអត់ឃ្លានគ្មានអាហារ តាំងពីសម័យព្រះពុទ្ធ **គោនាគមន** និងព្រះពុទ្ធ **កស្សប** ហើយនឹងអាចត្រូវបានទទួលផលក្នុងសម័យតថាគត នេះអំពីព្រះមហារាជជាញាតិ. អ្នកឧទ្ទិសឱ្យទៅ ។ ហេតុតែព្រះមហារាជមិនបានឧទ្ទិសជូន ទើបប្រេតជនទាំងនោះស្រែកឃ្លានស្រែកទ្រហោយំយ៉ាងនេះ ។

កាលបើជ្រាបការណ៍ហើយទើបព្រះរាជា ធ្វើកុសលបន្ថែមទៀត ហើយធ្វើបត្តិទានគាថា : ផ្សាយដល់ប្រេតជាញាតិនោះៗ ឱ្យបានទទួល ដោយស្ងប់ចិត្តរំដោះកម្មកាចរបស់ខ្លួន ។ ព្រោះតែអតីតនិទាននេះ សម័យនោះជនទាំងឡាយក៏ប្រារព្ធធ្វើឆ្នាំក្រោយៗមក ។ ហើយគេធ្វើអស់ ៣ខែពេញ ។ ដល់ថ្ងៃ ១៥កើត ជាថ្ងៃចេញវស្សា ពិធីដារឆ្លងបុណ្យខាងដើមប្រមូលផ្តុំបញ្ចប់តែម្តងដែលអាចឱ្យឈ្មោះថា បុណ្យភ្ជុំតាមពាក្យខ្មែរយើងធ្លាប់ធ្វើក៏បាន ។ លុះចំណេរកាលក្រោយៗមកអត់ពីព្រះបរមសម្ពុទ្ធកន្លងទៅ បរិស័ទពុទ្ធសាសនិក ក៏នៅតែធ្វើបុណ្យទំនុកបំរុងព្រះសង្ឃអស់ ៣ខែពេញ បន្តរហូតមក ។ ក៏ប៉ុន្តែពេលក្រោយៗមក គេយកថ្ងៃចេញវស្សាដែលជាថ្ងៃ ភ្ជុំបុណ្យដារឆ្លងនោះ បន្ថែមធ្វើពិធីបណ្តែតប្រទីបផង តើការធ្វើពិធីបណ្តែតប្រទីបថ្ងៃចេញវស្សានោះ គេធ្វើដើម្បីអ្វី ? ធ្វើយ៉ាងណា ? គឺគេធ្វើជាកូនប្រាសាទ ខ្ចម ឬរានសង្ហឹក ប្រក់ដំបូលធ្វើតូចៗប្រមាណទំហំពីរ ឬជាងពីរបីតឹក បួនជ្រុងដោយមានរៀបចំជាអង្ករបន្តិច ប្រហុកអំបិល ត្រីសាច់ នំនែកបង្អែមចំអាបទុកជាស្បៀង បង្ហិច



www.elibraryofcambodia.org

សំពាយ វេចខ្ចប់របស់របរ ធូបទៀន ឬពោត អង្ករ បណ្ដែតតាមទឹក បញ្ជូនដំណើរបេតជន ជាញាតិបន្ថែមសំរាប់ជាស្បៀង ពេលត្រលប់ទៅវិញ នៅថ្ងៃចេញវស្សាបញ្ចប់ដារឆ្លងបុណ្យឧទ្ទិសនោះឯង ។ យើងសព្វថ្ងៃហៅថា បុណ្យចេញព្រះវស្សា បណ្ដែតប្រទីបនោះ ឬក៏បុណ្យភ្ជុំ កាលពីជំនាន់ដើម បន្ទាប់ពីព្រះពុទ្ធបរិនិព្វាន កន្លងផុតច្រើនឆ្នាំហើយ ។

*<u>បុណ្យបិណ្ឌភ្ជុំ គឺបុណ្យដាក់បិណ្ឌ និង បុណ្យភ្ជុំរបស់ពុទ្ធសាសនិកជនជាតិខ្មែរ</u>*

តាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង ឃើញថា : ជនជាតិខ្មែរបាន ទទួលឥទ្ធិពលគោរពប្រតិបត្តិព្រហ្មញ្ញសាសនា ជាដំបូងបង្អស់ ។ ឯព្រះពុទ្ធ សាសនា ទើបតែចូលមកប្រតិស្ឋានជាខាងក្រោយ ដែលក្នុងសម្ដីតិកថាបាន បញ្ជាក់ថា ព្រះពុទ្ធជាម្ចាស់បរិនិព្វានទៅកន្លងប្រហែលជាង ២០០ឆ្នាំ (ព-ស ២៣៤) សាវ័កបានរៀបចំធ្វើសង្គាយនាលើកទី៣ ដែលមានព្រះមហាមោគល្លី បុត្តតិស្សត្ថេរ ជាប្រធានបានប្រារព្ធឡើង ។ ក្រោយពីបញ្ចប់សង្គាយនាលើក ទី៣ព្រះមហាមោគល្លីបុត្តតិស្សត្ថេរ បានពិចារណាឃើញភាពរុងរឿងនៃព្រះ ពុទ្ធសាសនា នៅនាបច្ចន្តប្រទេស ។ព្រោះហេតុនោះទើបព្រះមហាថេរ ចាត់ ចែងបញ្ជូនសាសនទូត ធម្មទូត ចេញទៅផ្សព្វផ្សាយសាសនាដូចជា ព្រះ មហិន្ទត្ថេរ ឱ្យនិមន្តទៅកាន់ **តម្ពបណ្ណិទ្វីប** ( សេរីលង្កាជាដើម ) ក្នុងនោះព្រះ ឧត្តរត្ថេរ និងព្រះសោណត្ថេរ ជាសាសនទូត មានបេសកកម្មទៅផ្សាយ សាសនានៅជ្រោយសុវណ្ណភូមិ គឺក្នុងសម័យនោះហើយដែលប្រទេសខ្មែរយើង ទទួលគោរពព្រះពុទ្ធសាសនា តរៀងមក ទោះបីព្រះពុទ្ធសាសនារុងរឿង ឬ ថយចុះតាមយុគសម័យនៃប្រទេសជាតិយ៉ាងណាក៏ដោយ ក៏ព្រះពុទ្ធសាសនា



www.elibraryofcambodia.org

នៅតែ តាំងនៅជារៀងរហូតមក ។

ប៉ុន្តែយើងបែរមកគិតរឿងបុណ្យបិណ្ឌភ្ជុំ ដែលជាបុណ្យធំមួយរបស់អ្នកកាន់ លទ្ធិពុទ្ធសាសនា នៃយើងវិញ ឃើញថាពីសម័យបុរាណរហូតដល់បច្ចុប្បន្ន ក៏ចេះតែរួញថយតាមកន្លែង បានសេចក្តីថា : ពីបុរាណលោកធ្វើ ពិស្តារមានពិធីកម្មបែបបទច្រើន រហូតដល់ថែមពិធីការមួយចំនួន ជាបែបព្រហ្មញ្ញសាសនាលាយឡំផង ព្រោះជនជាតិខ្មែរ មានគំនិតជាប់ឥទ្ធិពលព្រហ្មញ្ញសាសនាមុន ។ ក្នុងសម័យដែលព្រះពុទ្ធសាសនាកំពុងរុងរឿងក្នុងអំណាចកម្ពុជា ពួកបុរាណាចារ្យរាជបណ្ឌិតខ្មែរយើង បានរៀបចំបុណ្យ ទំនុកបំរុងព្រះសង្ឃក្នុងពេលចាំវស្សា នេះដែលកំណត់ឱ្យឈ្មោះថា បុណ្យបិណ្ឌភ្ជុំនឹងកំណត់រយៈពេលធ្វើ ១៥ថ្ងៃ ពីថ្ងៃ ១ រោចដល់ថ្ងៃ ១៥រោចខែភទ្របទ ជាពិធីបុណ្យឧទ្ទិសកុសលដល់បេតជនជាញាតិដែលស្លាប់ទៅនោះ ហើយអាចារ្យខ្លះសំអាងតាមគម្ពីរបេតវត្ថុ គម្ពីរវិមានវត្ថុ ។ អាចារ្យខ្លះថា ធ្វើតាមរឿងព្រះបាទ ពិម្ពិសារ ឬក៏ធ្វើតាមតម្រាប់តាមនាងឧត្តរាធ្លាប់ធ្វើ ......... ជាដើម ក៏ដូចគ្នាដែរមានប្លែកគ្នាខ្លះតាមទម្លាប់ កន្លែងនិមួយៗដែលមានការរៀបចំជាបាយបិណ្ឌ ឬបន្ថែមបាយបត្តបូរណ៍.ប៉ុណ្ណោះ ទើបជាប់ជាតំណមកដល់សព្វថ្ងៃនេះ ។

យើងចាប់ផ្តើមធ្វើបុណ្យដាក់បិណ្ឌ ១៥ថ្ងៃគឺ ១រោច ដល់ថ្ងៃ ១៥រោច ខែភទ្របទ ។ មិនតែប៉ុណ្ណោះកន្លែងខ្លះធ្វើត្រឹមតែ ១០ថ្ងៃ ហើយកន្លែងខ្លះទៀតរួញរហូតនៅតែ ៥ថ្ងៃ និងថ្ងៃភ្ជុំដែលគេហៅថា ដាក់បិណ្ឌ ៥នោះឯង ។ រួចបញ្ចប់ថ្ងៃ ១៥រោចខែភទ្របទជាថ្ងៃភ្ជុំដូចគ្នា អាស្រ័យជីវភាពប្រជាជនក្នុងតំបន់នោះតាមសម័យកាលនោះៗ ។ ព្រោះតែការរួញពេលវេលានេះហើយទើបក្នុង



www.elibraryofcambodia.org

សង្ឃបវារណាចេញវស្សា ១៥កើតខែអស្សុជ ខ្មែរយើងប្រារព្ធធ្វើបុណ្យថ្ងៃនេះ ១ថ្ងៃទៀតហៅថាចេញព្រះវស្សា ( **បណ្តែតប្រទីប** ) ។ បុណ្យនេះមានពិធីកម្ម និងលក្ខណៈប្រហាក់ប្រហែលគ្នានឹងបុណ្យភ្ជុំបុណ្យដាក់បិណ្ឌតាមវេនទិមួយៗ;ឯចំណុះជើងវត្តណាមានចំនួនវេនតូចៗ តាមទម្លាប់ធ្វើចង្ហាន់រាល់ថ្ងៃគ្រប់ ១៤វេនស្រាប់ក៏ល្មមទៅ. បើច្រើនក៏បង្រួមគ្នាឱ្យបានត្រឹម ១៤ក្រុមនោះឯង ។ បើកន្លែងទីក្រុងទីផ្សារ ច្រើនផ្តល់បច្ច័យឱ្យអាចារ្យយាយតាគណៈកម្មការវត្ត ធ្វើចង្ហាន់ប្រចាំថ្ងៃតាំងពីបិណ្ឌមួយទៅ ហើយអ្នកដទៃអាចធ្វើថ្ងៃណាជាឯកជនថែមមកក៏បាន ។ ប៉ុន្តែទោះធ្វើជាក្រុមវេនក្តីប្រមូលឱ្យយាយតា ធ្វើនៅវត្តក្តីក៏ក្នុង ១៤ថ្ងៃ គិតពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោចខែភទ្របទ នេះកំណត់ឱ្យឈ្មោះថា បុណ្យដាក់បិណ្ឌ ។ នៅថ្ងៃ ១៥រោចខែភទ្របទនេះមិនមានក្រុមវេនទេ គឺគេ រួមគ្នាចំណុះជើងវត្តទាំងអស់ដែលបានធ្វើទាំង ១៤បិណ្ឌនោះរួមធ្វើ១ថ្ងៃហៅថា ថ្ងៃភ្ជុំគឺ (**បុណ្យភ្ជុំបិណ្ឌ**) ។ ចំពោះថ្ងៃដាក់បិណ្ឌទិមួយៗមេវេនចាត់ចែងជា៣ឬ៤ ក្រុមតូចធ្វើយាគូឬធ្វើភត្តាហារជា៣-៤ឆ្នាំងស្មើ ៣ឬ៤មុខម្ហូប ។ (តំបន់ខ្លះដែលក្រុមវេននៅឆ្ងាយពីវត្ត គេបរទេះដឹកអីវ៉ាន់ ប្រដាប់ប្រដា ធ្វើបុណ្យទៅដេកនៅវត្ត ដើម្បីប្រារព្ធពិធីតាមវេនខ្លួន) ។ ពេលទូងស្គរចំណាំវស្សា អ្នកក្រុមវេនចាប់ផ្តើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុងក្រុមវេន យកផ្ទះណាមួយ ទៅនាំគ្នាប្រមូលនំនែករៀបចំបាយបិណ្ឌ បាយបត្តបូរណ៍ រៀបរួចហើយគាត់នាំគ្នាទៅវត្តស្តាប់លោកសូត្រថ្វាយបង្គំធម៌សុខោ និង ធម៌បរាភវសូត្រ ។ កូនចៅនៅឯផ្ទះគេខំដុតដៃដុតជើងបបរឬស្លស្លុកតាមមុខ ម្ហូបដោយឡែកៗ ក្នុងភាពសប្បាយរីករាយ ។



www.elibraryofcambodia.org

ព្រឹកព្រាង អរុណោទ័យ ពួកគេនាំគ្នារៀបចំខ្លួន កណ្ដៀត យួរ កាន់ ខ្លះទូល វែក សែង ចង្ហាន់ទៅវត្ត ។ គេធ្វើពិធីរាប់បាត្រជាមួយបរិស័ទ ស្រី ប្រុស ចាស់ ក្មេង លើឧបដ្ឋានសាលាយ៉ាងកកកុញកុះករនិងរៀបចំចង្ហាន់ ។ លោកអាចារ្យវត្តជាប្រធានបាននាំបរិស័ទវេរចង្ហាន់ប្រគេនព្រះសង្ឃ វេរបាយបត្តបូរណ៍ ។ល។ ព្រះសង្ឃធ្វើបត្តានុមោទន គាថា ដោយ **តិរោកុឌ្ឌសូត្រ-អទាសិមេ-យទិហិនេ** ឬ **បច្ចយាការ** ( អវិជ្ជា ) ឬក៏ **កុសលា ធម្មា** ។ល។ សមគួរតាមពេលវេលា ។ ពេលអង្គាសចង្ហាន់ហើយ មេវេននាំក្រុមវេនរៀបចំម្ហូបអាហារ ចំណីចូលគំនាប់ជូនលោកអាចារ្យវត្តព្រមទាំងចាត់ចែងភោជ-នាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យ ក្នុងវេនរបស់ខ្លួន នោះផងដែរ ។

លុះពេលថ្ងៃត្រង់ ក្រុមវេនដដែលនេះ ធ្វើភត្តាហារចង្ហាន់ផ្សេងៗយកទៅប្រគេនព្រះសង្ឃទៀត ។ ពេលរសៀលក្រុមវេននិមួយៗ នាំគ្នាសរុបធ្វើភេសជ្ជៈប្រគេនព្រះសង្ឃហើយវត្តខ្លះមានទេសនាមហាជាតក៍ ( រឿងព្រះវេស្សន្តរ ) តាមលំដាប់កណ្ឌ័តាមលំដាប់វេនផងដែរឬក៏ទេសនាធម៌ណាតាមព្រះធម្មកថិកចេះចាំ ។ សូមបញ្ជាក់ថា ក្រុមវេននិមួយៗ ក្រៅពីចំណាយធ្វើចង្ហាន់ ភេសជ្ជៈ ក៏នៅមានសល់បច្ច័យសំរាប់តម្កល់កសាងវត្តអារាមគ្រប់វេនផងដែរ ។ ការរៀបរាប់មកនេះគ្រាន់តែសេចក្ដីខ្លីៗនៃពិធីធ្វើបុណ្យដាក់បិណ្ឌ តាមថ្ងៃតាមក្រុមវេននិមួយៗ ប៉ុណ្ណោះដើម្បីជាពន្លឺខ្លះៗដល់ជនានុជនដែលពុំធ្លាប់ដឹង ។ ការធ្វើនេះតាំងពីបិណ្ឌ ១ ( ថ្ងៃ១រោចខែភទ្របទ ) តទៅដល់ ថ្ងៃ១៤រោច គឺ១៤ថ្ងៃ ហៅថាបុណ្យដាក់បិណ្ឌ ។ ក្នុងបិណ្ឌនិមួយៗនេះមានរៀបបាយបត្តបូរណ៍គ្រប់វេនហើយជារៀងរាល់ព្រឹកនោះ គេធ្វើបាយបិណ្ឌ សំរាប់បញ្ជូនទៅឱ្យពួកប្រេតទៀតផង ។



www.elibraryofcambodia.org

តើអ្វី ទៅជាបាយបិណ្ឌ. បាយបត្តបូរណ៍. ? ហើយគេធ្វើនៅពេលណា ? ធ្វើដើម្បីអ្វី ?

**បាយបិណ្ឌ** : ពាក្យថា ( បាយបិណ្ឌ ) នេះពុំមែនបាយដែលយកទៅរាប់បាត្រ ឬប្រគេនព្រះសង្ឃនោះទេ គឺជាបាយម្ហូបចំណី បង្អែម ចំអាប គេដាក់បញ្ចូលគ្នា តែ១ចាន ឬ១ជើងស្រាប ដោយឡែកប៉ុណ្ណោះ ។ សេចក្តីថា លោកយាយចាស់ទុំក្នុងវេនក្តី អ្នកក្រៅក្តី និយាយរួមរាល់ថ្ងៃដាក់បិណ្ឌគាត់មានគ្នាជិតខាង ពេលស្តាវស្សាបន្ទីឡើង គាត់មកជួជុំគ្នាក្នុងផ្ទះណាមួយ ហើយដាក់បាយបន្តិចម្នាក់ៗ ប្រមូលដាក់ចាន១ ឬជើងស្រាបតូច ១ ដាក់ម្ហូប មានទឹកមានពោតមានគ្រឿងតាមលទ្ធភាព រួចចិត្តនំឬត្របែកទុំ ឬ ល្ហុងទុំផងជាដើម ដាក់ចម្រុះគ្នាហើយអុជទៀន ធូប ប្រួចទឹកតិចៗនិយាយអញ្ជើញព្រលឹង ញាតិមិត្ត ម៉ែឪស្លាប់ទៅឱ្យមកទទួលសោយនូវអាហារចំណី ដែលកូនចៅបានរៀបជូន ។ ច្រើនតែយាយៗពេលធ្វើកិច្ចនេះចប់ហើយ នាំគ្នាកាន់បាយបិណ្ឌទៅវត្តតែម្តង ។ ឯក្មេងៗនៅស្លស្លុក ។ ពេលលោកសូត្រធម៌សុខោ និងបរាចប់ គាត់យកបាយបិណ្ឌនេះទៅចាក់ត្រង់គល់ឈើ ឬ ជ្រុងវិហារ អុជធូបនិយាយតាមនិយម រួចត្រឡប់មកឧបដ្ឋានសាលាវិញ ។ កន្លែងខ្លះវេរចង្ហាន់រួចហើយ ទើបយកបាយបិណ្ឌទៅចាក់ដូចគ្នានេះ ។

**បាយបិត្តបុរ** ពុំមែនជាបាយទេ គឺជានំ ផ្លែឈើសុទ្ធៗសព្វមុខ សំរាប់បំពេញបន្ថែមឱ្យសម្បូណ៌ លើចង្ហាន់បិណ្ឌបាតរបស់ក្រុមវេននិមួយៗដែលម្នាក់ៗគេបំរុងទុក ពេលស្តាវស្សាទូងឡើង ចាស់ៗរៀបបាយបិត្តបូរនោះកាន់ អន្សម នំគម នំ ផ្លែឈើសព្វមុខយកមកដាក់រួម គ្នាក្នុងល្អី ឬ ថាសធំ



www.elibraryofcambodia.org

ឬចានដែក ( ខ្លះរបស់នេះខ្លះរបស់នោះ ) ហើយធ្វើជាផ្កាឬទង់ដោតចំកណ្ដាល តេក៏អុជធូបឧទ្ទិសកុសល ម្ដងរួចហើយ នៅឯផ្ទះជុំគ្នានោះ រួចនាំយកទៅវត្ត ទុកវេរប្រគេនព្រះសង្ឃជាមួយគ្នា និងយាគូឬភត្តាហារភោជនក្នុងក្រុមវេនរបស់ គេនោះម្ដង ។

ដូច្នេះពាក្យថាបាយបត្តបូរណ៍ ឬបាយបិតបូរ. ពុំមែនជាបាយនោះទេ គឺ ជានំនែកនិងផ្លែឈើសុទ្ធ ជាវត្ថុសំរាប់បំពេញបន្ថែម ឱ្យកាន់តែសំបូរបែបលើ ចង្ហាន់ បិណ្ឌបាត បង្ហែមចំអាបរបស់ក្រុមវេន គេនោះឯង ។

## បុណ្យភ្ជុំ ឬ ភ្ជុំបិណ្ឌ

ឆ្លៀតឱកាសនេះ បញ្ជាក់ជូនពាក្យខ្មែរ " បុណ្យបិណ្ឌភ្ជុំនិង" បុណ្យភ្ជុំបិណ្ឌផ្សេង គ្នា " មួយឆ្នាំយើងធ្វើបុណ្យ បិណ្ឌភ្ជុំ ម្ដង ឬ និយាយថា " ជិតដល់ថ្ងៃបុណ្យ បិណ្ឌភ្ជុំហើយ " ។ ពាក្យថា " បិណ្យភ្ជុំ " នេះគឺជាឈ្មោះបុណ្យទាំងមូល ហើយ ចែកជាពីរឈ្មោះគឺ បុណ្យដាក់បិណ្ឌមួយថ្ងៃ១ បន្តបន្ទាប់ដោយឡែក១ ដូចជា បិណ្ឌ១ បិណ្ឌ២..... ។ល។ រហូតដល់ថ្ងៃ១៤ ជាបុណ្យដាក់បិណ្ឌទី១៤ មួយប៉ែក នៅថ្ងៃក្រោយតែមួយថ្ងៃគឺ ថ្ងៃ១៥រោចខែភទ្របទ គេហៅថា បុណ្យភ្ជុំ ។ ដូចនេះសរុបឈ្មោះទាំងពីរបញ្ចូលគ្នាហៅថា " បុណ្យបិណ្ឌភ្ជុំ" ដាក់ពាក្យ( បិណ្ឌ) ខាងដើមព្រោះមិនដល់ថ្ងៃភ្ជុំ គេធ្វើបុណ្យដាក់ បិណ្ឌសិន ។

ឯពាក្យថា ( បុណ្យភ្ជុំបិណ្ឌ) ឃើញដាក់ពាក្យ( ភ្ជុំ) ខាងដើមគឺបុណ្យភ្ជុំ នេះឯងតែមួយថ្ងៃ ។ តែជួនកាលគេហៅថា ទៅបុណ្យភ្ជុំ ខ្លះគេហៅថា ( ទៅធ្វើបុណ្យភ្ជុំបិណ្ឌ) ក្នុងន័យថាប្រជុំរួមអ្នកធ្វើបុណ្យដាក់បិណ្ឌតាមវេននីមួយ១ នោះមករួមគ្នាធ្វើ ឬ ភ្ជុំគ្នាធ្វើ មិនជាក្រុមវេនណាម្នាក់គឺធ្វើសរុបទាំងអស់គ្នា



www.elibraryofcambodia.org

តែម្តង។ នៅថ្ងៃ១៥កើតខែភទ្របទ (បន្ទាប់ពីពុទ្ធបរិស័ទធ្វើបុណ្យដាក់បិណ្ឌ អស់១៤ថ្ងៃ ពីខាងដើមមកហើយ) ក៏ហៅបុណ្យភ្ជុំឬហៅថា " បុណ្យភ្ជុំបិណ្ឌ " គឺ ប្រជុំបិណ្ឌខាងដើម ទាំងអស់មករួមគ្នាធ្វើតែមួយថ្ងៃទៀត ។

បុណ្យភ្ជុំនេះ ពុទ្ធសាសនិកខ្មែរ បានចាត់ទុកថា ជាបុណ្យធំមួយរបស់ខ្លួនតដូនតាមកយូរហើយ ញាតិសាច់សាលោហិត កូនចៅ ចៅសន្តានដែលរស់នៅឆ្ងាយៗក៏តែងវិលមកភូមិកំណើតចូលរួមជួបជុំបងប្អូននៅថ្ងៃភ្ជុំភ្ជួរនេះ ។ ( ត្រង់នេះក៏បញ្ជាក់នូវគំនិតស៊ីជម្រៅ ដ៏វៃឆ្លាតនិងគោលបំណងរបស់បុរាណាចារ្យខ្មែរយើង ដែលដាក់ឈ្មោះបុណ្យនេះថា **បុណ្យភ្ជុំ** គឺ " ភ្ជួរត្រូវតែមុំ ថ្ងៃភ្ជុំត្រូវតែមក " ។

ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដូចនេះមន្ត្រីរាជការទាំងឡាយក៏ត្រូវបានច្បាប់អនុញ្ញាតឈប់សំរាក ដើម្បីទៅធ្វើបុណ្យភ្ជុំនេះដែរ ។ កាលបើថ្ងៃស្អែកជាថ្ងៃភ្ជុំ ពុទ្ធសាសនិកគ្រប់គ្រួសារបានខ្វល់ខ្វាយវេចនំបុ័ង ស្មោរ នំអន្សម នំបត់ នំគម នំជាល នំនាល ។ល។ ខ្លះទិញនំចុង នំប៉ោត ផ្លែឈើផ្សេងៗ ត្រៀមទុកតាំងពីថ្ងៃ ១៤រោចជាស្រេច ។

## ថ្ងៃភ្ជុំ

ស្គរចំណាំវស្សា បន្លឺឡើងយឺតៗហើយរន្ថើនៗឡើង រោទិ៍តាមរបៀបនេះ ៣បទ ។ នៅវេលាប្រហែលម៉ោង ៤ភ្លឺ មាន់រងាវមីក្រូក្នុងវត្ត ក៏បន្លឺសម្លេងយ៉ាងរណ្តំ មិនយូរប៉ុន្មាន តាមមីក្រូយើងឮសូរសព្ទធម៌នមស្ការរូចបទបរាភវសូត្ររបស់ព្រះសង្ឃយ៉ាងពិរោះ គួរឱ្យព្រឺព្រួចសង្វេគនិងជ្រះថ្លា ។



www.elibraryofcambodia.org

លោកយាយលោកតាបានរៀបចំខ្លួន ដើម្បីទៅវត្ត ។ យាយតាថ្ងៃនេះក៏ដូចជាថ្ងៃដាក់បិណ្ឌដែរ មកជួបជុំគ្នាតាមក្រុម រៀបចំបាយបិណ្ឌ បាយបត្តបូរណ៍រួចទើបទៅវត្តឱ្យទាន់ព្រះសង្ឃសូត្រ **មរាគចស្វូត្រ** ។ រីឯកូនចៅនៅឯផ្ទះក៏ដាំស្លធ្វើចង្ហាន់ដាក់ជាស្រាក់ខ្លះ ជាឆ្នាំងខ្លះ ជាស្តុកខ្លះ តាមគ្រួសារនិមួយៗរៀងរាល់ផ្ទះ ។ រួចហើយគេស្អិតស្អាងកាយ ស្លៀកពាក់ស្អាតៗនាំប្តី ប្រពន្ធ កូន បង ប្អូនកំលោះក្រមុំ ក្មេងចាស់នាំគ្នាយួរស្រាក់ កណ្តៀតបាយ ពិសេសនំអន្សមនំគម គ្រប់គ្រួសារយកទៅវត្តនៅពេលភ្លឺស្រាងៗ ។ នៅលើឧបដ្ឋានសាលាយើងឃើញមនុស្សម្នា មហាជនក្មេងចាស់កុះករ ច្រាលមកនៅខាងក្រៅសាលាពង់ខាងក្រោមសាលាទៀត ឯកង់ ម៉ូតូ ឡាន ក៏នៅដំរៀបក្រោមដើមឈើក្បែរសាលា ។

ពេលពេញពន្លឺនោះ ក្រោយពីលោកអាចារ្យវត្ត នាំនមស្ការថ្វាយបង្គំសមាទានសីលរួច ក៏ចាប់ផ្តើមពិធីរាប់បាត្រ ។ ទស្សនីយភាពនៃការរាប់បាត្រចាប់ផ្តើមជាសង្កាត់ៗ លោកតាៗលោកយាយៗ វ័យកណ្តាលស្រីប្រុស កម្លោះក្រមុំ យុវជន យុវនារី និងកុមារា កុមារី ជាបន្តួរជាទីពិតពិលរមឹលមើល លើបែបបទកាយវិការសំលៀកបំពាក់ ចម្រុះពណ៌ ផ្កាផ្លែកៗគ្នា សក្តិសមដោយយ៉ាងៗ ។ ជាមួយគ្នានោះព្រះសង្ឃបាំងធ្លិត ស្វាធ្យាយធម៌ សត្តប្បករណ៍ បន្តរណ្តំមិនដាច់សូរ ។ បើងាកមើលទៅឆ្វេងខាងមុខព្រះពុទ្ធបដិមា ចំពីខាងដើមព្រះភិក្ខុ ដើមអាសនៈ យើងឃើញមានល្អីចាស ចានដែកដិកល់បាយបត្តបូរណ៍ជាច្រើននិងមានគំនរនំនែក អន្សមធំៗដាក់ដំរៀបលើកន្ទេលគរដូចភ្នំ ហើយនំអន្សមនេះ ចេះតែកើនឡើងៗ តាមចំនួនអ្នកទៅបុណ្យ ដែលមុនឬក្រោយរាប់



www.elibraryofcambodia.org

បាត្រគេនាំយកម្នាក់មួយឬពីរអន្សមទៅដាក់កន្លែងនោះជាបាយបត្តបូរណ៍ដែរ សំរាប់ភ្ជុំនេះ ។ រយៈកាលរាប់បាត្រ ប្រហែលជាងមួយម៉ោង ទើបចប់ ពួ១រៀបចំយកបាត្រមកដាក់ចំពោះព្រះភក្ត្រព្រះសង្ឃ រួចហើយលោកអាចារ្យ ប្រាប់ឱ្យម្ចាស់ទានកាន់ចង្ហាន់រៀងខ្លួន ដើម្បីវេរចង្ហាន់ គឺថាតាមលោកអា- ចារ្យ ។ ចប់ហើយក៏ចូលទៅប្រគេនចង្ហាន់ដល់ព្រះសង្ឃបន្ទាប់មកព្រះសង្ឃ ធ្វើភត្តានុមោ ទនា គាថា ៣ឬ៤មេ ហើយក៏ធ្វើភត្តកិច្ចតទៅ ។

ឆ្លៀតឱកាសនោះ លោកអាចារ្យឬប្រធានគណៈកម្មការវត្ត ប្រកាស តាមបញ្ជីនូវបច្ច័យ សង្កត់បាយបត្តបូរណ៍គ្រប់ក្រុមវេនរួមនិងបច្ច័យចូលបុណ្យ ថ្ងៃភ្ជុំនេះផង សរុបឱ្យដឹងគ្រប់គ្នាជាបច្ច័យសំរាប់កសាងដែរ ព្រមទាំង បន្ថែមអំពីការដង្ហែអង្គផ្កា តាមក្រុមវេននិមួយ១ នៅរសៀលម៉ោងប៉ុណ្ណេះ ប៉ុណ្ណោះទៀតផង ។

ពេលព្រះសង្ឃធ្វើភត្តកិច្ច ( ឆាន់ ) រួចត្រូវភារៈគណៈកម្មការវត្តអ្នក រៀបភោជនាហារថ្ងៃនេះជូនអតិថិជន ដោយភាពស្និទ្ធស្នាលរីករាយក្រៃ លែង ។ ការធ្វើចង្ហាន់ទាំងព្រឹកទាំងថ្ងៃត្រង់ក្នុងថ្ងៃភ្ជុំនេះគឺគេធ្វើទាំងអស់គ្នា ។

បញ្ហាចង្ហាន់ថ្ងៃភ្ជុំនេះ វត្តខ្លះសំបូរកុះករ ទាំងមនុស្សទាំងចង្ហាន់ ធំនែកនៅពេលព្រឹក ព្រោះគេរាប់បាត្រពេលព្រឹក ដោយគេយល់ថារាប់បាត្រ ពេលព្រឹក បានក្មេង១រាប់ផង ពេលថ្ងៃក្មេងជាប់ឃ្វាលគោក្របីដើរកំសាន្ត ។ ដល់ចង្ហាន់ថ្ងៃត្រង់ គេធ្វើមិនរាប់បាត្រ គឺវេរប្រគេនព្រះសង្ឃតែម្តង ដើម្បី ពិតគួរផ្តាបន្ថែមទៀត ។



www.elibraryofcambodia.org

វត្តខ្លះពេលព្រឹកគេធ្វើរួម យាគូឬចង្ហាន់ដែរ តែមិនយូរ ហើយលុះពេលថ្ងៃត្រង់ ប្រហែលម៉ោង៩ទៅទើបកកកុញកុះករឈូរឆរទាំងមនុស្សសម្បូរទាំងចង្ហាន់នំនែក ព្រោះគេរាប់បាត្រពេលថ្ងៃ គេថាមានពេលវែងអ្នកមកមុនរាប់បណ្តើរៗ បន្តគ្នា មិនប្រជ្រៀតគ្នា ក្មេង ចាស់គ្រប់រូបមករាប់ក៏បាន ។

សរុបមក ស្រេចតែតាមទម្លាប់ តាមនិយមរបស់កន្លែងនិមួយៗ ពុំមានខុសទាស់ឬខាតខានអានិសង្ស ដោយសារពេលព្រឹក ឬពេលថ្ងៃនេះទេ ។ កាលត្រឡប់ពីធ្វើចង្ហាន់ថ្ងៃត្រង់ទៅដល់ផ្ទះ មិនយូរប៉ុន្មាន ពុទ្ធសាសនិកគ្រប់គ្រួសារយកបច្ច័យតាមសទ្ធា មករួមគ្នានៅផ្ទះមេវេន ឬ កន្លែងកំណត់ចូលបុណ្យចងផ្កាតាមវេនរៀងៗខ្លួន ។ ហើយយ៉ាងយូរប្រហែលម៉ោង២រសៀល គេនាំគ្នាហែផ្កាតាមក្រុម ទៅជួបជុំគ្នាលើឧបដ្ឋានសាលា ។ កាលបើជួបជុំគ្រប់ក្រុមរ. ហើយ លោកអាចារ្យវត្តនាំដង្ហែ ហិរញ្ញបុប្ផា (ផ្កាប្រាក់) ឆ្ពោះទៅព្រះវិហារដែលពេលនោះស្គរ ជួង រគាំង មិត្រភ្លេង ពិណពាទ្យ ឆៃយ៉ាំ បន្លឺព្រម រណ្តំកងរំពង យ៉ាងគគ្រឹកគគ្រេង ។ ក្បួនដង្ហែហិរញ្ញបុប្ផា បានហែពទ្ធ័ប្រទក្សិណព្រះវិហារ ៣ជុំហើយចូលក្នុង ព្រះវិហារតំរៀបដើមផ្កាជាជួរ គួរឱ្យចង់ទស្សនា។ គណៈកម្មការវត្តពិតគូបញ្ជី បូកសរុបទឹកប្រាក់ ។ ឯលោកអាចារ្យនិងពុទ្ធបរិសទ័និមន្តព្រះសង្ឃមកអង្គាសភេសជ្ជៈ រួចនមស្សការ. សមាទានសីល. (ទេសនាត្រៃ១ - ឬត្រៃ ៣ នៅកន្លែងខ្លះ ) ចប់ហើយធ្វើពិធីប្រកាសបច្ច័យបុណ្យផ្កាថ្ងៃភ្ជុំ ប្រកាសចំណាយ ចំណូលនិងប្រាក់សរុបមួយរដូវបុណ្យបិណ្ឌភ្ជុំទាំងមូល ហើយធ្វើការវេរ ហិរញ្ញបុប្ផា (ផ្កាប្រាក់ ) ទុកសំរាប់កសាងវត្តអារាម ។

<u>*សូមបញ្ជាក់ថា*</u> : ក្នុងថ្ងៃភ្ជុំមានរៀបចំកញ្ចប់ ចតុប្បច្ច័យ (ស៊ីង ) ប្រ



www.elibraryofcambodia.org

គេនគ្រប់ភិក្ខុ សាមណេរ ។ ឯគណៈកម្មការវត្តបានចាត់ចែង ទំអន្សម ទំគមនិងនំនែក ដែលជាបាយបត្តបូរណ៍គរដូចភ្នំនោះឱ្យសិស្សគណទុកប្រគេន ភិក្ខុសាម ណេរតាមចំណែកសំរាប់ធ្វើចង្ហាន់ព្រឹកស្អែកផងដែរ ។

ម្យ៉ាងទៀត ថ្ងៃបុណ្យភ្ជុំបិណ្ឌនេះ ខ្មែរយើងពីដើមមានលេងល្បែងប្រណាំង ក្របី សេះ តាមកន្លែង គឺដោយគេថែបំប៉ន សំអាត សិរិតសម្រាំងក្របីស្ទាវៗ ស្អាតៗ ស្អាតតាំងពីរាង និងរង្វង់ស្នែង ចំនួន ៣ទៅ៤គូ ។ គេតុបតែងក្របីដោយ កោរសំអាត ខ្មៅរលើបរលោង ពាក់ប្រឡៅ កណ្ដឹងគ្រដោក ពាក់ស្លង់ចង្រ្កង់ ចុងស្នែងទាំងពីរ លាបប្រេង ហើយគេកំណត់ទីកន្លែងតាមថ្នល់មុខវត្តជាដើម ។ ពេលព្រឹកឬពេលរសៀលទាប គេជិះក្របីបំបោល ប្រណាំងគ្នា ជាល្បែងអបអរក្នុងបុណ្យភ្ជុំបិណ្ឌ បង្ហើយនេះ ។

កន្លែងខ្លះ ក៏មានលេងល្បែងផ្សេងពីនេះក៏មាន ប៉ុន្តែបច្ចុប្បន្ន ចេះតែបាត់ទៅៗ ពោលនាការតែតន្លងវែងទៅ ពិធីកម្មនៃបុណ្យ ចេះតែរួញថយទៅៗ ច្រើនណាស់ដែរ ។



www.elibraryofcambodia.org

# បុណ្យចេញវស្សា

## អារម្ភកថានៃបុណ្យ

ការចេញវស្សា មានតែក្នុងព្រះពុទ្ធសាសនា ដែលព្រះបរមគ្រូទ្រង់អនុញ្ញាតដល់សាវ័ក ឱ្យចូលវស្សាអស់ ៣ ខែ ហើយ ត្រូវធ្វើពិធីចេញវស្សា ។ ប៉ុន្តែថ្ងៃចេញវស្សា ចំលើថ្ងៃ ១៥ កើតខែអស្សុជ ដែលជាថ្ងៃឧបោសថរបស់ភិក្ខុសង្ឃ ។ ហេតុនេះការចេញវស្សា ត្រូវធ្វើដោយ **បវារណាកម្ម** ទម្លាប់ហៅថា បវារណាចេញវស្សា ។ ការធ្វើបវារណាចេញវស្សានេះ ជាសង្ឃកម្មមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងឧបោសថកម្ម ត្រង់បុព្វករណ៍-បុព្វកិច្ចរបស់បវារណាកម្ម ហើយមានតាំងញត្តិញ៉ាំងសង្ឃ ឱ្យដឹងការងារត្រូវធ្វើផង ព្រោះតែ ផ្សេងខ្លឹមសារគ្នានៃបវារណាកម្មនិងឧបោសថកម្មប៉ុណ្ណោះ ។

កាលបើនិយាយពី ការចេញវស្សា ជាបវារណាកម្ម . ដូចនេះសង្ឃកម្មគឺយើងដឹងថាជាកម្មសំរាប់តែពួកភិក្ខុ ។ ព្រោះហេតុនោះទើបព្រះពុទ្ធជាម្ចាស់អនុញ្ញាត ការចូលវស្សា ឱ្យភិក្ខុសាមណេរ សូត្របាលីអធិដ្ឋាន ដូចគ្នា ។ តែពេលចេញវស្សា សាមណេរមិនបាច់ធ្វើពិធី សូត្របាលីចេញ វស្សាឡើយ ព្រោះសូត្របវារណាចេញវស្សាជាសង្ឃកម្ម ។ សាមណេរមិន អាចធ្វើសង្ឃកម្មបាន ។ ប៉ុន្តែរឿងសង្ឃកម្មផ្សេងៗ យើងមិនបានយកមកនិយាយក្នុងទីនេះទេ យើងនិយាយតែអំពីការចេញវស្សាមួយតែប៉ុណ្ណោះ ។ ការចេញវស្សា របស់ភិក្ខុសង្ឃ ផ្សេងពីការធ្វើកិច្ចចេញវស្សារបស់ពុទ្ធបរិសទ័ចំណុះជើងវត្ត ដែលគេហៅថា ( បុណ្យចេញវស្សា ) ឬ ( បុណ្យបណ្តែតប្រទីបផ្កាលាចេញព្រះវស្សា ) ។



www.elibraryofcambodia.org

# ពិធីចេញវស្សារបស់ភិក្ខុសង្ឃ :

ព្រះភិក្ខុទាំងឡាយ ដែលបានគង់ចាំវស្សា ក្នុងវត្តណាមួយអស់ត្រីមាសហើយគឺពី ថ្ងៃ១រោច ខែអាសាឍ ដល់ថ្ងៃ១៥កើតខែអស្សុជ ( ៣ខែ ) ថ្ងៃចុងក្រោយនេះគឺជាថ្ងៃបវារណា ចេញវស្សា ។ បវារណាថ្ងៃនេះ លោកហៅតាមថ្ងៃថា " **បណ្ណរសី បវារណា** " គឺបវារណា ថ្ងៃ១៥កើត ។ មុនពេលកំណត់ចូល ធ្វើបវារណា ពួកភិក្ខុ ត្រូវបំពេញបុព្វករណ៍ ៤ យ៉ាងនិងបុព្វកិច្ច ៥យ៉ាង ជាដាច់ខាត ។ បើភិក្ខុសង្ឃមិនធ្វើខ្លួនឯងឬមិនបានប្រើភិក្ខុថ្មីឱ្យធ្វើទេ ស្រាប់តែទៅបវារណាតែម្តងត្រូវអាបត្តិទុក្កដ ។ ឯបុព្វករណ៍ ៤យ៉ាងត្រូវធ្វើមុន សង្ឃទៅជួបជុំគ្នាគឺ " **សម្មជ្ជនី** " ការបោសសំអាតព្រះវិហារឧបោស ថាគារកន្លែងបវារណា១ " **បទីបៈ** " អុជប្រទីប១ ( បើពេលយប់ ) **ឧទកៈ** ( ការរៀបចំឱ្យមានទឹកសំរាប់ឆាន់ និង ប្រើប្រាស់១ ) **អាសនៈ** ការក្រាល អាសនៈ មានកន្ទេលជាដើម ១ ។

ចំណែកបុព្វកិច្ច ៥ ធ្វើមុនពេលសូត្របវារណា គឺធ្វើមុនពិធីតាំងញត្តិ នោះឯងមាន : **ឆន្ទៈ** ការនាំឆន្ទៈ១ **បវារណា** ការនាំបវារណា១ ( របស់ភិក្ខុក្នុងអាវាសនេះអង្គណាមិនបានចូលទៅធ្វើ ) **ឧតុក្ខានំ** : ( ការប្រាប់រដូវកាលដែលធ្វើបវារណានេះ១ ) ភិក្ខុគណនា = ការរាប់ចំនួនភិក្ខុ ( ដែលមកជុំគ្នាពេលនេះ១ ) ឱវាទោ ( ប្រាប់ថា: បច្ចុប្បន្នគ្មានភិក្ខុនីសំរាប់ឱ្យឱវាទ ទេ១ ) ។

លុះពេលវេលាដែលលោកត្រូវចៅអាវាសបានកំណត់មកដល់ហើយ ភិក្ខុទាំងឡាយត្រូវរៀបចំខ្លួនជា បរិមណ្ឌល ( សមណសារុប្បៈ ) ចូលទៅក្នុងព្រះវិហារ គង់នៅចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធបដិមា ហើយសំដែងអាបត្តិ



www.elibraryofcambodia.org

ចេញ រួចមកគ្រប់អង្គនមស្សការ ថ្វាយបង្គំព្រះរតនត្រៃ ចប់កាលណោះ ទើបសូត្រដោយញត្តិដើម្បីសួរបុព្វករណ៍បុព្វកិច្ច ដូចបានរៀបរាប់ខាងលើ ដោយភិក្ខុឈ្លាសប្រតិពលពីររូបគឺ មួយរូប អ្នកសួរនិង មួយរូបឆ្លើយ ( បាលី សួរ ឆ្លើយនៅក្នុងសៀវភៅភិក្ខុបាតិមោក្ខរបស់ព្រះធម្មរាមោ **ប៊ុណ្ណ សម្ភាជន៍** ត្រង់បវារណាកម្ម ) ។ បន្ទាប់មកភិក្ខុឈ្លាសមួយរូបតាំងញត្តិឡើង ។ បាលីតាំងញត្តិថា : **សុណាតុ មេ ភន្តេ សង្ឃោ អជ្ជប្បវារណា បណ្ណរសី ។ យទិ សង្ឃស្ស បត្តកល្លំ ។ សង្ឃោ តេវាចិកំ បវារេយ្យ ។**

កាលបើចប់ហើយ ទើបព្រះមហាថេរ (ចាស់វស្សាជាង គេ) អង្គុយច្រហោងអញ្ជលី បែរមករកសង្ឃ សូត្របវារណា ៣ ចប់ ។ តមក ភិក្ខុចាស់វស្សាជាលំដាប់ អង្គុយច្រហោង ផ្គងអញ្ជលីស្រាប់នោះ សូត្រ បវារណា នោះ ៣ ចប់ ដូច១គ្នាជាបន្តបន្ទាប់ រហូតដល់អស់ភិក្ខុដែលចូលទៅ បវារណានោះ ។ ហៅថា : **តេវាចិកប្បវារណា** ។

<u>បញ្ជាក់</u> ការសូត្របវារណា ភិក្ខុទាំងអស់ ត្រូវតែអង្គុយច្រហោង ជាដាច់ខាត ការសូត្របវារណា ត្រូវសូត្រមួយអង្គម្តង១តាមលំដាប់វស្សា ។ បើ ពេលមុនសូត្រឬកំពុងសូត្របវារណា ភិក្ខុណាអង្គុយរាបត្រូវ អាបត្តិទុក្កដ ។ ព្រះអង្គអនុញ្ញាតដល់ភិក្ខុដែលបានសូត្របវារណារួចហើយឱ្យអង្គុយរាបបាន ។

## <u>សង្ឃប្បវារណា</u>

ចំពោះបវារណា ដូចពោលខាងលើ ដែលបាននិយាយរួចមកហើយ ជាសង្ឃប្បវារណាសំដៅក្នុងវត្ត មានភិក្ខុពី ៥ អង្គឡើង ( បានកាន់វស្សា )



www.elibraryofcambodia.org

[illegible] ថា : [illegible] អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ

បដិករិស្សាមិ { ....ទុតិយម្បិ ភន្តេ សង្ឃំ បវារេមិ...... / ....តតិយម្បិ ភន្តេ......................ម }

( ការបវារណានេះ មានល្អិតល្អន់នៅក្នុងវិន័យបិដកមហាវគ្គភាគ៧ )

## គណប្បវារណា

( នេះជាឈ្មោះបវារណាចេញវស្សារបស់ភិក្ខុ ៤អង្គឬ ៣អង្គក្នុងវត្ត មួយ )

ដូចបានជ្រាបហើយថា "ការបវារណាចេញវស្សា" ជាបវារណាកម្ម ( សង្ឃកម្មដែលត្រូវប្រើសង្ឃបញ្ចវគ្គ គឺភិក្ខុពី៥អង្គឡើងទៅ ) ដូចនេះបើក្នុងវត្តមួយមានភិក្ខុតែបួនអង្គ ឬ បីអង្គគង់ចាំវស្សា មិនអាចធ្វើសង្ឃប្បវារណាទេ គឺត្រូវធ្វើជា" គណប្បវារណា" ។ ពិធីធ្វើគឺ : ភិក្ខុឈ្លាសវៃមួយអង្គញ៉ាំងភិក្ខុពាអង្គ ឬ ២អង្គក្រៅនេះឱ្យដឹងថា : "សុណន្តុ មេ អាយស្មន្តោ អជ្ជប្បវារណា បណ្ណរសី យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ តេវាចិកំ បវារេយ្យាម ។ តមកភិក្ខុចាស់វស្សាជាងគេអង្គុយប្រហោងផ្គងអញ្ជលី ពោល នឹងភិក្ខុពារូប ឬ២ រូបទៀតថា : "អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា..." ( ពាដង ) ។ ដូចបាលីក្នុងសង្ឃប្បវារណា ខុសតែខាងដើមជាសង្ឃ ប៉ុណ្ណោះ ។ តមកភិក្ខុមានវស្សាចាស់បន្តបន្ទាប់សូត្ររកភិក្ខុទាំងនេះ តាមលំដាប់ពាចប់។ ។



www.elibraryofcambodia.org

<u>គណប្បវារណា</u> ដែលចំពោះភិក្ខុក្នុងវត្តមានតែ ២រូប ។ បើក្នុងវត្តមួយមានភិក្ខុចាំវស្សាតែ២អង្គ ត្រាំតែបវារណាដល់គ្នានឹងគ្នា គឺភិក្ខុចាស់វស្សាផ្គងអញ្ជលីពោលទៅភិក្ខុខ្ចីវស្សាថា : **អហំ អាវុសោ អា-យស្ម-ន្តំ បវារេមិ ទិដ្ឋេន វា...។ល។ ទុតិ តតិយម្បិ...។ល។** ទើបភិក្ខុខ្ចីបវារណា និងភិក្ខុចាស់ថា · **អហំ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេនវា បរិសង្កាយ វា វទន្តុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ៗ ទុតិ.....តតិ ៗ**

<u>អធិដ្ឋានប្បវារណា</u> ការបវារណារបស់ភិក្ខុមានតែមួយរូបក្នុងវត្ត ។ បើវត្តមួយមានភិក្ខុចាំវស្សាតែមួយអង្គ លោកប្រាប់ថា បើបវារណាត្រូវរៀបចំកន្លែង ចាត់ចែងបុព្វករណ៍ ហើយរង់ចាំភិក្ខុដទៃទៀត បើឃើញថាគ្មានទេ ត្រូវអធិដ្ឋានម្នាក់ឯងថា **អជ្ជ មេ បវារណា** " ថ្ងៃនេះជាថ្ងៃបវារណារបស់អាត្មាអញ ប៉ុណ្ណោះជាការស្រេច " ។

## <u>ពិធីបុណ្យចេញវស្សារបស់ពុទ្ធបរិស័ទជាគ្រហស្ថ</u>

( មិនមែនជាលក្ខណៈវិនយបញ្ញត្តិទេ )

នៅថ្ងៃ ១៥កើតខែអស្សុជ ពុទ្ធមាមកជន ចំណុះជើងវត្តនិមួយៗតែងតែធ្វើបុណ្យមួយហៅថា " បុណ្យចេញវស្សា " ដើម្បីសំដែងសេចក្តីត្រេកអរជ្រះថ្លា ចំពោះភិក្ខុសាមណេរ ដែលបានប្រតិបត្តិត្រឹមត្រូវ , មិនឱ្យដាច់វស្សាមានសាមគ្គីភាពល្អរយៈពេល ៣ខែ ក្នុងវស្សានោះ ។ បុណ្យចេញ វស្សាពីសម័យពុទ្ធកាល គេធ្វើផ្សេងពីសម័យបច្ចុប្បន្ន ។ ឯសម័យក្រោយ ពុទ្ធកាល



www.elibraryofcambodia.org

ក៏ខុសគ្នាតាមបែបបុរាណនិយម និងសម័យនិយម ពីពីបុរាណធ្វើបុណ្យចេញវស្សា មានបណ្តែតប្រទីបផ្កាលាផង មិនចាំបាច់តែវត្តជាប់មាត់ទន្លេឬមាត់ស្ទឹងនោះទេ សូម្បីតែវត្តដែលគ្មានព្រែករំលេចទន្លេ ក៏គេធ្វើពិធីបណ្តែតប្រទីបនៅក្នុងស្រះដែរ ។

ឯបច្ចុប្បន្នសម័យយើងឃើញមានតែកន្លែងមួយចំនួនប៉ុណ្ណោះ ដែលធ្វើពិធីបណ្តែតប្រទីប ។ ចំណែកបុណ្យចេញវស្សា នៅមានគ្រប់វត្ត គ្រាន់តែតូច ធំ មធ្យម ឬ ឧឡារិក ផ្សេងៗគ្នាតាមវត្តនិមួយៗ ។

<u>បុណ្យចេញវស្សាក្នុងសម័យពុទ្ធកាល</u> : ថ្ងៃចេញវស្សាគឺជាថ្ងៃចុងបង្ហើយនៃបុណ្យដាក់បិណ្ឌឬជាថ្ងៃចុងក្រោយនៃសង្ឃភត្តចំណាំវស្សា ៣ខែ គឺបុណ្យភ្ជុំនោះឯង ។ សេចក្តីថា : ក្នុង ៣ខែ ដើមវស្សានរដូវនេះ ព្រះពុទ្ធជាម្ចាស់ព្រះអង្គអនុញ្ញាត ឱ្យភិក្ខុសង្ឃសាមណេរ នៅចាំវស្សា ( ចូលវស្សា ) មិនឱ្យត្រាច់ចរចេញដំណើរទៅណាមកណា ត្រូវសម្ងំនៅបំពេញវត្តបដិបត្តិក្នុងអារាមហើយចូលវស្សាក្នុងទីណា ភិក្ខុត្រូវសុំឱ្យបរិស័ទទីនោះជួយឧបត្ថម្ភទំនុកបំរុង ដោយបច្ច័យ ៤ ក្នុងរយះពេល ៣ខែ នេះតែម្តង ។ សម័យនោះមានជនអ្នកមានសទ្ធាជាច្រើន ដូចជាយាយ ឧបាសិកា វិសាខាជាដើម តែងបវារណា ទំនុកបំរុងព្រះសង្ឃក្នុងវត្តនិមួយដោយបច្ច័យ ៤ មិនបាច់ចេញគោចរបិណ្ឌបាត តាំងពីថ្ងៃចូលវស្សា រហូតដល់ថ្ងៃចេញវស្សា គឺគេធ្វើជា **វារភត្ត** ( ចង្ហាន់រាល់ថ្ងៃ ) ឬ ហៅថា ដាក់បិណ្ឌ ( យកចង្ហាន់ទៅរាប់បាត្រក្នុងវត្ត ) ជាប្រចាំមាន នំនែក បង្អែម ចំអាប ជាស្រាក់ជាឆ្នាំងក៏មាន ។ គេធ្វើចង្ហាន់នេះហៅថា **និច្ចភត្ត** ក៏បាន ។ លុះដល់ថ្ងៃចេញវស្សា ជាថ្ងៃចុងក្រោយបង្អស់នៃ



www.elibraryofcambodia.org

បុណ្យនៅថ្ងៃក្នុងវស្សានោះ គេក៏ធ្វើបុណ្យដែលនេះរួមតែម្តងនៅ១ថ្ងៃ ចំថ្ងៃចេញវស្សាដែលសព្វថ្ងៃយើងកំណត់ហៅថា **បុណ្យភ្ជុំ** គឺភ្ជុំរួមបុណ្យកុសលទាំងឡាយ ឧទ្ទិសជូនបុព្វការីជន ធ្វើពិធីដាឆ្លងបុណ្យបិណ្ឌ ៣ខែ នោះឯង ។ ដូច្នេះបុណ្យចេញវស្សាសព្វថ្ងៃនេះ គឺជាបុណ្យភ្ជុំ ពីសម័យពុទ្ធកាលឯណោះទេ ។

ដោយសារតែសម័យបច្ចុប្បន្ន ពុទ្ធបរិស័ទធ្វើបុណ្យបិណ្ឌភ្ជុំ ត្រឹមតែ១៥ថ្ងៃក្នុងរនោច ខែភទ្របទ ទើបដល់ថ្ងៃ១៥កើតខែអស្សុជ ដែលជាថ្ងៃបវារណាចេញវស្សាគេនាំគ្នាធ្វើបុណ្យមួយថ្ងៃនេះទៀតហៅថា "**បុណ្យចេញវស្សា**"។

ជាដំបូងពុទ្ធបរិស័ទ នាំគ្នាត្រៀមសំភារៈសំរាប់បុណ្យធ្វើនំនែកតាំងពីថ្ងៃទី១៣កើតថ្ងៃ១៤កើតខែអស្សុជ ។ ពុទ្ធបរិស័ទទាំងឡាយ ក្រោមការដឹកនាំរបស់លោកអាចារ្យវត្ត បានជួបជុំគ្នាលើឧបដ្ឋានសាលា ប្រហែលម៉ោង៣រសៀលនៃថ្ងៃទី១៤កើតធ្វើវិធីនមស្សការ ថ្វាយបង្គំ ហើយនិមន្តព្រះភិក្ខុសង្ឃសាមណេរទាំងអស់អង្គាស ភេសជ្ជៈ សមាទានសីល អារាធនាចំរើនព្រះបរិត្តដែលហៅថា សូត្រមន្តចេញវស្សា "កន្លែងខ្លះមានបន្តទេសនាផង" ។

លុះព្រឹកឡើងថ្ងៃទី១៥កើតខែអស្សុជ ពុទ្ធបរិស័ទក្មេងចាស់ ប្រុសស្រីស្លៀកពាក់សមរម្យយួរស្រាក់ កណ្តៀតល្អី ថាស នំអន្សម ផ្លែចេក ដូង ដំឡូងជាដើម និងផ្កាភ្ញី ទៀនធូប គ្រប់ដៃខ្លះរែក ឬទូល សែងឆ្នាំងបបរ សម្ល ចង្ហាន់បិណ្ឌបាតតាមក្រុម១ ហូរហែមកដល់ឧបដ្ឋានសាលាធ្វើពិធីរាប់បាត្រពេលព្រឹកកន្លែងខ្លះរាប់បាត្រថ្ងៃត្រង់ដោយវេរចង្ហាន់ប្រគេនព្រះសង្ឃ១ធ្វើភត្តានុមោទនាពហូទេវាដារឆ្លងបុណ្យកុសលពេលថ្ងៃ ត្រង់នោះ ។



www.elibraryofcambodia.org

# ពិធីបណ្តែតប្រទីប

ពិធីបណ្តែតប្រទីប គេធ្វើក្នុងថ្ងៃចេញវស្សានៅពេលល្ងាច ហើយកន្លែងខ្លះគេនិយមធ្វើព្រឹកថ្ងៃ១រោជខែអស្សុជ បន្ទាប់ពីថ្ងៃចេញវស្សា ។ ពីដើមសូម្បីវត្តជាប់មាត់ទន្លេក្តីវត្តគ្មានជាប់ ទន្លេ ព្រែកក្តី ក៏គេធ្វើពិធីបណ្តែតប្រទីបតាមស្រះនៅក្នុងវត្តដែរ ។ តែបច្ចុប្បន្នមានធ្វើតែវត្ត ដែលនៅជាប់មាត់ទន្លេប៉ុណ្ណោះ ឯវត្តជាប់មាត់ទន្លេខ្លះទៀត ក៏មិនសូវឃើញធ្វើផងដែរ ។ វិធីបណ្តែតប្រទីបនេះ បុរាណយល់ថា ញាតិដែលស្លាប់តាមបាបកម្មនាំទៅកើតអបាយភូមិ កាលបើនៅពេលរដូវវស្សា មានទឹកភ្លៀង ជោគជាំ ពួកមេយមបាលតែងដោះលែងអ្នកទាំងនោះ ឱ្យស្វែងរក អាហារ មានទទួលផលពីញាតិដែលធ្វើបុណ្យផ្សេងៗ មានបុណ្យបិណ្ឌភ្ជុំជាដើម ដែលហៅថា : ពួកប្រេតតិរោក ។ លុះថ្ងៃចេញវស្សា បញ្ចប់បុណ្យទាំងនោះផង ត្រូវរដូវទឹកស្រកទៅវិញផង ពួកប្រេតតិរោកទាំងឡាយ ត្រូវទទួលបាបកម្ម នៅឯកន្លែងដើមវិញម្ល៉ោះហើយញាតិដែលនៅរស់ ត្រូវធ្វើវិធីជូនដំណើរ ដោយរៀបចំរវេចខ្ចប់អីវ៉ាន់ជាបច្ច័យដាក់ក្នុងរទេះមួយដែលហៅថា : (សង្សឹក) បញ្ជូនតាមផ្លូវទឹកគឺការបណ្តែតប្រទីបតាមបណ្តោយទឹកស្ទឹង ទន្លេ ព្រែកឬស្រះ ដែលហៅថា : បណ្តែតប្រទីបនោះឯង ។ សង្សឹកនោះគេធ្វើពីឈើ ឬស្សី ជញ្ជាំងប្រក់ព្រំដោយគ្រឿងក្រដាសរាងដូចប្រាសាទតូចមួយនៅក្នុងនោះមាន អង្ករ បាយស្រូវ សម្លូ ខរ អាំង ចៀន ប្រហុកអំបិល ត្រី សាច់ មាន់ ទា ជាដើម អន្សម នំនែក ចេក ។ល។ មានអុជធូបទៀន ឬ គោម បណ្តែតតាមទឹកដឹកនាំស្បៀងសំរាប់ពួកប្រេតនោះៗ តែម្តង ។



www.elibraryofcambodia.org

ចាស់ៗរកពោធិ៍ដើម លោកធ្វើសង្វៀក និងសំការៈរីវ៉ាន់ដាក់ក្នុងនោះ ដោយយកចិត្តទុកដាក់ម៉ត់ចត់ជាទីបំផុត ព្រោះលោកមានមេត្តាករុណាធម៌ខ្លោចចិត្តអាណិតអាសូរពួកប្រេតញាតិ ដែលត្រូវត្រឡប់ទៅទទួលទោសជាប់ក្នុងគុកអបាយភូមិវិញ គ្មានឱកាសមកទទួលបួរកអាហារភោជនទៀតទេ អស់រយៈពេលមួយឆ្នាំទៅមុខ ។ ហេតុនេះទើបបុរាណខំធ្វើមិនខាននោះឥតស្តាយស្រណោះរបស់ប៉ុណ្ណឹង សូម្បីតែវត្តដែលគ្មានជាប់មាត់ទន្លេ ក៏គេធ្វើបណ្តែតក្នុងស្រះវត្តដែរ មិនដែលខាន ។

ប៉ុន្តែវត្តភាគច្រើន សព្វថ្ងៃមិនធ្វើទេ ហើយអាចារ្យវត្តខ្លះផង នឹងមិនសូវយល់ការ ល្បិចផង់ដូលរមូលផង់គ្រេចផង ទើបគេសួរនាំពីបញ្ហានេះ គាត់បែរជារកលេស ឆ្លើយយកសម ផ្អែកថា ៖ ចេញវស្សាមិនបាច់បណ្តែតប្រទីបទេ ចាំទៅបណ្តែតប្រទីបថ្ងៃបុណ្យអកអំបុក អុំទូកសំពះព្រះខែ (បុណ្យទ្វារទសមាស) ឯភ្នំពេញ ថ្ងៃ១៥កើតខែកត្តិកខាងមុខតែម្តងជាការស្រេច ។

បើយើងតាមដានការពិតនោះវិញ ឃើញថា ៖ ដល់ថ្ងៃសំពះព្រះខែ មានពិធីអុំទូក សំពះព្រះខែ បណ្តែតប្រទីប នៅឯភ្នំពេញនោះពិតមែន ប៉ុន្តែឯលោកអាចារ្យវត្តដែលឆ្លើយដោះដៃនោះ មិនបានចោលភូមិខ្លួនទៅធ្វើពិធីបណ្តែតប្រទីបនឹងគេផងទេ គឺនៅអកអំបុកឯវត្តខ្លួនជាមួយព្រះសង្ឃ ឯណោះសោះមិនដូចសំដីដោះស្រាយទេ ។ រួចពោលថា ៖ ខ្លួនចាស់ហើយ បណ្តោយឱ្យក្មេងៗទៅលេងចុះ ។

យើងពុំហ៊ានថាអ្វីទេ តែគួរនិយាយឱ្យត្រង់ថា ៖ ខ្ញុំអាចារ្យមែនតែមិនសូវចេះរបៀប បុណ្យលយប្រទីបតាមបែបបុរាណឡើយ យ៉ាងនេះទើបគេអ្នក



www.elibraryofcambodia.org

ដឹងការប៉ានប្រាប់ប្រង ព្រោះបែបបទទំនៀមប្រពៃណីនេះជាលក្ខណៈរក្សាអត្តសញ្ញាណជាតិ ។

យើងពោលមកប៉ុណ្ណេះ ពិតពុំមានចេតនា បៀតបៀនដល់លោកអាចារ្យវត្តណាម្នាក់ទេ ប៉ុន្តែយើងគួរគិតថា : " បើយើងធ្វើមិនជាខាតប៉ុន្មាន បើបែរជាខាន ក៏មិនបានចុះនរកជ្រៅ បើនាំគ្នាធ្វើឱ្យបានរាល់ឆ្នាំទៅអាចបានជាផ្លូវ រក្សាប្រពៃណីដែរ" ។



www.elibraryofcambodia.org

# បុណ្យកឋិនទាន

## ១ អារម្ភកថានៃបុណ្យ

កឋិនទានគឺជាបុណ្យមួយ មានតែក្នុងព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ជាទានមានមកតាមផ្លូវព្រះវិន័យ ហើយក៏ជាកាលទានដ៏ពិសេសមួយមានកំណត់ពេលវេលាច្បាស់លាស់ ពុំមែនចេះតែធ្វើនៅពេលណាក៏បានតាមចិត្តចង់នោះឡើយ គឺរយៈកាលទទួលកឋិនទានក្តី និងរយៈកាលធ្វើកឋិនទានក្តី អាចធ្វើបានតែក្នុងសម័យតែ១ខែគត់ (២៩ថ្ងៃ )ចាប់ពីថ្ងៃ ១រោចខែអស្សុជដល់ថ្ងៃ១៥កើតខែកត្តិក ។ បើខុសពីសម័យកាលនេះ ទោះបីអ្នកមានសទ្ធាធ្វើបុណ្យមានលក្ខណៈសណ្ឋានដូចកឋិនក៏ដោយ ក៏មិនអាចហៅថា កឋិនទានបានទេ ។ ព្រោះធ្វើខុសកាលទានមិនចំសម័យ១ខែ ចុងវស្សានរដូវនេះពោលគឺ មិនត្រូវតាមពុទ្ធានុញ្ញាត ឡើយ ។

ក្នុងវត្តមួយបើការចាំវស្សាគ្មានភិក្ខុសោះក៏មិនអាចហែកឋិនចូលដែរ ព្រោះសាមណេរគ្មានសិទ្ធិទទួលក្រាលគ្រងកឋិនទេ លុះតែយ៉ាងហោចបំផុតត្រូវមានភិក្ខុ ១អង្គដែរ ហើយដែលបានចាំវស្សាអស់៣ខែបានត្រឹមត្រូវ ទើបអាចហែកឋិនចូលបាន ។

បព្វជិតក៏ដោយ គ្រហស្ថក៏ដោយ អាចធ្វើកឋិនទានបានដូចគ្នា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃទទួលកឋិន ហើយភិក្ខុធ្វើកឋិនត្ថារកិច្ច គឺក្រាលគ្រង ........អនុមោទនាកឋិននោះ ដើម្បីសម្រាលនូវទុក្ខលំបាកក្នុងការប្រើប្រាស់បច្ច័យមួយចំនួនដូចជា ត្រៃចីវរ អាហារភោជន និង លាភសក្ការៈផ្សេងៗ ដែលកើតមានដល់សង្ឃប៉ុណ្ណោះ ។ ហើយការសម្រាលទុក្ខ



www.elibraryofcambodia.org

នេះទៀតសោត ក៏បានតែត្រឹមរយៈកាល ៥ខែ និងបានចំពោះតែភិក្ខុដែលចូល បុរិមិកាវស្សា អស់ត្រៃមាសបានត្រឹមត្រូវមិនដាច់វស្សានោះឯង ។

ម្យ៉ាងទៀត ការធ្វើកឋិន លោកសំដៅយកតែ ចីវរប្បច្ច័យ គឺអ្នកធ្វើកឋិន មានសំពត់ត្រឹមតែអាចធ្វើស្បង់មួយ ក៏អាចធ្វើកឋិនបានដែរ ។ ព្រោះលោកទទួលក្រាលកឋិនក្នុងចំណោមត្រៃចីវរ ( ស្បង់ ១.ចីពរ១សង្ឃាដី ១ ) គឺក្រាលបានតែ ១មុខប៉ុណ្ណោះ បើក្រាលដល់ទៅពីរមុខមិនឡើងជាកឋិនឡើយលោកហៅថាខូចកឋិន ឬកឋិនត្មាវិបត្តិ។ ប៉ុន្តែការដែលអ្នកមានសទ្ធាជាអ្នកមានធូរធារ ស្តុកស្តម្ភ អាចនាំសំភារៈច្រើនៗ ដូចជា ចីវរ១ត្រៃ ២ឬ ៣ត្រៃ ឬក៏លើសទៅទៀត ក៏អាចទាំងសេនាសនបច្ច័យ គិលានបច្ច័យ បិណ្ឌបាតបច្ច័យ ឱ្យកាន់តែសម្បូរបែបច្រើនៗ ទៅទៀតក៏រឹតតែប្រសើរវិសេស គឺបានផលានិសង្សលើអ្នកធ្វើកឋិន កាន់តែច្រើនលើសលប់ តាមសំភារៈបរិក្ខារ គឺអានិសង្សលាភ ឬ បរិវារកឋិននោះឯង ។

ឯផ្នែក **បដិគ្គាហកៈ** គឺភិក្ខុសង្ឃទទួល បើក្រាលបានត្រឹមត្រូវគឺទទួលបានអានិសង្សដែរ គឺបានអានិសង្ស ៥យ៉ាងប៉ុណ្ណោះ ទោះបីកឋិននោះតូចតាច តិចតួច ស្តួចស្តើង ឬធំដុំសម្បូរបែប យ៉ាងណាក៏ដោយ បដិគ្គាហកៈទៅតែទទួលអានិសង្ស បានត្រឹមតែ ៥យ៉ាង អស់រយៈ៥ខែមាន " **អនាមន្តចារោ** ធ្វើឱ្យភិក្ខុរួចពីអាបត្តិ ក្នុងចារិត្តសិក្ខាបទទី៦ ក្នុងអចេលកវគ្គជាដើមតែប៉ុណ្ណោះឯង " ។

ចំណែកទាយក-ទាយិកា អ្នកធ្វើកឋិន ទើបអានិសង្ស ត្រូវបាន តិច ឬ ច្រើននិងច្រើនលើសលុបប្រែប្រួលទៅតាម កុសលចេតនា បសាទសទ្ធា



www.elibraryofcambodia.org

ទៅតាមបរិក្ខាតិច ច្រើន ល្អប្រណីត ថ្លៃថ្លា ។ ព្រោះហេតុនោះទើបលោកពោលថា : ទានមានតែមួយគត់ដែលអាចផ្តល់អានិសង្សឱ្យបានទាំងពីរប៉ែក គឺបានផលដល់អ្នកទទួល (**បដិគ្គាហកៈ**) និង បានដល់អ្នកឱ្យ (ទាយក ទាយិកា) ពោលគឺ (**កឋិនទាន**) ។

***២.កំណើតកឋិន***

ដូចបានជម្រាបរួចមកហើយថា : កឋិនមានតែក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះ ក៏ក្នុងសាសនាព្រះសមណគោតមបរមគ្រូនៃយើង ព្រះអង្គទ្រង់អនុញ្ញាតនូវកឋិនត្ថារកិច្ចនេះ ក្នុងរវាងមជ្ឈិមពោធិកាល ប្រារព្ធចំពោះភទ្ទវគ្គិយភិក្ខុ ទាំង ៣០អង្គ (កន្លែងខ្លះថាភិក្ខុទាំង៣០អង្គនេះជាបងប្អូន នឹងគ្នា ថាជា បងប្អូនបសេនទិកោសលរាជដូចមានដំណើររឿងជានិទានតទៅនេះ : កាលនោះភទ្ទវគ្គិយភិក្ខុទាំង៣០រូបប្រព្រឹត្តអារញ្ញិកធុតង្គវត្ត ( **សមាទានធុតង្គ** នៅព្រៃ) ។ នៅពេលមុនថ្ងៃចូលវស្សា លោកមានបំណងទៅវន្ទាលាព្រះជាម្ចាស់ដើម្បីទៅនៅចាំវស្សាកន្លែងណាមួយ ។

( នេះជាទំនៀមកិច្ចវត្ត របស់សហធម្មិកៈនៅព្រះពុទ្ធសាសនាដែលរហូតដល់សព្វថ្ងៃនេះ ភិក្ខុសាមណេរទាំងឡាយ គួរធ្វើកិច្ចវត្តដ៏ប្រពៃនេះ ព្រោះជាទំនៀមល្អតាំងពីដើមមក ទោះបីភិក្ខុសាមណេរនៅក្នុងវត្តដើមក្តី ឬ ចេញទៅសិក្សានៅអាស្រ័យរៀនសូត្រក្នុងវត្តដទៃក្តី ដែលសុទ្ធតែពុំទាន់ជា និស្ស័យមុត្តកៈ(រួចចាកនិស្ស័យ)នៅឡើយ ។ ចំពោះសាលារៀនខាងបព្វជិត ក៏អនុញ្ញាតសំរាករៀនមួយអាទិត្យមុនថ្ងៃចូលវស្សាដែរ ដើម្បីភិក្ខុ សាមណេរទាំងឡាយ និមន្តទៅធ្វើកិច្ចវត្ត ចំពោះគ្រូឧបជ្ឈាយាចារ្យ



www.elibraryofcambodia.org

របស់ខ្លួន វន្ទាណាទៅចាំវស្សាងវត្តសំណាក់ដែលត្រូវ នៅរៀមសូត្រ ) ។

ប៉ុន្តែភទ្ទិយភិក្ខុទាំង៣០អង្គ ដោយដំណើរធ្វើរជើងផ្លូវឆ្ងាយនិមន្តមិនទាន់ដល់អាវាសដែលព្រះដ៏មានភាគព្រះអង្គគង់នៅ ត្រូវពេលថ្ងៃចូលវស្សាមកដល់ ក៏ព្រមព្រៀងគ្នានៅចាំវស្សាក្នុងដែន **បាថេយ្យៈ** នាក្រុងសាកេតត្រង់កណ្តាលផ្លូវតែម្តងទៅ ។

លុះដល់ថ្ងៃចេញវស្សាហើយ ក៏និមន្តទៅថ្វាយបង្គំគាល់ ព្រះសម្មាសម្ពុទ្ធ ដែលគង់ចាំវស្សានៅវត្ត **ជេតពន** នាក្រុង **សាវត្ថី** ចំកាលវេលាចុងរដូវវស្សា ជាសម័យភ្លៀងជោគជាំជានិច្ច ពព្រិចរាល់ថ្ងៃ ធ្វើឱ្យភិក្ខុទាំង៣០អង្គ ទទឹកជោកទាំងស្បង់ ចីវរសង្ឃាដី ជួបការលំបាកមកតាមផ្លូវរហូត ( មួយអង្គៗគ្មានត្រៃចីវរ២បន្លាស់ទេ ) លុះដល់ហើយចូលគាល់បង្គំព្រះដ៏មានព្រះភាគទាំងទទឹកជោគ ។

ជាទំនៀមព្រះពុទ្ធបរមគ្រូតែងទទួលធម្មប្បដិសណ្ឋារៈសួរនាំរាក់ទាក់សុខទុក្ខ អំពីការរស់នៅក្នុងវស្សា៣ ខែ អាហារភោជន និងការព្រមព្រៀងគ្នាយ៉ាងណាៗ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះតម្រិះថាប្រសិនបើតថាគតបានអនុញ្ញាតកឋិនត្ថារកិច្ចដល់ភិក្ខុសង្ឃពីមុនមករួចហើយ សមបើលោកទាំងនេះមិនជួបការលំបាកយ៉ាងហ្នឹងទេ ។ ហើយកឋិននេះព្រះពុទ្ធពីអតីតៈក៏បានអនុញ្ញាតដល់សាវ័កដូចគ្នាដែរ ។

ព្រោះដំណើរនេះ ទើបព្រះពុទ្ធជាម្ចាស់ប្រជុំភិក្ខុសង្ឃទាំងឡាយសំដែងធម្មីកថា ហើយទ្រង់អនុញ្ញាតកឋិនត្ថារកិច្ចនេះថា : "អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ



www.elibraryofcambodia.org

ភិក្ខវេ  បញ្ចា  កប្បិស្សន្តិ  "  ។

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយ ទទួលក្រាលកឋិនបាន ម្នាលភិក្ខុទាំងឡាយ អានិសង្ស៥ ប្រការនឹងសំរេចដល់ភិក្ខុទាំងឡាយ ដែលបានក្រាល( អនុមោទនា) កឋិនរួចហើយ ។

ដូច្នេះ កឋិនត្ថារកិច្ចនេះ គឺព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតដល់សង្ឃសាវ័កចាប់តាំងពីពេលនោះមក ( មានក្នុងវិនយបិដកមហាវគ្គភាគ៨ ត្រង់កឋិនក្ខន្ធកៈ លោកសំដែងយ៉ាងពិស្តារ) ។

## អ្នកធ្វើកឋិនមុនគេក្នុងសម័យពុទ្ធកាល

បន្ទាប់ពីបានដឹងថា ព្រះពុទ្ធអង្គ អនុញ្ញាតឱ្យសាវ័កទទួលកឋិនត្ថារកិច្ច ព្រះបាទបសេនទិកោសលបានផ្តើមធ្វើកឋិនទានមុនគេបង្អស់ក្នុងសម័យពុទ្ធកាល ។ កាលនោះព្រះ**មហាកច្ចាយនត្ថេរ** ជាប្រធាន បានទទួលក្រាលគ្រងកឋិនឱ្យសំរេចគ្រប់ប្រការ ។ ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គបានទេសនាក្នុងពិធីបុណ្យនោះ ដោយទ្រង់សរសើរអំពីអានិសង្សនៃកឋិនទានជាអនេកបរិយាយ ។

ក្នុងធម្មទេសនា ព្រះអង្គលើកអតីតនិទានកាលព្រះអង្គយោនយកកំណើតកើតជា **នរជីវទុគ្គតបរមពោធិសត្វ**បានជួយវេយ្យាវច្ចៈ ខ្វល់ខ្វាយក្នុងអង្គកឋិនទានរបស់ **កុដុម្ពិក**ម្នាក់ នាំទៅថ្វាយ ព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ដែលពេលនោះព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱ្យព្រះសុជាតត្ថេរ អគ្គសាវ័ក ព្រះអង្គជាអ្នកក្រាលគ្រង ។ ឯនរជីវទុគ្គតបរមពោធិសត្វ នៃយើងបាន



www.elibraryofcambodia.org

ពុទ្ធព្យាករ ពីពេលនោះមក ដោយសារការជួយកាត់ដេររបស់ពីកម្លាំងកាយ ចិត្ត និងប្រាជ្ញាស្មារតី ក្នុងពិធីបុណ្យនោះ ។ ឯប៉ែកខាងបព្វជិតវិញ ព្រះភិក្ខុនាម**ធារតត្ថេរ**កាលបើបានស្ដាប់នូវព្រះធម្មទេសនារបស់ព្រះបរមគ្រូក្នុងបុណ្យរបស់ព្រះបាទ**បសេនទិកោសល**មហារាជ ហើយមានសេចក្ដី ជ្រះថ្លាក៏ទៅបបួលញាតិសាច់សាលោហិតរបស់លោកធ្វើកឋិនទានមួយ ដង្ហែទៅថ្វាយព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះអង្គទ្រង់សរសើរទាននេះ ហើយទ្រង់ក៏លើកយកអតីតនិទាន កាលព្រះអង្គនៅជាស្ដេចចក្រព័ត្តិនាម **វិជិតរាជ** ជាធំលើទ្វីបទាំងបួនបាននាំកឋិនទៅថ្វាយព្រះពុទ្ធនាម **កោណ្ឌញ្ញៈ** ដែរ ។

ចំណែកផលានិសង្សធ្វើកឋិន សូមពិនិត្យមើលអតីតនិទានខាងលើដែលព្រះពុទ្ធអង្គទ្រង់ទេសនាសរសើរជាអនេកបរិយាយ និងនាំអតីតនិទានទាំងពីររឿងនោះ ឱ្យបានច្បាស់លាស់ចុះ ។ ក្រៅពីនេះអានិសង្សដូចដែលយើងបានជំរាបខាងលើហើយថា :

ផលបុណ្យរបស់អ្នកធ្វើកឋិនត្រូវបាន ទោះគ្រហស្ថក្ដីបព្វជិតក្ដី គឺផ្អែកទៅលើចេតនាទាំងបីរបស់អ្នកធ្វើផង ប្រកបដោយសទ្ធា និងបញ្ញាសម្បយុត្តផង ទាំងសំភារៈកឋិន ថ្លៃថ្លាឧត្ដមប្រណីត សម្បូរបែបផង ។ កាលណាពិនិត្យលើគុណធម៌ទាំងប៉ុណ្ណេះ លោកអ្នកអាចយល់បានថា មានអានិសង្សផលច្រើនប្លែកគ្នាពីកឋិនទាននិមួយៗ ។

បើពោលដោយរួបរួមយ៉ាងខ្លីមកថា : អ្នកមាន បសាទសទ្ធា បានធ្វើកឋិនទាន រមែងទទួលបាន : **សុរូបតា** មានរូបស្អាត ធ្វើឱ្យបុរសស្ត្រី ឃើញហើយស្រឡាញ់ពេញចិត្តជារូបមានសម្ផស្សគួរស្ម័គ្រស្មាគមនិយមមេត្រីភាព ។



www.elibraryofcambodia.org

**សុវណ្ណវណ្ណោ** ពោធរស្បែរល្អតែ មិនខ្មៅ ពុំមានស្នាកស្នាមឬប្រជ្រុយជាដើម មិនខ្មៅស្រិល មិនសស្លុស មិនពពាលពព្រុស គឺសម្បុរល្អគួរជាទីចាប់ចិត្តនៃអ្នកផងទាំងឡាយ ។

**សុសណ្ឋានោ** មានទ្រង់ទ្រាយ. កំពស់កំព. រាងរៅ សំសួនតាមកាលសម័យនៃអាយុកប្បនិមួយៗ ។

**ចក្កវត្តិរាជា.ហោតិ** ត្រូវបានជាស្តេចចក្រពត្រាធិរាជ ប្រកបដោយទសពិធរាជធម៌ ក្នុងជាតិណាមួយជាច់ខាត ។

**ផលចុងក្រោយគឺ :**

**ឯហិភិក្ខុ** :និងបានជួបព្រះប្រទះធម៌ ក្នុងអវសានជាតិ ហើយសម្រេចអរហត្តមគ្គ អរហត្តផល ដល់ព្រះនិព្វាន ។ បើស្ត្រីភេទ ក៏និងបានលុះមគ្គផលក្នុងជាតិជាទីបំផុតមិនខាន ។

## តើភារកិច្ចម្ចាស់កឋិន ត្រូវបញ្ចប់ត្រឹមណា ?

តាមធម្មតាម្ចាស់កឋិន ហែអង្គកឋិនទានចូលដល់ព្រះវិហារ ហើយធ្វើពិធីតាមសាសនា ចុងក្រោយវេរសំពត់កឋិន បរិវារកឋិន ឈ្មោះថា បានប្រគេនដល់សង្ឃហើយ ។ ភិក្ខុសង្ឃធ្វើអនុមោទនាគាថា : បី . បួន . មេ . ចប់ . ម្ចាស់ទានមានអាចារ្យជាប្រធាន ផ្សាយបត្តិទានគាថា **យំកិញ្ចិ** ឧទ្ទិសជូនមហាកុសលនោះឈ្មោះថាជាទីបញ្ចប់កិច្ចរបស់ម្ចាស់កឋិនត្រឹមនោះឯង ។ ទាយក-ទាយិកា ម្ចាស់ទានទាំងអស់ អាចត្រឡប់ទៅលំនៅដ្ឋានរៀងៗខ្លួនវិញ ។ តទៅនោះ នៅតែពួកភិក្ខុសង្ឃ មានភារកិច្ចត្រូវធ្វើពិធីកម្ម ដើរញកឋិនត្ថារកិច្ច កិច្ចការក្រាលកឋិនរបស់លោក ។



www.elibraryofcambodia.org

ប៉ុន្តែសម័យបច្ចុប្បន្ននោះ កន្លែងខ្លះប្រពៃណីកឋិន ពិធីហែពីរាក្សបើ ភូមិស្រុកឆ្ងាយ១ឬនៅក្នុងតំបន់ជិត១ក្តី ក្នុងភូមិចំណុះវត្តក្តី គេពុំប្រញាប់ប្រញាល់ទេនោះ គេចង់នៅរង់ចាំមើលព្រះសង្ឃធ្វើពិធីកម្មរហូតដល់ចប់ ។ បានសេចក្តីថា ៖ ពេលលោកអាចារ្យវេរប្រគេនកឋិនចប់ហើយ ព្រះសង្ឃគ្រាន់តែធ្វើអនុមោទនាខ្លី១ប៉ុណ្ណោះ ទាំងខាងទាយកទាយិកា ក៏ពុំទាន់យំ កិច្ចិទេ គេនៅក្នុងព្រះវិហារដែរ ចាំមើលលោកធ្វើពិធីក្រាលកឋិន គ្រាន់តែអង្គុយឆ្ងាយពីហត្ថបាសព្រះសង្ឃប៉ុណ្ណោះ ទើបភិក្ខុពីរអង្គតំណាងសង្ឃ អបលោកន៍ ( ក្រើនកឋិន )ឡើង ១អង្គ សួរនាំរកភិក្ខុអ្នកខ្វះខាតឬមានស្បង់ស្បៃត្រៃចីវរទុព្វលភាពដាច់ដាច ឱ្យលោកឆ្លើយប្រាប់សង្ឃ ។ ១អង្គទៀតជាតំណាងខាងឆ្លើយប្រាប់ថា ភិក្ខុនេះភិក្ខុនោះទើបសមគួរក្រាលគ្រង ។ល។ ដោយការព្រមព្រៀងក្នុងសង្ឃហើយ ទើបភិក្ខុឈ្លាសទាំងពីររូបសូត្រញត្តិប្រគល់សំពត់កឋិន ដល់ភិក្ខុអង្គនោះ១ ដោយ **ញត្តិទុតិយកម្មវាចា** ជាលក្ខណៈសង្ឃកម្ម ។ រួចហើយភិក្ខុសង្ឃទាំងអស់ ជួយក្នុងការធ្វើកិច្ចការក្រាលគ្រងគ្រប់យ៉ាង រហូតញ៉ាំងកឋិនត្ថារកិច្ច ឱ្យសម្រេចតាមធម៌ និងអនុមោទនារួចឈ្មោះថាចប់កិច្ចខាងព្រះសង្ឃ ទើបលោកក្រោកមកគង់តាមលំដាប់ជួរដូចដើម ហើយសូត្រមង្គល **ពាហុំ ឆេទរ** ជាវរឆ្លងបុណ្យកឋិនចប់ហើយ ទាយក-យិកា សូត្រ **យំកិញ្ចិ** ឧទ្ទិសកុសលជូនបុព្វបេតជន ជាកិច្ចចុងក្រោយ ។ បរិស័ទក៏ជួយកាន់បញ្ជូនអីវ៉ាន់កឋិន ចេញពីព្រះវិហារយកទៅ ឯកុដិតែម្តង ។

<u>**គួរពិគ្រោះយោបល់ ពិចារណាទាំងអស់គ្នា អំពីការវេរសំពត់បរិក្ខារកឋិន**</u>



www.elibraryofcambodia.org

ការវេរសំពត់កឋិន និងបរិក្ខារជាបរិវារកឋិនទាំងឡាយ មានពិធីវេរត្រូវគ្នាខ្លះ ផ្សេងគ្នាខ្លះហាក់ដូចតាមនិយមរបស់អាចារ្យ ។

កន្លែងមួយចំនួន វេរសំពត់កឋិនរួចជាមុនហើយ ទើបវេរកឋិនបរិវារម្តងទៀត ឬ ទាល់តែភិក្ខុក្រាលកឋិនហើយ ទើបវេរបរិវារកឋិនក៏មាន ។ ពួកគេយល់ថា : ការវេរសំពត់កឋិនជា សង្ឃទានស្មោះមិនចំពោះភិក្ខុណាទេចប់ម្តង ហើយបន្តវេរបរិវារកឋិនចំពោះលោកណាក្រាលគ្រង ។ តែគេនៅតែយល់ថា : វេរក្រោយនោះ ក៏មិនចំពោះភិក្ខុណាទេ ព្រោះគេមិនដឹង មិនអាចថា ចំពោះបុគ្គលបានទេ ព្រោះសង្ឃមិនទាន់អបលោកន៏ ប្រគេនលោកណានៅឡើយ ការវេរបែបនេះ គេត្រូវវេរជា ២លើកគឺ :

ដំបូងវេរថា : **មយំ ភន្តេ ឥមំ កឋិនចីវរំ សង្ឃស្ស ទេម ទុតិ តតិ** : បពិត្រព្រះសង្ឃដ៏ចំរើនយើងខ្ញុំទាំងឡាយ សូមវេរប្រគេននូវសំពត់កឋិនចីវរនេះ ចំពោះព្រះសង្ឃ ។ អស់វារៈ ២ដងផង អស់វារៈ ៣ដងផង ។ លើកយកកឋិនចីវរទៅដាក់កណ្តាលជំនុំសង្ឃ ហើយត្រឡប់មកវេរម្តងទៀតថា : **យេនម្ហាកំ ភន្តេ កឋិន គហិតំ តស្សេវ ទេម** " បពិត្រព្រះសង្ឃដ៏ចំរើន កឋិនរបស់យើងខ្ញុំលោកអង្គណាទទួលយើងខ្ញុំសូមវេរប្រគេន អានិសង្សលាភ ចំពោះភិក្ខុនោះ" ។

កន្លែងខ្លះយល់ថា : ការវេរសំពត់កឋិន ត្រូវភ្ជាប់អានិសង្សលាភជាមួយផង ទើបសង្ឃជាឥស្សរៈ នឹងបានជាធំលើសំភារបរិក្ខារគ្រប់យ៉ាងពោលគឺកឋិនចីវរក្តី អានិសង្សលាភក្តី សុទ្ធតែជាសង្ឃទានស្មោះ គេវេរតែម្យ៉ាងថា

**ឱកាស មយំ ភន្តេ កឋិនចីវរំ សានិសំសំ សង្ឃស្ស**



www.elibraryofcambodia.org

បពិត្រព្រះសង្ឃដ៏ចំរើនយើងខ្ញុំទាំងឡាយសូមវេរប្រគេន នូវកឋិនចីវរ ព្រម ទាំងបរិក្ខារជាអានិសង្សលាភ ចំពោះព្រះសង្ឃ អស់វារៈ ២ដងផង អស់វារៈ ៣ ដងផង ។

បើតាមការពិគ្រោះឯកភាពគ្នា និងសមស្របតាមហេតុបច្ច័យបាន ចេញជា :

- តាមបែបវេរ ២ ដងរបស់ក្រុមខាងលើ ចំពោះវេរកឋិនចីវរពិត ជាសំរេចបានជាសង្ឃទានមែនហើយ ប៉ុន្តែចំពោះការវេរអានិសង្សលាភវិញ ទោះបីជាថាមិនចំពោះអង្គណាក្តី ថាសង្ឃមិនទាន់ប្រគល់ឱ្យលោកណា ១ ក្តី ថាយើងមិនដឹងពិតក្តី យ៉ាងនេះមែនហើយ ប៉ុន្តែអានិសង្សលាភបែបនេះគឺ លោកអ្នកក្រាលគ្រងតែមួយអង្គគត់ជាធំជាម្ចាស់ទាំងស្រុងលើបរិវារកឋិន ឯ សង្ឃមិនជាធំលើបរិវារកឋិនឡើយ គឺសង្ឃគ្មានសិទ្ធិបែងចែក គឺកម្មសិទ្ធិ របស់ភិក្ខុអ្នកក្រាលគ្រងពិត១ សូម្បីនិមិត្តស្តាប់ពាក្យវេរ ក៏អាចពិចារណា បានដែរ ដែលវេរថា : បើលោកអង្គណាក្រាលគ្រង យើងប្រគេនអង្គនោះ ពាក្យអង្គណា អង្គនោះគឺតែ ១អង្គ បើទុកជាយើងមិនដឹងថាអង្គណាជាអង្គ ណាក៏សំដីទាញទៅរកបុគ្គលដោយចំពោះទៅហើយ មិនមែនចំពោះសង្ឃទេ។ ការវេរយ៉ាងនេះក៏បាន មិនមានខុសទាស់នឹងវិន័យទេ តែវាខាតយើងអ្នកធ្វើ ព្រោះបានជាសង្ឃទាន១ឯ១ទៀតបានជាបាដិបុគ្គលិកទាន ។ វេរអានិសង្ស លាភ បែបខាងលើ បើមិនមែនជាបាដិបុគ្គលិកទាន តើឱ្យឈ្មោះទានអ្វីទៅ វិញ ? ដែលត្រឹមត្រូវហើយ ចំណោញដល់អ្នកធ្វើនោះ គឺវេរតាមបែបខាង



www.elibraryofcambodia.org

ក្រោយដែលវេរកថិនចីវរ ទាំងបរិវារកឋិន គឺសង្ឃ
ទានស្មោះ ព្រោះវេរចំពោះសង្ឃ មិនមែនចំពោះលោកណាទេ ។ ពាក្យថា :
ចំណេញ គឺបានផលានិសង្សជា "សង្ឃគតាទក្ខិណាទាន" ទាំងអស់ ។

## សុន្ទរកថា :

### ( សុន្ទរកថាបុណ្យកឋិនទាន )

ម្ចាស់ដើមបុណ្យផ្ទាល់ ឬ លោកអាចារ្យវត្ត ឬ ក៏រកលោកអ្នកវាគ្មិន ម្នាក់ តំណាងឱ្យម្ចាស់ទាន ថ្លែងឡើងក្នុងពេល មុនអារាធនាព្រះធម្មកថិកាចារ្យសំដែងធម្មទេសនា ។ គេថ្លែងដើម្បីប្រគេនពត៌មានដល់ព្រះធម្មកថិក និងជូនអតិថិជនអ្នកភ្ញៀវបុណ្យ បានជ្រាបពីមូលហេតុនៃបុណ្យពីគោលបំណង នៃអ្នកធ្វើ ......។ យើងខ្ញុំសូមជូនសុន្ទរកថា គ្រាន់ជាទិដ្ឋានុគតិខ្លះៗដូចតទៅ

### សុន្ទរកថា

សូមនមស្សការ តេជព្រះគុណ អង្គធម្មកថិក ជាទីគោរព !

សូមឱនកាយ ប្រណិបត័នលោកតាលោកយាយ សាធុសប្បុរសទាំងឡាយជាទីមេត្រី !

ថ្ងៃនេះ គឺជាអភិលក្ខិតសម័យដ៏បវរ ក៏ជាសម័យកាលទាន មានតាមផ្លូវព្រះពុទ្ធសាសនា ហើយក៏ជាឱកាស ប្រកបដោយ មហានក្ខត្តឫក្ស យ៉ាងត្រចះត្រចង់ របស់ ( លោក .......... និងលោកស្រី ..........) ជាម្ចាស់ទានប្រធានបុណ្យ ដែលកំពុងញ៉ាំងកុសលចេតនាថ្លាសទ្ធា ឱ្យដុះផុសចេញ ឧត្តមទានមួយឈ្មោះថា : កឋិនទាន ជាទានមានមកតាមផ្លូវព្រះវិន័យ ។

ខ្ញុំព្រះករុណា-ខ្ញុំបាទ តំណាងឱ្យម្ចាស់ដើមបុណ្យ សូមឆ្លៀតនូវវេលា



www.elibraryofcambodia.org

កាសនេះបន្តិច ដើម្បីថ្លែងសុន្ទរកថាប្រគេនជូន អំពីមូលហេតុដែលនាំឱ្យកើតឡើងជាបុណ្យកឋិនទាននាវេលានេះ ដើម្បីបានជាពត៌មាន ប្រគេនព្រះគុណម្ចាស់ផង បានជាទីសណ្ដាប់ដល់សន្ដាន ដែលបានអញ្ជើញចូលរួមក្នុងពិធីបុណ្យនេះផង ។

**ភន្តេ** បពិត្រព្រះអង្គធម្មកថិកាចារ្យ ជាទីសក្ការៈ !

**សាធុជន** បពិត្រអស់លោកអ្នកសាធុសប្បុរសទាំងឡាយជាទីគោរព !

កឋិនទាន ដែលបានឧប្បត្តិកកើតឡើងក្នុងឱកាសនេះគឺជាទានដ៏ប្រសើរមួយ ដែលផុសចេញពីទឹកចិត្តប្រកបដោយបសាទសទ្ធាដ៏បរិសុទ្ធ ដែលសម្បយុត្តដោយប្រាជ្ញាជាអសង្ខារិករបស់ ( លោក ........លោកស្រី ....... ព្រមទាំងបុត្រធីតា ..... ) ជាម្ចាស់ទានបានឯកភាពគ្នាជាធ្លុងមួយ ចំណាយនូវធនធានកសាងឱ្យកើតមានឡើងដើម្បីដង្ហែ ទៅវេរប្រគេនព្រះភិក្ខុសង្ឃ ដែលគង់ចាំវស្សានៅវត្ត ........ក្នុងថ្ងៃស្អែកនោះអាស្រ័យដោយលោកមានបំណងដោយសង្ខេប៣ យ៉ាងគឺ :

១. ( លោក ....... លោកស្រី ...... និង ..... ) បានយល់ឃើញថាកឋិនទានគឺជាទានដ៏ចំឡែក ប្លែកពីទានដទៃ ដោយផ្ដល់នូវផលានិសង្សដល់អ្នកធ្វើទានផង ផ្ដល់អានិសង្សដល់ភិក្ខុសង្ឃ ជាបដិគ្គាហកៈ អ្នកទទួលផងហើយក៏ជាទានមានកំណត់កាលត្រឹមត្រូវ ពុំមែនអាចគិតចង់ធ្វើ ខែណាថ្ងៃណា ចេះតែធ្វើបានដូចទានដទៃនោះឡើយ ។ ព្រោះហេតុនោះហើយបត្តិកល្ប បើកាលសម័យដ៏សំគួរដល់ព្រមហើយក៏នាំគ្នាប្រារព្ធធ្វើក្នុងពេលនេះតែម្តង ដើម្បីប្រមូលផ្តុំបច្ច័យមួយចំនួន សម្រាប់ឧបត្ថម្ភក្នុងការ



www.elibraryofcambodia.org

កសាងវត្តអារាមផង ។

២. ដោយយល់ឃើញថា ៖ យប់និងថ្ងៃចេះតែកន្លងផុតទៅ មិននៅរង់រង់បង្អង់ចាំអ្នកណាមួយឡើយ ហើយទំពាស៊ីនូវអាយុសង្ខារទៅជាមួយផង បើឱ្យតែអ្នកមានក្តីប្រមាទធ្វេសប្រហែសភ្លេចខ្លួន ក្បួនទព័ស្តេចមច្ចុរាជ នឹងឆ្លៀតឱកាសចូលមកសង្គ្រប់គ្រញិចផ្តាច់ ជីវិតិន្ទ្រិយ៍ រកតែផ្សំស្បៀងសំរាប់លៀងជីពជន្ម ទុកជាជំនួនជូនដំណើរជីវិតអនាគតនៅខាងមុខ ពិតជាខកខានពុំបានដូចប្រាថ្នាឡើយ ដោយសារតែការធ្វេសប្រហែសនេះឯង ។

៣.ម្យ៉ាងទៀតដើម្បីបាននូវកំរៃនៃអានិសង្សកឋិននេះ សំរាប់ជាធម្មបណ្ណាការ ឧទ្ទិសជូនជាកិច្ច កតញ្ញូតាធម៌ចំពោះបុព្វការីជនទាំងឡាយដែលទំលុះកាយទំលាយខន្ធចាកលោកនេះទៅហើយនោះឯង ។

ដូច្នេះកុសលផលានិសង្ស ដែលកើតឡើងអំពីកឋិនទានក្នុងពេលនេះទាំងប៉ុន្មានយើងខ្ញុំសូមឧទ្ទិសជូនចំពោះវិញ្ញាណក្ខន្ធ នៃបុព្វការីជនទាំងឡាយគឺ .......... លោកតា ........... លោកយាយ ........... ( អាចរាប់ឈ្មោះដូនតាម៉ែឪញាតិមិត្ត ) សូមលោកជាបុព្វការីជន អនុជន និងបច្ឆាជនទាំងអស់នោះបានប្រកបនូវសម្បត្តិទិព្វគ្រប់ប្រការតាមសេចក្តីប្រាថ្នា ។

ព្រះគុណម្ចាស់ជាទីគោរព !

សាធុជនជាទីមេត្រីទាំងឡាយ !

ឆន្ទៈទាំងបីយ៉ាងនេះហើយដែលជាមូលហេតុដ៏សង្ខេប បានជាកត្តាសំខាន់ ជំរុញនូវមហាកុសលចេតនារបស់យើងខ្ញុំជាម្ចាស់ទានទាំងអស់គ្នា ឱ្យផ្តើមធ្វើជាកឋិនទានមានក្នុងពេលនេះ ។



www.elibraryofcambodia.org

ដូច្នេះ បុទនិងបក្ខេវសុទ្ធរកជា ខ្ញុំព្រះករុណាខ្ញុំ ជាម្ចាស់ដើមទាន ប្រធានដើមបុណ្យ សូមខន្តីអភ័យទោស អំពីសំណាក់ព្រះករុណាម្ចាស់ និង ញាតិមិត្តជិតឆ្ងាយជាអតិថិជនទាំងអស់ចំពោះបដិសណ្ឋារកិច្ចរបស់យើងខ្ញុំព្រះ ករុណាក្រែងមានការខ្វះខាតដោយប្រការណាមួយ មិនគាប់ទឹកព្រះទ័យ ទឹក ចិត្តព្រះគុណម្ចាស់ អស់លោកដោយអចេតនា ព្រោះតែភាពល្ងង់ខ្លៅមិនវៃ ឈ្លាសរបស់យើងខ្ញុំ ។ ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាសូមសំដែងនូវកតញ្ញុតា ធម៌ដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះវត្តមានព្រះគុណម្ចាស់អង្គធម្មកថិកនិងវត្ត មាន របស់អស់លោកអ្នកជាញាតិមិត្តជិតឆ្ងាយទាំងឡាយដែលបាន និមន្តនិង អញ្ជើញមកជាអធិបតីកិត្តិយស ក្នុងពិធីបុណ្យតាមការអារាធនា និមន្តនិង អញ្ជើញរបស់យើងខ្ញុំព្រះករុណា រឹងរឹតតែញ៉ាំងពិធីបុណ្យ ឱ្យមានសភាព គគ្រឹកគគ្រេង មហោឡារិកថែមឡើងមួយកំរិតទៀត ។ កាយវិការនិងវចី សមាចារ ដ៏ឧត្តុង្គឧត្តមនេះ បានធ្វើឱ្យយើងខ្ញុំមានបីតិសោមនស្សរីករាយឥត ឧបមា មិនអាចណានឹងថ្លែងបាន ហើយពុំមានវត្ថុអ្វីដើម្បីនឹងធ្វើបដិការៈ ឆ្លើយតបឱ្យសមស្របប្រកបស្មើ នឹងទឹកព្រះទ័យ ទឹកចិត្តដ៏សែនសប្បុរស នោះទេ មានតែកងការមហាកុសល ផលវិសេស ដែលកើតអំពីកឋិនទាន ដែលមានតាំងពីព្រឹករហូតដល់បញ្ចប់ថ្ងៃស្អែកនោះផង និងកើតពីធម្មទានក្នុង ពេលឥឡូវនេះផង **ឲតោ សុ អានិសំសចសេន** ដោយអំណាចនៃផលា និសង្សក្នុងទានទាំងពីរនេះ សូមបានក្លាយទៅជាធម្មយានឬនាវីកដឹកនាំពាំ យូរញាតិញោមបងប្អូន ប្រិយមិត្តជិតឆ្ងាយទាំងអស់បានប្រកបជួបប្រទះតែ សម្បត្តិ ៣ មនុស្ស សូគ៌ាល័យ ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។



www.elibraryofcambodia.org

# អំពីសង្ឃកម្ម

សង្ឃកម្ម គឺការងាររបស់សង្ឃ ដែលក្រុមភិក្ខុរួមគ្នាអនុមតិធ្វើដោយការព្រមព្រៀង ។

សង្ឃដែលត្រូវធ្វើសង្ឃកម្ម និមួយៗនោះលោកបញ្ញត្តិចំនួនភិក្ខុជាក្រុមជាវគ្គចំនួន ៥វគ្គឬ ៥ពួកគឺ :

១. **សង្ឃចតុវគ្គ.** ប្រជុំភិក្ខុ ៤អង្គឬការកសង្ឃចំនួន ៤រូប អាចធ្វើសង្ឃកម្មគ្រប់យ៉ាងបាន លើកលែងតែ **បវារណាកម្ម១ កឋិនកម្ម១ ឧបសម្បទាកម្ម១ អព្ភានកម្ម១** ។ ( សង្ឃកម្មទាំងបួននេះសំរេចដោយភិក្ខុ ៤អង្គមិនបាន ) ។

២. **សង្ឃបញ្ចវគ្គ.** ប្រជុំភិក្ខុ ៥អង្គ ឬការកសង្ឃចំនួន ៥រូបអាចធ្វើសង្ឃកម្មបានគ្រប់យ៉ាង លើកលែងតែ **ឧបសម្បទាកម្ម** ក្នុងមជ្ឈិមប្រទេស និង **អព្ភានកម្ម** ចេញពីពួកភិក្ខុ ៥រូប ប្រជុំធ្វើកម្ម ពីរយ៉ាងនេះមិនបាន ។

៣. **សង្ឃទសវគ្គ.** ប្រជុំភិក្ខុ ១០អង្គ អាចធ្វើសង្ឃកម្មគ្រប់យ៉ាងបានលើកលែងតែ **អព្ភានកម្ម១** មិនអាចធ្វើបានឡើយ ។

៤. **សង្ឃវីសតិវគ្គ.** ប្រជុំភិក្ខុ ២០អង្គ អាចធ្វើសង្ឃកម្មគ្រប់ប្រការ បានមិនមានទាស់ ។

៥. **សង្ឃអតិរេកវីសតិវគ្គ.** ប្រជុំភិក្ខុលើសអំពី ២០អង្គឡើងទៅធ្វើសង្ឃកម្មគ្រប់យ៉ាងបានដ៏ប្រពៃ ។

✳ **សង្ឃកម្ម** បើពោលដោយឈ្មោះមានច្រើនដូចជា : ឧបោសថកម្ម បវារណាកម្ម កឋិនកម្ម ឧបសម្បទាកម្ម ករុកិកម្ម តជ្ជនីយកម្ម



www.elibraryofcambodia.org

ទំរោបរោទីយកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម បរិវាសកម្ម អព្ភានកម្ម ជាដើម ............ ។

**សង្ឃកម្ម** ទាំងអស់នេះ បើពោលអំពីពិធីដែលសង្ឃត្រូវធ្វើ (សូត្រ) មាន៤យ៉ាងគឺ :

១. **អបលោកនកម្ម**. សង្ឃកម្មដែលភិក្ខុសង្ឃធ្វើដោយគ្រាន់តែ សូត្រប្រកាស (អបលោកន៍) មិនមានសូត្រកម្មវាចាឡើយ ។

២. **ញត្តិកម្ម** សង្ឃកម្មដែលសង្ឃធ្វើ គ្រាន់តែសូត្រតាំងញត្តិជាការស្រេច មិនមានសូត្រអនុស្សាវនាទេ ។

៣. **ញត្តិទុតិយកម្ម**. សង្ឃកម្មដែលសង្ឃធ្វើ ដោយសូត្រកម្មវាចាពីរគឺ តាំងញត្តិ១ និង អនុស្សាវនា ១ផង ។

៤. **ញត្តិចតុត្ថកម្ម** សង្ឃកម្មដែលសង្ឃធ្វើដោយកម្មវាចា៤ គឺការតាំងញត្តិ១ និងអនុស្សាវនា ៣ទៀត ។

**បញ្ជាក់ៈ** គ្រប់សង្ឃកម្មទាំងអស់ទោះកម្មនោះធ្វើដោយអបលោកនកម្មក្តី ដោយញត្តិកម្ម ឬញត្តិទុតិយកម្ម ឬក៏ដោយញត្តិចតុត្ថកម្មក្តី ត្រូវតែធ្វើដោយអនុមតិរបស់សង្ឃ ដែលព្រមព្រៀងគ្នា ។ ម្យ៉ាងទៀត កម្មដែលធ្វើដោយអបលោកនកម្ម មិនអាចយកធ្វើដោយញត្តិកម្មទេ ធ្វើដោយញត្តិកម្មមិនអាចធ្វើដោយញត្តិទុតិយកម្មឬដោយញត្តិចតុត្ថកម្មឡើយគឺថា សង្ឃកម្មគ្រប់ប្រភេទ ដែលត្រូវធ្វើកម្មណា ធ្វើបានតែតាមវិធីកម្មនោះធ្វើ ជំនួសគ្នាមិនបាន ។

សង្ឃកម្មគ្រប់យ៉ាង ទោះធ្វើដោយអបលោកនកម្មទាំងប៉ុន្មានក្តី ធ្វើដោយញត្តិកម្មចំនួនប៉ុន្មានក្តី ធ្វើដោយញត្តិទុតិយកម្មចំនួនប៉ុន្មានក្តី ធ្វើដោយ



www.elibraryofcambodia.org

ពាក្យពេចន៍ពុំរៀបរយ ការធ្វើសង្ឃកម្មទាំងអស់នោះ ត្រូវតែធ្វើឱ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាត គឺធ្វើឱ្យបានជា **ធម្មសមគ្គ** (ព្រមព្រៀងគ្នាប្រកបដោយធម៌) ទើបបានឈ្មោះថា **ជាធម្មកម្ម វិនយកម្ម** (ត្រូវតាមធម៌ ត្រូវតាមវិន័យ) បានឈ្មោះថា **អកុប្បកម្ម** (ជាកម្មមិនកំរើក ប្រកបដោយហេតុ ទើបការធ្វើនោះសំរេចត្រឹមត្រូវ និងទទួលផលបាន ។ ព្រះពុទ្ធអង្គហាមផ្ដាច់ មិនឱ្យធ្វើជា ÷

- **អធម្មវគ្គ** : កម្មជាពួក មិនប្រកបដោយធម៌
- **ធម្មវគ្គ** : កម្មជាពួក ប្រកបដោយធម៌
- **អធម្មសមគ្គ** : កម្មព្រមព្រៀងគ្នាដែរ តែមិនប្រកបដោយធម៌

កម្មទាំង៣នេះ ទ្រង់ហាមមិនឱ្យធ្វើ ព្រោះជាកុប្បកម្ម (កម្មកំរើក មិនប្រកបហេតុ) **ជាអធម្មកម្ម អវិនយកម្ម** (កម្មមិនត្រូវតាមធម៌ មិនតាមវិន័យ) បើទុកជាខំប្រឹងធ្វើ ក៏ឈ្មោះថាមិនបានធ្វើដែរ ហើយមានទោស (អាបត្តិ) ផង ។

ពាក្យថា **កម្មជាពួក** គឺការកសង្ឃមិនគ្រប់ចំនួនក្នុងសង្ឃកម្មនោះ ឬភិក្ខុដែលគួរដល់ឆន្ទៈ មិននាំឆន្ទៈមក ។ សូម្បីក្នុងអារាមដែលត្រូវធ្វើសង្ឃកម្មនោះ១ មានភិក្ខុសង្ឃដល់ទៅជាង២០ ឬ៣០-៤០អង្គ តែពេលត្រូវធ្វើសង្ឃកម្ម មានភិក្ខុសូម្បីតែមួយរូប មិនព្រមចូលរួមធ្វើ ហើយទាំងមិនឱ្យឆន្ទៈដល់សង្ឃទៀតផង ។ ភិក្ខុសង្ឃនៅសល់ក្រៅពីនេះ មានចំនួនលើសកំណត់ការកសង្ឃក្នុងសង្ឃកម្មក៏ដោយ ធ្វើសង្ឃកម្មនេះគឺធ្វើមិនបាន បើធ្វើហៅថា កម្មជាពួក គឺមិនព្រមព្រៀងគ្នា ។

ពាក្យថា : **មិនប្រកបដោយធម៌** សំដៅយកការធ្វើជា អបលោកនកម្ម



www.elibraryofcambodia.org

បែរជាធ្វើដោយតាំងញត្តិ ( ញត្តិកម្ម ) កម្មធ្វើត្រូវញត្តិកម្ម បែរជាធ្វើពោលតាំងញត្តិផង មានអនុស្សាវនាផង គឺធ្វើដោយកម្មវាចាពីរ ( ញត្តិទុតិយកម្ម ) ឬត្រូវធ្វើដោយកម្មវាចាពីរ បែរជាធ្វើដោយកម្មវាចា៤ ( ញត្តិចតុត្ថកម្មទៅវិញ ) ឬក៏តាំងញត្តិក្រោយអនុស្សាវនា គឺសូត្រអនុស្សាវនា មុនតាំងញត្តិ ។ម្យ៉ាងទៀត ការសូត្រកម្មវាចា ឬការសូត្រញត្តិ ឬក៏ការសូត្រប្រកាស ( អបលោកន៍) អ្នកសូត្រមិនត្រឹមត្រូវតាមអក្ខរប្បភេទ ( **សិថិលធនិត ទុដាលហុ**...។ល។ មិនត្រឹមត្រូវតាមឋានករណៈ ( មើលក្នុងកច្ចាយនូបត្ថម្ភក ភាគ១ផង ) ។ ការដែលភិក្ខុសង្ឃសូត្រសង្ឃកម្ម ខុស-ភ្លាត់ តាមប្រការណាមួយ ដូចរៀបរាប់ខាងលើនេះឈ្មោះថា **អធម្មកម្ម** កម្មមិនប្រកបដោយធម៌ ។

ពាក្យថា **ប្រកបដោយធម៌** គឺផ្ទុយពីខាងលើនេះ ដោយធ្វើត្រឹមត្រូវតាមកម្មអានត្រឹមត្រូវ ។

ពាក្យថា **ព្រមព្រៀងគ្នា** គឺការកសង្ឃជាភិក្ខុបកតត្ត ( ភិក្ខុប្រក្រតីមិនត្រូវអាបត្តិ ) មានគ្រប់ចំនួនក្នុងសង្ឃកម្មនិមួយ១ ឬ ការកសង្ឃ មានចំនួនលើសក៏ដោយបើមានភិក្ខុ១រូបណា ឈឺ មិនអាចចូលរួមបានក្តី ភិក្ខុជាប់នៅថែទាំគិលានភិក្ខុក្តី ឬ ភិក្ខុមានជាប់រវល់ក្នុងសង្ឃករណីយកិច្ចក្តី សុទ្ធតែបាននាំឆន្ទៈមកដល់សង្ឃ ទោះបីភិក្ខុត្រូវនាំឆន្ទៈនោះ មានចំនួនច្រើនអង្គក្តី ឱ្យតែសល់ភិក្ខុនៅគ្រប់ចំនួន ការកសង្ឃក្នុងសង្ឃកម្មនោះ១ អាចធ្វើសង្ឃកម្មបាន ហៅថា ព្រមព្រៀងគ្នា ទាំងអស់ ។

**សង្ឃករណីយកិច្ច** គឺកិច្ចការទាំងឡាយជារបស់សង្ឃពិត១ ត្រូវភិក្ខុតំណាងសង្ឃជាអ្នកអនុវត្ត ។ ក្នុងអាវាសនិមួយ១ ក្រៅពីចៅអធិការ និង គ្រូ



www.elibraryofcambodia.org

សូត្រញត្តិទុតិយកម្ម ទៅកាន់ការចាត់តាំងភិក្ខុដោយកសង្ឃ ដែលហៅថា **សង្ឃធ្វើសម្មតិកម្ម** សន្មតភិក្ខុនេះជា **ភត្តុទ្ទេសកៈ** ភិក្ខុនោះជា **សេនាសនបញ្ញាបកៈ** "អ្នករៀបចំចាត់ចែងទីសេនាសនៈ ឱ្យភិក្ខុសាមណេរក្នុងវត្ត" ជាដើម ។ ប៉ុន្តែវត្តអារាមខ្លះមិនមានសន្មត **ឧទ្ទេសកភិក្ខុ** ទេ គឺលោកគ្រូចៅអធិការផ្ទាល់ ដែលលោក បំពេញសង្ឃករណីកិច្ច តែម្តង ព្រោះបច្ចុប្បន្ន ព្រះសង្ឃ ភិក្ខុសាមណេរតិចតួចក្នុងអាវាសវត្តភាគច្រើន ។

( សូមមើលសៀវភៅ "សង្ឃករណីយកិច្ច" បន្ថែម )

## កម្មវិបត្តិ

( សំដៅយកសង្ឃកម្មខុស ឬ ខូចសង្ឃកម្ម )

ដើម្បីធ្វើសង្ឃកម្ម ឱ្យបានត្រឹមត្រូវតាមធម៌វិន័យជាពុទ្ធានុញ្ញាត និងពុទ្ធបញ្ញត្តិ គប្បីស្គាល់ឱ្យច្បាស់ វិបត្តិរបស់សង្ឃកម្មគ្រប់យ៉ាង ។

*វិបត្តិសង្ឃកម្មដែលហៅថាកម្មវិបត្តិនោះមាន ៤យ៉ាងគឺ :*

១. **វត្ថុវិបត្តិ** វិបត្តិដោយវត្ថុ គឺខូច ឬ ខុសពី **ពុទ្ធប្បញ្ញត្តិ** ដូចជា បំបួសកុលបុត្រឱ្យជាភិក្ខុដែលមានអាយុ មិនគ្រប់ ២០ឆ្នាំ ជាដើម ។

២. **សីមាវិបត្តិ** វិបត្តិដោយសីមា គឺខូច ឬ សីមាខុស បានដល់សីមាវិបត្តិ ១១យ៉ាង ណាមួយ ។

៣. **បរិសវិបត្តិ** វិបត្តិដោយបរិសទ័ គឺប្រជុំសង្ឃមិនគ្រប់អង្គតាមកំណត់ ឬ ភិក្ខុណាមួយក្នុងអាវាសនោះ មិនចូលរួម មិននាំឆន្ទៈ ។

៤. **កម្មវាចាវិបត្តិ** វិបត្តិដោយកម្មវាចា គឺសូត្រភ្លាំងភ្លាត់ខ្វះខាតមិន



www.elibraryofcambodia.org

ត្រូវតាមរបៀប **អក្ខរៈ** . គួរតាំងញត្តិ ឬ សូត្រអនុសាវនា តែមិនតាំងញត្តិ ឬ មិនសូត្រអនុសាវនា ។

---

## ឧបោសថកម្ម

តទៅនេះ សូមលើកយកសង្ឃកម្មមួយប្រភេទ ដែលឈ្មោះថា : **ឧបោសថកម្ម** ដែលជាការងាររបស់ភិក្ខុសង្ឃគ្រប់រូប ត្រូវតែប្រតិបត្តិរាល់ថ្ងៃឧបោសថ ព្រោះជាចំណី ឬ ថ្នាំឱសថកែបំប៉នសីល ជម្រះសីលរបស់ផងភិក្ខុ ឱ្យស្អាតបរិសុទ្ធ សមតាម **លោកស្សបុញ្ញក្ខេត្ត** គឺជាស្រែបុណ្យដ៏ល្អ របស់ទាយកទាយិកាផង បានជាអរិយធន ផ្ទាល់ព្រះអង្គផង ។ ពិសេសដើម្បីសាមគ្គីដល់ភិក្ខុសង្ឃ ការពារបាននូវវិវាទាធិករណ៍របស់បព្វជិតក្នុងព្រះពុទ្ធសាសនាផង ។ **ឧបោសថកម្ម** ជា **ញត្តិកម្ម** ។

ឧបោសថកម្មក្នុងឱកាសនេះ សូមលើកតែ សង្ឃុបោសថ គឺឧបោសថដែលធ្វើដោយសង្ឃចតុវគ្គ ( ភិក្ខុ ៤ អង្គឡើងទៅ ) មិនបាននិយាយដល់គណុបោសថ ( ឧបោសថធ្វើដោយភិក្ខុ ២ ឬ ៣ អង្គ ) និង អធិដ្ឋានុបោសថ ( ឧបោសថដែលធ្វើដោយភិក្ខុតែ ១ អង្គ ) នោះទេ ។ **សង្ឃុឧបោសថ** ដែលសង្ឃត្រូវធ្វើនោះ គឺ ធ្វើឧបោសថ សំដែងបាតិមោក្ខ ហៅថា **សុត្តុទ្ទេសុបោសថ** ( ឧបោសថដោយសូត្របាតិមោក្ខគ្រប់ឧទ្ទេស ) ។

ឧបោសថកម្មនេះ **បកតត្តភិក្ខុ** ត្រូវធ្វើក្នុង ១ បក្ខម្តង គឺកន្លះខែធ្វើម្តង ហើយធ្វើចំខែពេញបូរមី ( ១៥កើត ) និងថ្ងៃខែដាច់ ។ ហេតុនេះ ទើបលោកសំដែងថា ឧបោសថ បើពោលតាមថ្ងៃត្រូវធ្វើ មាន ២ យ៉ាងគឺ :



www.elibraryofcambodia.org

១. **មាតុទ្ទសិកុបោសថ** ឧបោសថថ្ងៃទី ១៤ ( បានដល់ថ្ងៃខែដាច់ សម្រាប់ខែហោដែលខាងរនោចលោកថា កោរពា ខែនោះដាច់ខែថ្ងៃ ១៤រោច )

២. **បណ្ណរសិកុបោសថ** ឧបោសថថ្ងៃ ១៥ ( បានដល់ថ្ងៃ ១៥ កើត ឬ ១៥ រោច ) ប៉ុន្តែប្រសិនបើមានអធិករណ៍ដោយភិក្ខុបែកបាក់គ្នា នៅពេលស្រុះស្រួលគ្នាវិញ ទ្រង់អនុញ្ញាតឱ្យធ្វើឧបោសថមួយទៀត ទោះចំថ្ងៃណាក៏ដោយ ឱ្យឈ្មោះថា **សាមគ្គីឧបោសថ** ឧបោសថថ្ងៃសាមគ្គីគ្នារបស់ភិក្ខុសង្ឃ ។

## ឧបោសថវិធី

របៀបធ្វើឧបោសថរបស់សង្ឃ ( សំដែងបាតិមោក្ខ )

ពេលនេះខ្ញុំលើកយកតែរបៀបរបប ធ្វើឧបោសថ តាមលំដាប់លំដោយ តាំងពីថ្ងៃ ឧបោសថ ចូលមកដល់ រហូតបានសំដែងបាតិមោក្ខចប់សព្វគ្រប់ តែប៉ុណ្ណេះ មិនលើកអំពី **ទោសប្បញ្ញត្តិ** ( អាបត្តិ ) ចំពោះភិក្ខុជាថេរៈ ឬ នវភិក្ខុ ដែលមិនអើពើមិនរវល់ មិនខ្វល់ខ្វាយ ឬ ថា មិនចាប់អារម្មណ៍ដល់ថ្ងៃឧបោសថនោះទេ ទាំងមិនលើកឡើងអំពីអានិសង្ស របស់ភិក្ខុ ដែលខ្វល់ខ្វាយចាត់ចែងធ្វើឧបោសថ ឬ ថា មានឆន្ទៈពិត១ក្នុងការបំពេញឧបោសថកម្ម នោះដែរ ព្រោះថា បើនឹងអធិប្បាយឱ្យសព្វគ្រប់ លើរឿងឧបោសថនេះ អាចធ្វើជាសៀវភៅមួយក្បាលដោយឡែកទៀត ទើបចូនល្មម ឬ សមគួរដល់អត្ថន័យទូលំទូលាយបាន ។ កាលបើថ្ងៃឧបោសថមកដល់ហើយ ភិក្ខុត្រូវអនុវត្តកិច្ចការដូចតទៅ គឺ ដំបូងធ្វើបុព្វករណ៍ ៤យ៉ាង បើព្រះថេរៈមិនបានធ្វើត្រូវប្រើភិក្ខុដទៃឱ្យធ្វើ :

១. **សម្មជ្ជនី** : បោសសំអាតឧបោសថាគារ



www.elibraryofcambodia.org

២. **បទីបោ** : រៀបចំ ចង្កៀង ទៀន ភ្លើង ទុកគ្រែងធ្វើពេលយប់

៣. **ឧទកំ** : រៀបចំទឹក សំរាប់ឆាន់ និង ប្រើប្រាស់ទុកឱ្យហើយ ។

៤. **អាសនេន** : រៀបចំក្រាលអាសនៈសំរាប់សង្ឃ និង ធម្មាសនៈ សំរាប់អ្នកសំដែង បាតិមោក្ខ ។ កិច្ចការ ៤ យ៉ាងនេះ ភិក្ខុត្រូវធ្វើទុកជាស្រេច មុនពេលភិក្ខុសង្ឃទៅជួប ជុំគ្នា ។

ភិក្ខុសង្ឃស្លៀកស្បង់ គ្រងចីពរ ដាក់សង្ឃាដិក្រវាត់វត្តពន្ធ ឱ្យជាបរិមណ្ឌលនិមន្តចូលទៅជួបជុំគ្នា ក្នុងរោងឧបោសថ ។ ជួបជុំហើយ ត្រូវសំដែងអាបត្តិ គ្រប់អង្គ ។

ភិក្ខុថេរៈនាំភិក្ខុសង្ឃ នមស្ការព្រះរតនត្រៃ ( ត្រៃបណាមគាថា ) ជាសង្ខេប ។ នមស្ការ ចប់ហើយ ភិក្ខុសង្ឃបែរមកប្រជុំគ្នា ធ្វើបុព្វកិច្ច ៥ មុនពេលសំដែងបាតិមោក្ខ គឺពិភាក្សាគ្នាជាមុន អំពី :

- ឆន្ទៈ និងបារិសុទ្ធី ដែលភិក្ខុអង្គណាត្រូវនាំមកក៏ប្រតិបត្តិចំពោះសង្ឃចុះបើមាន ។

- ឧតុក្ខានំ ការពិភាក្សាអំពីរដូវកាល ពេលនេះមានឧបោសថកន្លងទៅប៉ុន្មានហើយ នៅសល់ប៉ុន្មាន ។

- ឱវាទោ បញ្ជាក់ថា បច្ចុប្បន្នគ្មានភិក្ខុនី ដើម្បីឱ្យឱវាទទេ ។ កាលបើចប់ពិភាក្សាបុព្វកិច្ចហើយ គប្បីកំណត់ភិក្ខុពីរអង្គ សំរាប់សួរឆ្លើយវិន័យ ។ ដោយភិក្ខុអ្នកឆ្លើយ ត្រូវបានភិក្ខុអ្នកសួរ អារាធនាឱ្យសំដែងបាតិមោក្ខ តែម្តងក្នុងពេលចុងបញ្ចប់សំនួរចម្លើយនោះ ។ បន្ទាប់ពីធ្វើបុព្វកិច្ចហើយ ភិក្ខុសង្ឃត្រូវគង់ឱ្យជាបរិហត្ថបាសគ្រប់អង្គ ពទ្ធ័ជុំវិញគ្រែ ធម្មាសនៈ ហើយភិក្ខុអង្គយប្រ



www.elibraryofcambodia.org

ហោង ផ្គងអញ្ជលី រគុក្នា ផ្តើម **នមោ** ៣បទ ដោយភិក្ខុអ្នកសួរ សន្មតខ្លួនជាអ្នកសួរវិន័យ រួចភិក្ខុអ្នកឆ្លើយផ្តើម **នមោ** ៣បទ ហើយសន្មតខ្លួនជាអ្នកឆ្លើយវិន័យ ។ **សម្មតិកម្ម** ( ការសន្មតិ ) នេះជា **ញត្តិកម្ម ។** សន្មតរួចហើយ ពាប់បន្ត សួរ-ឆ្លើយ ជាបាលីសុទ្ធ អំពីបុព្វករណ៍ ៤ បុព្វកិច្ច ៥ និងអំពី **បត្តកល្លឧបោសថ** តទៅ រហូតចប់ ។ ចុងក្រោយភិក្ខុអ្នកសួរ អារាធនាភិក្ខុអ្នកឆ្លើយដើម្បីឱ្យជាអ្នកសំដែងបាតិមោក្ខតទៅ ។ ( កិច្ចវិន័យ សន្មតខ្លួន សួរឆ្លើយវិន័យជាដើម នេះមាននៅក្នុងសៀវភៅ ភិក្ខុបាតិមោក្ខ បាលីប្រែរបស់ព្រះភិក្ខុធម្មារាមោ ប៊ុណ្ណ សម្ភាជន៍ សូមពិនិត្យ និងសិក្សាចុះ ) ។

ពេលនោះភិក្ខុអ្នកត្រូវសំដែងបាតិមោក្ខ ត្រូវថ្វាយបង្គំព្រះពុទ្ធបដិមា និងថ្វាយបង្គំព្រះមហាថេរនៅក្នុងទីចំពោះមុខនោះ ( បើមាន ) ហើយឡើងគង់លើធម្មាសនៈ ដែលរៀបចំទុកស្រេច ជាប់ហត្ថបាសនឹងភិក្ខុសង្ឃ ហើយចាប់ផ្តើម សូត្របាតិមោក្ខ ដែលមានក្នុងសៀវភៅ បាតិមោក្ខ តាំងពីដើមដល់ចប់ ។

កិច្ចឧបោសថកម្ម ឈ្មោះថា ចប់ ឬ សំរេចជាស្ថាពរ នៅពេលសំដែងបាតិមោក្ខ ចប់ដោយបរិបូណ៌ ។

<u>**បញ្ជាក់**</u> **តាមទំនៀមព្រះពុទ្ធសាសនា :** ថ្ងៃឧបោសថនិមួយៗ ទោះជាចាតុទ្ទសី ( ទី១៤កើ្ត ) បណ្ណរសី ( ថ្ងៃទី១៥ ) ក្តី លោកកំណត់គិតពីពេលនេះ តទៅពេញមួយថ្ងៃ រហូតដល់មួយចប់ **បច្ឆិមយាម** ទៀបភ្លឺ គឺ ទល់និងថ្ងៃបន្ទាប់ គឺថាទល់និងដើមថ្ងៃ ១ កើត ឬ ដើម ថ្ងៃ ១ រោច ។ រយៈ ១ថ្ងៃ ១យប់នោះហើយដែលកំណត់ថាជា ថ្ងៃឧបោសថ ។

កាលបើចូលដល់ថ្ងៃឧបោសថហើយ ភិក្ខុសង្ឃអាចធ្វើឧបោសថ ពេល



www.elibraryofcambodia.org

ណាក៏គួរ ។ អាចធ្វើពេលព្រឹក-រសៀល-យប់ ស្រេចហើយ តែឱកាសពេល មានលទ្ធភាពតាមកាលៈទេសៈ និង ឯកភាពគ្នា ។ តាមមតិខ្ញុំផ្ទាល់ ចំពោះ **បុព្វករណ៍** ៤ យ៉ាង គួរតែរៀបចំឱ្យហើយស្រេច នៅព្រឹកថ្ងៃឧបោសថ ។

ម្យ៉ាងទៀត មុនថ្ងៃឧបោសថ គឺថ្ងៃកោរ ដែលបព្វជិតត្រូវដាក់កំណោរ គ្រប់អង្គ ។ ពេលល្ងាចថ្ងៃកោរនោះ ពួកសាមណេរត្រូវធ្វើកិច្ចវត្តមួយគឺ សមាទានទូវ **ទសសីល** ( សីល១០ ) ឬ ហៅថា **អធិវាសសីល** ដោយសាមណេរ គ្រប់អង្គ ត្រូវស្លៀកស្បង់គ្រងចីពរ ឱ្យជាបរិមណ្ឌលក្រវាត់វត្តពទ្ធ យកទៀន ៥ ធូប ៥ ដាក់លើគំរបបាត្រថ្វាយ ទៅវន្ទាគ្រូឧបជ្ឈាយ៍ ឬ គ្រូអាចារ្យ ដើម្បី សមាទានសីល និងបានស្តាប់ដំបូន្មានពីលោកផង ។ ដូច្នេះ ពួកភិក្ខុ ក៏អាច រលឹកឃើញបានថា ថ្ងៃស្អែក ជាថ្ងៃឧបោសថរបស់អាត្មាអញ ។

*ប៉ុន្តែលោកបានប្រាប់ថា :*

- ភិក្ខុ មិនគួរនាំគ្នាបង្ខំធ្វើ ឬ ប្រញាប់ប្រញាល់ធ្វើឧបោសថ ក្នុងបំណងធ្វើចោលភិក្ខុដទៃ ឬ មិនឱ្យភិក្ខុឯទៀតមកទាន់ នោះទេ ។

- លោកផ្តាំថែមទៀតថាក្នុងថ្ងៃឧបោសថ ភិក្ខុមិនត្រូវចេញចាកអាវាសឡើយ ។ តែបើមានសង្ឃករណីយកិច្ចចាំបាច់ ត្រូវតែទៅថ្ងៃនេះ ហើយមិនអាចត្រឡប់មកវិញទាន់ក្នុងថ្ងៃនេះទេ ភិក្ខុដែលតំណាងសង្ឃត្រូវចេញទៅបំពេញកិច្ចការសង្ឃនោះ គប្បីឱ្យឆន្ទៈ និង បារិសុទ្ធិ ដល់សង្ឃ តាមរយៈភិក្ខុណាមួយក៏គួរ ។



www.elibraryofcambodia.org

# បុណ្យបច្ច័យបួន

ពាក្យថា ( **បច្ច័យ** ) សំដៅដល់ "គ្រឿងសំរាប់អាស្រ័យរបស់បព្វជិត" ។

អ្វីទៅដែលហៅថា ( **បច្ច័យ** ) គ្រឿងអាស្រ័យបព្វជិត ?

បើជាទូទៅ ហៅថា **អាមិស** ។ **អាមិស** ជាវត្ថុ សំភារៈ ឧបភោគ បរិភោគ ប្រើប្រាស់ បំរើសុខភាព ជួយជាកម្លាំង បំរើតម្រូវការ សេចក្តីប្រាថ្នាចង់បាន របស់មនុស្សទូទៅ ។

*តាមន័យនេះ :* **អាមិសៈ** បានដល់វត្ថុគ្រប់យ៉ាង សំរាប់ទំនុកបំរុង ឧបត្ថម្ភជីវិតមនុស្សឱ្យរស់នៅបានសុខស្រួល ឈានទៅរុងរឿងថ្លៃថ្លា ។ ដូចជា សំពត់ខោអាវ សំលៀកបំពាក់ សំរាប់បិតបាំង កែលំអរាងកាយ អាហារភោជន គ្រប់ប្រភេទសំរាប់ហូបពិសា សម្ភារៈ ភស្តុភារ បណ្ណាការ ទ្រព្យសម្បត្តិ សំរាប់សំរួលការដេកដើរ អង្គុយ សំរាកស្នាក់អាស្រ័យនឹងថ្នាំកែរោគគ្រប់មុខ ។ ជារូម អ្វីៗជាវត្ថុ សម្ភារៈ របស់របរប្រដាប់ប្រដា គ្រឿងបរិភោគ ប្រើប្រាស់ របស់មនុស្ស សំរាប់ជួយផ្តល់ការសុខស្រួល ឱ្យកើតជាផលប្រយោជន៍ ផ្តត់ផ្គង់ជីវិត ប្រមូលផ្តុំវត្ថុរួមទាំងអស់នោះ លោកហៅជាពាក្យ បច្ចេកទេស តែមួយម៉ាត់ថា **អាមិស** ។

**អាមិស** ជាវត្ថុជួយមនុស្ស ឱ្យរស់នៅបានស្រួល ជួយផ្តល់ផលប្រយោជន៍ឱ្យមនុស្សមានអានុភាព មានអានិសង្សច្រើនសំរាប់ការរស់នៅ ។

***ព្រះពុទ្ធសាសនា*** ព្រះពុទ្ធអង្គទ្រង់ឆ្វេងយល់ច្បាស់នូវផលប្រយោជន៍ នៃ **អាមិស** ទើបទ្រង់អនុញ្ញាតឱ្យបព្វជិតបរិភោគ ប្រើប្រាស់ **អាមិស** តាមការគួរ ។ ក្រៅពី **បង្សុកូល** ចីវរ ដើរបិណ្ឌបាតដេកនៅក្រោមដើមឈើ ផឹកថ្នាំ



www.elibraryofcambodia.org

មូលភេសជ្ជៈ ព្រះអង្គអនុញ្ញាតឱ្យប្រើ **អតិរេក** លោភបាន ដើម្បីជួយសម្រួលជីវភាពភិក្ខុសង្ឃឱ្យប្រព្រឹត្តទៅបានស្រួល ។ តែព្រះអង្គមិនហៅថា **អាមិស** ទេ ទ្រង់ហៅ " **បច្ច័យ** " ។ ព្រោះបច្ច័យជាគ្រឿងបន្តជីវិតឬជួយសំរួលជីវិតមនុស្សឱ្យរស់ល្មមប្រព្រឹត្តទៅបានស្រួល ។ ពិសេសបច្ច័យអាចផ្តល់ផលប្រយោជន៍សំខាន់ដល់មគ្គញ្ញជន អ្នកស្គាល់ប្រមាណក្នុងកាបរិភោគប្រើប្រាស់ ។ មនុស្សយើងបើពុំមានបច្ច័យទាំងអស់ជាជំនួយទេ នឹងរស់នៅពុំបាន ធ្វើប្រយោជន៍អ្វីក៏ពុំកើតដែរ ។

បច្ច័យដ៏ច្រើនសន្ធឹកសន្ធាប់នោះ ប្រមូលមកហៅត្រឹមតែ ៤បច្ច័យ គឺ **ចីវរប្បច្ច័យ១. បិណ្ឌបាតប្បច្ច័យ១. សេនាសនប្បច្ច័យ១. និងគិលានភេសជ្ជប្បច្ច័យ១ ។**

ជាការពិត ការរស់នៅបើមានតែបច្ច័យ៣ ខ្វះបច្ច័យណាមួយក៏រស់មិនស្រួល ។

១. សំពត់ខោអាវសារស្បៃជាសំលៀកបំពាក់គ្រឿងស្លៀកដណ្តប់បិទបាំងរាងកាយ ការពារក្តៅត្រជាក់ជាដើម មានស្បង់ចីពរសង្ឃាដី និងបរិក្ខារបន្ទាប់បន្សំដូចអង្សាក់វត្ថពន្ធកាយពន្ធនិសីទនៈសាដក កន្សែង........ជាដើមរាប់បញ្ចូលជា **ចីវរប្បច្ច័យ ។**

២. គ្រឿងបរិភោគ ហូប ពិសា ឆាន់ មានអាហារភោជន នំនែកបង្អែម ចំអាប បាយ សម្ល ត្រី សាច់ ប្រហុក ផ្អក អំបិល ... ជាដើមរាប់បញ្ចូលជា : បិណ្ឌបាតប្បច្ច័យ ។

៣. ទីលំនៅភូមិស្ថានសំរាប់ជ្រកកោន ដេកអង្គុយ ស្នាក់អាស្រ័យ



www.elibraryofcambodia.org

ថ្ងៃយប់មានផ្ទះសំបែង កុដិ សាលា វិហារ កន្ទេល ខ្នើយ គ្រែ តុទូ កៅអី ឆ្នាំងចាន ស្លាបព្រាបាត្រ ....ជាដើម រាប់បញ្ចូលហៅថា សេនាសនប្បច្ច័យ ។

៤. ថ្នាំសង្កូវ កែរោគ ការពារ ព្យាបាលជម្ងឺដម្កាត់ផ្សេងៗមាន ថ្នាំបុរាណ ឱសថសម័យសំរាប់ផឹកលេប លាប ចាក់ ភេសជ្ជៈ៥មុខជាដើម មានទឹកដោះរាវ ទឹកដោះខាប់ ប្រេង ស្ករ ទឹកឃ្មុំ និងទឹកអជ្ជបាន ជាដើម រាប់បញ្ចូលហៅថា គិលានភេសជ្ជប្បច្ច័យ ។

ប៉ុន្តែបច្ច័យគ្រប់យ៉ាងដែលរាប់បញ្ចូលតាមឈ្មោះតែ ៤បច្ច័យនេះ ជាបច្ច័យ ( **អាមិសវត្ថុ** ) សំរាប់មនុស្សទូទៅ . ចំពោះបព្វជិតក្នុងពុទ្ធសាសនា ព្រះអង្គទ្រង់អនុញ្ញាតឱ្យ បរិភោគ ប្រើប្រាស់បច្ច័យ " ដែលជាគ្រឿងអាស្រ័យរបស់បព្វជិតនោះដោយមានកំណត់ " ។

ម្យ៉ាងទៀត បច្ច័យ៤ ដែលមានកំណត់នោះបព្វជិតមុននឹងបរិភោគប្រើប្រាស់នូវបច្ច័យណាមួយ ដែលទ្រង់បានអនុញ្ញាត សុទ្ធតែត្រូវពិចារណាដោយសតិសម្បជញ្ញៈសិន សឹមបរិភោគប្រើប្រាស់ ។ ការរៀបរាប់ដោយសង្ខេបមកប៉ុណ្ណោះឯងដែលជាចម្លើយឆ្លើយតបទៅនឹងសំណួរខាងដើមថា : អ្វីទៅដែល ហៅថាបច្ច័យ គ្រឿងអាស្រ័យរបស់បព្វជិត នោះឯង ។

ពាក្យថា "**បុណ្យបច្ច័យបួន**" គឺជាឈ្មោះ **បុញ្ញកម្ម** មួយបែបដែលបូរាណាចារ្យខ្មែរយើងសន្មតហៅ តាមបច្ច័យទេយ្យវត្ថុដែលគេធ្វើទាន ដោយរៀបខ្ចប់បច្ច័យទាំងបួនមុខ ក្នុងមួយកញ្ចប់ៗសំរាប់ជាទេយ្យទាន ។

តើបុណ្យបច្ច័យបួន **ទាយកទាយិកា** ត្រូវធ្វើដូចម្តេច ? មុននឹងធ្វើបុណ្យលោកអ្នកម្ចាស់ដើមបុណ្យឬម្ចាស់ដើមទានប្រធានបុណ្យ តែងប្រជុំពិភាក្សាគ្នា



www.elibraryofcambodia.org

ថា ត្រូវនិមន្តលោកប៉ុន្មានអង្គ ? និមន្តលោក ១អង្គ-២អង្គ-៣ឬ៤អង្គឬ៥-៦ ៧អង្គ ។ លោកអ្នកអាចនិមន្តលោកមកទទួលក្នុងបុណ្យប៉ុន្មានអង្គក៏បាន អា-ស្រ័យ **បសាទសទ្ធា** និងលទ្ធភាពរបស់ទាយកទាយិកាម្ចាស់បុណ្យ ។

បើយើងតម្រូវនិមន្តលោក ២អង្គ យើងរៀបទេយ្យវត្ថុ ២កញ្ចប់ និមន្ត ៣អង្គ រៀបទេយ្យវត្ថុ ៣កញ្ចប់ បើ ៤អង្គ រៀបទេយ្យវត្ថុ ៤កញ្ចប់ . បើមាន សទ្ធានិមន្ត ៧អង្គ គប្បីរៀបទេយ្យវត្ថុ ៧កញ្ចប់គឺត្រូវរៀបទេយ្យវត្ថុជាកញ្ចប់ៗ តាមជំនួនលោកដែលត្រូវនិមន្តមកនោះ ឱ្យបានមួយកញ្ចប់ ១អង្គគ្រប់ៗអង្គ ។

ឯទេយ្យវត្ថុក្នុងមួយកញ្ចប់ៗត្រូវមានបច្ច័យបួនមុខគឺ ចីវរ បិណ្ឌបាត្រ សេនាសនៈ ភេសជ្ជៈ ដាក់បញ្ចូលក្នុងមួយកញ្ចប់ៗ ដូចៗគ្នា ។

មានអ្នកខ្លះយល់ច្រឡំថា " ធ្វើបុណ្យបច្ច័យបួន គេនិមន្តលោកតែ ៤ អង្គទេ បើនិមន្តលោកដល់ ៥អង្គវាទៅជាធ្វើបុណ្យបច្ច័យប្រាំហើយ ?

ការយល់យ៉ាងនេះ មុខគួរឱ្យសង្វេគបែរជាយកព្រះសង្ឃធ្វើជាបច្ច័យ ទៅវិញពុទ្ធោអើយ ! បច្ច័យមានតែបួនប្រភេទទេ មានបច្ច័យឯណាដល់ទៅប្រាំ ឬក៏ ប្រាំមួយមុខនោះ ! ការធ្វើបុណ្យបច្ច័យបួនគឺ គេរៀបទេយ្យវត្ថុឱ្យមានគ្រប់ ទាំងបួនបច្ច័យក្នុងមួយកញ្ចប់ ។ បើម្ចាស់បុណ្យ ជាអ្នកមានធូរធារ គេអាច បញ្ចូល ចីវរប្បច្ច័យ២ មានស្បង់ផង កន្សែងផង . បិណ្ឌបាតប្បច្ច័យ ៣ឬ៤ មានអង្ករផង ត្រីងៀតផង ទឹកត្រីផង សេនាសនប្បច្ច័យ ៣ឬ៤ មានកន្ទេល ផង ខ្នើយផង ស្បែកជើងឬប៉ាន់ពែងផងក៏បាន និង គិលានភេសជ្ជប្បច្ច័យ ៣-៤ មានទឹកដោះគោ តែ ស្ករ ឬ ថ្នាំពេទ្យថែមទៀតក៏បាន ។ រួមបច្ច័យ ទាំង ៤ ដ៏ច្រើនមុខនេះបញ្ចូលគ្នា វេចខ្ចប់ជាមួយកញ្ចប់ ។



www.elibraryofcambodia.org

ទេយ្យវត្ថុដ៏ច្រើនមុខនេះក៏ឈ្មោះថា បច្ច័យបួន ។ យើងរៀបកញ្ចប់សំរាប់តែលោកមួយអង្គក៏បច្ច័យបួន រៀប ៤-៥-៦ កញ្ចប់ សំរាប់លោក ៤-៥ ៦ អង្គក៏ឈ្មោះថា "ធ្វើបច្ច័យបួន" ដែរ ។

ព្រោះតែថា : បើធ្វើតូច បច្ច័យទាំងបួន, មួយមុខ១ក៏តិច ។ ទោះបីតិចក្ដី ច្រើនក្ដី ក៏ត្រូវឱ្យបាន ៤ មុខ ។

ឯវិធីធ្វើ ដូចជាបុណ្យផ្សេងដែរ គឺថ្ងៃបុណ្យនោះ ពេលព្រឹកបងប្អូនជិតខាង ជួយធ្វើរោងបុណ្យមុខផ្ទះ តុបតែងរោង ហើយយករណ្ដាប់ទេយ្យវត្ថុ ដែលខ្ចប់ដោយក្រដាសភ្លឺស្អាតចំនួនប៉ុន្មានកញ្ចប់ ដែលយើងតម្រូវនិមន្តព្រះសង្ឃប៉ុន្មានអង្គនោះ មកដាក់តម្រៀបលើគ្រែក្បែរគ្រឿងសក្ការៈព្រះពុទ្ធរូប ។ ដល់ពេលរសៀល មេក្រុបុណ្យបន្លឺសម្លេង ជាពេលដែលភ្ញៀវអញ្ជើញទៅចូលបុណ្យ ។ ពេលល្ងាចលោកអាចារ្យ ចាប់ផ្ដើមនមស្ការថ្វាយបង្គំ ហើយនិមន្តព្រះសង្ឃតាមចំនួនមក រួចសមាទានសីល និង អារាធនាចំរើនព្រះបរិត្ត ។ បើមានទេសនាផង ក៏រៀបធម្មាសនៈ ហើយនិមន្តព្រះធម្មកថិក សំដែងធម៌ទេសនា តទៅ ។ លុះព្រឹកឡើងនិមន្តព្រះសង្ឃទទួលយាគូ ។ បើមិនបានធ្វើយាគូទេ ធ្វើសង្ឃភត្តតែម្ដងនោះ គប្បីសមាទានសីល ហើយអ្នកដើមបុណ្យព្រមទាំងកូនចៅ ញាតិមិត្ត នាំគ្នាកាន់គ្រឿងប្រដាប់ទេយ្យវត្ថុឡើង ដើម្បីវេរទេយ្យវត្ថុ បច្ច័យ៤ នេះនិងវេរចង្ហាន់ទៅជាមួយគ្នា ។

*លោកអាចារ្យនាំពុទ្ធបរិសទ័វេរ :* **នមោ** ៣បទ (តាមទម្លាប់ រួចអ្នកដើមបុណ្យទាំងអស់និងពុទ្ធបរិស័ទថាតាមលោកអាចារ្យវេរ :

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស**



www.elibraryofcambodia.org

ឥម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ ( មាតាបិតាទីនំ គុណវន្តានញ្ច ) អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៕

ទុតិយម្បិ . មយំ . ភន្តេ ................

តតិយម្បិ . មយំ . ភន្តេ ..............៕

បពិត្រព្រះសង្ឃដ៏ចំរើនអើយ ! យើងខ្ញុំទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤នេះ មកដាក់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវបច្ច័យទាំងឡាយ ៤នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ (ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង អស់កាលអង្វែងទៅហោង ។

អស់វារៈ២ដងផង អស់វារៈ៣ដងផង ។

បន្ទាប់មកចូលទៅអង្គុយឱ្យជាប់ហត្ថបាស ហើយប្រគេនទេយ្យវត្ថុនិងចង្ហាន់ដល់ព្រះសង្ឃ ។ ព្រះសង្ឃ **អនុមោទនា** (គឺសូត្រ ធមិ )ចប់ហើយ យើងសូត្រ ឧទ្ទិសកុសលផលទាន តាមទម្លាប់ ។

***សូមបញ្ជាក់ថា :*** ការវេរនេះ បើមានតែទេយ្យវត្ថុក៏វេរយ៉ាងនេះ ។ បើមានធ្វើចង្ហាន់ ព្រះសង្ឃឆាន់នៅផ្ទះបុណ្យឬរាប់បាត្រ ចង្ហាន់ដាក់ចានស្រាក់យកទៅឆាន់ឯវត្តផង ក៏វេរតែមួយលើកដូចខាងលើនោះតែម្តងជាការស្រេច ។

តែបើលោកអាចារ្យចង់វេរដោយឡែក ជាពីរវត្ថុ គឺ : វេរទេយ្យវត្ថុបច្ច័យបួន ដូចខាងលើ រួចហើយសឹមវេរចង្ហាន់ មួយលើកទៀត ដោយឡែកពីបាលីវេរខាងលើនេះ ក៏បាន គឺ វេរ :



www.elibraryofcambodia.org

- អយំ នោ ភន្តេ បិណ្ឌបាតោ ឧម្ហិកោ ឧម្ហូលក្ខោ ឧម្មនេហ ឧប្បាទិតោ .................... ៣ដង

- មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជិតា សង្ឃស្ស ទេម ....................៣ដង

ប៉ុន្តែសូមលោកអាចារ្យ មើលពេលវេលាផង ព្រោះតែគេហៅថា : (លោកអាចារ្យអ្នកនាំមុខគេនោះ) ត្រូវឈ្វេងយល់ឱ្យសព្វ គឺ : **កាលញ្ញូ** គួរដឹង-ស្គាល់កាលវេលា (ក្រែងយូរពេកទៅនាំសៅហ្មង) **បរិសញ្ញូ** គួរដឹងស្គាល់បរិសទ័ជុំវិញខ្លួន (ក្រែងមានអ្នកសំដែង អាកប្បកិរិយា ទឹកមុខធុញទ្រាន់) ។

ព្រោះថាបញ្ហាចង្អាន់ សំខាន់លើការប្រគេន ទទួលតាមផ្លូវកាយ ទើបព្រះសង្ឃទទួលឆាន់បាន មិនសំខាន់ពេកលើការវេរដោយវាចា ហើយមិនប្រគេនដោយកាយ លោកមិនអាចឆាន់ដោយដាច់ខាត ។ (នេះជាវិនយបញ្ញត្តិ) ។ ម្យ៉ាងទៀត ទម្លាប់កន្លែងមួយចំនួន កាលលោកសូត្រមន្តនៅថ្ងៃរសៀល ល្ងាច ឬ ពេលយប់ចប់ហើយ គេវេរទេយ្យវត្ថុប្រគេនលោកតែម្ដង ប៉ុន្តែលោកអាចារ្យខ្លះថា ការវេរប្រគេនយ៉ាងនេះមិនបានទេ ព្រោះក្នុងបច្ច័យទាំង៤នោះ មានបិណ្ឌបាតបច្ច័យផង វេរប្រគេនខុសកាលមិនកើត គឺផុតពីថ្ងៃត្រង់ ហើយជាវេលាវិកាល ។

ត្រង់ចំណុចនេះ សូមយល់ថា : បើក្នុងកញ្ចប់ទេយ្យវត្ថុ បច្ច័យ ៤នោះ មានវត្ថុបិណ្ឌបាត្រពិត។ ដូចជា អង្ករ ត្រី សាច់ ប្រហុក អំបិល ទឹកត្រី ។ល។ យ៉ាងនេះនឹងវេរប្រគេនក្នុងវេលាខុសកាល ក៏ពិតជាមិនគួរមែន ដូច្នេះ គួរត្រឹមតែបវារណា ហើយព្រឹកឡើងសឹមប្រគេន ។ ប៉ុន្តែបើក្នុងកញ្ចប់ទេយ្យវត្ថុមាន



www.elibraryofcambodia.org

សំភារៈបរិក្ខាបីបច្ច័យ រួចយកថវិកាដាក់ស៊ងបញ្ចូលជំនួសបិណ្ឌបាតបច្ច័យថែម ទៅក្នុងកញ្ចប់ នោះការវេរជាបច្ច័យបួនបាន ហើយវេរប្រគេនពេលណាក៏បាន ។

បច្ចុប្បន្ននេះ ស្ទើរគ្រប់កន្លែងក្នុងកម្ពុជាយើង កាលណាគេធ្វើបុណ្យបច្ច័យបួន គេរៀបចំរណ្ដាប់អង្គ ទេយ្យវត្ថុ ក្នុង១កញ្ចប់ៗ ដែលសំបូរបែបឃើញមានត្រឹមតែ ៣បច្ច័យ គឺ សាដក ឬ ស្បង់-ចីពរ និង មានសាប៊ូប្រាសថ្នាំដុសធ្មេញ ប្រេងក្រូឡា ថ្នាំពេទ្យ ទឹកដោះគោ តែ ស្ករ កាហ្វេ ទឹកក្រូចប៉ាន់ កែវ ស្បែកជើង ចាន ស្លាបព្រា ភួយ មុង និងមាននៅអែបក្រៅកញ្ចប់និមួយៗ ជូនកាលអាចមាន ចានស្រាក់ កំសៀវ ចង្ក្រាន កន្ទេលខ្នើយ ។ល។ រាប់មកប៉ុណ្ណោះសុទ្ធតែបច្ច័យ៣ ពុំទាន់មានបិណ្ឌបាតប្បច្ច័យឡើយ ហើយបិណ្ឌបាតប្បច្ច័យសុទ្ធៗ ជាអង្ករ ត្រី សាច់ ពុំដែលឃើញគេដាក់បញ្ចូលជាមួយបច្ច័យទាំង ៣ក្នុងកញ្ចប់នោះឡើយ ប៉ុន្តែគេនិយមដាក់ ថវិកា គឺប្រាក់កាស ពីរបីពាន់ ប្រាំពាន់ មួយម៉ឺនរៀលក្នុង ១កញ្ចប់ៗ តាមលទ្ធភាព។ ប្រាក់នេះក៏សម្រាប់បច្ច័យ ៤ពិត ដូច្នេះវេរ ជាបច្ច័យ ៤ បានហើយគឺទេយ្យវត្ថុក្នុង ១កញ្ចប់ៗ សំរាប់អង្គនោះ ពិតជាបច្ច័យបួន ដោយត្រឹមត្រូវ ថែមទាំងអាចារ្យវេរប្រគេន ពេលណាក៏បានឥតមានខាស់ ។



www.elibraryofcambodia.org

# អំពីបុណ្យសង្ឃទាន

*ទានមានពីរជំពូក គឺ :*

១- ទានដែលប្រគេនចំពោះ ភិក្ខុឬសាមណេរមួយរូប១ តាមចិត្តស្រឡាញ់ដោយចំពោះ ហៅថា : **បាដិបុគ្គលិកទាន** ។

២- ទានដែលប្រគេនចំពោះព្រះសង្ឃគឺ ភិក្ខុតាំងពី៤រូបឡើងទៅមិនចំពោះ មិនរើសមុខ ឬ ប្រគេនដល់ភិក្ខុ សាមណេរតែមួយរូប១ក៏ដោយឱ្យតែសង្ឃចាត់មក ឬថា តែ១ អង្គពិត ឱ្យតែម្ចាស់ទានតាំងចិត្តផ្តោតចំពោះទង់អរិយសង្ឃ ហៅថា សង្ឃគតាទក្ខិណេយ្យទាន ឬ សង្ឃគតាទាន ឬហៅបំព្រួញត្រឹមតែ សង្ឃទាន ។

ចំពោះទានទាំងពីរជំពូកនេះ សង្ឃទាននេះមានផលានិសង្សច្រើនលើសលុប ជាងបាដិបុគ្គលិកទាន ព្រោះទានក្នុងព្រះពុទ្ធសាសនាស់ដៅលើ ទឹកចិត្តទូលំទូលាយ ជាសាធារណៈ មិនចង្អៀតចង្អល់គឺ ឈរលើទស្សនៈប្រកបដោយបញ្ញា នាំឱ្យព្រះពុទ្ធសាសនារង់រឿងយូរអង្វែង ។

សូម្បីព្រះនាង **បជាបតិគោតមី** ម្តាយមីងព្រះពុទ្ធខំធ្វើត្រៃចីវរដោយផ្ទាល់តាំងពីចាប់ផ្តើមដាំ កប្បាស រហូតដេរបានចីវរ ១ត្រៃ យកទៅថ្វាយផ្ទាល់ចំពោះព្រះពុទ្ធជាម្ចាស់ ក៏ព្រះអង្គមិនទទួល ដោយទ្រង់ស្វែងយល់ច្បាស់នូវកុសលចេតនារបស់ព្រះនាង បរិច្ចាគទាន ពេលនោះ ជាបាដិបុគ្គលិទាន ប្រគេនចំពោះព្រះពុទ្ធអង្គផ្ទាល់ នាំឱ្យបានអានិសង្សតិច ដោយព្រះទ័យមហាករុណាទិគុណ ប្រកបដោយកតញ្ញូ ចំពោះម្តាយមីង ទើបទ្រង់បង្វែរឱ្យប្រគេនចំពោះព្រះសង្ឃ ទើបជាសង្ឃគតាទាន ឬ ជាសង្ឃទានស្មោះ មិនចំពោះភិក្ខុសាមណេរ



www.elibraryofcambodia.org

ពោរបូបរឡើយ ហើយទ្រង់សសើរសង្ឃទានទេះ ជាកោនរាពិសរុះ ត្រើរជា អនេក ។

សង្ឃទានមាន ៧ ប្រភេទ តែសម័យបច្ចុប្បន្ន យើងធ្វើបុណ្យសង្ឃទានមិនបានគ្រប់ទាំង ៧ ប្រភេទនោះទេ បានត្រឹមតែមួយប្រភេទ គឺធ្វើចំពោះភិក្ខុសាមណេរ ដែលសង្ឃចាត់មកតាមការអារាធនានិមន្តរបស់ខ្លួនប៉ុណ្ណោះ ។

ការនិមន្តសង្ឃទៀតសោត អាស្រ័យព្រះចៅអធិការវត្តឬភិក្ខុតំណាងសង្ឃ ( ភត្តុទ្ទេសកភិក្ខុ ) ចាត់មក ទោះជាភិក្ខុក្តី សាមណេរក្តី ក្មេងក្តី ចាស់ក្តី ទាយកទាយិកា មិនត្រូវអាក់អន់ចិត្តឬរង្កៀសចិត្តទេ ព្រោះថាបើសម្លឹងចំពោះ ភិក្ខុសាមណេរ ១រូប១ នាំឱ្យចិត្តសោមនស្ស ឬ ទោមនស្ស ជាហេតុក្លាយទៅជាបាដិបុគ្គលិកទាន ដូច្នេះត្រូវតែតាំងចិត្តគោរពចំពោះសង្ឃ ឧទ្ទិសចំពោះសង្ឃទាន នោះទើបឈ្មោះថា សង្ឃទានពេញលក្ខណៈពិតប្រាកដ ។

ឯវិធីធ្វើសង្ឃភត្តទានមាន ២ បែបគឺ :

១- ធ្វើសង្ឃភត្តទាំង ១៤ ណាមួយ ឬធ្វើបុណ្យផ្សេងៗដែលនិមន្តភិក្ខុសង្ឃយ៉ាងតិច ពី ៤ អង្គឡើងទៅ ដោយមានអាមិសប្បដិសណ្ឋារៈក្តីធម្មប្បដិសណ្ឋារៈក្តី ប្រកបដោយធម៌ និង សម្បយុត្តដោយសទ្ធា និង បញ្ញា ។ យើងធ្វើកិច្ចហើយ វេរចង្ហាន់និងទេយ្យវត្ថុ ។ ពេលចប់កិច្ច ព្រះអង្គឆាន់នៅរោងបុណ្យតែម្តង ។ បែបនេះឈ្មោះថា សង្ឃទាន មានទ្រង់ទ្រាយធំ ។

២- ធ្វើចង្ហាន់តាមផ្ទះ ដោយនិមន្តតែ ១អង្គ ឬ ២អង្គ ៣អង្គ ប៉ុណ្ណោះ ទោះសាមណេរ ឬ ភិក្ខុ ដែលសង្ឃចាត់មក យើងធ្វើកិច្ចតាមទម្លាប់ រាប់បាត្រ ហើយវេរចង្ហាន់មានម្ហូបដាក់ចានស្រាក់ ចប់កិច្ចហើយ ព្រះអង្គយកចង្ហាន់ទាំង



www.elibraryofcambodia.org

នោះទៅឆាន់ឯវត្តវិញ ។ បែបនោះក៏ឈ្មោះថា **សង្ឃទានដែរ** តែមានទ្រង់ទ្រាយតូច ។

សង្ឃទានមានទ្រង់ទ្រាយធំ ឬ តូច អាស្រ័យលើចង្ហាន់និងទេយ្យវត្ថុ ហើយនិង **បរិក្ខារ** មានចំនួនច្រើន មធ្យម តិច តាមលទ្ធភាពអ្នកម្ចាស់ដើមបុណ្យធ្វើ ។

ចំពោះអានិសង្ស អាស្រ័យលើកម្លាំងនៃកុសលចេតនាទាំង ៣ គឺ : **បុព្វចេតនា១ មុញ្ចនចេតនា១ អបរាបរចេតនា១ ។**

ការនិមន្តព្រះសង្ឃតែ ១អង្គ ២អង្គ ឬ ច្រើនដល់ ១០អង្គ ក៏ដោយ ហើយប្រគេនចង្ហាន់ ប្រគេនឆាន់នៅផ្ទះបុណ្យក៏បាន និមន្តច្រើនអង្គ ធ្វើពិធីរាប់បាត្រវេរចង្ហាន់ ប្រគេនដាក់ចានស្រាក់. ចប់កិច្ចហើយ ព្រះអង្គនិមន្តយកទៅឆាន់ឯវត្តក៏បាន អាស្រ័យលើចំណូលចិត្តរបស់អ្នកដើមបុណ្យ ។

## ពិធីកម្មបុណ្យសង្ឃទាន

នមស្សការព្រះរតនត្រ័យ សមាទានសីលចប់ រាប់បាត្រួចវេរសង្ឃទាន ដោយអ្នកដើមបុណ្យនាំគ្នា ទ្របាត្រ ទ្រចង្ហាន់ កាន់គ្រឿងបរិក្ខារទេយ្យវត្ថុ ឬអ្នកផ្សេងទៀតជួយកាន់ក៏បានលើកឡើង សូត្រ វេរតាមលោកអាចារ្យដូចតទៅ :

- **នមោ** ៣បទ ( **សូត្រទាំងអស់គ្នា** )
- បន្ទាប់មកអាចារ្យថា មួយសង្កាត់ម្តងៗច្បាស់ៗ

( អាចារ្យខ្លះអាងខ្លួនចេះចាំស្ទាត់ ថារួច អ្នកថាតាមមិនទាន់ចប់ផង ខ្លួនថាបន្តទៀត ធ្វើឱ្យអ្នកខ្លះចេះមិនច្បាស់ស្តាប់មិនទាន់ក៏មាន ) ។



www.elibraryofcambodia.org

“ មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សបរិវារានិ សង្ឃស្ស ទេម ។ សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជ-នីយានិ បដិគ្គណ្ហាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ” ។

ទុតិយម្បិ មយំ ភន្តេ ............. ។ល។

តតិយម្បិ មយំ ភន្តេ ............. ។ល។

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយបានចាត់ចែងហើយនូវវត្ថុទាំងឡាយ មាន **ខាទនីយៈ** និងភោជនីយាហារជាដើមនេះ ( មកដំកល់ទុកក្នុងទីនេះ ) សូមវេរប្រគេនដល់ព្រះសង្ឃ ។

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយមាន **ខាទនីយៈ** និងភោជនីហារជាដើមនេះ ដោយប្រពៃ ដើម្បីសេចក្តីចំរើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំង ឡាយមានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង អស់វារៈ ២ ដងផង អស់វារៈ ៣ ដងផង ។

## សេចក្តីបញ្ជាក់

ការប្រគេនចង្ហាន់ដោយវាចា គឺការវេរចង្ហាន់ប្រគេនព្រះសង្ឃ ពុំមែនជាកត្តាសំខាន់ទេ ចង្ហាន់ដែលភិក្ខុសង្ឃអាចឆាន់បាន លុះណាប្រគេនដោយកាយ ។

- បើគ្រាន់តែវេរ ( វចីភេទ ) តែមិនប្រគេន ក៏ឆាន់មិនបានគឺឆាន់មានទោស ( វិន័យបញ្ញត្តិ ) ។



www.elibraryofcambodia.org

– បើមិនបាច់វេរប្រគេនតែម្តង លោកអាចឆាន់បាន ។ បើវេរផង ប្រគេនផងក៏ល្អដែរលោកក៏ឆាន់បាន ហើយសំដីវេរអាចជំនូសពាក្យឧទ្ទិសអធិ-ដ្ឋានបុណ្យកុសលដល់អ្នកស្លាប់ ។ ដូចនេះការវេរត្រូវវេរតាមចំនួនបដិគ្គាហកៈ នៅចំពោះមុខគឺបើនិមន្តមកភិក្ខុ ៤ អង្គឡើងទៅយើងវេរថា **សង្ឃោ** ។ បើនិមន្តមកភិក្ខុសាមណេរ ២-៣ អង្គ យើងវេរថា **សីលវន្តោ** ។ បើតែ១អង្គ យើងវេរថា **សីលវា** ។ ព្រោះហេតុថា ការវេរត្រូវអនុវត្តតាមក្រឹត្យក្រម វេយ្យាករណ៍ នៃមគធភាសា ( **បាលី** ) ។ ឯបដិគ្គាហកៈ ក៏អនុវត្តតាមក្រឹត្យក្រម វិនយប្បញ្ញត្តិផងដែរ ដូចពាក្យថា **សង្ឃ** សំដៅតែភិក្ខុតាំងពី៤រូបឡើងទៅ ។ បើសាមណេរវិញទោះបីច្រើនប៉ុណ្ណាក៏មិនរាប់ថាសង្ឃដែរ ព្រោះផ្លូវវិន័យហៅថាសង្ឃ សំរាប់ធ្វើសង្ឃកម្ម គឺភិក្ខុ **បកតត្ត** ( ភិក្ខុធម្មតា ភិក្ខុប្រក្រតី ភិក្ខុមិនមានទោសប៉ុណ្ណោះ ) ចំពោះបុណ្យទាន ដែលទាក់ទងដល់ផ្លូវវិន័យ ក៏ពាក្យថាសង្ឃត្រូវគិតតាមវិនយប្បញ្ញត្តិដែរ ។

ចំណែកឯបុណ្យដែលយើងធ្វើហើយក្លាយជា **បាដិបុគ្គលិកទាន** ឬបានជា **សង្ឃទាន** នោះមិនពាក់ពាន់ដល់ការវេរនោះទេ សំខាន់លើទឹកចិត្ត ( ចេតនារបស់ម្ចាស់ដើមបុណ្យម្នាក់ៗ សម្លឹងមើល បដិគ្គាហកៈ បានត្រឹមត្រូវឬមិនត្រឹមត្រូវប៉ុណ្ណោះ ។

***ពិនិត្យសង្ឃទាននិងបាដិបុគ្គលិកទាន*** ; បើប្តីប្រពន្ធនៃគ្រួសារមួយធ្វើបុណ្យសង្ឃទាន តំណាងសង្ឃចាត់សាមណេរមួយអង្គមកទទួល ម្ចាស់ទានជាប្តីអន់ចិត្តថានេះលោកនេន កូនអ្នកនេះអ្នកនោះ មិនសូវគោរពសង្ឃទានខ្លួន ( នោះក្លាយជាបាដិបុគ្គលិកទាន ) ឯប្រពន្ធសប្បាយចិត្តថានេះទង់ជ័យព្រះអរ-



www.elibraryofcambodia.org

ហេតុ គោរពសង្ឃទានខ្លួន ( នេះជាសង្ឃគតាទានពិត ) ។ ដូច្នេះបើអ្នកបដិគ្គាហកៈ មួយអង្គក្តី រាប់សិបអង្គក្តី បើម្ចាស់ទានអន់ចិត្តឬត្រេកអរថា នេះនេនឬនេះគ្រូធំពូកែ ការសម្លឹងយ៉ាងដូច្នេះនោះ ទោះរាប់សិបអង្គក្តី ក៏មិនក្លាយជាសង្ឃទានដែរ ។ ផ្ទុយទៅវិញនិមន្តមួយអង្គទោះជាសាមណេរតូចក្តីឱ្យតែសម្លឹងថាតំណាងសង្ឃចាត់មក ឬ គិតថា លោកនៅក្មេង តែជាអ្នកបួសប្រព្រឹត្តព្រហ្មចរិយធម៌ដូច្នេះជាដើម នោះជាសង្ឃគតាទានពិតៗ ។

ដូច្នេះហើយបានជាបុណ្យ ដែលធ្វើឱ្យបានជាសង្ឃគតាទានត្រូវសម្បយុត្តដោយបញ្ញា ( ញាណសម្បយុត្ត ) ពិចារណាដោយសម្មាទិដ្ឋិ ។

សរុបមកការធ្វើទានឱ្យបានជាសង្ឃទានស្មោះគឺ :

- ចិត្តសោមនស្សរីករាយ ជាញាណសម្បយុត្តព្រមដោយបញ្ញា

- ចិត្តឧបេក្ខា សម្លឹងតាមឃើញជាញាណសម្បយុត្ត ប្រកបដោយបញ្ញា ។ ចិត្តទាំងពីរវារៈនេះសុទ្ធតែគោរពក្នុងទេសទ្យធម៌ក្នុងបដិគ្គាហកៈ ។



www.elibraryofcambodia.org

# បុណ្យបញ្ចុះសីមា

លោកអាចារ្យត្រូវឈ្លាសវៃពីភារកិច្ចរបស់ខ្លួន គឺមើលកម្មវិធីបុណ្យត្រូវធ្វើយ៉ាងណា ? នៅពេលណា ? តាមលំដាប់លំដោយ ។ ពីព្រោះបុណ្យបញ្ចុះខណ្ឌសីមានេះ តាមទម្លាប់ គេនិយមធ្វើពីរយប់បីថ្ងៃ ឬបីយប់បួនថ្ងៃ តាមការឯកភាពគ្នា របស់ពុទ្ធបរិសទ័ក្នុងវត្តនិមួយៗ ។

ដើម្បីធ្វើបុណ្យបញ្ចុះសីមា ដំបូងត្រូវពិនិត្យដុំថ្មជានិមិត្តសីមាមានចំនួនគ្រប់គ្រាន់ ឬ នៅ ? -ស្នែង- អំបោះចងស្រេះជាសង្រែក អន្លូងកាំបិត ផ្តិលទឹក កំបោស ( ចំពោះកំបោសសំរាប់លោកសង្ឃអ្នកដឹកនាំពិធីគូសក្រឡា ជាន់តារាង ) កន្លែងដាក់មេក្រូ ( ព្រោះពេលជាន់តារាងមិនមាននរណាទៅចូលបានទេ ) ។ ពិសេសមើលការដឹករណ្តៅ សីមា កុំឱ្យឆ្ងាយពីគ្រឹះខឿនវិហារ គួរជីកជាប់ចែងខឿនព្រះវិហារតែម្តង ងាយក្នុងពិធីព្រះសង្ឃធ្វើសង្ឃកម្ម ។

ជាធម្មតា ក្នុងពិធីបញ្ចុះសីមា ត្រូវមានអភិសេកព្រះពុទ្ធរូប ។ ដូច្នេះត្រូវត្រៀមឱ្យហើយ ផ្កាភ្ញី ធូប ទៀន សំរាប់ជាសក្ការៈ ។ ( ពិធីអភិសេកព្រះពុទ្ធរូបនេះ យើងបានរៀបរាប់ក្នុងពិធីពុទ្ធាភិសេកស្រាប់ )

អាចារ្យត្រូវ យល់ពី ពិធីបញ្ចុះសីមាថា ពិតជាមានលោកពហុស្សូតឈ្លាសវៃដឹកនាំពិធីនេះ ។ តែអាចារ្យត្រូវយល់ផងដែរ ពិសេសពិភាក្សាសួរយោបល់ទៅវិញទៅមកជាប់ជានិច្ច ជាមួយព្រះសង្ឃត្ថេរ ជាវិសុំគាម ( = អ្នកដឹកនាំពេលធ្វើពិធីបញ្ចុះសីមា ) គឺសីមាសម្មតិកម្មជាកិច្ចការសង្ឃ ជៀសវាង មានៈ ក្មេងក្មាង ម្តាង១សំរេច កុំឱ្យមានឧបសគ្គក្នុង



www.elibraryofcambodia.org

កម្មវិធីបុណ្យមានពិត តែមុនប្រព្រឹត្តត្រូវពិភាក្សាប្តូរយោបល់គ្នាដោយចាំបាច់ ។ ម្យ៉ាងទៀត ដុំថ្មនិមិត្តសីមា មាន៩ដុំ តាមរោងកំណោត់ឱ្យច្បាស់ ។ កន្លែងខ្លះទិសមួយ១មានអ្នកកាន់ដល់ ៤-៥ម្នាស់ ម៉្លោះហើយដណ្តើមគ្នាសែង ខ្វះពោលការឯកភាពក៏កើតទំនាស់ក្នុងពិធីបុណ្យ ។

អ្នកកាន់អង្គ ត្រូវឱ្យច្បាស់ចំនួនអណ្តាប់ដែលមាននិងព្រះសង្ឃតាមរោងទិស ត្រូវមានកំណត់ពិតប្រាកដ ។ ព្រោះកន្លែងខ្លះ លុះដល់ពេលវេលាត្រូវការហើយ មិនដឹងលោកនៅឯណាខ្លះ ក៏វេរឡោ ទីសទាស ។ ព្រះសង្ឃដែលត្រូវនិមន្តត្រូវដឹងចំនួនពិតប្រាកដយ៉ាងតិច១០ថ្ងៃមុនបុណ្យ ។

ដល់ថ្ងៃ បុណ្យ ពេលព្រះសង្ឃនិមន្តមកត្រូវមានគណកម្មការមួយចាំទទួលចុះឈ្មោះ ព្រះសង្ឃនឹងចែកតាមរោងទិស កំណត់នាម និង វត្តឱ្យបានច្បាស់ ។ ព្រោះពេលធ្វើពិធីសង្ឃកម្ម ព្រះសង្ឃគ្រោងជាវិសុំពាមត្រូវប្រកាសឱ្យភិក្ខុ ចូលរួមទាំងអស់បាត់មុខមិនបាន ដោយគ្មានមូលហេតុ ! បើមិនបានចូលរួមទេ ត្រូវចេញឱ្យឆ្ងាយផុតពីព្រំដែនវត្ត ។ កន្លែងខ្លះពេលលោកប្រកាសយ៉ាងនេះក៏បែរជាអាក់អន់ស្រពន់ចិត្ត តែតាមពិតគឺជាលក្ខណៈវិន័យសុទ្ធសាធ ។ ព្រោះមានភិក្ខុអង្គខ្លះ ខ្ជិលតាមតែចិត្ត ពុំព្រមចូលរួមក្នុងពិធី សម្ងំនៅក្នុងរោងបុណ្យឬក្នុងកុដិ ល្ងង់ឬធ្វើជាល្ងង់ពុំចេះវិន័យសង្ឃកម្ម ដែលព្រះអង្គបញ្ញត្តិថា ពេលធ្វើសង្ឃកម្មណាមួយ ដូចជាសីមាសម្មតិកម្មជាដើម នេះបើភិក្ខុនៅក្នុងអាវាស មានធុរៈ ឈឺក្តីមកចូលរួមមិនកើតត្រូវតែឱ្យឆន្ទៈ បើភិក្ខុសូម្បីតែមួយរូបមិនឱ្យឆន្ទៈដល់ជំនុំ



www.elibraryofcambodia.org

សង្ឃទេហើយគេចនៅមិនព្រមទៅចូលរួមសង្ឃកម្ម ភិក្ខុនោះត្រូវទោសផង ឯសង្ឃកម្មរបស់សង្ឃ មិនអាចដំណើរការបានផង ។ ព្រោះហេតុដូច្នេះ ហើយទើបមានការប្រកាសរបស់ព្រះសង្ឃត្ថេរ វិសុំគាម យ៉ាងនេះ ។

## លំដាប់លំដោយនៃការធ្វើបុណ្យបញ្ចុះសីមា

តទៅនេះជារបៀបសីមាវិធី ដែលលោកអាចារ្យគប្បីស្វែងយល់គឺ ឱ្យចេះអនុវត្តតាមកម្មវិធីបុណ្យ ហើយយកកម្មវិធីទាំងអស់បែងចែក ពេលវេលាប្រារព្ធពិធីនិមួយៗ តម្រូវតាមកាលកំណត់ចំនួនថ្ងៃបុណ្យក្នុង ១ថ្ងៃឬ ២ថ្ងៃឬ ៣ថ្ងៃនោះចុះ ។

ទី១ : អាចពេលព្រឹក ឬ ពេលរសៀល លោកអាចារ្យរៀបចំធ្វើពិធីកម្មមួយ ឈ្មោះថាក្រុងពាលី ជាពិធីធ្វើតាមទំលាប់អាចារ្យពីបុរាណ : ប្រកាសបួងសួង ទេព្តា ប្តីងវត្ថុសក្តិសិទ្ធិឱ្យជួយដឹងឮ ទទួលស្គាល់ជាសាក្សី មានរៀបចំនំចំណីៗ-ល-ៗមានភ្លេង ( មាននៅទំព័រខាងមុខអំពីក្រុងពលីស្រាប់ ) ។ ធ្វើនេះជាការបញ្ជាក់ថា ទីកដីវត្តអារាមនេះ បានការអនុញ្ញាតពីរដ្ឋហើយ ឯរាជពលី ឬ ក្រុងពលីប្រែថា បូជាដល់ស្តេចផែនដី - ប្រមុខរដ្ឋ - រដ្ឋាភិបាល ឬ អាជ្ញាធរ - រដ្ឋអំណាច ដែលបានអនុញ្ញាតទទួលស្គាល់ហើយនោះ ។-ល-ៗ រីឯច្បាប់ធ្វើបុណ្យក៏យើងបានធ្វើពាក្យសុំរួចជាមុនហើយដែរ តែធ្វើពិធីក្រុងពលីនេះ គឺជាពិធីកម្ម តាមលំអានទំនៀមខ្មែរបុរាណប៉ុណ្ណោះ ។

តពីនេះទៅលោកអាចារ្យអនុវត្តកម្មពិធីបុណ្យមាន ចំរើនបរិត្ត



www.elibraryofcambodia.org

ទេសនា ។
ទី២ : ជាបន្ត ដំរូវយកដុំថ្មនិមិត្តសីមា ហែប្រទក្សិណរោងឧបោសថ ( ព្រះវិហារ ) បីជុំរួចចូលក្នុងព្រះវិហារ និមន្តព្រះសង្ឃមក លោកអាចារ្យនាំបរិសទ័នមស្សការ សមាទានសីលរួចហើយវេរវត្តអារាម ( បើវត្តថ្មី ) និងវេរដុំថ្មប្រគេនព្រះសង្ឃដែលនិមន្តចូលក្នុងពិធីនេះ រួចវេរ រោងឧបោសថ ( ព្រះវិហារ ) ប្រគេនព្រះភិក្ខុសង្ឃ ដែលនិមន្តមកពីទិស ទាំង ៨ សំរាប់សង្ឃធ្វើសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជា ដើមតទៅ ។ តមកអារាធនាព្រះសង្ឃចំរើនព្រះបរិត្ត ។
ទី៣ : បន្តមកទៀតលើកដុំថ្មនិមិត្តសីមា ដាក់មាត់រណ្ដៅសីមាគ្រប់ទិស ។
ទី៤ : អាចារ្យវត្តគួរនិមន្តព្រះសង្ឃធ្វើពុទ្ធាភិសេក គឺសូត្រអភិសេកព្រះជីវ ( ព្រះពុទ្ធរូបទើបសាងថ្មី ) ឬព្រះពុទ្ធរូប ដែលគង់លើបល្ល័ង្កក្នុងព្រះវិហារនោះស្រាប់តាមពិធីពុទ្ធាភិសេកដែលធ្លាប់រៀបចំធ្វើនោះ ទោះបីព្រះពុទ្ធរូបអង្គនេះ ម្ចាស់ទានគេបានធ្វើបុណ្យអភិសេករួចហើយក៏ដោយពេលនេះគួរធ្វើអភិសេកព្រះអង្គម្ដងទៀត ។ រួចហើយតប្បីដំណើរការរៀបចំធ្វើសីមាសង្ឃកម្មតាមពេលកំណត់ក្នុងកម្មវិធីបុណ្យតទៅ ។

( ក្នុងវង់ក្រចកនេះ ខ្ញុំសូមបញ្ជាក់បន្ថែមថា : របៀបធ្វើសីមាសង្ឃកម្មជាភារកិច្ចព្រះសង្ឃពិតមែនហើយ ប៉ុន្តែលោកអាចារ្យត្រូវតែចេះត្រូវតែយល់ដឹងអោយច្បាស់ថា លើទិសមួយៗមានអ្វីជានិមិត្ត ? ទោះបីយើងបានវេរដុំថ្មប្រគេនរួចហើយក៏ដោយ ប៉ុន្តែចាំបាច់ព្រះសង្ឃត្ថេរ វិសុំតាមត្រូវតែសួរឡើងវិញតាមវិន័យកិច្ច ។ អាចារ្យត្រូវចេះឆ្លើយពិសេសត្រូវណែ


www.elibraryofcambodia.org

នាំអ្នកទទួលឆ្លើយ ដែលនៅចាំតាមរណ្ដៅសីមានិមួយៗគ្រប់ទិស ឱ្យចេះឆ្លើយ ( ព្រោះអ្នកឆ្លើយវិន័យអនុញ្ញាត ទាំងឧបាសក - ឧបាសិកា ទាំងវេញជិតមិនប្រកាន់ឡើយ ) ។ ឧទាហរណ៍ : ព្រះវិន័យធរ ( វិសុំគាម ) លោកនិមន្តទៅទិសខាងកើតលោកសួរ ថា : " **បុរត្ថិមាយ ទិសាយ កឹ និមិត្តំ ?** " យើងឆ្លើយថា **បាសាណោ ភន្តេ** ។ ស្ដាប់ចម្លើយហើយលោកងាកមករកជំនុំសង្ឃហើយពោលថា " **ឯសោ បាសាណោ និមិត្តំ** " ។ រួចលោកនិមន្តទៅមុខតាមលំដាប់ទិសឬរណ្ដៅរហូតដល់ចប់ ។ ងាយបំផុតត្រង់យើងបញ្ចុះសីមាសព្វថ្ងៃយកតែថ្មមួយមុខជានិមិត្តគ្រប់ទិស ។ ដូច្នេះបើលោកសួរយើងឆ្លើយថា " **បាសាណោភន្តេ** " តែប៉ុណ្ណោះជាការស្រេច ។

ទី៥ : របៀបធ្វើសីមាសង្ឃកម្មជាការងាររបស់សង្ឃ បន្តពីការងារខាងលើតាមលំដាប់លំដោយទៀតពី :

ដំបូងភិក្ខុសង្ឃទាំងអស់ដណ្ដប់ជាបរិមណ្ឌល ចូលក្នុងព្រះវិហារហើយសំដែងអាបត្តិចេញរួចទៅ ប្រជុំនៅជុំវិញរណ្ដៅសីមា **ឥន្ទខីល** ។ ( សីមា **ឥន្ទខីល** គឺរណ្ដៅកណ្ដាលវិហារ ខាងមុខបល្ល័ង្ក នោះឯង ) ។ ពេលជុំគ្រប់អង្គហើយ ព្រះមហាថេរដែលជាវិសុំគាម ឈរឡើងប្រកាសប្រាប់សង្ឃថា : " **អយំ គុមិប្បទេសោ វិសុំគាមោ ហោតុ ៖** " ប្រទេសនេះចូរជាប្រទេស ផ្សេងពីស្រុក ។ រួចហើយព្រះមហាថេរវិសុំគាមនាំសង្ឃសូត្រថា **សព្វេ ពុទ្ធា ពលប្បត្តា** ។ល។ **រក្ខំ ពន្ធា៕**



www.elibraryofcambodia.org

មិសព្វសោ " សូត្រលេះបីលើ ។

ទី៦ : សូត្ររូចព្រះសង្ឃផ្ដើមធ្វើសង្ឃកម្ម " **សីមាសមូហនៈ** " ការសូត្រដកសីមា ។ ការដកសីមាត្រូវដក " **អវិប្បវាសសីមា** " ជាមុន រួចដក " **សមានសំវាសសីមា** " ទៀត ។

តមកទើបសួរនិមិត្តសីមាទាំង ៨ទិស ។ ក្នុងការសួរឆ្លើយគប្បីចាប់ផ្ដើមពីទិស បូពិ តទៅ អាគ្នេយ៍ តាមលំដាប់ដល់ទិស ឦសាន ហើយសួរឆ្លើយនិមិត្តទៅទិស បូពិ ម្ដងទៀតទើបត្រឹមត្រូវ ។

ទី៧ : សួរនិមិត្តគ្រប់សព្វហើយ សង្ឃជួបជុំគ្នាទាំងអស់ក្នុងវិហារ ដើម្បីសូត្រចងសីមាឈ្មោះថា សីមាសម្មតិកម្ម ជាសង្ឃកម្មតាមវិធី " **ញត្តិទុតិយកម្មវាចា** " ដែលវិន័យលោកប្រាប់ថា ត្រូវប្រើជំនុំសង្ឃឬការកសង្ឃ យ៉ាងតិចមានភិក្ខុ ៤អង្គឡើងទៅ ។

ការសូត្រចងសីមានេះពីចង **សមានសំវាសសីមា** ជាមុនសិនទើបចង **អវិប្បវាសសីមា** ជាក្រោយ ។

កាលបើសូត្រ សីមាសម្មតិកម្ម ចប់ហើយ សង្ឃទាំងអស់ដដែលនេះ សូត្រសន្មតរោងឧបោសថ ។

**បញ្ជាក់** : មុនសូត្រសន្មតរោងឧបោសថ សង្ឃត្រូវពិនិត្យសិនក្រែងវត្តនេះមានរោងឧបោសថពីរកន្លែងឬក៏ធ្វើលើរោងឧបោសថចាស់ ។ បើមានដូច្នេះត្រូវតែសូត្រដករោងឧបោសថចាស់ចេញសិន ។ បើមិនមានទេសង្ឃសូត្រសន្មត តែម្ដងចុះ ព្រោះព្រះពុទ្ធអង្គមិនអនុញ្ញាតឱ្យ ក្នុងអាវាសមួយមាន



www.elibraryofcambodia.org

រោងឧបោសថពីរកន្លែងទេ ។

ឯការបញ្ចុះសីមាពីសីមា សម្មតិកម្មក្តី សន្មតរោងឧបោសថសំរេច បរិបូរតាមវិន័យ និង ត្រឹមត្រូវតាមពុទ្ធានុញ្ញាត នៅពេលបញ្ចប់សង្ឃកម្ម ក្នុងពិធីទាំងអស់នេះ ។

ចំណែកការកាត់ឫសសីមា តាមតែពេលណា យប់-ថ្ងៃ-ល្ងាច ឬ ជិតភ្លឺ ក៏បាន ស្រេចតែឯកភាពគ្នារវាងគណៈកម្មការ អាចារ្យវត្ត អ្នកដើមបុណ្យ នឹងអ្នកមុខអ្នកការ ទាំងនោះឯង ។

**មតិផ្តល់យោបល់** : លំដាប់លំដោយនៃពិធីបញ្ចុះសីមា របៀបសីមាពិធី តាំងពី ទី១ ដល់ទី៧ ជាទីបញ្ចប់នេះសូមលោកអាចារ្យដែលជាប្រធានកម្មវិធីបុណ្យយកទៅបែងចែកពេលតាមលំដាប់ និង តាមចំនួនថ្ងៃបុណ្យនោះចុះ គឺបើធ្វើបុណ្យ មួយយប់ពីរថ្ងៃ រៀបចំពេលតាមនោះទៅ បើធ្វើ ពីរយប់បីថ្ងៃ ឬបីយប់បួនថ្ងៃ ក៏យកវិធីលំដាប់លំដាយនេះចែកតាមចំនួន យប់ ថ្ងៃ ធ្វើបុណ្យនោះចុះ ។

ម្យ៉ាងទៀតសូមជ្រាបថា : ពិធីកម្មក្នុងបុណ្យអ្វីក៏ដោយសុទ្ធតែចែកជាពីរខ្លឹមសារ ដូចយ៉ាងពិធីបុណ្យបញ្ចុះសីមានេះជាតួយ៉ាងគឺ :

១- ពិធីក្រុងពលី ពិធីហែប្រទក្សិណ ពិធីពុទ្ធាភិសេក ។ល។ ខ្លឹមសារទាំងនេះធ្វើតាមទំនៀមទំលាប់ខ្មែរអ្នកកាន់ព្រះពុទ្ធសាសនា ពុំមែនជាព្រះពុទ្ធដីកាទេ តែជាពិធីកម្មអមកែលំអរបុណ្យ ។

២- ឯពិធីសួរឆ្លើយនិមិត្តសីមាតាមទិស និងពិធីសីមាសមូហនៈ ( ការដកសីមា ) ពិធីសីមាសម្មតិ ( ការសន្មតសីមា ) ពិធីសន្មតរោងឧបោ-



www.elibraryofcambodia.org

សមជាយើង ខ្លួនសាងបរិវារនេះដែលគ្រប់ការប្រព្រឹត្តតាមព្រះពុទ្ធដីកា ធ្វើតាម វិន័យពិត១ ។

ដូច្នេះលោកអ្នក គោរិទបណ្ឌិតជន គប្បីពិនិត្យនិងគួរប្រតិបត្តិ ឱ្យត្រូវតាមព្រះពុទ្ធដីកា ។ ឯពិធីផ្សេង១ក្រៅពីនេះ អាចធ្វើគ្រប់វិធីឬកាត់បន្ថយខ្លះ១បាន ព្រោះជាលក្ខណៈនៃចេតនាកម្ម ។

## ពិធីក្រុងពលី

( ជាពិធីផ្ដើមដំបូងក្នុងថ្ងៃបុណ្យបញ្ចុះសីមា )

ពេលព្រឹកព្រលឹមឬពេលរសៀលទេរទាបទៅតាមកម្មវិធីបុណ្យដែលបានកំណត់គឺ :

១- អាចារ្យ ត្រូវរៀបតុមួយមានកម្រាលមានបង្គោលចងឆត្រឬក្លោះបាំងពីលើ ។

២- លើតុត្រូវមានម្ហូបមួយថាស បង្អែមមួយថាស បាយ ទឹក១ផ្ដិល ផ្កា១ថូ សំពត់ស១គូ សំពត់ពណ៌១គូ ទៀន ធូប សំរាប់អុជ ។

៣- អាចារ្យប្រកាសទេវតា ក្នុងពិធីក្រុងពលីនេះអាចារ្យគួរតែស្លៀកពាក់ស យ៉ាងហោចណាស់ក៏ពាក់សំពត់សដែរ ។

៤- អាចារ្យប្រកាសបួងសួងទេវតាដូចតទៅ : **ភោន្តោ ទេវសង្ឃា យោ !** បពិត្រពពួកទេពនិករ អមរទេវតាទាំងឡាយដែលឋិតនៅនាគីរីបព្វតា ក្នុងព្រៃព្រឹក្សា លើដែនពសុធា ជ្រោះជ្រង ជ្រលងដងស្ទឹង



www.elibraryofcambodia.org

បឹងបួរ ទន្លេ សមុទ្រក្តី ទាំងទេពកោសិយ៍ សហស្សន័យ ឥន្ទ្រាធិរាជ ដែលកាន់អំណាចត្រួតត្រាលើស្ថាន ចាតុម្មហារាជិកានិងថែរក្សា មនុស្សលោក ក្រោមអធិបតីភាពនៃព្រះឥន្ទក្តី អាកាសទេវា រុក្ខទេវា ទាំងទេព្តារក្សា ភូមិស្ថាន ទីលានព្រះចេតិយ៍ រក្សាអារាមនេះក្តី សូមលោកទ្រង់ជាបថា : ថ្ងៃនេះជាថ្ងៃ .......... កើតឬរោជ ខែ ........ ឆ្នាំ ......... ត្រូវនឹងថ្ងៃទី ........ ខែ ..... ឆ្នាំ ..... ពុទ្ធបរិស័ទចំណុះជើងវត្ត ..... មាន ( ឯកឧត្តមលោកជំទាវឬ លោក ...... ជួយឧបត្ថម្ភផង បានធ្វើពិធីបញ្ចុះសីមាព្រះវិហារដែលសាងឡើង តាំងពីឆ្នាំ ...... ហើយស្រេចនៅថ្ងៃ ...... ខែ ...... ឆ្នាំ ...... ។

ឥឡូវនេះរៀបចំធ្វើពិធីបុណ្យបញ្ចុះសីមា វេរប្រគេនដល់ព្រះសង្ឃ សំរាប់តម្កល់ទុកជាសម្បត្តិព្រះពុទ្ធសាសនា ដើម្បីព្រះសង្ឃធ្វើសង្ឃកម្មតរៀង ទៅ ។

ហេតុដូច្នេះសូមពួកទេព្តាដែលយើងខ្ញុំបានរៀបរាប់នាមរួចមកហើយ មេត្តាទទួលជ្រាបនូវដំណើរនេះ ហើយអញ្ជើញមកទទួលនូវអំណោរសាទរ ជួយប្រសិទ្ធិពរមង្គលសួស្តីចំពោះ ...... ។ ដុំថ្មធំ១ជានិមិត្តសីមាដែលរៀប ចំទុកបញ្ចុះក្នុងព្រះវិហារនេះ នឹងថ្កល់ ខ្យល់បក់មិនដល់មិនកម្រើកយ៉ាងណា សូមសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ មានជានិច្ចនិរន្តរ៍ក្នុងព្រះពុទ្ធសាសនាយ៉ាង នោះ ។ម្យ៉ាងទៀតសូមពួកទេព្តា ជួយថែរក្សាទាំងបព្វជិត ទាំងគ្រហស្ថ ដែលបានមកចូលរួមក្នុងពិធីបុណ្យនេះក្តី មិនបានចូលមកក្តី ដែលបានចូល រួមកសាងវត្តនេះក្តី ដោយភាពសោមនស្សរីករាយ សូមឱ្យអស់លោកអ្នកបាន សេចក្តីសុខចំរើន និងកើនផលប្រយោជន៍ ដូចសេចក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត



www.elibraryofcambodia.org

ដល់អវសានជាតិ សូមឲ្យសំរេចព្រះនិព្វានជាទីបំផុតរបស់លោក ។

**អនុមោទនា** ..... ! ( បីដង ) ។ **សាធុ** ..... ! ( បីដង ) ។

តពីក្រុងពលីបួងសួងទេវតាមក ដល់ពេលព្រលប់ លោកអាចារ្យបន្តកម្មវិធី នាំឧបាសក ឧបាសិកា នមស្សការ ថ្វាយបង្គំ សុំសីលនិងចម្រើនព្រះបរិត្តតទៅ ។ បន្តបន្ទាប់មកអនុវត្តតាមលំដាប់លំដោយនៃកម្មវិធីបុណ្យដូចបានជំរាបខាងដើមទី១ដល់ទី៧ តាមសមគួរដល់កាលវេលា ។



www.elibraryofcambodia.org

## បាលីវេរវត្តថ្មីទាំងមូល

## ព្រមទាំងឧបោសថាគារ និង កុដិថ្មីផង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

( សូត្រទាំងអស់គ្នា ៣ ចប់

ឧកាស. មយំ ភន្តេ ឥមំ ឧបោសថាគារាទិ សសេនាសនំ នវវិហារំ ការាបេត្វា (ជោតញ្ញាណោ) ឥតិ ឥមស្ស នាមំ កត្វា ឥទានិមំ សសេនាសនំ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ឱណោជេម. សាធុ ភន្តេ ភិក្ខុសង្ឃោ សបរិនិដ្ឋិត សេនាសនំ ឥមំ វិហារំ បដិគ្គណ្ហតុ, បដិគ្គហេត្វាន ពុទ្ធានុញ្ញាតានុសារេន យថិច្ឆិតំ បរិភុញ្ជតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះតម្លៃងសង្ឃ ដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានចាត់ការ ឱ្យស្ថាបនានូវវត្តថ្មីនេះ ព្រមទាំងសេនាសនៈ មានឧបោសថាគារ គឺវិហារ ជារោងឧបោសថជាដើម រួចស្រេចហើយ បានកំណត់នាម នៃវត្តថ្មីនេះ ថាវត្ត (ជោតញ្ញាណោ) ឥឡូវនេះ (យើងខ្ញុំ) សូមវេរនូវវត្តនេះ ព្រមទាំងសេនាសនៈ ប្រគេនដល់ព្រះសង្ឃ ដែលនិមន្តមកពីទិសទាំងបួន បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួល នៅវត្ត (ជោតញ្ញាណោ) នេះ ព្រះទាំងសេនាសនៈ ដែលបានស្ថាបនារួចស្រេចហើយ លុះទទួលរួចហើយ សូមនិមន្តប្រើប្រាស់តាមលំអាននៃពុទ្ធានុញ្ញាត តាមគួរដល់សេចក្តីត្រូវការចុះ



www.elibraryofcambodia.org

ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំ ទាំងឡាយ អស់កាលជាអង្វែង ទៅហោង ។

( ព្រះសង្ឃទទួលថា សាធុព្រមៗគ្នាបីដង)

*បញ្ជាក់* : ព្រោះកន្លែងខ្លះវត្តថ្មីទើបនឹងសាងសង់មានព្រះវិហារ (គឺរោងឧបោសថ) ឧបដ្ឋានសាលា កុដិ ជាដើម ។ ម្ល៉ោះហើយការវេរ ត្រូវតែវេរវត្តទាំងមូលនេះទើបយើងធ្វើពិធីផ្សេងៗទៅ មានការបញ្ចុះខណ្ឌសីមាជាដើម ។

ការវេរវត្តថ្មីនេះ បាលីនៅក្នុងវង់ក្រចក ( ... ) ត្រូវដាក់បញ្ចូលឈ្មោះ វត្តថ្មីដែលត្រូវវេរ ។ ដូចជាឧទាហរណ៍ ( ជោតញ្ញាណោ ) ខាងលើ ។

**<u>បាលីវេរដុំថ្ម ជានិមិត្តសីមា</u>**

**ឱកាស មយំ ភន្តេ ឥមេ មហន្តេ បាសាណបិណ្ឌេ សីមាយ និមិត្តករណត្ថាយ តិក្ខុសង្ឃស្ស . ទេម, សាធុ ភន្តេ តិក្ខុសង្ឃោ ឥមេ បាសាណបិណ្ឌេ បដិគ្គណ្ហតុ បដិគ្គហិត្វាន ឥមេហិ បាសាណបិណ្ឌេហិ និមិត្តំ កិត្តេត្វា ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

សូមគោរព ! បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយ សូមវេរ នូវដុំថ្មធំៗ ទាំងឡាយនេះប្រគេនចំពោះព្រះសង្ឃ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើជានិមិត្ត សីមា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវដុំថ្មទាំងឡាយនេះ ហើយសន្មតនូវខណ្ឌសីមាចុះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ដើម្បី សេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។



www.elibraryofcambodia.org

## ពាក្យវេររោងឧបោសថ ( ព្រះវិហារ )

មយំ ភន្តេ ឥមំ ឧបោសថាគារំ ការេត្វា ឧបោសថប្បវារណាទិកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ ឧបោសថាគារំ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ទុតិ......តតិ.... ។

"បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយ បានចាត់ចែងធ្វើរោងសំរាប់ឧបោសថនេះហើយសូមវេរប្រគេន ដល់ព្រះសង្ឃដែលមកពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់ កិរិយាធ្វើសង្ឃកម្មមានឧបោសថកម្ម និង បវារណាកម្មជាដើម បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវរោងឧបោសថនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង "។

អស់វារៈពីរដងផង! អស់វារៈបីដងផង!

ឯបាលីសូត្រដកសីមាក្តី សូត្រចងសីមាក្តី និងសន្មតរោងឧបោសថក្តី សូមមើលក្នុងសៀវភៅសង្ឃកម្មកថាភាគ ១របស់ព្រះឃោសធម្ម មហាម៉ឹង សេស (ចន្ទម្នោ) និងសៀវភៅភិក្ខុបាតិមោក្ខបាលី ប្រែរបស់ព្រះភិក្ខុធម្មារាមោ ប៉ុណ. សំភាជន៍ផង ។



www.elibraryofcambodia.org

# បុណ្យពុទ្ធាភិសេក

កំណើតព្រះពុទ្ធរូប : ក្នុងសៀវភៅដំណាលពុទ្ធចេតិយ៍ មានសេចក្ដី ថា ក្នុងកាលពុទ្ធសករាជកន្លងទៅបាន ៤០០ឆ្នាំ មានស្ដេចមួយអង្គព្រះនាម កនិស្កៈ ជាតិក្រិក បានប្រឹក្សាជាមួយរាជបណ្ឌិតនាម អស្វឃោសៈ ហើយបាន កសាងព្រះពុទ្ធរូបឡើង ស្ដេច កនិស្កៈ នេះពីដើមកាន់សាសនាព្រាហ្មណ៍ យក ទេវរូបពីរូប ព្រះ ឥស្សរ មកតាំងទុកនមស្ការថ្វាយបង្គំ មកដល់ជ្រះថ្លាក្នុង ព្រះពុទ្ធសាសនា ព្រះអង្គក៏ទ្រង់ព្រះរាជតិរិះថា គេកាន់សាសនាព្រាហ្មណ៍គេសាង ទេវរូបទុក នមស្ការថ្វាយបង្គំ យើងជាអ្នកកាន់ព្រះពុទ្ធសាសនាត្រូវតែធ្វើ ពុទ្ធរូប ដើម្បីជាភស្ដុតាងដល់ចិត្តជាកុសល រួចក៏ទ្រង់ឱ្យជាងសាងព្រះពុទ្ធរូប ឡើង ។ ដូច្នេះព្រះពុទ្ធរូបនេះមិនមែនជាពុទ្ធានុញ្ញាតទេ គឺកើតឡើងដោយ ស្ដេចកនិស្កៈ ជាតិក្រិក ។

ចំពោះព្រះពុទ្ធព្រះអង្គទ្រង់អនុញ្ញាត **សំវេជនីយដ្ឋាន** បួនកន្លែងគឺ

១- ព្រៃលុម្ពិនី កន្លែងដែលព្រះអង្គទ្រង់ប្រសូតិ

២- ដើមពោធិព្រឹក្ស កន្លែងដែលព្រះអង្គបានត្រាស់

៣- ព្រៃ ឥសិបតនមិគទាយវ័ន កន្លែងដែលព្រះអង្គទ្រង់សំដែង ធម្ម ចក្រ ប្រោស បញ្ចវគ្គីយ

៤- ក្រោមដើមរាំងទាំងគូកន្លែងដែលព្រះអង្គបរិនិព្វាន

ដូច្នេះការអភិសេកព្រះពុទ្ធរូប គឺជាពិធីត១គ្នា តាមទំនៀមប្រពៃណី ខ្មែរបុរាណ ព្រោះជាពិធីមួយដែលញ៉ាំងសទ្ធារបស់ម្ចាស់ទានឱ្យកាន់តែជ្រះថ្លា ឡើង ។ ឯព្រះពុទ្ធរូបដែលធ្លាប់មានមក ជាទីគោរពសក្ការៈ របស់ប្រជាជាតិ



www.elibraryofcambodia.org

ក្បួនមើលភាព៨ផ្សេងគឺ :

១ ព្រះពុទ្ធរូបសមាធិ គង់ព្រះភ្នែនមានព្រះហស្តស្តាំ ផ្កាលើព្រះហស្តឆ្វេង គំរូតលើព្រះភ្នែនហៅថា **វិតក៏មុទ្រា** ។

២ ព្រះពុទ្ធរូប មារវិជ័យ ( កាលផ្ចាញ់មារ ) គង់បត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំ ផ្កាប់លើព្រះ ឧរុ ( ភ្លៅ ) ចង្អុលចុះទៅផែនដី ព្រះហស្តឆ្វេងផ្ងារលើព្រះ ឧរុ ហៅថា : ភូមិស្បមុទ្រា ។ ព្រះពុទ្ធរូបបែបនេះ កាលគេគូរនៅជញ្ជាំងវិហារឬលើផ្ទាំងសំពត់ឃើញមានពួកមារាធិរាជកាន់អាវុធគ្រប់ដៃ កំពុងលង់ទឹកមានសត្វក្រពើ សត្វឆ្លាមជាដើមដេញខាំ ។

៣ ព្រះពុទ្ធរូបសំដែងធម្មចក្រគង់ពត់ព្រះភ្នែន មានព្រះហស្តស្តាំក្តោបម្រាមធ្វើជារង្វង់មូលដូចជាកង់រទេះ ព្រះហស្តឆ្វេងធ្វើអាការៈដូចជាព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរុក៏មាន ហៅថា : **ធម្មចក្រមុទ្រា** ។

៤ ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលព្រះអង្គសំដែងធម៌ប្រោសសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មាន គង់ពត់ព្រះភ្នែនក៏មាន ព្រះហស្តស្តាំវាចេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះហៅថា: **អភយមុទ្រា ។**

៥ ព្រះពុទ្ធរូបប្រទានពរ បាតព្រះហស្តទាំងពីរសំយុងចុះបែរបាតព្រះហស្តទៅខាងមុខទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មាន ជាតំណាងកាលបរិសទ័ណាមួយចូលមកថ្វាយបង្គំ ដោយត្រូវការចង់ជួបចង់ឃើញក្តី ក្រាបទូល សួរធម៌ចំពោះព្រះអង្គក្តី ហៅថា : **វរមុទ្រា** ។

៦. ព្រះពុទ្ធរូបទ្រង់ឈរអោបបាត្រ ជាតំណាងកាលព្រះអង្គទ្រង់និមន្ត បិណ្ឌបាតហៅថា : **បាត្រគានមុទ្រា** ។



www.elibraryofcambodia.org

៧. ព្រះពុទ្ធរូបទ្រង់ផ្ទំ ជាតំណាងកាលព្រះអង្គ ផ្ទំផ្អៀងព្រះកាយទៅស្តាំ ព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ ដោយទ្រង់ផ្ទំធម្មតាក្តី ផ្ទំលើមញ្ចាសនៈជា អនុដ្ឋានសញ្ញាទ្រង់ព្រះនិព្វានក្តីហៅថា: **សយនមុទ្រា** ។

៨. ព្រះពុទ្ធរូបនាគប្រក់ ជាតំណាងកាល ព្រះអង្គគង់លើភ្លីស្រះ **មុច្ចលិន្ទ** ។

ដែលពេលនោះមានភ្លៀងធ្លាក់ខ្លាំងមាននាគមកពត់ពែនព្រះអង្គបើកពពារគ្របបាំងព្រះអង្គដើម្បីការពារភ្លៀង ។

ពាក្យថា **មុទ្រា** ជាពាក្យសំស្ក្រឹត ប្រែថា គ្រឿងសំគាល់ បែបយ៉ាងអាការៈ កាយវិការត្រា សញ្ញា ។

## ពិធីអភិសេក

ទំលាប់នេះអាស្រ័យតាមពេលវេលាទីកន្លែងនិងធនធាន អ្នកម្ចាស់ទាន ។ តែបើពេលបញ្ចុះសីមា មានគេធ្វើពិធីអភិសេកព្រះពុទ្ធរូបធំដុំណាស់ ព្រោះហេតុអ្វី ? ព្រោះពេលនោះភាគច្រើន ធ្វើវិហារថ្មី ព្រះពុទ្ធរូបក៏ថ្មី ។ ម្យ៉ាងទៀតគេមានទម្លាប់ជឿថា ព្រះបដិមានិមួយៗទោះតូចក្តី ធំក្តី សុទ្ធតែផ្តល់នូវសេចក្តីសុខដល់គេ និងក្រុមគ្រួសារគេ ។ ដូចយើងធ្លាប់ដឹង ខ្មែរយើងភាគច្រើនតែងយកពុទ្ធរូប ដែលឆ្លាក់អំពីធ្មេញឪពុកម្តាយ ឬ យាយតា ឬឆ្លាក់អំពីភ្លុកឈើអ្វីម្យ៉ាងធ្វើជាបន្តោងខ្សែក ដើម្បីឱ្យកាន់តែប្រសិទ្ធភាព គេពុះពារស្ពាត់គ្រប់ទីកន្លែងដើម្បីស្វែងរកវត្ត ដែលមានធ្វើពិធីបញ្ចុះសីមា និងអភិសេកព្រះពុទ្ធរូប គេយកព្រះពុទ្ធរូបរបស់គេនោះ ទៅដាក់អភិសេកឱ្យបានៗវត ។ ឬក៏ប្រជាជនយើងមួយចំនួន បានជាវព្រះពុទ្ធរូបដើម្បីដាក់ជាទី



www.elibraryofcambodia.org

សក្ការៈរៀបតាមផ្ទះ ពេលបកទៅចូលរួមពិធីអភិសេកផងដែរ ព្រោះពិធីពេលនោះមានព្រះសង្ឃយ៉ាងច្រើន ដែលមកអំពីទិសទាំង៨ ក៏កាន់តែបង្កើននូវសទ្ធាជ្រះថ្លារបស់គេថែមទៀត ។

ពិធីនេះ ព្រះសង្ឃចូលក្នុងព្រះវិហារនមស្សការព្រះរតនត្រៃនិងសូត្រធម៌ផ្សេងៗច្រើនរូមមាន **ពាហុំ ឥតោចេ ឆរចី ៣០** ជាដើម ។ល។ ព្រះសង្ឃសូត្រចប់ ឧបាសក-សិកា នមស្ការម្តង ។ ចប់នមស្ការឧបាសក-សិកាមួយចំនួនអង្គុយពទ្ធ័ជុំវិញបល្លង្កនៅព្រះវិហារដោយមានអុជទៀនព្រោងព្រាតពិសេសគឺទៀនពពិលដូចជា ពិធីបង្វិលពពិលមង្គលការដែរ ។ ពេលនោះព្រះសង្ឃសូត្រ **ជយន្តោ** បណ្តើរគ្រហស្ថបង្វិលទៀនបណ្តើរជាទក្ខិណាវដ្ត ចំនួន ៣ឬ ៧ជុំ ។

រួចមកអាចារ្យម្នាក់ យកផ្កាដែលដាក់ក្នុងកញ្ច្រែង ឬ ក្នុងចានទុកត្រៀមហើយនោះ ក្រោកឈរឡើង ស្រែកអានបាលីឱ្យទាំងអស់គ្នាថាតាមច្បាស់ៗ **ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិ-មតោ បរាជយោ** ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់មានសេរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាបចាញ់ព្រះអង្គហើយ ។ រួចបាចផ្កាឬប្រោះព្រំទឹកម្តង ធ្វើដូច្នេះចំនួន ៣ដង ។

ឯពិធីកន្លែងមួយចំនួនទៀត គេធ្វើបុណ្យនៅតាមផ្ទះ ក៏អាស្រ័យលទ្ធភាពម្ចាស់ទាន ប្រធានបុណ្យនោះដែរ ។ ព្រោះបើធ្វើអភិសេកក៏ជារបៀបខាងលើ ឬ ក៏ជូនកាលរៀបចំសព្វគ្រប់ហើយ បន្ទាប់អំពីព្រះសង្ឃសូត្រមន្តទេសនាចប់ ព្រះសង្ឃសូត្រត្រឹម **ពាហុំ ឆរចី ៣០ ឥតោចេ ជយន្តោ ខ**



www.elibraryofcambodia.org

ពិធីអ្វីៗទាំងនោះគឺជាពុទ្ធគារវកិច្ច. កិរិយាគោរពចំពោះព្រះបរមគ្រូ និងជាការអបស្តុបជំរុញចិត្តជាកុសលឱ្យកាន់តែខ្លាំងឡើងក៏ដូចជា ពិធីបុណ្យឆ្លងសមិទ្ធិផ្សេងៗដែរ ។ ចំណុចសំខាន់នៃព្រះពុទ្ធដីកាគឺ **ចេតនាហំ ភិក្ខវេ បុញ្ញំ វទាមិ** ម្នាលភិក្ខុទាំងឡាយតថាគតពោលថា បុណ្យកើតដោយចេតនា ( ចេតនាជាតួបុណ្យ ) ។

## បុណ្យកតញ្ញូ

- ពិធីនេះភាគច្រើន មួយថ្ងៃ មួយយប់ និង មួយព្រឹក
- និមន្តព្រះសង្ឃយ៉ាងតិច ៤អង្គឡើងទៅ ។
- អណ្តាប់មានគ្រប់គ្នា ។

អត្ថន័យដែលធ្វើគឺ ដើម្បីគោរពចំពោះមាតាបិតា ជីដូនជីតា នៅរស់ ដោយមានសម្ភារៈមួយចំនួនមាន សំលៀកបំពាក់ និងឧបករណ៍ប្រើប្រាស់ខ្លះៗ គោរព ជូនវត្ថុទាំងនោះសុំខមាទោសនិងសូមពរជ័យពីគាត់ ។

**របៀបធ្វើ** គេពិភាក្សាគ្នាជាមួយបងប្អូនសុំការឯកភាព តាមលទ្ធភាពអ្នកមានធូរធារ ក្រនិង មធ្យម ដើម្បីទិញសាជកនិងវត្ថុផ្សេងៗ សំរាប់ធ្វើបុណ្យ ។

ព្រលឹមឡើងកំណត់ គេនិមន្តព្រះសង្ឃមកឆាន់ ទាំងព្រឹក ទាំងថ្ងៃត្រង់ ឬ ថ្ងៃត្រង់តែម្តងក៏បាន តាមលទ្ធភាព ។

បើព្រះសង្ឃវត្តជិតផ្ទះ លោកនិមន្តទៅវត្តវិញ បើវត្តនៅឆ្ងាយពីផ្ទះ គេនិមន្តព្រះសង្ឃឱ្យសំរាកត្រង់ម្តុំណាជិតៗផ្ទះបុណ្យ ។

ថ្ងៃរសៀលកូនចៅជួបជុំគ្នា ប្រមូលប្រដាប់ប្រដា មានខោអាវ មុងភួយ កន្ទេល ខ្នើយ វត្ថុប្រើប្រាស់ និង បច្ច័យដែលគេត្រៀមមក សំរាប់ជូន



www.elibraryofcambodia.org

មាតាបិតា ជីដូនជីតា ធំ ពេកវែង តាមលទ្ធភាពដែលគេមានដើម្បីគោរពជូន និងធ្វើពិធីងូតទឹកឱ្យគាត់ ។

ដំបូងអាចារ្យចាប់ពិធីបួងសួងទេវតា ប្រកាសពីពិធីដែលកូនចៅមាននាមជាអាទិ៍ គឺ .......... មានកតញ្ញូចំពោះ .......... ប្រារព្ធធ្វើពិធីនេះឡើង ។

បន្ទាប់មក អាចារ្យនិយាយជំនួសបូសាមីខ្លួន កូនចៅណាមួយអាចនិយាយផ្ទាល់ពីការសុំខមាទោសនូវរាល់ទោសកំហុស ដែលកូនចៅបានប្រព្រឹត្តមិនសមហេតុផលចំពោះលោកមាន គុណ ក្នុង កាលកន្លងនិងសូមប្ដេជ្ញាគោរពរាប់អានស្រឡាញ់បងប្អូន មិនធ្វើអំពើអាក្រក់ណាមួយ ឱ្យមាតាបិតា ជីដូនជីតា ព្រួយបារម្ភឡើយ ។ រួចលុតជង្គង់គោរពជូនវត្ថុទាំងនេះទៅលោកអ្នកដែលយើងបំរុងជូន ។

ពេលកូនចៅជូន អ្នកមានគុណត្រូវជូនពរជ័យ ដល់កូនចៅផ្ទាល់មាត់ ។ បន្ទាប់មកអញ្ជើញគាត់ទៅងូតទឹក ។ (ពិធីនេះមាននៅក្នុងពិធីស្រង់ព្រះ )

<u>**បញ្ជាក់**</u> : ការធ្វើនេះមិនប្រកាន់ថា ជីដូនជីតា ធំ មាមីងទេ ។ ឧទាហរណ៍ , កូនឈ្មោះ "ឃ" ធ្វើជូនយាយ "ក" តា "ខ" ឯកូនរបស់ "ឃ" គាត់ធ្វើជូនតាយាយផង ជូន ម្ដាយឪពុកផង ឬ ប្អូនធ្វើជូនឪពុកម្ដាយហើយគេរៀបចំជូនបង១ ក៏មាន ។

ពេលយប់ក្រោយសូត្រមន្តរួចហើយមានពិធីទេសនា ។ មុនទេសនាត្រូវមានសុន្ទរកថា ។ <u>**គំរូសុន្ទរកថា**</u> :

សូមថ្វាយបង្គំ ........................................



www.elibraryofcambodia.org

សូមគោរព ............................................

ក្នុងចេតនាទាំងបី ដ៏មានន័យខ្លឹមសារ តាមលំអាននៃព្រះពុទ្ធសាសនា ឱកាសនេះជាពិធីមាននក្ខត្តឫក្សដែលមានលោក ........... ( រៀបរាប់អ្នកផ្តើមបុណ្យ ) ដែលឃើញនិងយល់ច្បាស់ ពីគុណូបការៈ ដ៏ថ្លៃថ្លារបស់មាតាបិតាជីដូនជីតា ដែលកំពុងរស់នៅសព្វថ្ងៃផងនិង ដែលទំលុះកាយ ទំលាយខន្ធទៅកាន់លោកខាងមុខផងគឺ ( រៀបរាប់ឈ្មោះអ្នកស្លាប់ ) ព្រោះហេតុថាការរស់នៅសព្វថ្ងៃ កូនចៅ ពិតជាមានការបង្កើតៗ ជាការបន្តវេនមែនពិតៗ បើមិនចាប់អារម្មណ៍ ហាក់បីដូចជាធម្មតា ។ បើគិតពិចារណាតាមព្រះពុទ្ធដីកានៃព្រះបរមគ្រូ និង យកសម្បជញ្ញៈ មកគិតពិតជាមិនធម្មតាទេ ។ មាតាបិតា បង្កើតបុត្រធីតាបានថ្នាក់ថ្នមថែរក្សា រហូតពេញរូបរាងឡើង បើខ្វះធម៌ទាំងបួន គឺ ព្រហ្មវិហារធម៌ ពិតជាមិនអាចកើត រស់នៅបានស្រួលឡើយ ។ កាលដឹងថាមានកូនក្នុងផ្ទៃពីថ្ងៃណាម្តាយឪពុក ផ្សាយមេត្តា គឺចិត្តភក្តី ភ័យខ្លាចសត្វក្នុងផ្ទៃ ក្តៅក្រហាយ ខ្លោចផ្សារ ម្ល៉ោះហើយអ្វីធ្លាប់ឆ្ងាញ់ពិសា ត្រូវបន្ថយអត់ទ្រាំស្រេកឃ្លាន តមថ្នមខ្លាចជីវិតកូនមិនឃើញពន្លឺព្រះអាទិត្យ និង ខ្លាចគ្មានអាហារៈគ្រប់គ្រាន់ ។ល។

ករុណាអាណិតបើមានហេតុ ទុក្ខអ្វីមួយ កើតឡើងសុខចិត្តយកជីវិតខ្លួនទៅប្តូរដើម្បីបុត្រធីតារស់បានសុខសាន្ត ។ **មុទិតា** បើកូនមានសេចក្តីសុខសប្បាយហើយក៏មានភាពរីករាយសប្បាយចិត្តនិងសេចក្តីសុខរបស់កូនមិនមានចិត្តច្រណែនឈ្នានិះ អ្វីបន្តិចសោះ មានតែបង្កើនស្មារតីស្រឡាញ់ថែមជួយថែរក្សាសេចក្តីសុខដ៏ល្អនោះឱ្យកាន់តែប្រសើរឡើង ។



www.elibraryofcambodia.org

ឲ្យមេត្តា ចិត្តជាកណ្តាលមិនលំអៀង ប្រកាន់មាំជាប់ជាប្រចាំ តាំងពីក្នុងផ្ទៃរហូតកូនមានគូស្រករ បន្តកូនចៅតទៅទៀត ចិត្តមាតាបិតា នៅតែផ្តល់មេត្តា ស្រឡាញ់អាណិតក្រាលស្មើជានិច្ច ដោយគ្មានភ្លេចពេលណាឡើយ ។ តែរឿងនេះជារឿងជិតពេក ស្ថិតស្តេរពេកយល់មិនច្បាស់ ខ្លះមិនបានពិតដល់ហាក់ដូចជា គ្មានប្រយោជន៍អ្វីបន្តិចសោះ ។

ចំពោះយើងខ្ញុំទាំងអស់គ្នា មានសទ្ធាជ្រះថ្លា យល់ច្បាស់តាមតំលៃពិត ថាពិតជាដូចព្រះពុទ្ធដីកា នៃព្រះបរមសាស្តាចារ្យ ជាអគ្គបុគ្គលឯកក្នុងលោក គុណមាតាបិតាពិតជារកវត្ថុអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ។

បុណ្យកើតឡើងពេលនេះ ពិតជាផុះចេញពីសន្តានចិត្តបរិសុទ្ធនៃយើងខ្ញុំជាកូនចៅពិតៗ ។ តែមិនអាចនឹងសងគុណនោះឱ្យរួចបានទេ. គ្រាន់តែជាការតបស្នង និង ញ៉ាំងកុសលឱ្យពេញ បរិបូណ៌ ពិសេសញ៉ាំងចិត្តឱ្យបរិសុទ្ធសម្រាប់ជាតិនេះ និង អនាគតជាតិ ។

មា្យ៉ាងទៀតដើម្បីឧទ្ទិសមគ្គផល ដល់ជីដូនជីតាញាតិកាប្រាំពីរសន្តានដែលទំលាយខន្ធ័ទៅកាន់ លោកខាងមុខហើយ សូមឱ្យលោកទទួលបាននូវមគ្គផល អំពីកិច្ចកតញ្ញូកតវេទិតាធម៌ ទាំងអាមិសទាននិងធម្មទានក្នុងពេលនេះដោយក្តីរីករាយ រៀង១ខ្លួន ។

ជាទីបញ្ចប់សូមប្រគេនពរ ............................................។

សូមជូនពរ ..................................................................។

បន្ទាប់មកអាចារ្យអារាធនាព្រះធម្មកថិកទេសនា ។ ព្រលឹមឡើងព្រគេនយាគូព្រះសង្ឃ ថ្ងៃត្រង់វេរភត្ត និងទេយ្យទានជាកិច្ចបង្ហើយបុណ្យ ។



www.elibraryofcambodia.org

## ពិធីឆាកទស្សបន្ទុង

ព្រះសង្ឃដឹងច្បាស់តាមការនិមន្តរួចហើយ ។ ដល់ពេលចេញដំណើរទៅត្រូវសូត្រថា : **កាយានុបស្សនា វេទនានុបស្សនា ចិត្តានុប-ស្សនា ធម្មានុបស្សនា** គឺសូត្រដើរចង្រ្កមរហូតដល់មុខរាជវត៍ ទីដែលគេដាក់សក្ការៈបូជា ។ ដល់ទីមុខរាជវត៍នេះឈប់សិនសូត្រ ពុទ្ធគុណ ធម្មគុណ សង្ឃគុណមួយចប់ រួចមកដើរទៅទៀតរហូតដល់ទ្វាររាជវត៍គេនៅរស់តែគេធ្វើបុណ្យលៀងជីវិត គេវាល់អង្គរតាមចំនួនអាយុ មានប្រដាប់ផ្សេងៗគេដាក់កណ្ដាលវាលឬតាមគល់ឈើ មនុស្សក្រាបទទូរសំពត់ឱ្យព្រះសង្ឃទៅឆាកយកដោយសូត្របាលីថា : **កាយានុបស្សនា សតិបដ្ឋានា វេទនានុ-បស្សនា សតិបដ្ឋានា ចិត្តានុបស្សនា សតិបដ្ឋានា ធម្មានុបស្សនា សតិបដ្ឋានា** ដើរចង្រ្កមទៅដល់ទ្វារឆាករួចឈរវ៉ព័ងសូត្រថា : " **សុណាតុ អរិយា** " សូត្របីដង រួចចាប់ទាញយកសំពត់ឆាកដោយសូត្រ **អនិច្ចា, អចិរំ, អាយុខយា, យថាឥណេន, សព្វពុទ្ធា, យថា-ចារិចហោ, គចតុ ......ឧ** រួចមកទស្សបន្ទុងដោយឈរវ៉ព័ងថា : **ឥមំ ចន្ទំ អសារិកំ មយ្ហំ** (សូត្របីដង) រួចសូត្រទស្សបន្ទុងថា :**ឥមំ បំសុ-កុលំ ធាបុណាតិ** ( សូត្របីដង ) រួចមកភត្តាដូចមុន ។

<u>**របៀបឈរ**</u> : ឈរទស្សបន្ទុងហើយត្រូវអង្គុយចុះ សូត្រ **ឥមិនា ......** ព្រួចទឹក មុនពេលដើរចង្រ្កមគប្បីកាន់ឈើច្រត់និងកំសៀវទឹកមួយ ។



www.elibraryofcambodia.org

# ពិធីលើករាសី

ជាដំបូងយើងគប្បីគួរដឹងថា រាសីគឺអ្វី ? រាសីជានាមមកពីបាលី **រាសិ** សំស្ក្រឹតថា **រាឝិ** ប្រែថាគំនរ ពំនូក ពូក គង ប្រជុំ ។ តែខ្មែរយើងយកពាក្យរាសីនេះទៅជា លំអ ស្រស់បស់ សមរម្យ ចំរើន ។ ដូចជាថា មនុស្សមានរាសី កំពុងឡើងរាសី អាប់រាសីជាដើម ។

ដូច្នេះការលើករាសី គឺការប្រសិទ្ធី តាមក្បួនតម្រា សូត្រលើករាសីដែលអាប់ឱន ឱ្យរុងរឿងឡើង ។ ការធ្វើដូច្នេះថាសំរេចផល ១00% ទាន់ចិត្ត ក៏មិនហ៊ានថា ឬថា មិនបានប្រយោជន៍អ្វីសោះ ក៏មិនហ៊ានថា ។ ព្រោះអ្វីនោះអាស្រ័យទឹកចិត្តរបស់សាមីខ្លួន ។

ហេតុដែលយើងលើកយកពិធីនេះមកដាក់ក្នុងសៀវភៅ លំអានខ្មែរពីបុរាណ ជាទំលាប់ធ្លាប់មានតៗមកហើយ ។

ឯរបៀបដែលធ្វើនោះ មានវិធីផ្សេងៗគ្នាតាមគតិរបស់អាចារ្យ ឬសាមីដើមការដែលមានបំណងធ្វើ ។ តែទោះជាយ៉ាងណា ក៏មិនប្លែកគ្នាណាស់ណាទេ ។ ហេតុនេះយើងសូមលើកយកបែបមួយមកចែងសំដែងជាគំរូយ៉ាងគឺ :

- ធ្វើបាយសីធំមួយ កំពស់ជំហរអ្នកសាមីខ្លួន
- បាយសីប៉ាក់ ឆាម១គូ ស្លាធ័រ១គូ ទឹកអប់១គូ ទៀន៥ ធូប៥ ផ្កា៥ លាជ៥ ថ្វាយជាពុទ្ធបូជា ។
- រៀបគ្រឿងសំណែនមាន : ពែរាយ៥រូច កន្ទោង៥ ដាក់បាយក្រហម



www.elibraryofcambodia.org

បាយស ន់ ចំណីតាមទំនៀម ឆត្ររូត៥ និង ធ្វើរូបសួងខ្លួនដាក់ក្នុងពែនោះ ។

- រៀបស្លាធ័រ៨ ទឹកអប់៨ ដាក់អមអ្នកសាមីខ្លួន ម្ខាង៤៧ ។ រួចមករៀបចំពិធីសែនព្រេននិយាយឧបកិច្ច បន្ទាប់មកនិមន្តព្រះសង្ឃចំរើនព្រះបរិត្តលើករាសី ទៅតាមទំនៀមដែលធ្លាប់សូត្រកន្លងមក ។

## ពិធីសូត្រមន្តរំដោះគ្រោះ

អ្នកមានជំងឺយូរថ្ងៃហើយ រកព្យាបាលមិនជាសះស្បើយ អ្នកខ្លះមានជំនឿថា ត្រូវរំដោះគ្រោះសិនសឹមផឹកថ្នាំព្យាបាល ។ ទម្លាប់នេះគេតែងរកគ្រូហោរមើលហេតុការណ៍ តើជំងឺនេះបណ្តាលមកពីអ្វី ? តើមានគ្រោះថ្នាក់យ៉ាងណា ? ក្រោយពីបានដឹងហើយគេក៏រៀបទៅតាមរបៀបដែលគ្រូហោរបានប្រាប់ ។ បើត្រូវសូត្រមន្តរំដោះគ្រោះ គេក៏ត្រូវធ្វើតាមនោះ ។

ទម្លាប់នេះ ក៏គេរៀបទៅតាមមូលដ្ឋានរៀង១ខ្លួន អាស្រ័យអាចារ្យដែលធ្លាប់រៀប មិនដូចគ្នាទាំងស្រុងទេ ខ្លះប្រើប្រដាប់ប្រដាច្រើន ខ្លះប្រើប្រដាប់ប្រដាតិច អាស្រ័យតាមធនធានរបស់អ្នកជំងឺ ។

ទីនេះនិយាយបែបមធ្យម ល្មមគ្រប់ស្រទាប់ធ្វើបានគឺ :

- រៀបគ្រឿងពុទ្ធបូជាមាន . បាយសីប៉ាក់ឆាម១គូ . ស្លាធ័រ១គូ .ទឹកអប់១គូ . ធូប៥ . ទៀន៥ . ផ្កា៥ ។

- រៀបគ្រឿងបូជាទេព្តាមាន . ស្លាធ័រ៨ . ទឹកអប់៨ . ដាក់សងខាងអ្នកជំងឺ ម្ខាងបួន ។



www.elibraryofcambodia.org

- ធ្វើពែរូបរបៅជា ពែរមេឃូស រកម្តេកក្រប្រវែងរូបករកត្ត អ្នកជំ ងឺទទឹងប្រវែងមួយចំអាម អ្នកជំងឺមានរៀបដាក់បាយ សម្ល ញាំ ភ្លា នំចំណី ក្នុងពែតាមទំនៀម និងមានសូទ្បូរូបមួយដោយម្សៅ គឺជារូបស្នងអ្នកជំងឺ រៀបដាក់ក្នុងពែ មានប្រី ឬ ស្បូវស្ងួត មួយក្តាប់ទុកដុតរូបនោះ ។

- សំពត់ប្រវែង៤ហត្ថអ្នកជំងឺ វាល់អង្ករដោយកំប៉ុង ឬ នាឡិ ឬ កូនកែវ ឬ ចាន ឱ្យមានចំនួនស្មើនិងអាយុអ្នកជំងឺ បើមានសេសថ្ងៃខែប៉ុន្មាន វាល់ដាក់ទៀតឱ្យគ្រប់ ។

- វាល់ទឹកអប់មានចំនួនដូចគ្នាដាក់ក្នុងផ្តិលធំមួយ ។

- ពូនភ្នំខ្សាច់មួយដាក់នៅថាស ។

- របស់ទាំងអម្បាលនេះយកទៅដាក់មុខលោកសូត្រមន្ត ។

មុនលោកសូត្រមន្ត អាចារ្យរៀបចំសែនបញ្ចៀសគ្រោះថ្នាក់ឱ្យស្បើយស្បើយ រួចយកភ្លើងដុតប្រី ឬស្បូវភ្លាំងនោះ ថាបានដុតរូបអ្នកជំងឺរួចហើយ រួចជូនពែនោះទៅតាមទិសនៃដង្ហើមថ្ងៃ ( ពិធីប្រាប់ទិសមានខាងមុខហើយ ) ។

## ពាក្យសែនព្រេន

អញខ្ញុំសូមអញ្ជើញទេវតា ព្រះបរមេស្វរ ពិស្ណុកា ព្រះម្រឹត្យូវ ព្រះកាល ព្រះអាទិត្យ ព្រះចន្ទ័ ព្រះអង្គារ ព្រះពុធ ព្រះហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ ព្រះរាហូ ព្រះកេតុ ទើបអញខ្ញុំ សូមអញ្ជើញព្រះរាម ទិសអគ្នេយ៍ ព្រះលក្ខណ៍ ទិសទក្សិណ រាពណ៍ ទិសនីរតី សិដា



www.elibraryofcambodia.org

ទិសបស្ចឹម ជតាយុ ទិសពាយ័ព្យ ហនុមាន ទិសឧត្តរ ពិភេក ទិសឦសាន សូមអស់លោកអញ្ជើញមកយកក្រយាបូជា អញខ្ញុំសូមស្មាលាទោសអ្នកហោង ។

ទោះបីជងឺ ឈឺក្បាលឈឺត្បូង ឈឺកឈឺខ្នង ឈឺត្រចៀក ឈឺសព្វសារពាង្គកាយផ្សេងៗក៏សូមស្មាទោស ។

មួយវិញទៀត ទោះបីរមួតរមួល ចុកចាប់ចុកឆ្អលក្អួតចង្អោរ ឈឺច្បាក់ ចុកចាប់សាច់សួត ស្ងួតកខាន់ស្លាក់ ខះទឹកមាត់ជាដើម ។ល។ ក៏សូមអញ្ជើញអ្នកមករំដោះគ្រោះជំងឺដម្កាត់រោគាឱ្យវិនាសបាត់សូន្យ ។

បពិត្រអស់លោក រឹងថ្ងាត់ ទៅដោយស្ថានទីខែ១ ហោង **នមះ នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស ហុះលោហុះលោ ស្វាហាយ** ចង្រេចេញទៅ ។

លំដាប់តមក ពិធីសូត្រមន្តយោងគ្រោះតាមទម្លាប់ ។

តទៅនេះ ចំណុចមួយចំនួនគួរយកចិត្តទុកដាក់ បុរាណលោកសូត្រតាមឆ្នាំនិមួយៗមានធម៌មួយៗគឺ :

| | | |
|---|---|---|
| ឆ្នាំជូត | សូត្រធម៌ | កស្សប |
| ឆ្នាំឆ្លូវ | សូត្រធម៌ | មោគ្គល្លាន |
| ឆ្នាំខាល | សូត្រធម៌ | ជីវទាន ឬ ធជគ្គបរិត្ត |
| ឆ្នាំថោះ | សូត្រធម៌ | ចន្ទបរិត្ត |
| ឆ្នាំរោង | សូត្រធម៌ | មហាមេត្រី |



www.elibraryofcambodia.org

ឆ្នាំឬក្សាញ់ សូត្រធម៌ ធម្មចក្ក

ឆ្នាំមមី សូត្រធមិ មហាសម័យ

ឆ្នាំមមែ សូត្រធមិ ឥសិគិលី

ឆ្នាំវក សូត្រធមិ អាដានាដិយសូត្រឬ ត្រឹមវិបស្សិស្សន មត្ថុ

ឆ្នាំរកា សូត្រធមិ វិជ្ជាភាគិនោ

ឆ្នាំច សូត្រធមិ អភិណ្ហប្បច្ចវេក្ខណៈ ឬ អង្គ

ឆ្នាំកុរ សូត្រធមិ គិរីមានន្ទសូត្រ ។

ចំពោះកន្លែងខ្លះ ដោយលោកមិនសូវចាំធមិ គេសូត្រតែត្រឹម **អត្ថិ ឥមស្មឹ** .......... ។

ដោយគេធ្វើកូនសំប្រែកមួយតូដាក់កន្ទោង ក្នុងសំប្រែកដាក់នំចំណីចង អំបោះកណ្ដាលផងវែក រួចដាក់ព្យួរខ្សែឡើង ហើយអ្នកជំងឺនៅ ទ្រសំប្រែក នោះព្រះសង្ឃលោកសូត្រធមិបណ្ដើរទាញខ្សែបណ្ដើរតិចៗ ទាល់តែផុតដៃអ្នកជំងឺ សូត្រចប់អាចារ្យមកយកសំប្រែកកន្ទោងនោះទៅទុក រួចមកលោកនិមន្ត ទៅវត្តវិញ គេមានយកកូនមាន់មួយប្រហែលទម្ងន់ ៣ឬ៤ខាំ ឬកន្លះគីឡូយួរ ទៅជាមួយកន្ទោងនោះ កន្ទោងបោះចោល ឯមាន់យកទៅលែងនៅក្នុងវត្ត ( ចាស់ៗថារំដោះកម្ម ) ។



www.elibraryofcambodia.org

## ពិធីរម្ងាប់

ពិធីនេះបុរាណហៅថា ស្លុតដីធំ គេធ្វើនៅពេលលើកផ្ទះថ្មីឬពិធីបណ្តេញចង្រៃផ្សេងៗដូចជា : ក្រោយពីពិធីក្រុងពលីលើកផ្ទះរួច ជូនពរួច ហើយអាចារ្យសូត្ររម្ងាប់ ឬក្នុងពិធីសូត្រមន្តរំដោះគ្រោះ ក្រោយពីនាំពរ អាចារ្យសូត្ររម្ងាប់រួចមកទើបព្រះសង្ឃស្វាធ្យាយធម៌ **សិរី ធារេហិ ៩យ.** **ន្តោ** ជាដើម ។ល។

**ឱកាស ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ធា.** **រមិតានុភាវេន ឧសមហារតេជោ បញ្ច ពុទ្ធា នមាមិ** : សារពេជ្ញហ៊ុនៗ ព្រះពុទ្ធដ៏មានបុណ្យ ព្រះអង្គអបលោកមកអញ ទើបអញរម្ងាប់ទាំងពុះដុំប្រមុំភ្លីស្រែ ប្រែផ្លែក្រោមលើកជាថ្មី សាងព្រះចេតិយ ជីកដីច្រាស់ថ្ម បង្កបន្ទាយ វាយប្រថពី ត្រវីពួន ទន្ទេនទ្រនាប់ កាប់ដំបូកលលកទំ ត្នោតទំ ឃ្មុំទំ គ្រោមទំ រម្ងាប់ទាំងជីកភ្នំ រំលំឈើធ្វើផ្ទះវៀលក្បាច់រចនាគូសវាស់ ចាក់ស្រេះ រ៉ុះត្រចៀក បៀកលាក់ បៀមលាក់ រម្ងាប់ទាំងដកភ្លុកគជសារ រម្ងាប់ទាំងកុកទំផ្ទះ រន្ទះបាញ់ភូមិ រម្ងាប់ទាំងឧបទ្រពចង្រៃ កាឡកិណ្ណី ឧត្បាត ព្យាធិរោគា រម្ងាប់ទាំងព្រាយមាយា រម្ងាប់ទាំងខ្មោចនានា ពីងមកពីទិសទាំង៨ ពីងដើរទាំងយប់ពីងដើរទាំងថ្ងៃ ពីងឈរពីងឈប់ដោយសព្វនានា ពីងមកម្នាក់ឯង ពីងមកមានគ្នា ទើបអញសំដែងនូវព្រះគាថា អារាធនាព្រះបារមី ព្រះកោជ័យនៃព្រះពុទ្ធរតន៍ នូវមាត់អញ បីដូចរន្ទះទាំង៧សែនហោងអញស្រែក



www.elibraryofcambodia.org

ស្វាត្រស្រុងៗ កក្រើកទាំងបាតដោល **ឧត្តរៈ បរិយន្តៈ** ទាំងក្រឡាមហាប្រ- ថពី **ឧមពុត្ថាជយាមុនី ធម្មាជយាមុនី សំឃាជយាមុនី ជ័យ- ជ័យសុខំពលំ**អស់ទាំងទេវតា ទាំងទសទិសា សឹងឥន្ទ្រីយ៍ជ័យទើបគំរាមមារ ឧមៈ រម្លាប់មហារម្ងាប់ ស្លាប់អញជាគ្រូបាធ្យាយ សព្វអន្តរាយ វិនាសន្តិ អសេសតោ ។

## ពិធីបូជាព្រះភូមិ

ពិធីនេះ អាចារ្យរៀបទៀនប្រាំ ធូបប្រាំ ផ្កាប្រាំ ស្លាធ័រដៃមួយគូ បាយបង្អែមចំអាបមួយថាសទឹកមួយពែង សុំទឹកដីធ្វើរោងផ្កាស្លា ធ្វើចង្ក្រានបាយ ។

**ចន្ទាមិ សព្វទេវា គន្ធាយ ទេចិន្ទនំ** សារពើទុក្ខសារពើភ័យ សារពើរោគ សារពើចង្រៃ សារពើបាបគ្រោះ **វិនាសន្តិ អសេសតោ** ។

សូមព្រះភូមិឯបូពាំ ព្រះចន្ទតារា ព្រះភូមិមានលក្ខណោ **ឯហិៗ- គច្ឆន្តុ ស្វាហាយះ ៥** យើងខ្ញុំ ឱនអង្គ **អតិធាន ចន្ទា ចចន្ទា ប្រណម្យចន្ទា** សូមព្រះរាជាអ្នកតែងធានានូវ ព្រះធរណីផងត្បិតអ្នកអើយ សូមអញ្ជើញមកថ្កាន ដល់ស្ថានយើងឆាប់ យើងខ្ញុំប្រុងប្រៀបរៀបប្រដាប់រុងរឿងស្រេចស្រាប់ អាហារត្រកាលពិសី សូមភូមិសូមដីនេះនៃសង់រោងផ្កាស្លាជាថ្មីកុំបីអ្នកមានសង្កា បពិត្រសូមអញ្ជើញមកឆាប់រ៉ា យើងសូបរៀបក្រយាបូជាអ្នកហោង ។



www.elibraryofcambodia.org

# មតិបំភ្លឺ

អ្នករៀបរៀងសៀវភៅ លំអានធំនៀមខ្មែរបូរាណ សូមជំរាបជូនដល់គ្រប់អតិថិជនឱ្យបានជ្រាបថា : សៀវភៅនេះ ដំបូងឡើយពីឆ្នាំ ១៩៩៣ ខ្ញុំបានដើរប្រមូលឯកសាររហូតឆ្នាំ ២០០០ ទើបរៀបរៀងបានខ្លះ ដោយសរសេរដៃ រួចផ្សព្វផ្សាយជាបណ្ដើរ ដើម្បីសុំយោបល់ពីអតិថិជន ។

ឆ្នាំ ២០០១ ខ្ញុំបានប្រមូលថែមនូវឯកសារដើមទាំងឡាយដូចជា សាស្ត្រស្លឹករឹត ដែលមានសេសសល់តាមបណ្ដាវត្តខ្លះ រួចវាយកុំព្យូទ័រផ្សព្វផ្សាយបានមួយចំនួន និង សុំយោបល់ពីអតិថិជនអ្នកអានទៀត ។ ឆ្នាំ ២០០២ នេះ មានសំណូមពរមួយចំនួនពីបណ្ដាអ្នកអាន សុំឱ្យថែមអត្ថបទខ្លះទៀតដូចជា ពិធីបុណ្យសង្ឃទាន បុណ្យបច្ច័យបួន និង ឧបោសថកម្មជាដើម ។ ប៉ុន្តែកំពុងតែរៀបចំដើម្បីឱ្យបានសុក្រិត អំពីខ្លឹមសារ អក្ខរាវិរុទ្ធ ស្រាប់តែមានអាជីវករខ្លះឆ្លៀតចម្លងបោះពុម្ពធ្វើអាជីវកម្ម ដោយធ្វើឱ្យខាងតែបានមិនគិតអំពីភាពត្រឹមត្រូវនៃច្បាប់ដើម ។

ពីមុនសៀវភៅនេះឈ្មោះថា **ឆន្លាប់អាចារ្យ** ឥឡូវនេះដូរឈ្មោះមកថា **លំអានធំនៀមខ្មែរបូរាណ** ដែលបានបោះពុម្ពផ្សព្វផ្សាយ ដោយ **ពុទ្ធសាសនបណ្ឌិត** ដែលមានលក្ខណៈត្រឹមត្រូវនឹងសុក្រិតបំផុត ។ សូមអតិថិជនមានបំណងប្រាថ្នាជាវសៀវភៅ សូមទាក់ទងមកយើងខ្ញុំដែលមាន ទូរស័ព្ទលេខ ០១១ ៩០ ៧៣ ១០ / ០១២ ៩៦ ៣៣ ៩១ .

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ រ៉ាមុន
ខ្ចៅ ភាពជា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ គីម វាសនា

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រួស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org



www.elibraryofcambodia.org